សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច
Université Royale de Droit et des Sciences Economiques
Royal University of Law and Economics

# សារណាបញ្ចប់ការសិក្សា

# នីតិវិធីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម

## (ការសិក្សាប្រៀបធៀបរវាងប្រទេសកម្ពុជា និងសហរដ្ឋអាមេរិក)

ស្រាវជ្រាវពីថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០១៦ ដល់ថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០១៦

គាត់តែងឡើងដោយ
និស្សិតឈ្មោះ **ណាំ វិសុទ្ធ**

សាស្ត្រាចារ្យណែនាំ
លោក **ឃឹម គិរី**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**
ជំនាន់ទី ១៦

ឆ្នាំចូលសិក្សា ២០១២
ឆ្នាំសរសេរសារណា ២០១៦

# សេចក្តីថ្លែងអំណរគុណ

ខ្ញុំបានឈ្មោះ **ណាំ ទិសុទ្ធ** ជានិស្សិតថ្នាក់បរិញ្ញបត្រផ្នែកនីតិសាស្ត្រ ជំនាន់ទី១៦ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច បានសរសេរសារណាបញ្ចប់ការសិក្សាក្រោមប្រធានបទស្តីពី "**នីតិវិធីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម** (**ការសិក្សាប្រៀបធៀបរវាងប្រទេសកម្ពុជា និងសហរដ្ឋអាមេរិក**)"។ ការសរសេរសារណាបញ្ចប់ការសិក្សានេះ អាចបញ្ចប់ទៅបានដោយជោគជ័យ គឺដោយមានការគាំទ្រពីសំណាក់បុគ្គលជាច្រើនទាំងផ្នែកស្មារតី និងផ្នែកសម្ភារៈ។

ជាបឋម ខ្ញុំបាទសូមគោរពប្រណិប័តន៍ និងសូមថ្លែងអំណរគុណ និងកត្តញ្ញូតាធម៌យ៉ាងជ្រាលជ្រៅចំពោះលោកឪពុក **នាក់ ធុច** និងអ្នកម្តាយ **សេង ស៊ីមាន** ដែលលោកអ្នកមានគុណទាំងពីរបានផ្តល់កំណើតដល់រូបកូន និងបានខិតខំអប់រំប្រៀនប្រដៅឲ្យរូបកូនក្លាយជាមនុស្សល្អនៅក្នុងសង្គម។ មិនត្រឹមតែប៉ុណ្ណោះ លោកទាំងពីរបាន និងកំពុងផ្តល់កំលាំងចិត្តឲ្យរូបកូន និងខិតខំប្រឹងធ្វើការដើម្បីផ្គត់ផ្គង់ឲ្យរូបកូនបានរៀនសូត្ររហូតដល់បញ្ចប់ថ្នាក់បរិញ្ញាបត្រ។

ក្នុងឱកាសនេះ ខ្ញុំបាទសូមសំដែងនូវអំណរគុណជាអនេកប្បការផងដែរចំពោះ ឯកឧត្តមសាកលវិទ្យាធិការ រួមទាំងលោក និងលោកស្រីសាស្ត្រាចារ្យនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានខិតខំបង្ហាត់បង្រៀន និងផ្តល់នូវបទពិសោធន៍ល្អៗជាច្រើនដែលជាមូលដ្ឋានមួយយ៉ាងសំខាន់សម្រាប់ខ្ញុំបាទសរសេរសារណាបញ្ចប់ការសិក្សា។

ជាពិសេស ខ្ញុំបាទសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅផងដែរចំពោះសាស្ត្រាចារ្យដឹកនាំរបស់ខ្ញុំបាទ គឺលោកសាស្ត្រាចារ្យ **ឃឹម គិរី** ដែលលោកបានចំណាយពេលដ៏មានតម្លៃដើម្បីពន្យល់បង្ហាញយ៉ាងពិស្តា និងលំអិតអំពីប្រធានបទ វិធីសាស្ត្រនៃការសិក្សាស្រាវជ្រាវ និងសរសេរសារណាបញ្ចប់ការសិក្សាប្រកបដោយជោគជ័យ។ លោក ក៏បានខិតប្រឹងប្រែងកែតម្រូវនូវកំហុសឆ្គងផ្សេងៗ និងយោបល់ល្អៗសម្រាប់កែតម្រូវឲ្យសារណារបស់ខ្ញុំបាទកាន់តែល្អប្រសើរឡើង។

ជាចុងបញ្ចប់ ខ្ញុំបាទសូមថ្លែងអំណរគុណដល់សិស្សច្បង និងមិត្តនិស្សិតទាំងអស់ដែលបានផ្តល់ជាយោបល់ល្អៗ និងបានចូលរួមកែតម្រូវនូវកំហុសឆ្គងផ្សេងៗឲ្យសារណាមួយនេះកាន់តែល្អប្រសើរឡើងផងដែរ។

ខ្ញុំបាទសូមប្រសិទ្ធិពរជ័យសិរីសួស្តីដល់អស់លោកអ្នកមានគុណ ដែលបានជួយជ្រោមជ្រែងនិងផ្តល់ជាកំលាំងចិត្ត និងពុទ្ធិនានា ឲ្យទទួលបាននូវពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ និងពលៈកុំបីឃ្លាងឃ្លាតឡើយ។

# អារម្ភកថា

មូលហេតុចម្បង ដែលបានជម្រុញទឹកចិត្តឲ្យខ្ញុំបាទសម្រេចចិត្តជ្រើសរើសយកប្រធានបទមួយនេះមកធ្វើការសិក្សាស្រាវជ្រាវ គឺដោយសារតែខ្ញុំមានចំណាប់អារម្មណ៍យ៉ាងខ្លាំងលើមុខវិជ្ជានីតិពាណិជ្ជកម្ម និងមើលឃើញពីសារៈប្រយោជន៍យ៉ាងច្រើនរបស់មជ្ឈត្តការផ្នែកពាណិជ្ជកម្មក្នុងការដោះស្រាយវិវាទពាណិជ្ជកម្មនៅប្រទេសកម្ពុជា បន្ទាប់ពីខ្ញុំបាទធ្លាប់បានសិក្សា និងចូលរួមប្រកួតសវនាការប្រឌិតទាំងថ្នាក់ជាតិ និងថ្នាក់អន្តរជាតិស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្មអន្តរជាតិចំនួនពីរលើកក្នុងឆ្នាំសិក្សា២០១៤ ដល់ ២០១៥ និង ២០១៥ ដល់ ២០១៦ រួចមក។

សារណាបញ្ចប់ការសិក្សានេះ ទាមទារឲ្យមានការខិតខំប្រឹងប្រែងប្រកបដោយភាពអត់ធ្មត់ និងមានទំនួលខុសត្រូវខ្ពស់ ដើម្បីជម្នះនូវរាល់ឧបសគ្គ និងការលំបាកផ្សេងៗ ដោយខ្ញុំបាទត្រូវធ្វើការសិក្សាស្រាវជ្រាវយ៉ាងស៊ីជម្រៅអំពីនីតិវិធីមជ្ឈត្តការផ្នែកពាណិជ្ជកម្មនៃប្រទេសកម្ពុជាផង និងសហរដ្ឋអាមេរិកផង បន្ទាប់មកត្រូវធ្វើការប្រៀបធៀបនីតិវិធីមជ្ឈត្តការនៃប្រទេសទាំងពីរ។ ដោយមើលឃើញពីភាពស្មុគស្មាញក្នុងនីតីវិធីនិមួយៗ និងដើម្បីឲ្យការប្រៀបធៀបអាចរំលេចឲ្យឃើញកាន់តែលំអិតអំពីភាពដូចគ្នា និងខុសគ្នា និងលក្ខណៈពិសេសផ្សេងៗក្នុងនីតិវិធីនៃប្រទេសទាំងពីរ ខ្ញុំបាទសម្រេចចិត្តធ្វើការបកស្រាយ និងប្រៀបធៀបនៅក្នុងចំណុចនិមួយៗនៃនីតិវិធីមជ្ឈត្តការផ្នែកពាណិជ្ជកម្មតែម្តង។ ធ្វើដូច្នេះ នឹងអាចបង្កឲ្យមានភាពងាយស្រួលដល់អ្នកអាន ឲ្យកាន់តែងាយយល់ និងមើលឃើញកាន់តែច្បាស់អំពីចំណុចដូចគ្នា និងខុសគ្នានៃនីតិវិធី ក៏ដូចជាខ្លឹមសារនៃស្នាដៃនេះទាំងមូលផងដែរ។

ទោះបីជាមានការខិតខំប្រឹងប្រែង និងយកចិត្តទុកដាក់នៅក្នុងការសរសេរសារណាមួយនេះយ៉ាងណាក៏ដោយ ក៏កំហុសឆ្គងផ្សេងៗអាចនឹងកើតមានឡើងក្នុងចំណុចណាមួយជាក់ជាមិនខាន។ អាស្រ័យហេតុដូច្នេះហើយ ក្នុងនាមជាអ្នកសរសេរសារណានេះ ខ្ញុំបាទសូមអភ័យទោសទុកជាមុន និងសូមស្នើនូវក្តីអនុគ្រោះអធ្យាស្រ័យពីសំណាក់អ្នកស្រាវជ្រាវ និងសាស្ត្រាចារ្យនានាចំពោះរាល់កំហុសឆ្គងផ្សេងៗដែលអាចនឹងកើតមានឡើង ត្បិតថាចំណេះដឹងរបស់ខ្ញុំបាទនៅមានកម្រិត។

# មាតិកា


**សេចក្តីផ្តើម** ........ ១

**ជំពូកទី ១៖ សញ្ញាណទូទៅនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្មក្នុងប្រទេសកម្ពុជា និង សហរដ្ឋអាមេរិក**

**១.១. មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្មនៃប្រទេសកម្ពុជា និង សមាគមមជ្ឈត្តការសហរដ្ឋអាមេរិក** ........ ៦

**១.១.១. មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម** ........ ៦

១.១.១.១. ការបង្កើតស្ថាប័នមជ្ឈត្តការ និងសេវារដ្ឋបាល ........ ៦

១.១.១.២. វិធានគ្រប់គ្រងរបស់ស្ថាប័នមជ្ឈត្តការ ........ ៧

**១.១.២. សមាគមមជ្ឈត្តការសហរដ្ឋអាមេរិក** ........ ៨

១.១.២.១. ការបង្កើតស្ថាប័នមជ្ឈត្តការ និងសេវារដ្ឋបាល ........ ៨

១.១.២.២. វិធានគ្រប់គ្រងរបស់ស្ថាប័នមជ្ឈត្តការ ........ ៩

**១.១.៣. ការប្រៀបធៀបរវាងស្ថាប័នមជ្ឈត្តការទាំងពីរ** ........ ១០

**១.២. កិច្ចព្រមព្រៀងផ្សះផ្សា ឬកិច្ចព្រមព្រៀងមជ្ឈត្តកម្ម** ........ ១១

**១.២.១. លក្ខណៈទូទៅនៃកិច្ចព្រមព្រៀងផ្សះផ្សា** ........ ១១

១.២.១.១. ប្រភេទនៃកិច្ចព្រមព្រៀងផ្សះផ្សា ........ ១២

១.២.១.២. ច្បាប់គ្រប់គ្រងកិច្ចព្រមព្រៀងផ្សះផ្សា ........ ១២

**១.២.២. លក្ខខណ្ឌគតិយុត្តនៃកិច្ចព្រមព្រៀងផ្សះផ្សា** ........ ១៣

១.២.២.១. លក្ខខណ្ឌគ្រឹះ ........ ១៤

ក. ការព្រមព្រៀងរួម ........ ១៥

ខ. សមត្ថភាពរបស់ភាគី ........................................................................ ១៥

គ. ទំនាក់ទំនងគតិយុត្ត ........................................................................ ១៦

ឃ. កម្មវត្ថុនៃវិវាទ ........................................................................ ១៦

១.២.២.២. លក្ខខណ្ឌទម្រង់ ........................................................................ ១៧

**១.២.៣. អានុភាពនៃកិច្ចព្រមព្រៀងផ្សះផ្សា** ........................................................................ ១៨

១.២.៣.១. ការបោះបង់សិទ្ធិប្តឹងទៅតុលាការ ........................................................................ ១៨

១.២.៣.២. ការផ្តល់សមត្ថកិច្ចទៅមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ........................................................................ ១៩

១.២.៣.៣. លក្ខណៈដាច់ដោយឡែកនៃកិច្ចព្រមព្រៀងផ្សះផ្សា ........................................................................ ១៩

## ជំពូកទី ២៖ នីតិវិធីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម

**២.១. ការចាប់ផ្តើមដំណើរការមជ្ឈត្តការ** ........................................................................ ២២

**២.១.១. ការចាប់ផ្តើមមជ្ឈត្តកម្ម** ........................................................................ ២២

២.១.១.១. ការជូនដំណឹងរបស់ភាគីប្តឹងទាមទារ ........................................................................ ២២

២.១.១.២. ការឆ្លើយតបរបស់ភាគីឆ្លើយតប ........................................................................ ២៥

**២.១.២. ការបង្កើតវេទិកាមជ្ឈត្តកម្ម** ........................................................................ ២៨

២.១.២.១. ការជ្រើសតាំងមជ្ឈត្តករ ........................................................................ ២៨

២.១.២.២. ការជំទាស់នឹងមជ្ឈត្តករ ........................................................................ ៣២

ក. មូលហេតុនៃការប្តឹងជំទាស់ ........................................................................ ៣២

ខ. នីតិវិធីក្នុងការប្តឹងជំទាស់ ........................................................................ ៣៤

២.១.២.៣. ការដាក់មជ្ឈករជំនួស ........................................................................ ៣៧

**២.១.៣. ការរៀបចំដំណើរការមជ្ឈត្តការ** ........................................................................ ៣៧

២.១.៣.១. ច្បាប់អនុវត្តក្នុងដំណើរការមជ្ឈត្តការ........................................... ៣៨

២.១.៣.២. ភាសាប្រើប្រាស់ក្នុងមជ្ឈត្តកម្ម..................................................... ៣៨

២.១.៣.៣. ទីកន្លែងធ្វើមជ្ឈត្តកម្ម................................................................ ៣៩

២.១.៣.៤. កាលបរិច្ឆេទ ពេលវេលា និងទីកន្លែងនៃសវនាការ ............................ ៤១

២.១.៣.៥. សាក្សី និងអ្នកជំនាញ ................................................................ ៤២

២.១.៣.៦. ការដោះស្រាយវិវាទដោយស្ម័គ្រចិត្ត............................................. ៤៤

២.១.៣.៧. វិធានការបណ្តោះអាសន្ន ............................................................ ៤៦

**២.២. សវនាការ និងមជ្ឈត្តវិនិច្ឆ័យ**............................................................ ៤៩

**២.២.១. សវនាការ** .......................................................................... ៤៩

២.២.១.១. ដំណើរការនៃសវនាការ............................................................... ៥០

២.២.១.២. លក្ខណៈឯកជននៃសវនាការ និងការចូលរួមក្នុងសវនាការ.............. ៥២

២.២.១.៣. ការបញ្ចប់សវនាការ និងដំណើរការមជ្ឈត្តការ ................................ ៥៣

២.២.១.៤. ការបើកសវនាការ និងដំណើរការមជ្ឈត្តការជាថ្មី............................ ៥៤

**២.២.២. មជ្ឈត្តវិនិច្ឆ័យ**.......................................................................... ៥៤

២.២.២.១. ការសម្រេចរបស់វេទិកាមជ្ឈត្តកម្ម.................................................. ៥៥

២.២.២.២. ទម្រង់នៃមជ្ឈត្តវិនិច្ឆ័យ................................................................. ៥៦

២.២.២.៣. ការចេញមជ្ឈត្តវិនិច្ឆ័យ ............................................................... ៥៨

២.២.២.៤. ការកែតម្រូវមជ្ឈត្តវិនិច្ឆ័យ .......................................................... ៦០

២.២.២.៥. ការបំភ្លឺលំអិត និងការបកស្រាយមជ្ឈត្តវិនិច្ឆ័យ និង មជ្ឈត្តវិនិច្ឆ័យបន្ថែម.
.......................................................................................................... ៦២

**ជំពូកទី ៣៖ ការប្តឹងជំទាស់ ការទទួលស្គាល់ និងការដាក់ឲ្យអនុវត្តមជ្ឈត្តវិនិច្ឆ័យ**


**៣.១. បណ្តឹងជំទាស់ការអនុវត្តមជ្ឈត្តវិនិច្ឆ័យ** ........................................ ៦៤

៣.១.១. បណ្តឹងជំទាស់នឹងមជ្ឈត្តវិនិច្ឆ័យរបស់មជ្ឈត្តការជាតិ ........................................ ៦៤

៣.១.១.១. មូលហេតុនៃបណ្តឹងជំទាស់ ........................................ ៦៤

៣.១.១.២. ការដាក់បណ្តឹងជំទាស់ ........................................ ៦៧

៣.១.២. បណ្តឹងជំទាស់ការអនុវត្តមជ្ឈត្តវិនិច្ឆ័យបរទេស ........................................ ៦៨

**៣.២. ការទទួលស្គាល់ និងការដាក់ឲ្យអនុវត្តមជ្ឈត្តវិនិច្ឆ័យ** ........................................ ៧០

៣.២.១. ការដាក់ឲ្យអនុវត្តមជ្ឈត្តវិនិច្ឆ័យរបស់មជ្ឈត្តការជាតិ ........................................ ៧១

៣.២.២. ការដាក់ឲ្យអនុវត្តមជ្ឈត្តវិនិច្ឆ័យបរទេស ........................................ ៧៣

**សេចក្តីសន្និដ្ឋាន** ........................................ ៧៦

**អនុសាសន៍** ........................................ ៨០

**តារាងសម្គាល់អក្សរកាត់ និងពាក្យបំព្រួញ**

**គន្ថនិទ្ទេស**

**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

មជ្ឈត្តការ គឺជាយន្តការដោះស្រាយវិវាទដ៏សំខាន់មួយនៅក្នុងចំណោមយន្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការដទៃទៀត ដែលគូភាគីព្រមព្រៀងយកវិវាទរបស់ខ្លួនទៅដោះស្រាយដោយមជ្ឈត្តករមួយ ឬច្រើន។ ចំណែកឯ **មជ្ឈត្តការផ្នែកពាណិជ្ជកម្ម** សំដៅទៅលើយន្តការដោះស្រាយវិវាទរបស់គូភាគីនៃទំនាក់ទំនងពាណិជ្ជកម្ម ទោះបីមានកិច្ចសន្យាពាណិជ្ជកម្ម ឬគ្មានក៏ដោយក្តី ដោយមជ្ឈត្តករមួយរូប ឬច្រើនរូប។ មជ្ឈត្តករដែលជាបុគ្គលអព្យាក្រឹត្យ ត្រូវពិចារណាលើភស្តុតាងរបស់ភាគី និងចេញសេចក្តីសម្រេចរបស់ខ្លួន ដែលហៅថាមជ្ឈត្តវិនិច្ឆ័យ។ ថ្វីបើមជ្ឈត្តវិនិច្ឆ័យមានអនុភាពចាប់បង្ខំឲ្យអនុវត្តក៏ដោយ ភាគីណាមួយអាចនឹងប្តឹងជំទាស់នឹងការអនុវត្តមជ្ឈត្តវិនិច្ឆ័យ ឬក៏ដាក់ពាក្យស្នើសុំទៅតុលាការដើម្បីឲ្យទទួលស្គាល់ និងអនុវត្តមជ្ឈត្តវិនិច្ឆ័យនោះផងដែរ។

មជ្ឈត្តការផ្នែកពាណិជ្ជកម្ម ពិតជាមានប្រវត្តិដ៏យូរលង់ណាស់មកហើយ។ កាលដើមឡើយ អ្នកជំនួញតែងតែធ្វើដំណើរយ៉ាងឆ្ងាយដើម្បីធ្វើការជួញដូរទំនិញ និងសេវាផ្សេងៗ។ ដោយសារតែការធ្វើដំណើរមានភាពគ្រោះថ្នាក់ និងត្រូវចំណាយច្រើន វិវាទដែលកើតឡើងត្រូវតែដោះស្រាយឲ្យបានឆាប់រហ័ស និងនៅក្បែរកន្លែងធ្វើជំនួញនោះ។ ក៏ប៉ុន្តែ នៅក្នុងសម័យនោះ តុលាការមិនអាចដោះស្រាយវិវាទរបស់ខ្លួនឲ្យបានឆាប់រហ័ស និងមិនមានការយល់ដឹងស៊ីជម្រៅអំពីវិស័យជំនួញរបស់គេនោះទេ។ ជាលទ្ធផល អ្នកជំនួញទាំងនោះបានបង្កើតនូវតុលាការឯកជនសម្រាប់មជ្ឈត្តការមួយដើម្បីដោះស្រាយវិវាទរបស់ខ្លួនប្រកបដោយប្រសិទ្ធភាព។ ក្រោយមកក្នុងអំឡុងសតវត្សទី១៧ និង១៨ ប្រជាជនអង់គ្លេសដែលបានមកតាំងទីលំនៅថ្មីក្នុងទឹកដីសហរដ្ឋអាមេរិក បាននាំមកនូវយន្តការមជ្ឈត្តការនេះមកសហរដ្ឋអាមេរិកផងដែរ។ ក្រោយមក យន្តការមជ្ឈត្តការបានដើរតួនាទីយ៉ាងសំខាន់នៅក្នុងការដោះស្រាយវិវាទពាណិជ្ជកម្មក្នុងសហរដ្ឋអាមេរិកនាសម័យអាណាព្យាបាលអង់គ្លេស។[1] ទោះជាយ៉ាងនេះក្តី តុលាការរបស់សហរដ្ឋអាមេរិកក្នុងសម័យនោះ មិនទាន់អាចទទួលស្គាល់ និងដាក់ឲ្យអនុវត្តសេចក្តីសម្រេចរបស់មជ្ឈត្តករនៅឡើយ។[2]

[1] Susan Patterson និង Grant Seabolt, *Essentials of Alternative Dispute Resolution* [ចំណុចសំខាន់ៗនៃការដោះ-ស្រាយវិវាទ ក្រៅប្រព័ន្ធតុលាការ], បោះពុម្ពលើកទី២ (២០០១), ទំព័រ ១១៨។

[2] Steven M. Austermiller, *Alternative Dispute Resolution: Cambodia: A Textbook of Essential Concepts* [ការដោះ-ស្រាយវិវាទក្រៅប្រព័ន្ធតុលាការនៅកម្ពុជា៖ សៀវភៅនៃទស្សនៈសំខាន់ៗ] (Phnom Penh: JSRC printing house, មករា ២០១០), ទំព័រ ១៣៨, អាចស្វែងរកបាននៅ៖ http://www.americanbar.org/content/dam/aba/directories/roli/cambodia/cambodia_adr_book_english_01_19_09.authcheckdam.pdf (ថតចម្លងនៅថ្ងៃទី ២៨ មិថុនា ២០១៦)។

ដោយមើលឃើញពីផលប្រយោជន៍របស់មជ្ឈត្តការផ្នែកពាណិជ្ជកម្ម សហរដ្ឋអាមេរិកបានបង្កើតនូវច្បាប់សហព័ន្ធស្តីពីមជ្ឈត្តការ (Federal Arbitration Act “FAA”) នៅដើមឆ្នាំ១៩២៥ ក្នុងគោលបំណងទទួលស្គាល់នូវសុពលភាព និងការអនុវត្តនៃកិច្ចព្រមព្រៀងមជ្ឈត្តកម្ម ក៏ដូចជាដើម្បីទទួលស្គាល់នូវមជ្ឈត្តវិនិច្ឆ័យ និងដាក់ឲ្យអនុវត្តដោយតុលាការ។ ក្នុងរយៈពេលមួយឆ្នាំក្រោយពីច្បាប់សហព័ន្ធនេះត្រូវបានបង្កើតឡើង សហរដ្ឋអាមេរិកបានបង្កើតនូវស្ថាប័នមជ្ឈត្តការមួយដែលមានឈ្មោះថា សមាគមមជ្ឈត្តការសហរដ្ឋអាមេរិក (American Arbitration Association “AAA”) ដើម្បីគ្រប់គ្រងលើដំណើរការនៃការដោះស្រាយវិវាទប្រកបដោយប្រសិទ្ធភាព។[3] មកដល់បច្ចុប្បន្ននេះ សមាគមមជ្ឈត្តការសហរដ្ឋអាមេរិក ពិតជាមានបទពិសោធន៍យ៉ាងច្រើនក្នុងវិស័យមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ហើយត្រូវបានចាត់ទុកថាជាស្ថាប័នចម្បងមួយទាំងនៅក្នុងសហរដ្ឋអាមេរិក និងនៅលើឆាកអន្តរជាតិ។

ដោយឡែកប្រទេសកម្ពុជា ដោយមើលឃើញពីអត្ថប្រយោជន៍ជាច្រើនរបស់មជ្ឈត្តការផ្នែកពាណិជ្ជកម្ម បានបង្កើតនូវច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្មនៅឆ្នាំ២០០៦ ក្នុងគោលបំណងឲ្យមជ្ឈត្តការផ្នែកពាណិជ្ជកម្មមានការរីកចម្រើន និងទទួលស្គាល់នូវយន្តការមជ្ឈត្តការថាជាយន្តការដោះស្រាយវិវាទមួយដែលស្របច្បាប់ ក៏ដូចជាទទួលស្គាល់នូវការអនុវត្តមជ្ឈត្តវិនិច្ឆ័យតាមរយៈតុលាការនៅកម្ពុជា។ លើសពីនេះ ច្បាប់នេះក៏មានគោលបំណងក្នុងការបង្កើតនូវមជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ដែលហៅកាត់ថា ម.ជ.ម. ដើម្បីគ្រប់គ្រងដំណើរការមជ្ឈត្តការផ្នែកពាណិជ្ជកម្ម និងជម្រុញឲ្យមានការដោះស្រាយវិវាទពាណិជ្ជកម្មតាមរយៈមជ្ឈត្តការនៅកម្ពុជា។[4]

ទោះជាយ៉ាងនេះក្តី ការដោះស្រាយវិវាទពាណិជ្ជកម្មតាមរយៈមជ្ឈត្តការមិនទាន់មានភាពទូលំទូលាយនៅឡើយ។ ម្យ៉ាងវិញទៀត មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្មទើបតែចាប់ផ្តើមប្រតិបត្តិការជាផ្លូវការនៅដើមឆ្នាំ២០១៣ នេះប៉ុណ្ណោះ។[5] ហេតុដូចនេះហើយ បទពិសោធន៍នៅក្នុងវិស័យមជ្ឈត្តការផ្នែកពាណិជ្ជកម្ម គឺនៅមានកម្រិត និងមិនទាន់ទទួលបានការជឿទុកចិត្តពេញទំហឹងពីសំណាក់សាធារណៈជន ពិសេសគូវិវាទពាណិជ្ជកម្មនៅឡើយ។ មូលហេតុបែបនេះ ជម្រុញ

---

[3] https://www.linkedin.com/company/american-arbitration-association (ចូលទស្សនាថ្ងៃទី២៨ មិថុនា ២០១៦)។

[4] ច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្មនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៥០៦/០១០, ០៥ ឧសភា ២០០៦ (ពីនេះតទៅហៅថា ច្បាប់ស្តីមជ្ឈត្តការផ្នែកពាណិជ្ជកម្មនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦), ជំពូក ៣, មាត្រា១០ ដល់១៧។

[5] Bun and Associates, *Introductory Guide: Commercial Arbitration in Cambodia* [សេចក្តីណែនាំ៖ មជ្ឈត្តការផ្នែកពាណិជ្ជកម្មនៅកម្ពុជា] (២០១៤), ទំព័រ ៤, អាចស្វែងរកបាននៅ៖ http://www.bun-associates.com/wp-content/uploads/2015/01/Introductory-Guide-Commercial-Arbitration-in-Cambodia.pdf (ថតចម្លងនៅថ្ងៃទី២០ មិថុនា ២០១៦)។

ទឹកចិត្តឲ្យស្ថាប័នមជ្ឈត្តការថ្មីមួយនេះ ប្រឹងប្រែងធ្វើយ៉ាងណាឲ្យស្ថាប័នមានភាពរីកចម្រើន និងទទួលបានការជឿទុកចិត្តពីសាធារណៈជន និងធ្វើឲ្យវិស័យមជ្ឈត្តការនៅកម្ពុជាមានការរីកចម្រើន។ ក្នុងស្មារតីនេះដែរ ម.ជ.ម. បានព្យាយាមបង្កើតនូវវិធានផ្ទាល់ខ្លួនមួយសម្រាប់គ្រប់គ្រងដំណើរការនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម រហូតដល់ថ្ងៃទី ១១ កក្កដា ឆ្នាំ២០១៤ មហាសន្និបាទរបស់ ម.ជ.ម. បានអនុម័តវិធានថ្មីស្តីពីមជ្ឈត្តការមួយដ៏ជោគជ័យ។[6] លើសពីនេះទៅទៀត ម.ជ.ម. បានទទួលនូវសេចក្តីជូនដំណឹងអំពីមជ្ឈត្តកម្មជាលើកទីមួយ នៅចុងខែឧសភា ឆ្នាំ២០១៥នេះ។[7] វិវាទពាណិជ្ជកម្មនោះ គឺជាវិវាទដែលកើតចេញកិច្ចសន្យាជួលរោងចក្រនៅកម្ពុជា រវាងជនបរទេស និងម្ចាស់កម្មសិទ្ធិដែលជាជនជាតិខ្មែរ។[8] ម.ជ.ម. ក៏ទើបតែទទួលសេចក្តីជូនដំណឹងអំពីមជ្ឈត្តការជាលើកទីពីរ នៅថ្ងៃទី២០ មិថុនា ២០១៦នេះ ដែលវិវាទនោះទាក់ទងនឹងកិច្ចសន្យារវាងក្រុមហ៊ុនឯកជន និងក្រសួង។[9] នេះជារឿងក្តីលើកទីពីររបស់ខ្លួន ដែលបង្ហាញឲ្យឃើញពីជោគជ័យមួយផងដែរ។

ទោះជាយ៉ាងណាក៏ដោយ មជ្ឈមណ្ឌលមជ្ឈត្តការរបស់កម្ពុជានៅមានភាពទន់ខ្សោយនៅឡើយ បើប្រៀបធៀបនឹងសមាគមមជ្ឈត្តការសហរដ្ឋអាមេរិក ត្បិតថាមជ្ឈមណ្ឌលមជ្ឈត្តការរបស់កម្ពុជានៅមានបទពិសោធន៍តិចតួច និងមិនទាន់ទទួលបានការជឿទុកចិត្តពីសាធារណៈជនយ៉ាងទូលំទូលាយនៅឡើយ។ ចំណុចនេះធ្វើឲ្យ ខ្ញុំបាទមើលឃើញថាកម្ពុជាគួរតែសិក្សានិងយកគម្រូតាមចំណុចល្អរបស់សហរដ្ឋអាមេរិក ដើម្បីឲ្យស្ថាប័ន និងវិស័យមជ្ឈត្តការផ្នែកពាណិជ្ជកម្មទាំងមូលមានការរីកចម្រើន។ តើកម្ពុជាគួរតែសិក្សាអ្វីខ្លះពីសហរដ្ឋអាមេរិក?

ក្នុងចំណុចនេះ ខ្ញុំបាទជឿជាក់យ៉ាងមុតមាំថា នីតិវិធីមជ្ឈត្តការដែលសហរដ្ឋអាមេរិកកំពុងប្រើប្រាស់ ពិតជាដើរតួនាទីយ៉ាងសំខាន់ក្នុងការជម្រុញឲ្យមជ្ឈត្តការផ្នែកពាណិជ្ជកម្មនៅក្នុងសហរដ្ឋអាមេរិករីកចម្រើនយ៉ាងខ្លាំង ប្រកបដោយការជឿទុកចិត្តពីសាធារណៈជន។ ហេតុដូចនេះហើយ ការសិក្សាប្រៀបធៀបពីនីតិវិធីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម នឹងធ្វើឲ្យយើងយល់ដឹងកាន់តែច្បាស់អំពីចំណុចល្អៗជាច្រើនក្នុងនីតិវិធីមជ្ឈត្តការផ្នែកពាណិជ្ជកម្មរបស់សហរដ្ឋអាមេរិក ដើម្បីជាទុនមួយក្នុង

---

[6] វិធានស្តីពីមជ្ឈត្តការរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្មនៃព្រះរាជាណាចក្រកម្ពុជា, ១១ កក្កដា ២០១៤ (ពីនេះតទៅហៅថា វិធានស្តីពីមជ្ឈត្តការរបស់ ម.ជ.ម. នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៤), វិធាន៥៧។

[7] Olga Boltenko, *Cambodia's Arbitration Centre sets off on its First Flight* [មជ្ឈមណ្ឌលមជ្ឈត្តការរបស់កម្ពុជាចាប់ផ្តើមដំណើរការដំបូងបំផុតរបស់ខ្លួន] (១០ មិថុនា ២០១៥), អាចស្វែងរកបាននៅ៖ http://kluwerarbitrationblog.com/2015/06/10/cambodias-arbitration-centre-sets-off-on-its-first-flight/ (ចូលទស្សនាថ្ងៃទី២០ មិថុនា ២០១៦)។

[8] ដូចខាងលើ។

[9] http://www.phnompenhpost.com/business/arbitration-body-gets-its-second-commercial-case (ចូលទស្សនានៅថ្ងៃទី២៨ មិថុនា ២០១៦)។

ការអភិវឌ្ឍវិស័យមជ្ឈត្តការនៅប្រទេសកម្ពុជា។ ហើយស្របពេលជាមួយនោះដែរ យើងនឹងសិក្សាកាន់តែស៊ីជម្រៅអំពីនីតិវិធីនៃមជ្ឈត្តការរបស់ប្រទេសទាំងពីរ។

ហេតុដូច្នេះ តើនីតិវិធីនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្មរបស់ប្រទេសកម្ពុជា និងសហរដ្ឋអាមេរិកមានលក្ខណៈដូចម្ដេច ហើយមានលក្ខណៈពិសេសយ៉ាងណាដែរ? តើនីតិវិធីក្នុងប្រទេសទាំងពីរមានលក្ខណៈដូចគ្នា និងខុសគ្នាយ៉ាងណាខ្លះ? តើកម្ពុជាអាចសិក្សាអំពីអ្វីខ្លះ ពីសហរដ្ឋអាមេរិកដើម្បីឲ្យមជ្ឈត្តការផ្នែកពាណិជ្ជកម្មមានការរីកចម្រើន តាមរយៈការសិក្សាប្រៀបធៀបនីតីវិធីក្នុងប្រទេសទាំងពីរ?

សារណានេះ នឹងធ្វើការសិក្សាប្រៀបធៀបនីតិវិធីមជ្ឈត្តការផ្នែកពាណិជ្ជកម្មរបស់ប្រទេសកម្ពុជា និងសហរដ្ឋអាមេរិក ដោយលើកយកច្បាប់គ្រប់គ្រងមជ្ឈត្តការផ្នែកពាណិជ្ជកម្មនៃប្រទេសទាំងពីរ អនុសញ្ញាអន្តរជាតិ និងច្បាប់នានាដែលពាក់ព័ន្ធ និងវិធានស្ដីពីមជ្ឈត្តការរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្មរបស់ប្រទេសកម្ពុជា និងសមាគមមជ្ឈត្តការរបស់សហរដ្ឋអាមេរិក ដោយសន្មត់ថាគូភាគីនៃវិវាទផ្នែកពាណិជ្ជកម្មនៅក្នុងប្រទេសទាំងពីរ បានព្រមព្រៀងគ្នាជ្រើសរើសមជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្មរបស់ប្រទេសកម្ពុជា និងសមាគមមជ្ឈត្តការរបស់សហរដ្ឋអាមេរិកដើម្បីគ្រប់គ្រងលើដំណើរការនៃមជ្ឈត្តការក្នុងប្រទេសរបស់ខ្លួន។

សារណានេះ នឹងធ្វើការសិក្សាប្រៀបធៀបដោយបែងចែកជាបីជំពូក ដែលមានដូចតទៅ៖

- **ជំពូកទី១** នឹងធ្វើការបកស្រាយអំពីសញ្ញាណទូទៅនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្មក្នុងប្រទេសកម្ពុជា និងសហរដ្ឋអាមេរិក។
- **ជំពូកទី២** នឹងធ្វើការបកស្រាយ និងប្រៀបធៀបពីនីតិវិធីមជ្ឈត្តការផ្នែកពាណិជ្ជកម្មដែលគ្រប់គ្រង ដោយមជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្មនៃប្រទេសកម្ពុជា និងសមាគមមជ្ឈត្តការរបស់សហរដ្ឋអាមេរិក។
- **ជំពូកទី៣** នឹងធ្វើការបកស្រាយ និងប្រៀបធៀបអំពីការប្ដឹងជំទាស់ ការទទួលស្គាល់ និងការដាក់ឲ្យអនុវត្តមជ្ឈត្តវិនិច្ឆ័យ។

# ជំពូកទី ១

# សញ្ញាណទូទៅនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្មក្នុងព្រះរាជាណាចក្រកម្ពុជា និងសហរដ្ឋអាមេរិក

នៅក្នុងប្រទេសកម្ពុជា ក៏ដូចជាសហរដ្ឋអាមេរិក ភាគីអាចដោះស្រាយវិវាទពាណិជ្ជកម្មរបស់ខ្លួនតាមរយៈយន្តការមជ្ឈត្តការ ទោះបីជាមាន ឬគ្មានស្ថាប័នមជ្ឈត្តការសម្រាប់គ្រប់គ្រងដំណើរការនៃការដោះស្រាយវិវាទរបស់ខ្លួនក៏ដោយ។ ទោះជាយ៉ាងនេះក្តី ការសិក្សាស្រាវជ្រាវបង្ហាញឲ្យឃើញថា នៅក្នុងសហរដ្ឋអាមេរិក មជ្ឈត្តការផ្នែកពាណិជ្ជកម្ម ជាទូទៅត្រូវបានធ្វើឡើងក្រោមការគ្រប់គ្រងរបស់ស្ថាប័នមជ្ឈត្តការណាមួយ។ ថ្វីត្បិតថាស្ថាប័នមជ្ឈត្តការនៅសហរដ្ឋអាមេរិកមានច្រើនក៏ពិតមែន[10] សមាគមមជ្ឈត្តការសហរដ្ឋអាមេរិក (ស.ម.ស.) ត្រូវបានចាត់ទុកថាជាស្ថាប័នចម្បងជាងគេក្នុងវិស័យមជ្ឈត្តការផ្នែកពាណិជ្ជកម្មនៅក្នុងសហរដ្ឋអាមេរិក ដោយសារភាពល្បីល្បាញ អាយុកាលសេវា ក៏ដូចជាវិសាលភាពរបស់ខ្លួន។[11]

ដោយឡែកនៅក្នុងប្រទេសកម្ពុជា ការដោះស្រាយវិវាទពាណិជ្ជកម្មតាមរយៈមជ្ឈត្តការមិនទាន់មានភាពទូលាយនៅឡើយ ហើយទើបតែមានមជ្ឈមណ្ឌលមជ្ឈត្តការផ្នែកពាណិជ្ជកម្មតែមួយគត់ ដែលទើបតែចាប់ផ្តើមប្រតិបត្តិការជាផ្លូវការនៅដើមឆ្នាំ២០១៣ នេះប៉ុណ្ណោះ។ ហេតុដូចនេះ ក្នុងការប្រៀបធៀបមជ្ឈត្តការផ្នែកពាណិជ្ជកម្មរបស់ប្រទេសទាំងពីរ យើងគប្បីលើកយកមជ្ឈត្តការផ្នែកពាណិជ្ជកម្មដែលគ្រប់គ្រងដោយមជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្មនៃប្រទេសកម្ពុជា និងសមាគមមជ្ឈត្តការសហរដ្ឋអាមេរិកមកធ្វើការសិក្សា។

ទន្ទឹមនឹងភាពសំខាន់នៃស្ថាប័នមជ្ឈត្តការ កិច្ចព្រមព្រៀងផ្សះផ្សា ឬកិច្ចព្រមព្រៀងមជ្ឈត្តកម្ម គឺជាកិច្ចព្រមព្រៀងដ៏សំខាន់មួយដែលត្រូវលើកមកពិភាក្សាផងដែរ ដោយហេតុថាកិច្ចព្រមព្រៀង

---

[10] ក្រៅពី ស.ម.ស. សហរដ្ឋអាមេរិកនៅមានស្ថាប័នមជ្ឈត្តការផ្សេងទៀតដូចជា ស្ថាប័នអន្តរជាតិសម្រាប់ការទប់ស្កាត់ និងដោះស្រាយវិវាទ (International Institution for Conflict Prevention and Resolution “CPR”) និង ស្ថាប័នមជ្ឈត្តការដែលមានឈ្មោះថា JAMS (Judicial Arbitration and Mediation Services, Inc.) រួមទាំងស្ថាប័នមជ្ឈត្តការដទៃទៀតដូចជា FIRA (the Financial Industry Regulatory Authority) និង ARIAS (the AIDA Reinsurance and Insurance Arbitration Society) ជាដើម។ សូមមើលបន្ថែមនៅ៖ David McLean, *US arbitral institutions and their rules* [ស្ថាប័នមជ្ឈត្តការរបស់សហរដ្ឋអាមេរិក និងវិធានរបស់ខ្លួន], (Latham & Watkins LLP), ទំព័រ ១, ២។ អាចស្វែងរកបាននៅ៖ http://documents.jdsupra.com/76566a75-775d-4dd0-83fb-b47a7076aa9a.pdf (ថតចម្លងនៅថ្ងៃទី ៩ កក្កដា ២០១៦)។

[11] ដូចខាងលើ។

នេះជាមូលដ្ឋានគតិយុត្តចម្បង ដែលនាំឲ្យគូភាគីវិវាទយកវិវាទពាណិជ្ជកម្មរបស់ខ្លួនទៅដោះស្រាយតាមរយៈមជ្ឈត្តការ។

ជំពូកនេះរួមមានបីចំណុច។ ចំណុចទី១ នៃជំពូកនេះ នឹងធ្វើការបកស្រាយ និងប្រៀបធៀបអំពីមជ្ឈមណ្ឌលជាតិនៃមជ្ឈការផ្នែកពាណិជ្ជកម្មរបស់ប្រទេសកម្ពុជា និងសមាគមមជ្ឈត្តការរបស់សហរដ្ឋអាមេរិក (១.១.)។ ចំណែកឯ កិច្ចព្រមព្រៀងផ្សះផ្សា ឬកិច្ចព្រមព្រៀងមជ្ឈត្តកម្ម នឹងត្រូវបានបកស្រាយក្នុងចំណុចទី២ នៃជំពូកនេះ (១.២.)។

## ១.១. មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្មនៃព្រះរាជាណាចក្រកម្ពុជា និង សមាគមមជ្ឈត្តការសហរដ្ឋអាមេរិក

មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្មរបស់ប្រទេសកម្ពុជា និងសមាគមមជ្ឈត្តការសហរដ្ឋអាមេរិក គឺជាស្ថាប័នចម្បងនៅក្នុងប្រទេសទាំងពីរ។ ចំណុច១.១.នេះរួមមាន ៣ចំណុច។ ចំណុចទី១ នឹងបកស្រាយអំពីមជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម (១.១.១.)។ ចំណុចទី២នឹងបកស្រាយអំពី សមាគមមជ្ឈត្តការសហរដ្ឋអាមេរិក (១.១.២.)។ រីឯការប្រៀបធៀបនៃស្ថាប័នទាំងពីរ នឹងត្រូវបានបកស្រាយដាច់ដោយឡែក នៅក្នុងចំណុច (១.១.៣.)។

### ១.១.១. មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម (ម.ជ.ម.)

ចំណុច ១.១.១. នេះនឹងធ្វើការបកស្រាយទាក់ទងនឹងការបង្កើតស្ថាប័នមជ្ឈត្តការ និងសេវារដ្ឋបាល (១.១.១.១.) និង វិធានគ្រប់គ្រងរបស់ស្ថាប័នមជ្ឈត្តការ (១.១.១.២.) របស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្មរបស់ប្រទេសកម្ពុជា។

#### ១.១.១.១. ការបង្កើតស្ថាប័នមជ្ឈត្តការ និងសេវារដ្ឋបាល

មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម គឺជានីតិបុគ្គលមិនស្វែងរកប្រាក់ចំណេញមួយ ដែលត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ២០០៦ ស្របតាមច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្មឆ្នាំ២០០៦ អនុក្រឹត្យលេខ១២៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្ត-ការផ្នែកពាណិជ្ជកម្ម ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០០៩ និងអនុក្រឹត្យលេខ ១៨២ ស្តីពីវិសោធនកម្ម

មាត្រា ៥២ នៃអនុក្រឹត្យលេខ ១២៤ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១០។[12] គោលបំណងនៃការបង្កើតឲ្យមាននូវស្ថាប័នមជ្ឈត្តការនេះឡើង គឺដើម្បីជម្រុញការដោះស្រាយវិវាទពាណិជ្ជកម្ម តាមរយៈការផ្សះផ្សានៅកម្ពុជា បង្កើតរចនាសម្ព័ន្ធ និងវិធានចាំបាច់សម្រាប់គ្រប់គ្រងលើរឿងមជ្ឈត្តការនៅកម្ពុជា និងធានាឲ្យមជ្ឈត្តការនៅកម្ពុជាមានគុណភាពខ្ពស់ រួមទាំងការកំណត់ស្តង់ដាសម្រាប់លក្ខណៈសម្បត្តិរបស់មជ្ឈត្តករផងដែរ។[13]

យ៉ាងណាមិញ ម.ជ.ម. ទើបតែចាប់ផ្តើមដំណើរការជាផ្លូវការនៅដើមឆ្នាំ២០១៣ ហើយមានបទពិសោធន៍តិចតួចនៅឡើយក្នុងវិស័យមជ្ឈត្តការផ្នែកពាណិជ្ជកម្ម។[14] លើសពីនេះ ម.ជ.ម. អាចទទួលត្រឹមរឿងក្តីដែលទាក់នឹងវិវាទពាណិជ្ជកម្មប៉ុណ្ណោះ។ ទោះជាយ៉ាងនេះក្តី ពាក្យ "**ពាណិជ្ជកម្ម**" ត្រូវបានបកស្រាយយ៉ាងទូលាយតាមរយៈច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ដែលនាំឲ្យ ម.ជ.ម. អាចទទួលរឿងក្តីនៃវិវាទពាណិជ្ជកម្មគ្រប់ប្រភេទ ទោះបីជាមានកិច្ចសន្យា ឬគ្មានក្តី ជាតិ ឬអន្តរជាតិក្តី។[15] ក្រៅពីសេវារដ្ឋបាលលើដំណើរការមជ្ឈត្តការ ម.ជ.ម. ក៏ផ្តល់នូវសេវាកម្មរបស់ខ្លួនទាក់ទងទៅនឹងការសម្រុះសម្រួលតាមបែបសន្ទានកម្ម និងផ្តល់នូវការបណ្តុះបណ្តាលដល់មជ្ឈត្តករ ក៏ដូចជាសាធារណៈជននានាអំពីការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការដែរ។ សរុបមក ម.ជ.ម. នៅមានបទពិសោធន៍តិចតួចនៅឡើយក្នុងមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ក៏ប៉ុន្តែកំពុងស្ថិតនៅក្នុងដំណើរការយ៉ាងរលូនឆ្ពោះទៅរកភាពជឿទុកចិត្តពីសាធារណៈជន ប្រកបដោយចក្ខុវិស័យរឹងមាំ។

### ១.១.១.២. វិធានគ្រប់គ្រងរបស់ស្ថាប័នមជ្ឈត្តការ

ដើម្បីជួយសម្រួលដល់ការដោះស្រាយវិវាទពាណិជ្ជកម្មឲ្យកាន់តែឆាប់រហ័ស និងប្រកបដោយប្រសិទ្ធភាព ម.ជ.ម. បានបង្កើតនូវវិធានផ្ទាល់ខ្លួនមួយ នៅថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១៤ ដើម្បីធ្វើជាជម្រើសសម្រាប់ភាគី ក្នុងការគ្រប់គ្រងលើដំណើរការមជ្ឈត្តការរបស់ខ្លួន។ វិធាននោះ គឺ **វិធានស្តីពីមជ្ឈត្តការ**[16] ដែលចែងអំពីនីតិវិធីនៃដំណើរការមជ្ឈត្តការពាណិជ្ជកម្មរបស់គូភាគីវិវាទ។

---

[12] បទបញ្ជាផ្ទៃក្នុងរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្មនៃព្រះរាជាណាចក្រកម្ពុជា, ១១ កក្កដា ២០១៤, ប្រកា១, អាចស្វែងរកនៅ៖ http://apps.americanbar.org/buslaw/newsletter/0051/materials/pp7.pdf (ថតចម្លងនៅថ្ងៃទី២១ មិថុនា ២០១៦)។

[13] ច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្មនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦, មាត្រា១០។

[14] Bun and Associates, *Introductory Guide: Commercial Arbitration in Cambodia* [សេចក្តីណែនាំ៖ មជ្ឈត្តការផ្នែកពាណិជ្ជកម្មនៅកម្ពុជា] (២០១៤), ទំព័រ ៤, អាចស្វែងរកបាននៅ៖ http://www.bun-associates.com/wp-content/uploads/2015/01/Introductory-Guide-Commercial-Arbitration-in-Cambodia.pdf (ថតចម្លងថ្ងៃទី២១ មិថុនា ២០១៦)។

[15] ច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្មនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦, មាត្រា២(ឈ)។

[16] ពីនេះតទៅហៅថា *"វិធាននៃប្រទេសកម្ពុជា"*។

យ៉ាងណាក៏ដោយ គូភាគីវិវាទនៅតែអាចធ្វើការព្រមព្រៀងដើម្បីជ្រើសរើសយកវិធាន ឬច្បាប់ផ្សេងទៀតមកគ្រប់គ្រងលើដំណើរការមជ្ឈត្តការរបស់ខ្លួន ឬក៏ធ្វើការកែប្រែបញ្ញត្តិមួយចំនួន ដែលវិធាននេះអនុញ្ញាត។[17] វិធានស្តីពីមជ្ឈត្តការរបស់ ម.ជ.ម. មិនមានបញ្ជាក់ពីខចែងគំរូសម្រាប់ភាគីដែលមានបំណងដាក់មជ្ឈត្តការរបស់ខ្លួនឲ្យគ្រប់គ្រងដោយ ម.ជ.ម. ក្រោមវិធាននេះឡើយ។ ទោះជាយ៉ាងនេះក្តី គេហទំព័រផ្លូវការរបស់ម.ជ.ម. មានផ្តល់ជាខចែងគំរូនេះ។[18] សរុបមក ម.ជ.ម មានវិធានស្តីពីមជ្ឈត្តការតែមួយគត់ ដែលទាក់ទងនឹងវិវាទពាណិជ្ជកម្ម ក្រៅពីវិធានផ្ទៃក្នុងផ្សេងទៀត។

### ១.១.២. សមាគមមជ្ឈត្តការរបស់សហរដ្ឋអាមេរិក (ស.ម.ស.)

ចំណុច ១.១.២. នេះ នឹងធ្វើការបកស្រាយទាក់ទងនឹងការបង្កើតស្ថាប័នមជ្ឈត្តការ និងសេវារដ្ឋបាល (១.១.២.១.) ក៏ដូចជា វិធានគ្រប់គ្រងរបស់ស្ថាប័នមជ្ឈត្តការ (១.១.២.២.) របស់សមាគមមជ្ឈត្តការរបស់សហរដ្ឋអាមេរិក។

#### ១.១.២.១. ការបង្កើតស្ថាប័នមជ្ឈត្តការ និងសេវារដ្ឋបាល

សមាគមមជ្ឈត្តការសហរដ្ឋអាមេរិក (American Arbitration Association) គឺជាអង្គការមិនស្វែងរកប្រាក់ចំណេញមួយ ដែលត្រូវបានបង្កើតឡើងក្នុងឆ្នាំ១៩២៦ នៅក្នុងទីក្រុងញូវយ៉ករបស់សហរដ្ឋអាមេរិក បន្ទាប់ពីច្បាប់សហព័ន្ធនៃមជ្ឈត្តការរបស់សហរដ្ឋអាមេរិកត្រូវបានបង្កើតឡើងបានមួយឆ្នាំ។[19] ស្ថាប័នសាធារណៈមួយនេះ មានសាខាជាច្រើនតាមរដ្ឋនានានៃសហរដ្ឋអាមេរិក ហើយបានឆ្លងកាត់នូវបទពិសោធន៍ជាច្រើនឆ្នាំក្នុងការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ។

ស.ម.ស. មិនមានតួនាទីក្នុងការដោះស្រាយវិវាទរបស់គូភាគីដោយផ្ទាល់ទេ។ ក៏ប៉ុន្តែ តួនាទីរបស់ ស.ម.ស. គឺផ្តល់សេវារដ្ឋបាលរបស់ខ្លួនដោយគ្រប់គ្រងលើដំណើរការនៃការដោះស្រាយវិវាទរបស់មជ្ឈត្តករ ចាប់តាំងពីពេលដែលភាគីដាក់សេចក្តីជូនដំណឹងអំពីមជ្ឈត្តការរហូតដល់ការបញ្ចប់ដំណើរការមជ្ឈត្តការ។ សេវារដ្ឋបាលរបស់ ស.ម.ស. រួមមានទាំងការសម្រួលនៅក្នុងការជ្រើសតាំង

[17] វិធានស្តីពីមជ្ឈត្តការរបស់ ម.ជ.ម. នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៤, វិធាន ២.៤។

[18] អាចស្វែងរកខចែងនេះ តាមរយៈ៖ http://ncac.org.kh/?page=detail&menu1=295&ctype=article&id=295&lg=en&menu1=217&menu2=228&lg=kh (ចូលទស្សនានៅ ២២ មិថុនា ២០១៦)។

[19] American Arbitration Association, *About the American Arbitration Association (AAA) and the International Centre for Dispute Resolution (ICDR)* [អំពីសមាគមមជ្ឈត្តការនៃសហរដ្ឋអាមេរិក និងមជ្ឈមណ្ឌលអន្តរជាតិសម្រាប់ការដោះស្រាយវិវាទ], តាមរយៈ៖ https://www.adr.org/aaa/faces/s/about?_afrLoop=328197943978297&_afrWindowMode=0&_afrWindowId=qbazdtfds_80#%40%3F_afrWindowId%3Dqbazdtfds_80%26_afrLoop%3D328197943978297%26_afrWindowMode%3D0%26_adf.ctrl-state%3Drc1ezdct6_4 (ចូលទស្សនាថ្ងៃទី ១ ឧសភា ២០១៦)។

មជ្ឈត្តករ ឬសន្ធានការី ការកំណត់អំពីសវនាការ ក៏ដូចជាផ្តល់នូវព័ត៌មានផ្សេងៗអំពីជម្រើសនៅក្នុងការដោះស្រាយវិវាទ ដូចជាសន្ធានកម្មជាដើម។ លើសពីនេះទៅទៀត ស.ម.ស. ក៏ផ្តល់សេវារបស់ខ្លួនទាក់ទងនឹងវិស័យអប់រំ ការហ្វឹកហាត់ ក៏ដូចជាការផ្សព្វផ្សាយផ្សេងៗសម្រាប់អ្នកដែលកំពុងស្វែងយល់បន្ថែមអំពីការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការផងដែរ។

ក្រៅពីសេវារដ្ឋបាលរបស់ខ្លួននៅក្នុងសហរដ្ឋអាមេរិក ស.ម.ស. ក៏ផ្តល់នូវសេវារដ្ឋបាលទៅលើដំណើរការមជ្ឈត្តការនេះផងដែរនៅក្រៅប្រទេស តាមរយៈមជ្ឈមណ្ឌលអន្តរជាតិសម្រាប់ការដោះស្រាយវិវាទ “International Centre for Dispute Resolution (ICDR)” ដែលត្រូវបានបង្កើតឡើងក្នុងឆ្នាំ ១៩៩៦ សម្រាប់ដោះស្រាយវិវាទអន្តរជាតិ។

### ១.១.២.២. វិធានគ្រប់គ្រងរបស់ស្ថាប័នមជ្ឈត្តការ

ក្រៅពីវិវាទពាណិជ្ជកម្ម ស.ម.ស. ជាសមាគមមជ្ឈត្តការមួយដែលផ្តល់សេវារដ្ឋបាលលើដំណើរការមជ្ឈត្តការនៃវិវាទច្រើនប្រភេទផ្សេងទៀត រួមមានទាំងវិវាទការងារផងដែរ។ ហេតុដូច្នេះហើយទើបបានជា ស.ម.ស. បង្កើតនូវវិធានជាច្រើនផ្សេងៗគ្នា ដើម្បីផ្តល់ជាជម្រើសដល់គូភាគីក្នុងការគ្រប់គ្រងលើដំណើរការមជ្ឈត្តការរបស់ខ្លួន។ វិធានទាំងនោះរួមមានជាអាទិ វិធានស្តីពីមជ្ឈត្តការផ្នែកឧស្សាហកម្មសំណង់ និងនីតិវិធីសន្ធានកម្ម (Construction Industry Arbitration Rules and Mediation Procedures) វិធានស្តីពីមជ្ឈត្តការផ្នែកអតិថិជន (Consumer Arbitration Rules) វិធានស្តីពីមជ្ឈត្តការផ្នែកការងារ (Labor Arbitration Rules) និងវិធានជាច្រើនផ្សេងទៀត។[20] ដោយឡែកវិធានដែលទាក់ទងនឹងមជ្ឈត្តការផ្នែកពាណិជ្ជកម្ម គឺវិធានស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម និងនីតិវិធីសន្ធានកម្ម[21] (Commercial Arbitration Rules and Mediation Procedures)។

វិធានស្តីពីមជ្ឈត្តការពាណិជ្ជកម្ម និងនីតិវិធីសន្ធានកម្មនេះ មានចែងអំពីនីតិវិធីយ៉ាងលម្អិតនៃដំណើរការមជ្ឈត្តការ។ លើសពីនេះទៅទៀត វិធាននេះមានបញ្ជាក់អំពីខចែងគំរូ សម្រាប់ភាគីដែលមានបំណងដាក់មជ្ឈត្តកម្មរបស់ខ្លួនឲ្យគ្រប់គ្រងដោយ ស.ម.ស. ក្រោមវិធាននេះ អាចដាក់បញ្ចូលនៅក្នុងកិច្ចព្រមព្រៀងមជ្ឈត្តកម្មរបស់ខ្លួនបានដែរ។ ក្រៅពីនេះ វិធាននេះក៏មានបញ្ជាក់អំពីកិច្ចព្រមព្រៀងមជ្ឈត្តកម្មគំរូ ក្រោយពេលដែលវិវាទបានកើតឡើងផងដែរ។

---

[20] https://www.adr.org/aaa/faces/rules/searchrules?_afrLoop=370143563130441&_afrWindowMode=0&_afrWindowId=121e2ry1qo_1#%40%3F_afrWindowId%3D121e2ry1qo_1%26_afrLoop%3D370143563130441%26_afrWindowMode%3D0%26_adf.ctrl-state%3D121e2ry1qo_91 (ចូលទស្សនានៅថ្ងៃទី០១ ឧសភា ២០១៦)។

[21] ពីនេះតទៅហៅថា *"វិធានរបស់សហរដ្ឋអាមេរិក"*។

### ១.១.៣. ការប្រៀបធៀបរវាងស្ថាប័នមជ្ឈត្តការទាំងពីរ

មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្មរបស់ប្រទេសកម្ពុជា មានបទពិសោធន៍តិចតួចនៅឡើយនៅក្នុងវិស័យមជ្ឈត្តការផ្នែកពាណិជ្ជកម្ម បើប្រៀបធៀបនឹងសមាគមមជ្ឈត្តការរបស់សហរដ្ឋអាមេរិក។ គិតមកដល់ពេលបច្ចុប្បន្ននេះ ស.ម.ស. មានអាយុកាល ៩០ឆ្នាំមកហើយ និងត្រូវបានចាត់ទុកថាជាស្ថាប័នចម្បងមួយលើវិស័យមជ្ឈត្តការនៅក្នុងសហរដ្ឋអាមេរិក។ ដោយឡែក ម.ជ.ម. ទើបតែចាប់ផ្តើមប្រតិបត្តិការជាផ្លូវការនៅដើមឆ្នាំ២០១៣ នេះប៉ុណ្ណោះ។ ក្រៅពីអាយុកាល និងបទពិសោធន៍ក្នុងវិស័យមជ្ឈត្តការ ស្ថាប័នមជ្ឈត្តការទាំងពីរនេះមានភាពខុសគ្នាមួយចំនួនគួរឲ្យកត់សម្គាល់លើ ទំហំ សេវា និងវិធានរបស់ខ្លួន។ ទាក់ទងនឹងទំហំ ម.ជ.ម. មានទីតាំងរបស់ខ្លួនតែមួយគត់នៅរាជធានីភ្នំពេញ និងមានសមាជិកតិចតួចនៅឡើយ។ ប៉ុន្តែ ស.ម.ស. មានការិយាល័យរបស់ខ្លួននៅក្នុងរដ្ឋជាច្រើននៃសហរដ្ឋអាមេរិក។ លើសពីនេះទៅទៀត ស.ម.ស. បានបង្កើតនូវមជ្ឈមណ្ឌលអន្តរជាតិសម្រាប់ការដោះស្រាយវិវាទ (ICDR) ដែលទទួលផ្តល់សេវារដ្ឋបាលលើការដោះស្រាយវិវាទអន្តរជាតិតាមរយៈមជ្ឈត្តការនៅជាង៨០ប្រទេសនៅលើពិភពលោក។[22] ទាក់ទងនឹងសេវារដ្ឋបាលវិញ ម.ជ.ម. ផ្តល់សេវារដ្ឋបាលលើមជ្ឈត្តការផ្នែកពាណិជ្ជកម្មប៉ុណ្ណោះ។ ចំណែកឯ ស.ម.ស. វិញ ផ្តល់សេវារដ្ឋបាលរបស់ខ្លួនលើមជ្ឈត្តការជាច្រើនផ្សេងទៀតក្រៅពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម។ សម្រាប់វិធានវិញ ម.ជ.ម. មានវិធានតែមួយគត់សម្រាប់តែវិវាទពាណិជ្ជកម្មប៉ុណ្ណោះ ប៉ុន្តែ ស.ម.ស. មានវិធានជាច្រើនសម្រាប់ដោះស្រាយវិវាទផ្សេងៗគ្នា។

សរុបមក ម.ជ.ម. មានបទពិសោធន៍តិចតួចនៅឡើយក្នុងវិស័យមជ្ឈត្តការផ្នែកពាណិជ្ជកម្ម បើប្រៀបធៀបជាមួយនឹង ស.ម.ស. របស់សហរដ្ឋអាមេរិក។ លើសពីនេះ ស.ម.ស. ទទួលបាននូវការទុកចិត្តពីសំណាក់សាធារណៈជននានាជាច្រើនទសវត្សមកហើយ និងក្លាយជាស្ថាប័នមជ្ឈត្តការចម្បងមួយនៅសហរដ្ឋអាមេរិក ក៏ដូចជានៅលើឆាកអន្តរជាតិ។ ហេតុដូចនេះ តាមរយៈការសិក្សាប្រៀបធៀបនេះ យើងនឹងអាចស្វែងរកចំណុចល្អៗជាច្រើនពី ស.ម.ស. ដើម្បីជាប្រយោជន៍ដ៏មានតម្លៃសម្រាប់ ម.ជ.ម. ក្នុងការអភិវឌ្ឍខ្លួនទៅថ្ងៃអនាគត។

[22] ដូច ១៩។

## ១.២. កិច្ចព្រមព្រៀងផ្សះផ្សា ឬកិច្ចព្រមព្រៀងមជ្ឈត្តកម្ម

កិច្ចព្រមព្រៀងផ្សះផ្សា ឬកិច្ចព្រមព្រៀងមជ្ឈត្តកម្ម ផ្តល់ជាមូលដ្ឋានសម្រាប់មជ្ឈត្តការផ្នែកពាណិជ្ជកម្ម។[23] កិច្ចព្រមព្រៀងផ្សះផ្សា សំដៅលើកិច្ចសន្យាដែលគូភាគីវិវាទបានព្រមព្រៀងគ្នាថានឹងដោះស្រាយជម្លោះរបស់ខ្លួនដែលបានកើតឡើង ឬនឹងកើតមានឡើងតាមរយៈមជ្ឈត្តការផ្នែកពាណិជ្ជកម្ម។[24] តាមច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្មរបស់ប្រទេសកម្ពុជា៖

> “កិច្ចព្រមព្រៀងផ្សះផ្សា” ជាកិច្ចព្រមព្រៀងរវាងភាគីវិវាទក្នុងការធ្វើមជ្ឈត្តការវិវាទទាំងអស់ ឬវិវាទបែបណាមួយដែលកើតឡើង ឬដែលអាចកើតឡើងរវាងគូភាគីវិវាទនានា ដោយគោរពតាមទំនាក់ទំនងកំណត់ដោយច្បាប់ ទោះបីមានកិច្ចសន្យា ឬគ្មានក៏ដោយ។[25]

ចំណុចនេះ មានគោលបំណងពន្យល់បង្ហាញអំពីកិច្ចព្រមព្រៀងផ្សះផ្សាក្រោមច្បាប់របស់ប្រទេសកម្ពុជា និងសហរដ្ឋអាមេរិក មុននឹងឈានដល់ការសិក្សាប្រៀបធៀបនីតិវិធីមជ្ឈត្តការផ្នែកពាណិជ្ជកម្មក្នុងជំពូកទី២។

ចំណុច **(១.២.១.)** នឹងសិក្សាប្រៀបធៀបទាក់ទងនឹងលក្ខណៈទូទៅនៃកិច្ចព្រមព្រៀងផ្សះផ្សា ឬកិច្ចព្រមព្រៀងមជ្ឈត្តកម្ម។ រីឯចំណុច **(១.២.២.)** នឹងសិក្សាប្រៀបធៀបអំពីលក្ខខណ្ឌគតិយុត្តិនៃកិច្ចព្រមព្រៀងផ្សះផ្សា។ ចុងក្រោយ ចំណុច **(១.២.៣.)** នឹងធ្វើការសិក្សាប្រៀបធៀបអំពីអានុភាពនៃកិច្ចព្រមព្រៀងផ្សះផ្សា។

### ១.២.១. លក្ខណៈទូទៅនៃកិច្ចព្រមព្រៀងផ្សះផ្សា

ចំណុច ១.២.១. នឹងធ្វើការបកស្រាយ និងប្រៀបធៀបអំពីប្រភេទនៃកិច្ចព្រមព្រៀងផ្សះផ្សា **(១.២.១.១.)** និងច្បាប់គ្រប់គ្រងកិច្ចព្រមព្រៀងផ្សះផ្សា **(១.២.១.២.)**។

[23] United Nations Conference on Trade and Development (UNCTAD), *Dispute Settlement: International Commercial Arbitration* [ការដោះស្រាយជម្លោះ៖ មជ្ឈត្តការផ្នែកពាណិជ្ជកម្មអន្តរជាតិ], ជំពូក ៥.២៖ Arbitration Agreement [កិច្ចព្រមព្រៀងមជ្ឈត្តកម្ម] (New York and Geneva: United Nations, 2005), ទំព័រ ៣។

[24] ដូចខាងលើ។

[25] ច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្មនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦, មាត្រា២(យ)។

### ១.២.១.១. ប្រភេទនៃកិច្ចព្រមព្រៀងផ្សះផ្សា

យោងតាមច្បាប់របស់ប្រទេសកម្ពុជា និងច្បាប់សហព័ន្ធនៃមជ្ឈត្តការរបស់សហរដ្ឋអាមេរិក កិច្ចព្រមព្រៀងផ្សះផ្សាត្រូវបានបែងចែកចេញជាពីរប្រភេទ គឺខចែងស្ដីពីមជ្ឈត្តការដែលបានចែងនៅក្នុងកិច្ចសន្យា និងកិច្ចព្រមព្រៀងដោយឡែក។[26]

ខចែងស្ដីពីមជ្ឈត្តការដែលបានចែងនៅក្នុងកិច្ចសន្យា សំដៅលើខចែងស្ដីពីការដោះស្រាយវិវាទរបស់ភាគីតាមរយៈមជ្ឈត្តការ ដែលមានចែងស្រាប់នៅក្នុងកិច្ចសន្យាពាណិជ្ជកម្មរបស់ភាគី។ ដោយហេតុថាខចែងនោះត្រូវបានធ្វើនៅពេលដែលវិវាទមិនទាន់កើតមានឡើង ភាគីមិនទាន់បានកំនត់ច្បាស់លាស់អំពីកម្មវត្ថុ ដែលនឹងត្រូវយកមកដោះស្រាយតាមរយៈមជ្ឈត្តការផ្នែកពាណិជ្ជកម្មនៅក្នុងខចែងពីមជ្ឈត្តការដែលមានចែងក្នុងកិច្ចសន្យានោះទេ។

យ៉ាងណាមិញ កិច្ចព្រមព្រៀងដោយឡែក សំដៅលើកិច្ចព្រមព្រៀងថ្មី ហើយមិនមានចែងនៅក្នុងកិច្ចសន្យា ដែលគូភាគីវិវាទបានបង្ហាញឆន្ទៈក្នុងការដោះស្រាយវិវាទដែលកើតឡើង ឬក៏ដែលនឹងកើតឡើង តាមរយៈមជ្ឈត្តការផ្នែកពាណិជ្ជកម្ម។ ក្នុងករណីដែលវិវាទមិនទាន់កើតឡើង កិច្ចព្រមព្រៀងដោយឡែកនោះ សំដៅដល់ឧបសម្ព័ន្ធដែលភ្ជាប់នឹងកិច្ចសន្យាពាណិជ្ជកម្មរបស់ភាគីដែលមិនទាន់បានកំនត់ពីកម្មវត្ថុជាក់លាក់នៃវិវាទនោះទេ។ ប៉ុន្តែក្នុងករណីដែលវិវាទបានកើតឡើងរួចហើយ កិច្ចព្រមព្រៀងដោយឡែកនោះតែងតែកំណត់ជាក់លាក់អំពីកម្មវត្ថុនៃវិវាទដែលត្រូវយកមកដោះស្រាយតាមរយៈមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ត្បិតថាគូភាគីបានដឹងនូវវិវាទច្បាស់លាស់។ លើសពីនេះទៅទៀត ក្រោយពីវិវាទកើតឡើងភាគីក៏អាចធ្វើកិច្ចព្រមព្រៀងបន្ថែមនឹងកិច្ចព្រមព្រៀង ឬក៏ខចែងនៅក្នុងកិច្ចសន្យាពាណិជ្ជកម្មដែលត្រូវបានធ្វើមុនពេលវិវាទកើតឡើង ដើម្បីកំណត់កម្មវត្ថុជាក់លាក់នៃវិវាទ និងនីតិវិធីផ្សេងៗនៃដំណើរការមជ្ឈត្តការផងដែរ។

### ១.២.១.២. ច្បាប់គ្រប់គ្រងកិច្ចព្រមព្រៀងផ្សះផ្សា

ច្បាប់គ្រប់គ្រងកិច្ចព្រមព្រៀងផ្សះផ្សា សំដៅទៅលើច្បាប់ទាំងឡាយណាដែលកំណត់អំពីការបង្កើតកិច្ចព្រមព្រៀងផ្សះផ្សា សុពលភាពនៃកិច្ចព្រមព្រៀងផ្សះផ្សា ការអនុវត្ត និងការរំលាយកិច្ចព្រមព្រៀងផ្សះផ្សា។[27] បើវិវាទមិនមានលក្ខណៈអន្តរជាតិ នោះកិច្ចព្រមព្រៀងផ្សះផ្សានឹងស្ថិត

[26] ច្បាប់ស្ដីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្មនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦, មាត្រា៧, កថា. ១។ និង ច្បាប់សហព័ន្ធនៃមជ្ឈត្តការរបស់សហរដ្ឋអាមេរិក (FAA) ឆ្នាំ១៩២៥, មាត្រា២។

[27] ដូច ១៨, ទំព័រ ១១។

នៅក្រោមច្បាប់ជាតិរបស់ខ្លួនជាអ្នកគ្រប់គ្រង។ ប៉ុន្តែបើវិវាទមានលក្ខណៈអន្តរជាតិ ច្បាប់ដែលគ្រប់គ្រងលើកិច្ចព្រមព្រៀងផ្សះផ្សានឹងក្លាយជាចំណោទបញ្ហា។ យ៉ាងណាមិញ ច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្មរបស់ប្រទេសកម្ពុជា ក៏ដូចជាច្បាប់សហព័ន្ធនៃមជ្ឈត្តការរបស់សហរដ្ឋអាមេរិក មិនមានកំណត់ច្បាស់លាស់អំពីច្បាប់ជាក់លាក់ណាមួយ ដែលនឹងត្រូវគ្រប់គ្រងកិច្ចព្រមព្រៀងផ្សះផ្សាក្នុងករណីនេះទេ។ លើសពីនេះ ច្បាប់នៃប្រទេសទាំងពីរក៏មិនមានចែងច្បាស់លាស់អំពីនីតិវិធីក្នុងការកំណត់ពីច្បាប់គ្រប់គ្រងលើកិច្ចព្រមព្រៀងផ្សះផ្សាក្នុងករណីនេះដែរ។

យោងតាម***សន្និសិទរបស់អង្គការសហប្រជាជាតិស្តីពីជំនួញ និងការអភិវឌ្ឍ*** វិធីសាស្ត្រទូទៅចំនួនបួនត្រូវបានយកមកប្រើប្រាស់នៅក្នុងការកំណត់ច្បាប់គ្រប់គ្រងលើកិច្ចព្រមព្រៀងផ្សះផ្សា។[28] **វិធីសាស្ត្រទីមួយ** គឺការកំណត់ច្បាប់គ្រប់គ្រងកិច្ចព្រមព្រៀងផ្សះផ្សាដោយពិនិត្យលើច្បាប់ដែលភាគីបានជ្រើសរើស។[29] ភាគីអាចជ្រើសរើសច្បាប់គ្រប់គ្រងកិច្ចព្រមព្រៀងផ្សះផ្សាដោយគ្រាន់តែបញ្ជាក់នៅក្នុងកិច្ចព្រមព្រៀងផ្សះផ្សានោះតែម្តង។ ឧទាហរណ៍ កិច្ចព្រមព្រៀងនេះត្រូវគ្រប់គ្រងដោយច្បាប់គ្រប់គ្រងកិច្ចសន្យារបស់ប្រទេសកម្ពុជា។ **វិធីសាស្ត្រទីពីរ** គឺការកំណត់ដោយផ្អែកលើច្បាប់ដែលគ្រប់គ្រងកិច្ចសន្យារបស់គូភាគី។[30] **វិធីសាស្ត្រទីបី** គឺការកំណត់ដោយផ្អែកលើច្បាប់គ្រប់គ្រងនីតិវិធីនៃមជ្ឈត្តការ។[31] ចំណែកឯ**វិធីសាស្ត្រចុងក្រោយ** គឺការកំណត់ច្បាប់គ្រប់គ្រងកិច្ចព្រមព្រៀងផ្សះផ្សាដោយផ្អែកលើច្បាប់នៃទីកន្លែងធ្វើមជ្ឈត្តកម្ម។[32]

### ១.២.២. លក្ខខណ្ឌគតិយុត្តនៃកិច្ចព្រមព្រៀងផ្សះផ្សា

សម្រាប់ប្រទេសកម្ពុជាដែលជារដ្ឋទោល លក្ខខណ្ឌគតិយុត្តនៃកិច្ចព្រមព្រៀងផ្សះផ្សាមិនមានលក្ខណៈស្មុគស្មាញនៅក្នុងការកំណត់ ដូចនៅក្នុងសហរដ្ឋអាមេរិកដែលជារដ្ឋសហព័ន្ធនោះឡើយ។ នេះគឺដោយសារតែ រដ្ឋនីមួយៗនៃសហរដ្ឋអាមេរិកសុទ្ធសឹងតែមានច្បាប់សម្រាប់គ្រង់គ្រងមជ្ឈត្តការរៀងៗខ្លួន ហើយក្នុងពេលជាមួយគ្នានេះដែរ រដ្ឋទាំងនោះក៏ត្រូវតែគោរពទៅតាមច្បាប់សហព័ន្ធនៃមជ្ឈត្តការរបស់សហរដ្ឋអាមេរិកទាំងមូលផងដែរ ក្នុងលក្ខណៈមួយដែលច្បាប់សហព័ន្ធមានឧត្តមានុភាពលើច្បាប់រដ្ឋ។ ហេតុដូច្នេះ លក្ខខណ្ឌគតិយុត្តអាចប្រែប្រួលទៅតាមរដ្ឋនីមួយៗក្នុងករណីដែលមជ្ឈត្តកម្មត្រូវធ្វើនៅរដ្ឋនោះនិងធ្វើឡើងរវាងពលរដ្ឋនៃរដ្ឋនោះ។ តែក្នុងករណីដែល

[28] ដូច ១៨, ទំព័រ ១១ ដល់ ១២។

[29] ដូចខាងលើ។

[30] ដូចខាងលើ។

[31] ដូច ១៨, ទំព័រ ១១។

[32] ដូចខាងលើ។

មជ្ឈត្តកម្មត្រូវធ្វើឡើងដោយពលរដ្ឋនៃរដ្ឋផ្សេងៗគ្នា លក្ខខណ្ឌគតិយុត្តនៃកិច្ចព្រមព្រៀងផ្សះផ្សាត្រូវគោរពតាមច្បាប់សហព័ន្ធនៃសហរដ្ឋអាមេរិក រួមទាំងតាមច្បាប់រដ្ឋណាមួយដែលគូភាគីវិវាទបានព្រមព្រៀងប្រសិនបើមាន។

ច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្មរបស់ប្រទេសកម្ពុជា មិនមានបញ្ជាក់ច្បាស់លាស់អំពីលក្ខខណ្ឌគតិយុត្តនៃកិច្ចព្រមព្រៀងផ្សះផ្សានោះទេ ប៉ុន្តែគ្រាន់តែបញ្ជាក់ថាកិច្ចព្រមព្រៀងផ្សះផ្សាត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ[33] ដែលជាលក្ខខណ្ឌទម្រង់នៃកិច្ចព្រមព្រៀងផ្សះផ្សា។ រីឯច្បាប់សហព័ន្ធរបស់សហរដ្ឋអាមេរិក ក៏តម្រូវឲ្យកិច្ចព្រមព្រៀងផ្សះផ្សាធ្វើឡើងជាលាយលក្ខណ៍អក្សរផងដែរ ហើយចែងបន្ថែមទៀតថាៈ

> ខចែងជាលាយលក្ខណ៍អក្សរក្នុងទំនាក់ទំនងពាណិជ្ជកម្ម ឬកិច្ចសន្យាដែលគូភាគីវិវាទបានព្រមព្រៀងដើម្បីដាក់វិវាទរបស់ខ្លួន ដែលអាចនឹងកើតមានឡើងពីទំនាក់ទំនងពាណិជ្ជកម្មឲ្យដោះស្រាយតាមរយៈមជ្ឈត្តការ [...] ឬកិច្ចសន្យាជាលាយលក្ខណ៍អក្សររបស់គូភាគីដើម្បីដាក់វិវាទរបស់ខ្លួនដែលបានកើតឡើងពីទំនាក់ទំនងពាណិជ្ជកម្មរបស់គូភាគីវិវាទ ត្រូវតែមានសុពលភាព ភាពមិនអាចលុបចោលបាន និងអាចអនុវត្តបាន ដោយយោងតាមលក្ខខណ្ឌដែលមានកំណត់ក្នុងច្បាប់ [...]។[34]

តាមការប្រៀបធៀបច្បាប់នៃប្រទេសទាំងពីរ យើងសង្កេតឃើញថា កិច្ចព្រមព្រៀងផ្សះផ្សាត្រូវតែបំពេញនូវលក្ខខណ្ឌចំនួនពីរដូចគ្នា ដើម្បីឲ្យកិច្ចព្រមព្រៀងនេះមានសុពលភាពអនុវត្តបានពោលគឺ លក្ខខណ្ឌគ្រឹះ **(១.២.២.១.)** និងលក្ខខណ្ឌទម្រង់ **(១.២.២.២.)**។

#### ១.២.២.១. លក្ខខណ្ឌគ្រឹះ

ច្បាប់របស់ប្រទេសទាំងពីរ បង្ហាញពីចំណុចដូចគ្នានៃលក្ខខណ្ឌគ្រឹះរបស់កិច្ចព្រមព្រៀងផ្សះផ្សាដើម្បីឲ្យកិច្ចព្រមព្រៀងនោះមានសុពលភាពអនុវត្តបាន។ លក្ខខណ្ឌគ្រឹះទាំងនោះ រួមមានការព្រមព្រៀង សមត្ថភាពរបស់ភាគី ទំនាក់ទំនងគតិយុត្ត និងកម្មវត្ថុនៃវិវាទ។

---

[33] ច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្មនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦, មាត្រា៧, កថា. ២។ សំគាល់៖ យ៉ាងណាក៏ដោយ តាមរយៈនិយមន័យនៃកិច្ចព្រមព្រៀងផ្សះផ្សា ដែលមានចែងក្នុងមាត្រា២នៃច្បាប់នេះដែរ យើងអាចកំណត់បាននូវលក្ខខណ្ឌគ្រឹះមួយចំនួនរបស់កិច្ចព្រមព្រៀងផ្សះផ្សា។

[34] ច្បាប់សហព័ន្ធនៃមជ្ឈត្តការរបស់សហរដ្ឋអាមេរិក (FAA) ឆ្នាំ១៩២៥, មាត្រា២។

### ក. ការព្រមព្រៀងរួម

ច្បាប់របស់ប្រទេសទាំងពីរ ទទួលស្គាល់ថា គូភាគីនៃកិច្ចសន្យា ឬក៏កិច្ចព្រមព្រៀងត្រូវបាន ផ្តល់ឲ្យនូវសេរីភាពនៃឆន្ទៈ នៅក្នុងការធ្វើកិច្ចព្រមព្រៀង។[35] ការព្រមព្រៀងរួមនៅទីនេះ សំដៅដល់ ការព្រមព្រៀងមួយដែលកើតចេញពីឆន្ទៈពិតប្រាកដ និងដោយសេរីរបស់គូភាគីនៃវិវាទក្នុងការធ្វើ កិច្ចព្រមព្រៀង។[36] ហេតុដូច្នេះហើយ កិច្ចព្រមព្រៀងផ្សះផ្សារបស់គូភាគីវិវាទ មិនត្រូវបង្កើតឡើង ដោយមានការបង្ខិតបង្ខំ ការភ័ន្តច្រឡំ ការឆបោក ការគម្រាមកំហែង និងការគេងចំនេញហួសហេតុ ពីភាគីណាមួយ ពោលគឺកិច្ចព្រមព្រៀងនោះត្រូវតែបានបង្កើតឡើងដោយគ្មានវិការៈ។[37]

***ឧទាហរណ៍*** កិច្ចព្រមព្រៀងផ្សះផ្សា ដែលធ្វើឡើងរវាងបុគ្គលមួយដែលមិនបានយល់ដឹង អំពីយន្តការមជ្ឈត្តការ ហើយភ័ន្តច្រឡំថាជាយន្តការសន្ធានកម្ម ជាមួយនឹងបុគ្គលមួយទៀតដែល បានយល់ដឹងច្បាស់អំពីយន្តការនេះ។ ក្នុងករណីបែបនេះ កិច្ចព្រមព្រៀងមជ្ឈត្តការមិនបានកើត ចេញពីការព្រមព្រៀងរួមរបស់គូភាគីនោះឡើយ ដោយភាគីម្ខាងមានការភ័ន្តច្រឡំ និងមិនមានឆន្ទៈ ពិតប្រាដកក្នុងការដាក់វិវាទឲ្យដោះស្រាយតាមមជ្ឈត្តការឡើយ។

### ខ. សមត្ថភាពរបស់ភាគី

សមត្ថភាពរបស់ភាគី សំដៅលើសមត្ថភាពក្នុងការបង្ហាញឆន្ទៈនៅក្នុងការចុះកិច្ចសន្យា។ ដើម្បីឲ្យកិច្ចសន្យា ឬកិច្ចព្រមព្រៀងមួយមានសុពលភាពបាន កិច្ចសន្យាឬកិច្ចព្រមព្រៀងនោះត្រូវតែ បានបង្កើតឡើយដោយបុគ្គលដែលមានសមត្ថភាពដើម្បីបង្ហាញឆន្ទៈក្នុងការចុះកិច្ចសន្យា។ បាន សេចក្តីថា បុគ្គលដែលខ្វះសមត្ថភាពខាងឆន្ទៈ ឬបុគ្គលដែលមិនអាចយល់ដឹង និងវិនិច្ឆ័យបានអំពី លទ្ធផលតាមផ្លូវច្បាប់នូវសកម្មភាពរបស់ខ្លួន មិនមានសិទ្ធិក្នុងការបង្កើតកិច្ចព្រមព្រៀងមួយដែល មានសុពលភាពអនុវត្តបានឡើយ។[38] បើយោងតាមក្រមរដ្ឋប្បវេណីរបស់កម្ពុជាមាត្រា១៦ បុគ្គល

---

[35] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧ (ពីនេះតទៅហៅថា ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧), មាត្រា ៣។ Mark W. Friedman និង Floriane Lavaud, International Bar Association, Arbitration Guide, IBA Arbitration Committee, *UNITED STATES* [សហរដ្ឋអាមេរិក], (New York, កញ្ញា ២០១២), ទំព័រ ៣, អាចរកបាននៅ៖ http://www.ibanet.org/Document/Default.aspx?DocumentUid=939CE0D4-8D8A-4350-81D7-B7FEFE923C11 (ចតចម្លងថ្ងៃទី០២ មិថុនា ២០១៦)។

[36] ដូច ១៨, ទំព័រ ១៥។

[37] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧, មាត្រា ៣៩៥។ និង ច្បាប់សហព័ន្ធនៃមជ្ឈត្តការរបស់សហរដ្ឋអាមេរិក (FAA) ឆ្នាំ១៩២៥, មាត្រា២។

[38] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧, មាត្រា ២៤។

ដែលគ្មានសមត្ថភាពទាំងនោះមានដូចជា អនីតិជន ជនស្ថិតក្រោមរបបអាណាព្យាបាលទូទៅ និងហិតូបត្ថម្ភកៈ ត្បិតថាបុគ្គលទាំងនេះខ្វះសមត្ថភាពខាងឆន្ទៈក្នុងការចុះកិច្ចសន្យា ឬកិច្ចព្រមព្រៀង។

**គ. ទំនាក់ទំនងគតិយុត្ត**

កិច្ចព្រមព្រៀងនេះត្រូវតែកើតចេញពីបុគ្គលដែលមានទំនាក់ទំនងគតិយុត្ត ទោះបីជាមានកិច្ចសន្យា ឬគ្មានកិច្ចសន្យាក៏ដោយ។[39] ទំនាក់ទំនងគតិយុត្តក្នុងន័យនេះ សំដៅទៅលើទំនាក់ទំនងតាមផ្លូវច្បាប់ណាមួយរវាងគូភាគី ដែលនាំឲ្យកើតមាននូវវិវាទ ហើយអាចដោះស្រាយបានតាមរយៈមជ្ឈត្តការផ្នែកពាណិជ្ជកម្ម។ ទោះបីជាច្បាប់មិនមានកំណត់អំពីទំហំនៃទំនាក់ទំនងគតិយុត្តិក៏ដោយ ទំនាក់ទំនងគតិយុត្តិត្រូវតែជាក់លាក់និងច្បាស់លាស់ ដែលអាចកើតចេញពីកិច្ចសន្យារវាងភាគី ឬមិនមែនកើតពីកិច្ចសន្យារវាងភាគី។

***ឧទាហរណ៍*** គូភាគីមួយបានធ្វើកិច្ចព្រមព្រៀងពាណិជ្ជកម្ម ប៉ុន្តែភាគីម្ខាងបានខកខានក្នុងការអនុវត្តកាតព្វកិច្ចរបស់ខ្លួនក្នុងកិច្ចព្រមព្រៀងពាណិជ្ជកម្មនោះ។ ក្រោយមកភាគីវិវាទទាំងពីរ បានធ្វើកិច្ចព្រមព្រៀងមជ្ឈត្តការមួយដើម្បីដាក់វិវាទរបស់ខ្លួនឲ្យដោះស្រាយតាមរយៈមជ្ឈត្តការ។ ក្នុងករណីនេះ កិច្ចព្រមព្រៀងមជ្ឈត្តការកើតឡើងចេញពីបុគ្គលដែលមានទំនាក់ទំនងគតិយុត្ត ពោលគឺទំនាក់ទំនងក្នុងកិច្ចព្រមព្រៀងពាណិជ្ជកម្ម។

**ឃ. កម្មវត្ថុនៃវិវាទ**

គូភាគីអាចដាក់វិវាទឲ្យស្ថិតនៅក្រោមការដោះស្រាយដោយមជ្ឈត្តការផ្នែកពាណិជ្ជកម្មបានលុះត្រាតែវិវាទនោះគឺជាប្រភេទនៃវិវាទមួយដែលអាចដោះស្រាយបាន តាមរយៈមជ្ឈត្តការផ្នែកពាណិជ្ជកម្ម។ ត្រង់ចំនុចនេះ *អនុសញ្ញាទីក្រុងញូវយ៉កស្តីពីការទទួលស្គាល់ និងការប្រតិបត្តិសេចក្តីសម្រេចរបស់មជ្ឈត្តករបរទេស* បានកំណត់យ៉ាងច្បាស់លាស់ថា កម្មវត្ថុនៃកិច្ចព្រមព្រៀងផ្សះផ្សាត្រូវតែអាចដោះស្រាយបានតាមរយៈមជ្ឈត្តការ បន្ថែមលើលក្ខខណ្ឌដទៃទៀត ដើម្បីឲ្យរដ្ឋដែលជាសមាជិកនៃអនុសញ្ញានេះទទួលស្គាល់នូវកិច្ចព្រមព្រៀងផ្សះផ្សារបស់គូភាគីវិវាទ។[40] យ៉ាងណាមិញ សម្រាប់មជ្ឈត្តការផ្នែកពាណិជ្ជកម្ម កម្មវត្ថុនៃវិវាទដែលមានចែងក្នុងកិច្ចព្រមព្រៀងផ្សះផ្សានោះត្រូវ

---

[39] អនុសញ្ញាអង្គការសហប្រជាតិស្តីពីការទទួលស្គាល់ និងការប្រតិបត្តិមជ្ឈត្តវិនិច្ឆ័យបរទេស, ១៩៥៨ (ពីនេះតទៅហៅថា អនុសញ្ញាទីក្រុងញូវយ៉ក ឆ្នាំ១៩៥៨), មាត្រា២(១)។

[40] ដូចខាងលើ។

តែអាចដោះស្រាយបានតាមរយៈមជ្ឈត្តការផ្នែកពាណិជ្ជកម្ម។[41] ទោះបីជាគូភាគីវិវាទមានសេរីភាព នៅក្នុងការជ្រើសរើសយកយន្តការមជ្ឈត្តការមកដោះស្រាយវិវាទរបស់ខ្លួនក៏ដោយ មជ្ឈត្តការផ្នែកពាណិជ្ជកម្មត្រូវបានកម្រិតត្រឹមការដោះស្រាយវិវាទផ្នែកពាណិជ្ជកម្មប៉ុណ្ណោះ។ ហេតុដូច្នេះហើយ ភាគីត្រូវតែកំណត់ឲ្យបានច្បាស់នៅក្នុងកិច្ចព្រមព្រៀងរបស់ខ្លួនថា វិវាទដែលខ្លួននឹងត្រូវយកមកដោះស្រាយតាមរយៈមជ្ឈត្តការផ្នែកពាណិជ្ជកម្ម គឺវិវាទពាណិជ្ជកម្ម។

### ១.២.២.២. លក្ខខណ្ឌទម្រង់

ច្បាប់របស់ប្រទេសទាំងពីរ សុទ្ធតែចែងដូចគ្នាទាក់ទងនឹងលក្ខខណ្ឌទម្រង់នៃកិច្ចព្រមព្រៀងផ្សះផ្សាថា កិច្ចព្រមព្រៀងផ្សះផ្សាត្រូវតែធ្វើឡើងជាលាយលក្ខណ៍អក្សរ។[42] តាមការប្រៀបធៀបច្បាប់នៃប្រទេសកម្ពុជាមានលក្ខណៈពិស្តាជាងត្រង់ចំនុចលក្ខខណ្ឌទម្រង់នេះ ដោយសារច្បាប់នៃប្រទេសកម្ពុជាពន្យល់បង្ហាញយ៉ាងពិស្តាអំពីលក្ខណៈលាយលក្ខណ៍អក្សរ នៃកិច្ចព្រមព្រៀងផ្សះផ្សាដូចដែលច្បាប់នេះចែងថា៖

> [...] ដែលហៅថាកិច្ចព្រមព្រៀងជាលាយលក្ខណ៍អក្សរ គឺកិច្ចព្រមព្រៀងដែលស្ថិតក្នុងឯកសារចុះហត្ថលេខាដោយភាគីវិវាទ ឬ ដែលស្ថិតនៅក្នុងការផ្ទេរលិខិតស្នាម ឬ មធ្យោបាយទូរគមនាគមន៍តាមប្រព័ន្ធអេឡិចត្រូនិច ដែលផ្តល់កំណត់ត្រាបញ្ជាក់ពីការព្រមព្រៀងគ្នា ឬ ដែលស្ថិតនៅក្នុងការផ្លាស់ប្តូរគ្នាទៅវិញទៅមកនូវពាក្យទាមទារ ឬ ពាក្យដោះសារដែលក្នុងនោះ ភាគីវិវាទមួយបានទាមទារ ហើយមិនត្រូវបានបដិសេធដោយភាគីវិវាទម្ខាងទៀត។ [...][43]

ដោយឡែក ច្បាប់សហព័ន្ធរបស់សហរដ្ឋអាមេរិកមិនមានបទបញ្ញត្តិណាមួយពន្យល់អំពីលក្ខណៈលាយលក្ខណ៍អក្សររបស់កិច្ចព្រមព្រៀងផ្សះផ្សាឡើយ ហើយការពន្យល់នោះជាទូទៅត្រូវផ្អែកលើអនុសញ្ញាទីក្រុងញូវយ៉កស្តីពីការទទួលស្គាល់ និងការប្រតិបត្តិសេចក្តីសម្រេចនៃមជ្ឈត្តករបរទេស[44] ដែលចែងថា៖

---

[41] ច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្មនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦, មាត្រា១។ និង ច្បាប់សហព័ន្ធនៃមជ្ឈត្តការរបស់សហរដ្ឋអាមេរិក (FAA) ឆ្នាំ១៩២៥, មាត្រា ២។

[42] ច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្មនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦, មាត្រា៧។ និង ច្បាប់សហព័ន្ធនៃមជ្ឈត្តការរបស់សហរដ្ឋអាមេរិក (FAA) ឆ្នាំ១៩២៥, មាត្រា ២។

[43] ច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្មនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦, មាត្រា៧, កថា. ២។

[44] Mark W. Friedman និង Floriane Lavaud, International Bar Association, Arbitration Guide, IBA Arbitration Committee, *UNITED STATES* [សហរដ្ឋអាមេរិក], (New York, កញ្ញា ២០១២), ទំព័រ ៣, អាចរកបាននៅ៖ http://www.ibanet.org/Document/Default.aspx?DocumentUid=939CE0D4-8D8A-4350-81D7-B7FEFE923C11 (ថតចម្លងនៅថ្ងៃទី០២ មិថុនា ២០១៦)។

ពាក្យថា "កិច្ចព្រមព្រៀងជាលាយលក្ខណ៍អក្សរ" ត្រូវរួមបញ្ចូលខចែងក្នុងកិច្ចសន្យា ឬនៅក្នុងកិច្ចព្រមព្រៀងដោយឡែក ដែលត្រូវបានចុះហត្ថលេខាដោយភាគី ឬ ដែលមាននៅក្នុងលិខិត ឬទូរសារឆ្លើយឆ្លងរបស់ភាគី។[45]

ម្យ៉ាងវិញទៀត ទាក់ទងនឹងលក្ខខណ្ឌទម្រង់នេះ គេក៏អាចពិនិត្យទៅលើលក្ខខណ្ឌដែលមានចែងនៅក្នុងច្បាប់រដ្ឋនីមួយៗផងដែរ ក្នុងកម្រិតមួយដែលមិនមានការបំពានលើច្បាប់សហព័ន្ធរបស់សហរដ្ឋអាមេរិកទាក់ទងនឹងមជ្ឈត្តការផ្នែកពាណិជ្ជកម្ម។

### ១.២.៣. អានុភាពនៃកិច្ចព្រមព្រៀងផ្សះផ្សា

តាមការប្រៀបធៀប ការបង្កើតកិច្ចព្រមព្រៀងផ្សះផ្សាមានអនុភាពដូចគ្នាទាំងនៅប្រទេសកម្ពុជា និងសហរដ្ឋអាមេរិក។ ចំណុចនេះនឹងបកស្រាយអំពីអនុភាពនៃកិច្ចព្រមព្រៀងផ្សះផ្សា ដែលមានដូចជា ការបោះបង់សិទ្ធិប្ដឹងទៅតុលាការ **(១.២.៣.១.)** ការផ្ដល់សមត្ថកិច្ចទៅមជ្ឈត្តការផ្នែកពាណិជ្ជកម្ម **(១.២.៣.២.)** និងចុងក្រោយ លក្ខណៈដាច់ដោយឡែកនៃកិច្ចព្រមព្រៀងផ្សះផ្សា **(១.២.៣.៤.)**។

#### ១.២.៣.១. ការបោះបង់សិទ្ធិប្ដឹងទៅតុលាការ

នៅពេលដែលភាគីសម្រេចធ្វើកិច្ចព្រមព្រៀងផ្សះផ្សា មានន័យថាភាគីបានបង្ហាញឆន្ទៈរួមមួយនៅក្នុងការយកវិវាទរបស់ខ្លួនទៅដោះស្រាយតាមរយៈមជ្ឈត្តការផ្នែកពាណិជ្ជកម្ម។ តាមរយៈកិច្ចព្រមព្រៀងផ្សះផ្សា ភាគីបានបង្ហាញឆន្ទៈផ្ដល់សមត្ថកិច្ចទៅឲ្យមជ្ឈត្តករជាអ្នកដោះស្រាយវិវាទរបស់ខ្លួន ហើយបោះបង់សិទ្ធិប្ដឹងទៅតុលាការ។ យោងទៅលើច្បាប់ស្ដីពីមជ្ឈត្តការនៃប្រទេសទាំងពីរ តុលាការដែលទទួលដោះស្រាយវិវាទដែលជាកម្មវត្ថុនៃកិច្ចព្រមព្រៀងមជ្ឈត្តកម្ម ត្រូវបញ្ជូនភាគីទៅធ្វើមជ្ឈត្តការ ប្រសិនបើមានសំណើរពីភាគីវិវាទណាមួយ លើកលែងតែតុលាការនោះរកឃើញថាកិច្ចព្រមព្រៀងផ្សះផ្សានោះត្រូវចាត់ទុកជាមោឃៈ ឬមិនអាចអនុវត្តបាន។[46] ហេតុដូច្នេះហើយ តុលាការមិនមានសមត្ថកិច្ចនៅក្នុងការដោះស្រាយវិវាទរបស់គូភាគីបាននោះឡើយ ប្រសិនបើមានកិច្ចព្រមព្រៀងផ្សះផ្សាដែលបានបំពេញនូវលក្ខខណ្ឌសុពលភាព ដូចបានបង្ហាញនៅក្នុងចំណុចលក្ខខណ្ឌគតិយុត្តខាងលើ។

---

[45] អនុសញ្ញាទីក្រុងញូវយ៉ក ឆ្នាំ១៩៥៨, មាត្រា២(២)។

[46] ច្បាប់ស្ដីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្មនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦, មាត្រា៨, កថា. ១។ និង ច្បាប់សហព័ន្ធនៃមជ្ឈត្តការរបស់សហរដ្ឋអាមេរិក ឆ្នាំ១៩២៥, មាត្រា៣។

### ១.២.៣.២. ការផ្តល់សមត្ថកិច្ចទៅមជ្ឈត្តការផ្នែកពាណិជ្ជកម្ម

មូលហេតុចម្បងនៅក្នុងការបង្កើតកិច្ចព្រមព្រៀងផ្សះផ្សា គឺក្នុងគោលបំណងផ្តល់សមត្ថកិច្ចឲ្យទៅមជ្ឈត្តករ ជាអ្នកដោះស្រាយវិវាទរបស់ខ្លួនតាមរយៈមជ្ឈត្តការផ្នែកពាណិជ្ជកម្ម។[47] ហេតុដូច្នេះហើយ ភាគីមិនអាចប្តឹងទៅតុលាការដើម្បីឲ្យដោះស្រាយវិវាទរបស់ខ្លួនឡើយ។ ក្នុងករណីដែលមានភាគីណាមួយប្តឹងទៅតុលាការដើម្បីឲ្យដោះស្រាយវិវាទ នោះភាគីម្ខាងទៀតមានសិទ្ធិប្តឹងជំទាស់នឹងសមត្ថកិច្ចរបស់តុលាការដែលទទួលពាក្យបណ្តឹងនោះបាន។ តុលាការត្រូវបញ្ជូនវិវាទឲ្យទៅមជ្ឈត្តករជាអ្នកដោះស្រាយវិញ លើកលែងតែតុលាការយល់ឃើញថាកិច្ចព្រមព្រៀងផ្សះផ្សាមិនមានសុពលភាពអនុវត្តបាន។

### ១.២.៣.៣. លក្ខណៈដាច់ដោយឡែកនៃកិច្ចព្រមព្រៀងផ្សះផ្សា

ទាំងច្បាប់កម្ពុជា និងច្បាប់របស់សហរដ្ឋអាមេរិកស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម សុទ្ធតែទទួលស្គាល់នូវលក្ខណៈពិសេសមួយនៃកិច្ចព្រមព្រៀងផ្សះផ្សា។ លក្ខណៈពិសេសនោះ សំដៅលើលក្ខណៈមួយ ដែលកិច្ចព្រមព្រៀងផ្សះផ្សាមានលក្ខណៈដាច់ដោយឡែកពីកិច្ចសន្យាពាណិជ្ជកម្មរបស់គូភាគី។[48] លក្ខណៈដាច់ឡែកនេះ មានន័យថាអសុពលភាពរបស់កិច្ចព្រមព្រៀងពាណិជ្ជកម្មរបស់គូភាគីវិវាទដោយប្រការណាមួយ មិនអាចនាំឲ្យកិច្ចព្រមព្រៀងផ្សះផ្សាដែលអាចជាខចែងនៅក្នុងកិច្ចសន្យាពាណិជ្ជកម្ម ឬកិច្ចព្រមព្រៀងដោយឡែក បាត់បង់សុពលភាពអនុវត្តឡើយ។ ច្បាប់នៃប្រទេសកម្ពុជាត្រង់ចំនុចនេះ មានចែងយ៉ាងច្បាស់ថា៖

> វេទិការមជ្ឈត្តកម្មអាចសម្រេចទៅតាមសមត្ថកិច្ចរបស់ខ្លួន នៅក្នុងនោះមានការជំទាស់នានាដែលទាក់ទងនឹងអត្ថិភាព ឬសុពលភាពនៃកិច្ចព្រមព្រៀងផ្សះផ្សា។ សម្រាប់គោលដៅនេះ

---

[47] ច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្មនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦, មាត្រា២(យ)។ ច្បាប់សហព័ន្ធនៃមជ្ឈត្តការរបស់សហរដ្ឋអាមេរិក ឆ្នាំ១៩២៥, មាត្រា២។

[48] ច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្មនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦, មាត្រា២៤(១)។ ចំណែកឯច្បាប់សហព័ន្ធនៃមជ្ឈត្តការរបស់សហរដ្ឋអាមេរិក៖ ថ្វីត្បិតថាច្បាប់សហព័ន្ធនេះ មិនមានចែងច្បាស់លាស់អំពីលក្ខណៈដាច់ដោយឡែកនេះក៏ដោយ លក្ខណៈដាច់ដោយឡែកនេះត្រូវបានតុលាការកំពូលរបស់សហរដ្ឋអាមេរិក ក្នុងរឿងក្តី Prima Paint Corp. v. Flood & Conklin Mfg. Co. ក្នុងឆ្នាំ១៩៦៧ សម្រេចទទួលស្គាល់ថាជាគោលការណ៍មូលដ្ឋានមួយរបស់ច្បាប់សហព័ន្ធនៃមជ្ឈត្តការតាំងពីជិត៥០ឆ្នាំមុនមកម្លេះ។ សូមមើលបន្ថែមនៅ៖ Stefan Michael Kröll, Loukas A. Mistelis, et. al., កែសម្រួល, *International Arbitration and International Commercial Law: Synergy, Convergence and Evolution* [មជ្ឈត្តការអន្តរជាតិ និងច្បាប់ពាណិជ្ជកម្មអន្តរជាតិ], *Chapter 8: Competence Competence and Separability-American Style* [គោលការណ៍ កំពិតង់ កំពិតង់ និងគោលការណ៍ដាច់ដោយឡែកតាមបែបអាមេរិក] (Great Britian: Kluwer Law International, 2011), ទំព័រ ១៥៨។ អាចស្វែងរកបាននៅ៖ http://digitalcommons.tourolaw.edu/cgi/viewcontent.cgi?article=1402&context=scholarlyworks (ថតចម្លងថ្ងៃទី ១១ កក្កដា ២០១៦)។

ខចែងស្តីពីការផ្សះផ្សាដែលបង្កើតបានជាផ្នែកមួយនៃកិច្ចសន្យា ត្រូវចាត់ទុកថាជាកិច្ចព្រម-ព្រៀងដោយឡែក ដែលមិនទាក់ទងទៅនឹងលក្ខខណ្ឌដទៃទៀតក្នុងកិច្ចសន្យាថាមោឃៈ និងអសារឥតការមិននាំឲ្យខចែងស្តីពីការផ្សះផ្សានោះបាត់សុពលភាពឡើយ។[49]

ចំណែកឯច្បាប់សហព័ន្ធរបស់សហរដ្ឋអាមេរិកវិញ **តុលាការកំពូលរបស់សហរដ្ឋអាមេរិក**[50] នៅក្នុងរឿងក្តី *Buckeye Check Cashing, INC. v. John Cardegna et al.* បានសម្រេចថា ខចែងស្តីអំពីមជ្ឈត្តការ ត្រូវមានលក្ខណៈដាច់ដោយឡែកពីកិច្ចសន្យាពាណិជ្ជកម្មរបស់គូភាគី យោងតាមច្បាប់សហព័ន្ធនៃមជ្ឈត្តការរបស់សហរដ្ឋអាមេរិក។ កិច្ចព្រមព្រៀងមជ្ឈត្តកម្មរបស់គូភាគីវិវាទនៅតែមានអនុភាពអនុវត្តបាន បើទោះបីជាកិច្ចសន្យាទាំងមូលមិនមានសុពលភាពអនុវត្តបានក៏ដោយ។ លើសពីនេះទៅទៀត ច្បាប់នៃរដ្ឋណាមួយដែលមិនទទួលស្គាល់នូវលក្ខណៈដាច់ដោយឡែកនេះនឹងត្រូវរារាំងដោយអនុភាពនៃច្បាប់សហព័ន្ធ ដោយហេតុថាច្បាប់សហព័ន្ធមានឧត្តមានុភាពលើច្បាប់រដ្ឋ។[51]

សរុបមក ច្បាប់នៃប្រទេសទាំងពីរសុទ្ធតែទទួលស្គាល់ថា លក្ខណៈដាច់ដោយឡែករបស់កិច្ចព្រមព្រៀងផ្សះផ្សាបង្កើតបានជាអនុភាពមួយ ដែលវេទិកាមជ្ឈត្តកម្ម ឬតុលាការត្រូវពិចារណាសម្រេចលើលក្ខខណ្ឌសុពលភាពរបស់កិច្ចព្រមព្រៀងផ្សះផ្សា ដោយឡែកពីកិច្ចសន្យាពាណិជ្ជកម្មរបស់គូភាគីវិវាទ ហើយអសុពលភាពអនុវត្តនៃកិច្ចសន្យាពាណិជ្ជកម្ម មិនអាចនាំឲ្យកិច្ចព្រមព្រៀងផ្សះផ្សាបាត់បង់អនុភាពនោះទេ។

---

[49] ច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្មនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦, មាត្រា២៤(១)។

[50] BUCKEYE CHECK CASHING, INC., Petitioner, v. John CARDEGNA et al, សាលដីការបស់តុលាកំពូលនៃរដ្ឋហ្វ្លរីដា, (សហរដ្ឋអាមេរិក, លេខ ០៤-១២៦៤, សម្រេចនៅថ្ងៃទី២១ កុម្ភៈ ២០០៦), អាចស្វែងរកបាននៅ៖ http://classactiondefense.jmbm.com/buckeyeclassactiondefense_opn.pdf។

[51] Stephen Smerek and Daniel Whang, *Preemption and the Federal Arbitration Act: What law will govern your Agreement to Arbitrate?* [ការរារាំងការអនុវត្ត និងច្បាប់សហ័ន្ធនៃមជ្ឈត្តការ៖ តើច្បាប់ណានឹងគ្រប់គ្រងកិច្ចព្រមព្រៀងមជ្ឈត្តកម្មរបស់អ្នក?], ទំព័រ ២, អាចស្វែករកបាននៅ៖ http://apps.americanbar.org/buslaw/newsletter/0051/materials/pp7.pdf ។

# ជំពូកទី ២

# នីតិវិធីមជ្ឈត្តកាផ្នែកពាណិជ្ជកម្ម

ច្បាប់របស់ប្រទេសទាំងពីរ សុទ្ធតែទទួលស្គាល់ដូចគ្នានូវគោលការណ៍សេរីភាពឆន្ទៈរបស់ភាគី។ដោយផ្អែកលើគោលការណ៍នេះ ភាគីអាចធ្វើការព្រមព្រៀងលើច្បាប់ ឬក៏វិធានណាមួយដើម្បីគ្រប់គ្រងលើនីតិវិធីនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម។ ប្រទេសកម្ពុជាមានច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ដែលច្បាប់នេះមានចែងផងដែរអំពីនីតិវិធីនៅក្នុងការធ្វើមជ្ឈត្តកម្ម ក្រៅពីបញ្ញត្តិស្តីពីការទទួលស្គាល់កិច្ចព្រមព្រៀងផ្សះផ្សា និងការអនុវត្តមជ្ឈត្តវិនិច្ឆ័យ។ តែសម្រាប់សហរដ្ឋអាមេរិកវិញច្បាប់សហព័ន្ធរបស់រដ្ឋអាមេរិកស្តីពីមជ្ឈត្តការ មិនមានចែងច្បាស់អំពីនីតិវិធីនៃក្នុងការធ្វើមជ្ឈត្តកម្មឡើយ ព្រោះច្បាប់នេះផ្តោតសំខាន់តែទៅលើការទទួលស្គាល់កិច្ចព្រមព្រៀងផ្សះផ្សា និងការអនុវត្តមជ្ឈត្តវិនិច្ឆ័យប៉ុណ្ណោះ។ យ៉ាងណាក៏ដោយ ភាគីនៅតែអាចព្រមព្រៀងគ្នាយកច្បាប់នៃរដ្ឋណាមួយនៃសហរដ្ឋអាមេរិកមកគ្រប់គ្រងលើនីតិវិធីមជ្ឈត្តការផ្នែកពាណិជ្ជកម្មរបស់ខ្លួនបាន ត្បិតថាច្បាប់រដ្ឋទាំងនោះមានបញ្ញត្តិស្តីពីនីតិវិធីនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម។[52] បើយោងតាមការអនុវត្តកន្លងមកនៅសហរដ្ឋអាមេរិក យើងសង្កេតឃើញថាភាគីតែងតែងជ្រើសរើសយកវិធាននៃស្ថាប័នមជ្ឈត្តការ ឬមជ្ឈមណ្ឌលមជ្ឈត្តការដែលខ្លួនជ្រើសរើស ដើម្បីគ្រប់គ្រងលើនីតិវិធីក្នុងការដោះស្រាយវិវាទពាណិជ្ជកម្មរបស់ខ្លួន។

ហេតុដូច្នេះ ជំពូកទី២នេះនឹងធ្វើការប្រៀបធៀបរវាងនីតិវិធីមជ្ឈត្តការផ្នែកពាណិជ្ជកម្មក្នុងប្រទេសកម្ពុជា និងសហរដ្ឋអាមេរិក ដោយផ្អែកជាចម្បងលើវិធានស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្មរបស់សមាគមមជ្ឈត្តការសហរដ្ឋអាមរិក និងមជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្មរបស់ប្រទេសកម្ពុជា រួមជាមួយនឹងច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្មរបស់កម្ពុជា និងច្បាប់សហព័ន្ធនៃមជ្ឈត្តការរបស់សហរដ្ឋអាមេរិក។ ជំពូកនេះ បែងចែកជាពីរចំណុចធំៗ គឺការចាប់ផ្តើមដំណើរការនៃមជ្ឈត្តការ (**២.១**) និងសវនាការនិងមជ្ឈត្តវិនិច្ឆ័យ (**២.២**)។

[52] សហរដ្ឋអាមេរិកបានអនុម័ត ច្បាប់ឯកភាពនៃមជ្ឈត្តការរបស់សហរដ្ឋអាមេរិក (Uniform Arbitration Act 1955) សម្រាប់ឲ្យរដ្ឋនិមួយៗទទួលយកមកអនុវត្តក្នុងរដ្ឋរបស់ខ្លួន និងដើម្បីឲ្យមានឯកភាពគ្នានៃច្បាប់រដ្ឋនិមួយៗដែរ។ សហរដ្ឋអាមេរិកបានបង្កើតច្បាប់មួយទៀតដើម្បីកែសម្រួលច្បាប់ឆ្នាំ១៩៥៥ ឲ្យស្របទៅតាមស្ថានភាពបច្ចុប្បន្នផងដែរ (Revised Uniform Arbitration Act 2000)។ សូមមើលបន្ថែមនៅ៖ http://www.uniformlaws.org/ActSummary.aspx?title=Arbitration%20Act%20(2000) (ចូលទស្សនាថ្ងៃទី២២ មិថុនា ២០១៦)។

ដោយមើលឃើញថា នីតិវិធីនៃមជ្ឈត្តការមានលក្ខណៈស្មុគ្រស្មាញ និងដើម្បីឲ្យអ្នកអានងាយយល់ពីលក្ខណៈដូចគ្នា និងខុសគ្នាតាមរយៈការប្រៀបធៀបនេះ ខ្ញុំបាទនឹងធ្វើការប្រៀបធៀបក្នុងចំណុចតូចៗនីមួយៗតែម្តង។

## ២.១. ការចាប់ផ្តើមដំណើរការមជ្ឈត្តការ

ចំណុច ២.១.នេះ នឹងធ្វើការពន្យល់ និងប្រៀបធៀបអំពីការចាប់ផ្តើមមជ្ឈត្តកម្ម **(២.១.១.)** ការបង្កើតវេទិកាមជ្ឈត្តកម្ម **(២.១.២.)** និងការរៀបចំដំណើរការមជ្ឈត្តការ **(២.១.៣.)**។

### ២.១.១. ការចាប់ផ្តើមមជ្ឈត្តកម្ម

ចំណុច ២.១.១. នេះនឹងធ្វើការបកស្រាយ និងប្រៀបធៀបអំពី ការជូនដំណឹងរបស់ភាគីប្តឹងទាមទារ **(២.១.១.១.)** និងការឆ្លើយតបរបស់ភាគីឆ្លើយតប **(២.១.១.២.)**។

#### ២.១.១.១. ការជូនដំណឹងរបស់ភាគីប្តឹងទាមទារ

- ករណីកម្ពុជា

ចំពោះប្រទេសកម្ពុជា ភាគីណាមួយដែលមានបំណងដាក់វិវាទរបស់ខ្លួនឲ្យដោះស្រាយតាមរយៈមជ្ឈត្តការផ្នែកពាណិជ្ជកម្ម “**ភាគីប្តឹងទាមទារ**” ដំបូងត្រូវបញ្ជូនសេចក្តីជូនដំណឹងអំពីមជ្ឈត្តកម្មទៅអគ្គលេខាធិកាដ្ឋាន។ ដោយយោងតាមវិធាន ៧.១ នៃវិធានស្តីពីមជ្ឈត្តការរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម សេចក្តីជូនដំណឹងនោះត្រូវបញ្ជាក់អំពីព័ត៌មានដូចខាងក្រោម៖

ក. សេចក្តីថ្លែងដែលបញ្ជាក់ថាភាគីដាក់វិវាទឲ្យដោះស្រាយតាមមជ្ឈត្តកម្ម

ខ. ឈ្មោះ អាសយដ្ឋាន លេខទូរស័ព្ទ លេខទូរសារ និងអាសយដ្ឋានសារអេឡិចត្រូនិច ប្រសិនបើមានព័ត៌មានទាំងនេះរបស់គូភាគីវិវាទ និងរបស់អ្នកតំណាងរបស់គូភាគីវិវាទ ប្រសិនបើមាន

គ. សញ្ជាតិ ឬប្រសិនបើតម្រូវ និងមានព័ត៌មាន អត្តសញ្ញាណរបស់ក្រុមហ៊ុនរបស់គូភាគីវិវាទ

ឃ. សេចក្តីយោងនៃខចែងស្តីពីមជ្ឈត្តកម្ម ឬកិច្ចសន្យាមជ្ឈត្តកម្មដោយឡែកដែលយកមកប្រើ និងភ្ជាប់សំណៅចម្លងនៃខចែងស្តីពីមជ្ឈត្តកម្ម ឬកិច្ចសន្យាមជ្ឈត្តកម្មដោយឡែកនោះ

ង. សេចក្តីយោងនៃកិច្ចសន្យា ឬទំនាក់ទំនងផ្សេងៗដែលកើតចេញពី ឬដែលទាក់ទងនឹងវិវាទ និងភ្ជាប់សំណៅចម្លងនៃកិច្ចសន្យាទាំងនោះប្រសិនបើអាច

ច. សេចក្ដីថ្លែងសង្ខេប ដែលពិពណ៌នាអំពីលក្ខណៈ និងកាលៈទេសៈនៃវិវាទ ការទាមទារ ឬការសង្គ្រោះដែលទាមទារ និងប្រសិនបើអាច ភ្ជាប់តម្លៃបឋមនៃការទាមទារដែលភាគីប្ដឹងទាមទារមានបំណងដាក់ស្នើ

ឆ. ចំនួនមជ្ឈត្តករដែលបានព្រមព្រៀង ឬនៅក្នុងករណីដែលមិនមានការព្រមព្រៀងទេនោះ ចំនួនមជ្ឈត្តករដែលស្នើសុំ ដែលត្រូវមានចំនួន ១ (មួយ)រូប ឬ៣(បី) រូប និង

ជ. សេចក្ដីថ្លែង ឬសំណើបន្ថែមផ្សេងៗ ពាក់ព័ន្ធនឹងដំណើរការមជ្ឈត្តការ រួមបញ្ចូលទាំងច្បាប់ដែលត្រូវអនុវត្ត ភាសាសម្រាប់ដំណើរការមជ្ឈត្តការ និងលក្ខណៈសម្បត្តិ និងសញ្ជាតិរបស់មជ្ឈត្តករដែលបានព្រមព្រៀង ឬដែលចង់បាន ប្រសិនបើមាន។

បន្ថែមលើសពីនេះទៅទៀត ចំពោះភាគីដែលមានបំណងដាក់វិវាទរបស់ខ្លួនឲ្យដោះស្រាយតាមរយៈមជ្ឈត្តការផ្នែកពាណិជ្ជកម្មត្រូវដាក់សេចក្ដីជូនដំណឹងអំពីមជ្ឈត្តការ ដោយភ្ជាប់មកជាមួយនូវការបង់ប្រាក់កម្រៃសេវាចុះបញ្ជីដែលអាចជាមូលប្បទានបត្រ ឬក៏ការផ្ទេរចូលគណនីធនាគារកំណត់ណាមួយរបស់ ម.ជ.ម.។[53] ភាគីប្ដឹងទាមទារអាចភ្ជាប់មកជាមួយនូវសេចក្ដីថ្លែងទាមទារ និងឯកសារគាំទ្រផ្សេងៗទៀត។[54] ម្យ៉ាងវិញទៀត ភាគីក៏អាចរួមបញ្ចូលការតែងតាំងមជ្ឈត្តករនៅក្នុងសេចក្ដីថ្លែងទាមទាររបស់ខ្លួនផងដែរ។[55] សេចក្ដីជូនដំណឹងអំពីមជ្ឈត្តកម្មត្រូវចាត់ទុកថាពេញលេញនៅពេលដែលចំនុចនានាដែលតម្រូវដូចមានបង្ហាញខាងលើត្រូវបានបំពេញ រួមបញ្ចូលទាំងការបង់កម្រៃសេវាចុះបញ្ជី។[56] ប្រសិនបើសេចក្ដីជូនដំណឹងអំពីមជ្ឈត្តកម្ម មានលក្ខណៈមិនពេញលេញនោះអគ្គលេខាធិការដ្ឋានអាចស្នើសុំភាគីប្ដឹងទាមទារឲ្យបំពេញបន្ថែមនូវចំនុចខ្វះខាតទាំងនោះ ក្នុងកំឡុងពេលសមស្របណាមួយដែលកំណត់ដោយអគ្គលេខាធិការដ្ឋាន។[57] អគ្គលេខាធិការដ្ឋានត្រូវជូនដំណឹងទៅគូភាគី នៅពេលដែលអគ្គលេខាធិការដ្ឋានបានទទួលសេចក្ដីជូនដំណឹងពេញលេញអំពីមជ្ឈត្តកម្ម។[58]

[53] វិធានស្ដីពីមជ្ឈត្តការរបស់ ម.ជ.ម. នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៤, វិធាន៧.១, កថា. ៣។
[54] វិធានស្ដីពីមជ្ឈត្តការរបស់ ម.ជ.ម. នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៤, វិធាន៧.៣ និង២២.២។
[55] វិធានស្ដីពីមជ្ឈត្តការរបស់ ម.ជ.ម. នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៤, វិធាន៧.២។
[56] វិធានស្ដីពីមជ្ឈត្តការរបស់ ម.ជ.ម. នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៤, វិធាន៧.៤, កថា. ១។
[57] វិធានស្ដីពីមជ្ឈត្តការរបស់ ម.ជ.ម. នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៤, វិធាន៧.៤, កថា. ១។
[58] វិធានស្ដីពីមជ្ឈត្តការរបស់ ម.ជ.ម. នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៤, វិធាន៧.៦។

❖ ករណីសហរដ្ឋអាមេរិក

ដោយឡែកនៅសហរដ្ឋអាមេរិក ភាគីប្ដឹងទាមទារត្រូវបញ្ជូនសេចក្ដីជូនដំណឹងអំពីមជ្ឈត្តកម្ម ទៅសមាគមមជ្ឈត្តការសហរដ្ឋអាមេរិក ដោយភ្ជាប់មកជាមួយផងដែរនូវថ្លៃសេវាដាក់ពាក្យ និង កិច្ចព្រមព្រៀងមជ្ឈត្តកម្មរបស់គូភាគី។[59] ភាគីប្ដឹងទាមទារត្រូវបញ្ជូនសេចក្ដីជូនដំណឹងអំពីមជ្ឈត្តកម្ម និងឯកសារគាំទ្រដែលទាក់ទងទាំងឡាយទៅភាគីម្ខាងទៀតដែរ។[60] ចំណែកឯព័តិមានដែលត្រូវរួម បញ្ចូលនៅក្នុងគ្រប់សេចក្ដីជូនដំណឹងអំពីមជ្ឈត្តកម្មទាំងអស់ រួមមាន៖[61]

ក. ឈ្មោះរបស់ភាគីនីមួយៗ

ខ. អាស័យដ្ឋានរបស់ភាគីនិមួយៗ រួមទាំងលេខទូរស័ព្ទនិងទូរសារ និងអ៊ីម៉េល

គ. ឈ្មោះ អាស័យដ្ឋាន លេខទូរស័ព្ទនិងទូរសារ និងអ៊ីម៉េលរបស់អ្នកតំណាងរបស់ភាគី ប្រសិនបើមាន

ឃ. សេចក្ដីថ្លែងដែលបង្ហាញពីលក្ខណៈនៃការទាមទាររួមទាំងសេចក្ដីសម្រេចរបស់មជ្ឈត្តការ ដែលខ្លួនចង់បាន និងចំនួនទឹកប្រាក់ដែលទាក់ទង; និង

ង. កន្លែងនៃមជ្ឈត្តកម្មដែលខ្លួនស្នើ បើសិនជាកិច្ចព្រមព្រៀងមជ្ឈត្តកម្មមិនបានបញ្ជាក់។

ក្នុងករណីដែលសេចក្ដីជូនដំណឹងស្ដីពីមជ្ឈត្តការមានលក្ខណៈមិនពេញលេញ ស.ម.ស. អាចស្នើសុំឲ្យភាគីប្ដឹងទាមទារបំពេញបន្ថែមចំនុចនូវខ្វះខាតទាំងនោះ ក្នុងកំឡុងពេលសមស្រប ណាមួយដែលកំណត់ដោយ ស.ម.ស.។[62] បន្ទាប់មក ស.ម.ស. ត្រូវជូនដំណឹងទៅគូភាគីវិវាទ នៅ ពេលដែល ស.ម.ស. បានទទួលសេចក្ដីជូនដំណឹងពេញលេញអំពីមជ្ឈត្តកម្មរួមទាំងថ្លៃដាក់ពាក្យ។

❖ ការប្រៀបធៀប

តាមការប្រៀបធៀប យើងសង្កេតឃើញថាវិធានក្នុងប្រទេសកម្ពុជាមានការទាមទារច្រើន ចំពោះពត៌មានដែលត្រូវដាក់បញ្ចូលនៅក្នុងសេចក្ដីជូនដំណឹងអំពីមជ្ឈត្តកម្ម។ យ៉ាងណាមិញ វិធាន របស់សហរដ្ឋអាមេរិកមានកំណត់ច្បាស់លាស់អំពីមធ្យោបាយ ដែលភាគីប្ដឹងទាមទារអាចដាក់នូវ សេចក្ដីជូនដំណឹងអំពីមជ្ឈត្តកម្ម ដែលអាចធ្វើឡើងតាមរយៈគេហទំព័ររបស់ ស.ម.ស. ឬក៏អាចដាក់

[59] វិធានស្ដីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម និងនីតិវិធីសន្ទានកម្ម រួមបញ្ចូលទាំងនីតិវិធីសម្រាប់វិវាទពាណិជ្ជកម្មដែលធំដុំ និង ស្មុគស្មាញ របស់សមាគមមជ្ឈត្តការសហរដ្ឋអាមេរិក, ១ តុលា ២០១៣ (ពីនេះតទៅហៅថា វិធានស្ដីពីមជ្ឈត្តការផ្នែក ពាណិជ្ជកម្ម និងនីតិវិធីសន្ទានកម្មរបស់ ស.ម.ស. ឆ្នាំ២០១៣), វិធាន៤(a)។

[60] វិធានស្ដីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម និងនីតិវិធីសន្ទានកម្មរបស់ ស.ម.ស. ឆ្នាំ២០១៣, វិធាន៤(g)។

[61] វិធានស្ដីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម និងនីតិវិធីសន្ទានកម្មរបស់ ស.ម.ស. ឆ្នាំ២០១៣, វិធាន៤(e)។

[62] វិធានស្ដីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម និងនីតិវិធីសន្ទានកម្មរបស់ ស.ម.ស. ឆ្នាំ២០១៣, វិធាន៤(i)។

នៅការិយាល័យណាមួយរបស់ ស.ម.ស. ទោះបីជាសវនាការដែលរពឹងទុកនោះត្រូវធ្វើនៅកន្លែងណាក៏ដោយ។[63]លើសពីនេះទៅទៀត វិធានរបស់សហរដ្ឋអាមេរិក មានចែងច្បាស់ក្នុងករណីដែលមានសាលក្រមរបស់តុលាការទទួលស្គាល់យន្តការមជ្ឈត្តការ សម្រាប់ដោះស្រាយវិវាទរបស់ភាគី។ ក្នុងករណីនេះ ភាគីត្រូវដាក់សេចក្តីជូនដំណឹងរបស់ខ្លួនទៅ ស.ម.ស. ដោយភ្ជាប់ជាមួយនូវថ្លៃសេវាដាក់ពាក្យ កិច្ចព្រមព្រៀងមជ្ឈត្តកម្មរបស់ខ្លួន និងសេចក្តីចម្លងនៃដីកាសម្រេចរបស់តុលាការ។[64] ចំណុចទាំងនេះគួរតែមាននៅក្នុងវិធានរបស់ប្រទេសកម្ពុជាដែរ ដើម្បីបង្កឲ្យមានភាពងាយស្រួលដល់ភាគី។

### ១.១.១.២. ការឆ្លើយតបរបស់ភាគីឆ្លើយតប

❖ ករណីកម្ពុជា

ក្នុងករណីប្រទេសកម្ពុជា ភាគីឆ្លើយតបត្រូវតែបញ្ជូនទៅអគ្គលេខាធិការដ្ឋាននូវសេចក្តីជូនដំណឹងអំពីការឆ្លើយតប ក្នុងរយៈពេល ១៥ថ្ងៃប្រតិទិន បន្ទាប់ពីបានទទួលសេចក្តីជូនដំណឹងអំពីការទទួលបានសេចក្តីជូនដំណឹងអំពីមជ្ឈត្តកម្មពីអគ្គលេខាធិការដ្ឋាន។[65] សេចក្តីជូនដំណឹងនោះត្រូវតែមានព័ត៌មានដូចខាងក្រោម៖[66]

ក. ឈ្មោះ អាសយដ្ឋាន លេខទូរស័ព្ទ លេខទូរសារ និងអាសយដ្ឋានសារអេឡិចត្រូនិចរបស់ភាគីឆ្លើយតប និងអ្នកតំណាងរបស់ខ្លួន ប្រសិនបើមាន និងប្រសិនបើព័ត៌មានទាំងនេះខុសពីព័ត៌មាន ដែលមានក្នុងសេចក្តីជូនដំណឹងអំពីមជ្ឈត្តកម្ម

ខ. សញ្ជាតិ ឬប្រសិនបើតម្រូវ អត្តសញ្ញាណរបស់ក្រុមហ៊ុនរបស់គូភាគីវិវាទ ប្រសិនបើព័ត៌មានទាំងនេះខុសពីព័ត៌មានដែលមានក្នុងសេចក្តីជូនដំណឹងអំពីមជ្ឈត្តកម្ម

គ. ការបញ្ជាក់សង្ខេបអំពីការទទួលយក ឬការបដិសេធចំពោះការទាមទារទាំងស្រុងឬដោយផ្នែក

ឃ. សេចក្តីថ្លែងសង្ខេប ដែលពិពណ៌នាអំពីលក្ខណៈ និងកាលៈទេសៈនៃបណ្តឹងតប ឬការដោះសាតាមការកាត់កង ដែលភាគីឆ្លើយតបមានបំណងបញ្ជូន និងប្រសិនបើអាចត្រូវភ្ជាប់តម្លៃបឋមនៃបណ្តឹងតប ឬ ការដោះសារតាមការកាត់កងនោះ

ង. ចំនួនមជ្ឈត្តករដែលបានព្រមព្រៀង ឬនៅក្នុងករណីដែលមិនមានការព្រមព្រៀងទេនោះចំនួនមជ្ឈត្តករដែលបានស្នើដែលត្រូវមានចំនួន ១ (មួយ) រូប ឬ៣ (បី) រូប និង

---

[63] វិធានស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម និងនីតិវិធីសន្ធានកម្មរបស់ ស.ម.ស. ឆ្នាំ២០១៣, វិធាន៤(f)។

[64] វិធានស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម និងនីតិវិធីសន្ធានកម្មរបស់ ស.ម.ស. ឆ្នាំ២០១៣, វិធាន៤(b) និង ៤(b)(i)។

[65] វិធានស្តីពីមជ្ឈត្តការរបស់ ម.ជ.ម. នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៤ , វិធាន៨.១, កថា. ១។

[66] វិធានស្តីពីមជ្ឈត្តការរបស់ ម.ជ.ម. នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៤, វិធាន៨.១, កថា. ១។

ច. ប្រសិនបើមាន សេចក្ដីថ្លែងការណ៍ ឬសំណើបន្ថែមផ្សេងៗ ដែលពាក់ព័ន្ធនឹងដំណើរការមជ្ឈត្តការ រួមបញ្ចូលទាំងច្បាប់ដែលត្រូវអនុវត្ត ភាសាសម្រាប់ដំណើរការមជ្ឈត្តការ និងលក្ខណៈសម្បត្តិ និងសញ្ជាតិរបស់មជ្ឈត្តករ ដែលតម្រូវ ឬដែលជាការឆ្លើយតបចំពោះសេក្ដីថ្លែង ឬសំណើនានា ដែលមានក្នុងសេចក្ដីជូនដំណឹងអំពីមជ្ឈត្តកម្ម។

ប្រសិនបើភាគីប្ដឹងទាមទារ បានភ្ជាប់សេចក្ដីថ្លែងទាមទារមកជាមួយនឹងសេចក្ដីជូនដំណឹងអំពីមជ្ឈត្តកម្មរបស់ខ្លួន ភាគីឆ្លើយតបក៏ត្រូវភ្ជាប់សេចក្ដីថ្លែងដោះសារមកជាមួយនឹងសេចក្ដីជូនដំណឹងអំពីការឆ្លើយតបដូចគ្នាដែរ ដែលរួមបញ្ចូលនូវបណ្ដឹងតប ឬការដោះសារតាមការកាត់កង និងឯកសារយោងនានា។[67] លើសពីនេះ ភាគីឆ្លើយតបក៏អាចភ្ជាប់មកជាមួយផងដែរនូវទឡ្ហីករណ៍ចំពោះយុត្តាធិការរបស់វេទិកាមជ្ឈត្តកម្ម។[68] ក្នុងករណីដែលសេចក្ដីជូនដំណឹងអំពីការឆ្លើយតបមានលក្ខណៈមិនពេញលេញ នោះអគ្គលេខាធិការដ្ឋានអាចស្នើសុំភាគីឆ្លើយតបឲ្យបំពេញបន្ថែមចំណុចខ្វះខាតនោះ ក្នុងអំឡុងពេលសមស្របណាមួយដែលកំណត់ដោយអគ្គលេខាធិកាដ្ឋាន។[69] សេចក្ដីជូនដំណឹងអំពីការឆ្លើយតបត្រូវចាត់ទុកថាពេញលេញ នៅពេលដែលចំណុចនានាដូចបានបង្ហាញខាងលើ ត្រូវបានបំពេញរួមបញ្ចូលទាំងការបង់កម្រៃសេវាចុះបញ្ជី។[70] នៅពេលអគ្គលេខាធិការដ្ឋានបានទទួលសេចក្ដីជូនដំណឹងពេញលេញអំពីការឆ្លើយតប អគ្គលេខាធិការដ្ឋានត្រូវជូនដំណឹងទៅគូភាគីវិវាទ។[71]

ប្រសិនបើភាគីឆ្លើយតបធ្វើបណ្ដឹងតប រួមបញ្ចូលទាំងការដោះសាតាមការកាត់កងនៅក្នុងសេចក្ដីជូនដំណឹងអំពីការឆ្លើយតប ភាគីឆ្លើយតបត្រូវបង់នូវកម្រៃសេវាចុះបញ្ជីសម្រាប់បណ្ដឹងតបរបស់ខ្លួនផងដែរ បើមិនដូច្នោះទេបណ្ដឹងតបនោះនឹងមិនត្រូវលើកយកមកពិចារណាក្នុងដំណើរការមជ្ឈត្តការឡើយ។[72] ទោះបីជាភាគីឆ្លើយតបខកខានក្នុងការដាក់សេចក្ដីជូនដំណឹងពេញលេញអំពីការឆ្លើយតប ចំពោះសេចក្ដីជូនដំណឹងអំពីមជ្ឈត្តកម្មឲ្យបានទាន់ពេលវេលាក៏ដោយ ក៏ការបង្កើតវេទិកាមជ្ឈត្តកម្មមិនត្រូវបង្អាក់ឡើយ។[73] ការខកខាននេះ មិនរារាំងភាគីឆ្លើយតបក្នុងការបដិសេធ

[67] វិធានស្ដីពីមជ្ឈត្តការរបស់ ម.ជ.ម. នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៩, វិធាន៨.៣ និង ២២.៣, កថា. ១។
[68] វិធានស្ដីពីមជ្ឈត្តការរបស់ ម.ជ.ម. នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៩, វិធាន៨.៣។
[69] វិធានស្ដីពីមជ្ឈត្តការរបស់ ម.ជ.ម. នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៩, វិធាន៨.៤។
[70] វិធានស្ដីពីមជ្ឈត្តការរបស់ ម.ជ.ម. នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៩, វិធាន៨.៤។
[71] វិធានស្ដីពីមជ្ឈត្តការរបស់ ម.ជ.ម. នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៩, វិធាន៨.៦, កថា. ១។
[72] វិធានស្ដីពីមជ្ឈត្តការរបស់ ម.ជ.ម. នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៩, វិធាន៨.៦, កថា. ២។
[73] វិធានស្ដីពីមជ្ឈត្តការរបស់ ម.ជ.ម. នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៩, វិធាន៨.៥។

ការទាមទារ ឬការដាក់បណ្តឹងតប ឬក៏ការដោះសារតាមការកាត់កង នៅក្នុងដំណើរការនៃមជ្ឈត្តការឡើយ។[74]

❖ ករណីសហរដ្ឋអាមេរិក

ដោយឡែកនៅសហរដ្ឋអាមេរិកវិញ ភាគីឆ្លើយតបអាចបញ្ជូនទៅ ស.ម.ស. នូវសេចក្តីថ្លែងអំពីការឆ្លើយតប ក្នុងរយៈពេល **១៤ថ្ងៃប្រតិទិន** បន្ទាប់ពីបានទទួលសេចក្តីជូនដំណឹងអំពីការទទួលបានសេចក្តីជូនដំណឹងអំពីមជ្ឈត្តកម្មពី ស.ម.ស.។[75] នៅពេលជាមួយគ្នានេះដែរ ភាគីឆ្លើយតបត្រូវបញ្ជូនទៅភាគីប្តឹងទាមទារ នូវសេចក្តីថ្លែងអំពីការឆ្លើយតប និងភាគីទាំងឡាយណានៃមជ្ឈត្តការនេះ។[76] បើក្នុងកំឡុងពេលនោះ ភាគីឆ្លើយតបមិនបានធ្វើសេចក្តីថ្លែងអំពីការឆ្លើយតបនោះទេ ភាគីឆ្លើយតបត្រូវបានចាត់ទុកថាបានបដិសេធចំពោះការទាមទារ។[77] ការខកខាននេះ មិនត្រូវបង្អាក់នូវដំណើរការមជ្ឈត្តកម្មបានឡើយ។[78] ទាក់ទងនឹងបណ្តឹងតប ភាគីឆ្លើយតបក៏អាចធ្វើបណ្តឹងតបនៅគ្រប់ពេលវេលាទាំងអស់បន្ទាប់ពីបានទទួលសេចក្តីជូនដំណឹងអំពីការទទួលបានសេចក្តីជូនដំណឹងអំពីមជ្ឈត្តកម្មពី ស.ម.ស.។[79] ភាគីឆ្លើយតបក៏ត្រូវបញ្ជូនបណ្តឹងតបទៅភាគីប្តឹងទាមទារ និងភាគីទាំងឡាយណានៃមជ្ឈត្តការនេះ។[80] បណ្តឹងតប ត្រូវរួមបញ្ចូលសេចក្តីថ្លែងដែលបង្ហាញអំពីលក្ខណៈនៃបណ្តឹងតបដែលមានសេចក្តីសម្រេចដែលខ្លួនចង់បាន រួមទាំងចំនួនទឹកប្រាក់ដែលពាក់ព័ន្ធ។[81] ស្របពេលជាមួយនឹងការដាក់បណ្តឹងតបនេះ ភាគីប្តឹងទាមទារត្រូវបងថ្លៃដាក់ពាក្យដូចបានបញ្ជាក់នៅក្នុងតារាងតម្លៃសេវារបស់ ស.ម.ស.។[82]

❖ ការប្រៀបធៀប

តាមការប្រៀបធៀប យើងសង្កេតឃើញថាវិធានរបស់កម្ពុជាបានកំណត់ច្បាស់លាស់អំពីព័ត៌មានដែលត្រូវបំពេញនៅក្នុងសេចក្តីជូនដំណឹងអំពីការឆ្លើយតប និងផ្តល់រយៈពេលវែងជាងនៅ

[74] វិធានស្តីពីមជ្ឈត្តការរបស់ ម.ជ.ម. នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៤, វិធាន៨.៥។
[75] វិធានស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម និងនីតិវិធីសន្ទានកម្មរបស់ ស.ម.ស. ឆ្នាំ២០១៣, វិធាន៥(a)។
[76] វិធានស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម និងនីតិវិធីសន្ទានកម្មរបស់ ស.ម.ស. ឆ្នាំ២០១៣, វិធាន៥(a)។
[77] វិធានស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម និងនីតិវិធីសន្ទានកម្មរបស់ ស.ម.ស. ឆ្នាំ២០១៣, វិធាន៥(a)។
[78] វិធានស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម និងនីតិវិធីសន្ទានកម្មរបស់ ស.ម.ស. ឆ្នាំ២០១៣, វិធាន៥(a)។
[79] វិធានស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម និងនីតិវិធីសន្ទានកម្មរបស់ ស.ម.ស. ឆ្នាំ២០១៣, វិធាន៥(b)។
[80] វិធានស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម និងនីតិវិធីសន្ទានកម្មរបស់ ស.ម.ស. ឆ្នាំ២០១៣, វិធាន៥(b)។
[81] វិធានស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម និងនីតិវិធីសន្ទានកម្មរបស់ ស.ម.ស. ឆ្នាំ២០១៣, វិធាន៥(b)។
[82] វិធានស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម និងនីតិវិធីសន្ទានកម្មរបស់ ស.ម.ស. ឆ្នាំ២០១៣, វិធាន៥(b)។

សហរដ្ឋអាមេរិក។ សម្រាប់សហរដ្ឋអាមេរិកវិញ ភាគីឆ្លើយតបមានរយៈខ្លីជាងក្នុងការឆ្លើយតប ហើយវិធានក៏មិនបានកំណត់ច្បាស់លាស់អំពីព័ត៌មាន ដែលត្រូវបំពេញនៅក្នុងសេចក្តីថ្លែងអំពីការឆ្លើយតបនោះដែរ។ លើសពីនេះទៅទៀត វិធានរបស់កម្ពុជាមានចែងផងដែរអំពីករណីដែលភាគីឆ្លើយតបអាចភ្ជាប់មកជាមួយនូវទឡ្ហីករណ៍ចំពោះយុត្តាធិការរបស់វេទិកាមជ្ឈត្តកម្ម ដែលចំណុចនេះមិនមានឃើញចែងនៅក្នុងវិធានរបស់សហរដ្ឋអាមេរិកឡើយ។ ក្រៅពីនេះ យើងសង្កេតឃើញថាវិធានរបស់ប្រទេសទាំងពីរ សុទ្ធតែផ្តល់សិទ្ធិឲ្យភាគីឆ្លើយតបភ្ជាប់មកជាមួយនូវបណ្តឹងតបនៅក្នុងសេចក្តីជូនដំណឹងអំពីការឆ្លើយតបរបស់ខ្លួន ដែលត្រូវបង់កម្រៃសេវាចុះបញ្ជីចំពោះបណ្តឹងតបនោះដូចគ្នា។ លក្ខណៈដូចគ្នាមួយគួរឲ្យកត់សម្គាល់នោះ គឺថាការខកខានរបស់ភាគីឆ្លើយតបក្នុងការដាក់សេចក្តីថ្លែងអំពីការឆ្លើយតបរបស់ខ្លួន មិនធ្វើឲ្យមានការបង្អាក់ដំណើរការមជ្ឈត្តការឡើយ។

### ២.១.២. ការបង្កើតវេទិកាមជ្ឈត្តកម្ម

ចំណុច ២.១.២. នឹងធ្វើការបកស្រាយ និងប្រៀបធៀបទាក់ទងនឹង ការជ្រើសតាំងមជ្ឈត្តករ **(២.១.២.១.)** ការជំទាស់នឹងមជ្ឈត្តករ **(២.១.២.២.)** និងចុងក្រោយ ការដាក់មជ្ឈត្តការជំនួស **(២.១.២.៣.)**។

#### ២.១.២.១. ការជ្រើសតាំងមជ្ឈត្តករ

- ករណីកម្ពុជា

ក្នុងវិធាននៃប្រទេសកម្ពុជា គូភាគីវិវាទអាចព្រមព្រៀងលើនីតិវិធីជ្រើសតាំងវេទិកាមជ្ឈត្តកម្ម ដែលខុសពីនីតិវិធីដូចមាន កំណត់ក្នុងវិធានស្តីពីមជ្ឈត្តការរបស់ ម.ជ.ម.។[83] ប្រសិនបើគូភាគីមិនបានព្រមព្រៀងលើអំឡុងពេលកំណត់សម្រាប់ការជ្រើសតាំងទេនោះ ការជ្រើសតាំងត្រូវធ្វើឡើងនៅក្នុងអំឡុងពេល ៣០ ថ្ងៃប្រតិទិន បន្ទាប់ពីបានទទួលនូវការជូនដំណឹងអំពីសេចក្តីជូនដំណឹងអំពីការឆ្លើយតប។[84]

ក្នុងករណីដែលភាគីមិនបានព្រមព្រៀងលើនីតិវិធីសម្រាប់ជ្រើសតាំងមជ្ឈត្តករទេ ភាគីត្រូវគោរពតាមនីតិវិធីដែលបានកំណត់ដោយវិធានរបស់ ម.ជ.ម.។ ចំពោះវេទិកាមជ្ឈត្តកម្មនៃមជ្ឈត្តករមួយរូប គូភាគីវិវាទត្រូវរួមគ្នាជ្រើសតាំងមជ្ឈត្តករមួយរូប ក្នុងអំឡុងពេល ១៥ ថ្ងៃប្រតិទិនបន្ទាប់ពីបានទទួលការជូនដំណឹង អំពីសេចក្តីជូនដំណឹងពេញលេញ អំពីការឆ្លើយតប ឬក្នុងអំឡុងពេល

[83] វិធានស្តីពីមជ្ឈត្តការរបស់ ម.ជ.ម. នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៤, វិធាន១០.១។
[84] វិធានស្តីពីមជ្ឈត្តការរបស់ ម.ជ.ម. នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៤, វិធាន១០.១។

១៥ ថ្ងៃប្រតិទិន បន្ទាប់ពីផុតអំឡុងពេលនៃវិធាន ១០.១។ ម.ជ.ម. តាមរយៈគណៈកម្មាធិការតែងតាំង ត្រូវជ្រើសតាំងមជ្ឈត្តករមួយរូប ដើម្បីបង្កើតវេទិកាមជ្ឈត្តកម្មប្រសិនបើគូភាគីវិវាទទាំងពីរខកខានក្នុងការរួមគ្នាជ្រើសតាំងមជ្ឈត្តករ ក្នុងអំឡុងពេលដែលមានបញ្ជាក់ក្នុងវិធាននេះ។ ចំពោះវេទិកាមជ្ឈត្តកម្មនៃមជ្ឈត្តករ ៣ រូប ឬវេទិកាមជ្ឈត្តកម្មនៃមជ្ឈត្តករច្រើនរូប ភាគីវិវាទនីមួយៗត្រូវជ្រើសតាំងមជ្ឈត្តករម្នាក់មួយរូប ឬច្រើនរូបស្មើៗគ្នា ក្នុងអំឡុងពេល ១៥ ថ្ងៃប្រតិទិន បន្ទាប់ពីបានទទួលការជូនដំណឹងអំពីការទទួលបានការឆ្លើយតបចំពោះសេចក្តីជូនដំណឹងអំពីមជ្ឈត្តកម្ម ឬក្នុងអំឡុងពេល ១៥ ថ្ងៃប្រតិទិន បន្ទាប់ពីផុតអំឡុងពេលតម្រូវតាមវិធាន ១០.១។[85] ក្នុងអំឡុងពេល ១៥ ថ្ងៃប្រតិទិន បន្ទាប់ពីមានការជ្រើសតាំងមជ្ឈត្តករចុងក្រោយ មជ្ឈត្តករដែលត្រូវបានជ្រើសតាំងទាំងអស់ ត្រូវរួមគ្នាក្នុងការជ្រើសតាំងមជ្ឈត្តករមួយរូបផ្សេងទៀត ជាប្រធានវេទិកាមជ្ឈត្តកម្ម។[86] ម.ជ.ម. តាមរយៈគណៈកម្មាធិការតែងតាំង ត្រូវជ្រើសតាំងមជ្ឈត្តករ ឬ/និង ចាត់តាំងមជ្ឈត្តករមួយរូប ក្នុងចំណោមមជ្ឈត្តករ ដែលត្រូវបានជ្រើសតាំង ឲ្យធ្វើជាប្រធានវេទិកាមជ្ឈត្តកម្ម ប្រសិនបើភាគីវិវាទណាមួយ ខកខានក្នុងការជ្រើសតាំងមជ្ឈត្តករតាមការតម្រូវ ឬមជ្ឈត្តករដែលត្រូវបានជ្រើសតាំងដោយភាគីវិវាទនោះ ខកខានមិនបានជ្រើសតាំងប្រធានវេទិកាមជ្ឈត្តកម្មក្នុងអំឡុងពេល ដែលបានកំណត់ក្នុងវិធាននេះ។[87] ក្នុងករណីដែលភាគីវិវាទមានលើសពីពីរនាក់ ភាគីទាំងអស់ត្រូវព្រមព្រៀងរួមគ្នាក្នុងការជ្រើសតាំងមជ្ឈត្តករ។[88] ហើយបើមានភាគីវិវាទណាមួយខកខាននៅក្នុងការជ្រើសតាំងមជ្ឈត្តករ នោះ ម.ជ.ម. តាមរយៈគណៈកម្មាធិការតែងតាំង ត្រូវធ្វើការជ្រើសតាំងមជ្ឈត្តករក្នុងនាមជាភាគីវិវាទដែលមិនបានជ្រើសតាំងនោះ។[89] បន្ទាប់ពីមជ្ឈត្តករត្រូវបានជ្រើសតាំង អគ្គលេខាធិការ-ដ្ឋានត្រូវជូនដំណឹងទៅគូភាគីវិវាទភ្លាម ថាវេទិកាមជ្ឈត្តកម្មត្រូវបានបង្កើត និងត្រូវជូនដំណឹងដល់គូភាគីអំពីឈ្មោះ និងព័ត៌មាន លម្អិតសម្រាប់ ទាក់ទង មជ្ឈត្តករដែលត្រូវបានជ្រើសតាំងទាំងអស់។[90] បន្ទាប់មក អគ្គលេខាធិការដ្ឋានត្រូវផ្ញើសំណុំរឿងនោះទៅវេទិកាមជ្ឈត្តកម្ម។

[85] វិធានស្តីពីមជ្ឈត្តការរបស់ ម.ជ.ម. នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៩, វិធាន១០.២(១)។
[86] វិធានស្តីពីមជ្ឈត្តការរបស់ ម.ជ.ម. នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៩, វិធាន១០.២(១)។
[87] វិធានស្តីពីមជ្ឈត្តការរបស់ ម.ជ.ម. នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៩, វិធាន១០.២(២)។
[88] វិធានស្តីពីមជ្ឈត្តការរបស់ ម.ជ.ម. នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៩, វិធាន១០.៤។
[89] វិធានស្តីពីមជ្ឈត្តការរបស់ ម.ជ.ម. នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៩, វិធាន១០.៤។
[90] វិធានស្តីពីមជ្ឈត្តការរបស់ ម.ជ.ម. នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៩, វិធាន១០.7។

❖ ករណីសហរដ្ឋអាមេរិក

ដោយឡែកនៅក្នុងវិធានរបស់សហរដ្ឋអាមេរិកវិញ ភាគីក៏អាចព្រមព្រៀងលើនីតិវិធីផ្សេងសម្រាប់ការជ្រើសតាំងមជ្ឈត្តករ ក្រៅពីនីតិវិធីដែលបានកំណត់នៅក្នុងវិធានដែរ។ ប្រសិនបើនៅក្នុងកិច្ចព្រមព្រៀង ភាគីបានជ្រើសរើសមជ្ឈត្តករមួយរួចហើយ ឬក៏បានបញ្ជាក់អំពីវិធីសាស្ត្រនៅក្នុងការជ្រើសតាំងមជ្ឈត្តកររួចហើយ ភាគីត្រូវតែគោរពតាមការជ្រើសរើស និងវិធីសាស្ត្រនៃការជ្រើសរើសមជ្ឈត្តករនោះ។[91] ប្រសិនបើគូភាគីបានព្រមព្រៀងថាភាគីនីមួយៗត្រូវជ្រើសរើសយកមជ្ឈត្តករមួយរបស់ខ្លួន មជ្ឈត្តករដែលត្រូវជ្រើសរើសនោះ ត្រូវតែបំពេញលក្ខខណ្ឌស្តង់ដាទាក់ទងជាមួយនឹងភាពមិនលំអៀង និងឯករាជ្យភាព។[92] ប៉ុន្តែគូភាគីអាចព្រមព្រៀងថា មជ្ឈត្តករដែលត្រូវជ្រើសរើសដោយភាគីនីមួយៗ ជាមជ្ឈត្តករដែលមានភាពលំអៀងទៅរកភាគីដែលជ្រើសរើសខ្លួន និងដែលមិនទាមទារឲ្យបំពេញលក្ខខណ្ឌស្តង់ដាទាំងនោះទេ។[93]

ប្រសិនបើនៅក្នុងកិច្ចព្រមព្រៀង គូភាគីបានព្រមព្រៀងទៅលើថេរវេលាសម្រាប់ជ្រើសតាំងមជ្ឈត្តករ ហើយភាគីខកខានក្នុងការជ្រើសតាំងនៅក្នុងកំឡុងពេលកំណត់នោះ នោះ ស.ម.ស. ត្រូវធ្វើការជ្រើសតាំងជំនួស។[94] បើគូភាគីវិវាទមិនបានព្រមព្រៀងលើថេរវេលាទេ ស.ម.ស. ត្រូវប្រាប់ដល់គូភាគីឲ្យធ្វើការជ្រើសតាំង។[95] បើក្នុងកំឡុងពេល ១៤ ថ្ងៃប្រតិទិនបន្ទាប់ពីថ្ងៃដែល ស.ម.ស. បានប្រាប់ ភាគីវិវាទណាមួយមិនបានជ្រើសតាំងមជ្ឈត្តករទេ នោះ ស.ម.ស. នឹងធ្វើការជ្រើសតាំងជំនួស។[96]

បន្ទាប់ពីភាគីវិវាទបានជ្រើសរើសមជ្ឈត្តកររៀងខ្លួនរួចហើយ មជ្ឈត្តករទាំងនោះត្រូវធ្វើការជ្រើសតាំងមជ្ឈត្តករម្នាក់ទៀតមកធ្វើជាប្រធានរបស់វេទិកាមជ្ឈត្តកម្ម នៅក្នុងកំឡុងពេលដែលបានកំណត់ដោយគូភាគីវិវាទ ពុំនោះទេ ស.ម.ស. នឹងជ្រើសតាំងជំនួស។[97] តែបើសិនជាគូភាគីវិវាទមិនបានព្រមព្រៀងលើថេរវេលាទេ មជ្ឈត្តករដែលត្រូវបានជ្រើសតាំងដោយភាគីវិវាទនីមួយៗ ត្រូវធ្វើការជ្រើសតាំងប្រធានវេទិកាមជ្ឈត្តកម្ម ក្នុងរយៈពេល១៤ថ្ងៃប្រតិទិន បន្ទាប់ពីថ្ងៃដែលមជ្ឈត្តករចុង-

[91] វិធានស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម និងនីតិវិធីសន្ទានកម្មរបស់ ស.ម.ស. ឆ្នាំ២០១៣, វិធាន១៣(a)។
[92] វិធានស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម និងនីតិវិធីសន្ទានកម្មរបស់ ស.ម.ស. ឆ្នាំ២០១៣, វិធាន១៣(b) និង១៨(a)។
[93] វិធានស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម និងនីតិវិធីសន្ទានកម្មរបស់ ស.ម.ស. ឆ្នាំ២០១៣, វិធាន១៣(b) និង១៨(b)។
[94] វិធានស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម និងនីតិវិធីសន្ទានកម្មរបស់ ស.ម.ស. ឆ្នាំ២០១៣, វិធាន១៣(c)។
[95] វិធានស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម និងនីតិវិធីសន្ទានកម្មរបស់ ស.ម.ស. ឆ្នាំ២០១៣, វិធាន១៣(d)។
[96] វិធានស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម និងនីតិវិធីសន្ទានកម្មរបស់ ស.ម.ស. ឆ្នាំ២០១៣, វិធាន១៣(b) និង១៨(d)។
[97] វិធានស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម និងនីតិវិធីសន្ទានកម្មរបស់ ស.ម.ស. ឆ្នាំ២០១៣, វិធាន១៤(a)។

ក្រោយត្រូវបានតែងតាំង ពុំនោះទេ ស.ម.ស. នឹងជ្រើសតាំងប្រធានវេទិកាមជ្ឈត្តកម្មជំនួស។[98] ភាគីអាចព្រមព្រៀងគ្នាក្នុងការជ្រើសតាំងប្រធានវេទិកាមជ្ឈត្តកម្មពីក្នុងបញ្ជីមជ្ឈត្តករបស់ ស.ម.ស. បានផងដែរ។[99]

❖ ការប្រៀបធៀប

តាមការប្រៀបធៀប យើងសង្កេតឃើញថា វិធានស្តីពីមជ្ឈត្តការរបស់ប្រទេសទាំងពីរមានលក្ខណៈស្រដៀងគ្នាទាក់ទងនឹងនីតិវិធីក្នុងការជ្រើសតាំងមជ្ឈត្តករ ទាំងក្នុងករណីវេទិកាមជ្ឈត្តកម្មនៃមជ្ឈត្តករមួយរូប និងបីរូបឬច្រើនជាងនេះ។ យ៉ាងណាក៏ដោយ ចំណុចមួយចំនួនមានលក្ខណៈខុសគ្នាគួរឲ្យកត់សម្គាល់។ ចំណុចទីមួយ គឺថាវិធាននៃប្រទេសកម្ពុជាផ្តល់រយៈពេលច្រើនជាងវិធានរបស់សហរដ្ឋអាមេរិកសម្រាប់ជ្រើសរើសមជ្ឈត្តកររបស់ខ្លួន ពោលគឺរហូតទៅដល់ ១៥ថ្ងៃប្រតិទិន។ ហើយចំណុចទីពីរនោះ គឺថាវិធានរបស់សហរដ្ឋអាមេរិកបានផ្តល់សិទ្ធិឲ្យគូភាគីវិវាទព្រមព្រៀងក្នុងការជ្រើសរើសយកមជ្ឈត្តកររបស់ខ្លួនដែលមានភាពលំអៀងទៅរកភាគី និងមិនទាមទារឲ្យគោរពនូវលក្ខខណ្ឌស្តង់ដាស្របតាមវិធាន១៨ឡើយ។ ក៏ប៉ុន្តែចំនុចនេះ មិនឃើញមានចែងនៅក្នុងវិធាន ក៏ដូចជាច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្មរបស់ប្រទេសកម្ពុជានោះឡើយ។ ចំណុចខុសគ្នាគួរឲ្យកត់សម្គាល់ចុងក្រោយនោះ គឺថាវិធាននៃប្រទេសកម្ពុជាកំណត់អំពីនីតិវិធីដូចគ្នា ទាំងការជ្រើសរើសមជ្ឈត្តករចេញពីបញ្ជីមជ្ឈត្តកររបស់ ម.ជ.ម. និងការជ្រើសរើសមជ្ឈត្តករដែលមិនបានចុះបញ្ជីជាមួយ ម.ជ.ម.។ ចំណែកឯវិធានរបស់សហរដ្ឋអាមេរិក មានចែងអំពីនីតិវិធីផ្សេងមួយសម្រាប់ភាគីនៅក្នុងការជ្រើសរើសមជ្ឈត្តករចេញពីបញ្ជីមជ្ឈត្តកររបស់ ស.ម.ស. ក្នុងករណីដែលភាគីមិនទាន់បានជ្រើសរើសមជ្ឈត្តកររបស់ខ្លួន ក៏ដូចជាមិនបានព្រមព្រៀងពីរបៀបជ្រើសរើសមជ្ឈត្តកររបស់ខ្លួននៅឡើយ។[100] នីតិវិធីនេះខុសគ្នាជាមួយនឹងនីតីវិធីដូចបានបង្ហាញខាងលើ។ ស្របតាមវិធាន១២នៃវិធានរបស់សហរដ្ឋអាមេរិក ការជ្រើសរើសមជ្ឈត្តករចេញពីបញ្ជីមជ្ឈត្តកររបស់ ស.ម.ស. អាចធ្វើតាមរបៀបដូចខាងក្រោម៖

ក. ស.ម.ស. ត្រូវផ្ញើទៅភាគីវិវាទទាំងអស់នូវបញ្ជីឈ្មោះរបស់មជ្ឈត្តករចំនួនដប់រូប ដែលត្រូវបានជ្រើសរើសចេញពីបញ្ជីមជ្ឈត្តកររបស់ ស.ម.ស.។ គូភាគីវិវាទត្រូវបានលើកទឹកចិត្តឲ្យ

[98] វិធានស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម និងនីតិវិធីសន្ទានកម្មរបស់ ស.ម.ស. ឆ្នាំ២០១៣, វិធាន១៤(b)។
[99] វិធានស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម និងនីតិវិធីសន្ទានកម្មរបស់ ស.ម.ស. ឆ្នាំ២០១៣, វិធាន១៤(c)។
[100] វិធានស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម និងនីតិវិធីសន្ទានកម្មរបស់ ស.ម.ស. ឆ្នាំ២០១៣, វិធាន១២។

ព្រមព្រៀងក្នុងការជ្រើសរើសយកមជ្ឈត្តករណាមួយចេញពីបញ្ជីមជ្ឈត្តករនោះ ហើយត្រូវជូនដំណឹងទៅ ស.ម.ស. អំពីការព្រមព្រៀងនេះ។

ខ. បើគូភាគីវិវាទមិនអាចយល់ព្រមក្នុងការជ្រើសរើសមជ្ឈត្តករណាមួយនោះទេ ភាគីវិវាទត្រូវមានរយៈពេល១៥ថ្ងៃប្រតិទិន ដើម្បីខ្វែងចោលឈ្មោះណាមួយដែលខ្លួនមិនពេញចិត្ត និងបង់លេខលើឈ្មោះណាដែលនៅសល់ស្របតាមកម្រិតនៃការពេញចិត្តរបស់ខ្លួន រួចផ្ញើបញ្ជីនោះទៅ ស.ម.ស. វិញ។ [...] បើសិនជាភាគីមិនបានផ្ញើបញ្ជីនោះមកវិញក្នុងកំឡុងពេលកំណត់ទេ ភាគីនោះត្រូវបានចាត់ទុកថាអាចទទួលយកមជ្ឈត្តករដែលមានឈ្មោះក្នុងបញ្ជីទាំងអស់នោះ។ ស.ម.ស. ចុងក្រោយត្រូវកំណត់ថាមជ្ឈត្តករមួយណាដែលត្រូវបានជ្រើសរើស ដោយផ្អែកលើលេខលំដាប់នៃមជ្ឈត្តករក្នុងបញ្ជីរបស់ភាគីនីមួយៗ។ [...]

### ២.១.២.២. ការជំទាស់ទៅនឹងមជ្ឈត្តករ

ការជំទាស់នឹងមជ្ឈត្តករណាមួយត្រូវធ្វើឡើងដោយមានមូលហេតុ និងនីតិវិធីច្បាស់លាស់ទាំងក្នុងវិធានរបស់ប្រទេសកម្ពុជា និងសហរដ្ឋអាមេរិក។ ចំណុច ២.១.២.២. នេះ នឹងធ្វើការសិក្សាប្រៀបធៀបអំពីមូលហេតុនៃការប្តឹងជំទាស់ **(ក.)** និងនីតិវិធីនៃការប្តឹងជំទាស់ **(ខ.)**។

#### ក. មូលហេតុនៃការប្តឹងជំទាស់

❖ ករណីកម្ពុជា

សម្រាប់វិធានរបស់ប្រទេសកម្ពុជា ការជំទាស់នឹងមជ្ឈត្តករត្រូវផ្អែកទៅលើមូលហេតុមួយដែលសមស្របដូចមានកំណត់នៅក្នុងវិធាន។ ក្នុងករណីដែលមានកាលៈទេសៈណាមួយ បង្កឲ្យមានការសង្ស័យសមហេតុផលចំពោះឯករាជភាព ឬអព្យាក្រឹតភាពរបស់មជ្ឈត្តករ មជ្ឈត្តករនោះអាចត្រូវបានជំទាស់ ។[101] ម្យ៉ាងទៀត មជ្ឈត្តករអាចត្រូវបានជំទាស់ផងដែរ ប្រសិនបើមជ្ឈត្តកររូបនោះមិនមានលក្ខណៈសម្បត្តិដូចដែលបានព្រមព្រៀងដោយគូភាគីវិវាទ។[102] ការជំទាស់របស់ភាគីវិវាទមួយ អាចធ្វើទៅបាន តែក្នុងករណីដែលភាគីវិវាទនោះបានដឹងអំពីមូលហេតុដើម្បីជំទាស់នោះក្រោយការតែងតាំងតែប៉ុណ្ណោះ។[103] ម៉្យាងមិញទៀត គូភាគីវិវាទក៏អាចឯកភាពបញ្ចប់អាណត្តិរបស់មជ្ឈត្តករណាមួយ ឬក៏មជ្ឈត្តករនោះដកខ្លួនពីតំណែងដោយខ្លួនឯង បើសិនជាមជ្ឈត្តករណាមួយ

---

101 វិធានស្តីពីមជ្ឈត្តការរបស់ ម.ជ.ម. នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៤, វិធាន១៣.១, កថា. ១។
102 វិធានស្តីពីមជ្ឈត្តការរបស់ ម.ជ.ម. នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៤, វិធាន១៣.១, កថា. ១។
103 វិធានស្តីពីមជ្ឈត្តការរបស់ ម.ជ.ម. នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៤, វិធាន១៣.១, កថា. ២។

មិនអាចបំពេញមុខងាររបស់ខ្លួនបានដោយមូលហេតុតាមផ្លូវច្បាប់ ឬក៏មូលហេតុជាក់ស្តែងណាមួយ ឬដោយមូលហេតុណាមួយផ្សេងទៀត។[104]

***ឧទាហរណ៍*** មជ្ឈត្តករដែលត្រូវបានជ្រើសរើស បានជួបនូវគ្រោះថ្នាក់ជាយថាហេតុមួយ ដែលនាំឲ្យគាត់មិនអាចបំពេញតួនាទីជាមជ្ឈត្តករបាន។ ក្នុងករណីនេះគូភាគីវិវាទអាចព្រមព្រៀងគ្នាដើម្បីបញ្ចប់អាណត្តិរបស់គាត់បាន។

❖ ករណីសហរដ្ឋអាមេរិក

យ៉ាងណាមិញ វិធានរបស់សហរដ្ឋអាមេរិកក៏មានកំណត់អំពីមូលហេតុច្បាស់លាស់ដើម្បីជំទាស់នឹងមជ្ឈត្តករដែរ។ ស្របតាមវិធាន១៨ ភាគីណាមួយអាចជំទាស់នឹងមជ្ឈត្តករណាមួយបាន ប្រសិនបើមជ្ឈត្តកររូបនោះ មិនមានអព្យាក្រឹតភាព ឬឯករាជភាព។ មួយវិញទៀត បើសិនមជ្ឈត្តករណាមួយមិនមានសមត្ថភាព ឬក៏បានបដិសេធក្នុងការអនុវត្តតួនាទីរបស់ខ្លួនដោយខិតខំប្រឹងប្រែង និងប្រុងប្រយ័ត្ន និងដោយសុឆន្ទៈនោះទេ ភាគីក៏អាចជំទាស់នឹងមជ្ឈត្តកររូបនោះដែរ។[105] លើសពីនេះទៀត ភាគីក៏អាចផ្អែកលើមូលដ្ឋានណាមួយដែលកំណត់ដោយច្បាប់ដែលត្រូវយកមកអនុវត្តផងដែរ ដើម្បីប្តឹងជំទាស់នឹងមជ្ឈត្តករនោះ។[106] យ៉ាងណាក៏ដោយ បើគូភាគីវិវាទបានព្រមព្រៀងគ្នាថាមជ្ឈត្តករដែលខ្លួនជ្រើសរើសមក មិនចាំបាច់មានអព្យាក្រឹតភាព ឬឯករាជភាពទេ នោះភាគីមិនអាចប្តឹងជំទាស់នឹងមជ្ឈត្តកររូបនោះដោយមូលហេតុគ្មានអព្យាក្រឹតភាព ឬឯករាជភាពនោះទេ។[107]

❖ ការប្រៀបធៀប

តាមការប្រៀបធៀប វិធានរបស់ប្រទេសទាំងពីរសុទ្ធតែទាមទារឲ្យមជ្ឈត្តករមានអព្យាក្រឹតភាព និងឯករាជភាព។ ហើយការខ្វះនូវព្យាក្រឹតភាព និងឯករាជភាពគឺជាមូលហេតុមួយនាំឲ្យភាគីធ្វើការជំទាស់នឹងមជ្ឈត្តករបាន។ ក៏ប៉ុន្តែ ត្រង់ចំណុចនេះ វិធានរបស់សហរដ្ឋអាមរិកអនុញ្ញាតឲ្យភាគីនៃវិវាទមានសិទ្ធិព្រមព្រៀងគ្នាក្នុងការជ្រើសរើសយកមជ្ឈត្តកររបស់ខ្លួន ដោយមិនទាមទារឲ្យមាននូវអព្យាក្រឹតភាពទៅវិញ។ ចំណុចនេះ ធ្វើឲ្យការខ្វះនូវអព្យាក្រឹតភាព និងឯករាជភាពមិនមែនជាមូលហេតុក្នុងការជំទាស់នឹងមជ្ឈត្តករដូចមុនទៀតឡើយ។

---

[104] វិធានស្តីពីមជ្ឈត្តការរបស់ ម.ជ.ម. នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៤, វិធាន១៤.១, កថា. ១។

[105] វិធានស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម និងនីតិវិធីសន្ទានកម្មរបស់ ស.ម.ស. ឆ្នាំ២០១៣, វិធាន១៨(a)។

[106] វិធានស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម និងនីតិវិធីសន្ទានកម្មរបស់ ស.ម.ស. ឆ្នាំ២០១៣, វិធាន១៨(a)។

[107] វិធានស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម និងនីតិវិធីសន្ទានកម្មរបស់ ស.ម.ស. ឆ្នាំ២០១៣, វិធាន១៨(b)។

ក្រៅពីនេះ វិធានរបស់ប្រទេសទាំងពីរសុទ្ធតែទាមទារឲ្យមជ្ឈត្តករដែលភាគីជ្រើសរើស មានសមត្ថភាពក្នុងការអនុវត្តតួនាទីរបស់ខ្លួន បើមិនដូច្នោះទេ វានឹងក្លាយជាមូលហេតុមួយដែលភាគីវិវាទអាចជំទាស់នឹងមជ្ឈត្តករបាន។ ប៉ុន្តែ វិធានរបស់សហរដ្ឋអាមេរិកឲ្យតម្លៃខ្ពស់ទៅលើការអនុវត្តតួនាទីដោយសុឆន្ទៈ និងការខិតខំប្រឹងប្រែងរបស់មជ្ឈត្តករ ហើយភាពគ្មានសុឆន្ទៈនឹងការខិតខំប្រឹងប្រែងនេះ ជាមូលហេតុមួយផងដែរដើម្បីបដិសេធមជ្ឈត្តករក្នុងសហរដ្ឋអាមេរិក។ ចំណុចគួរឲ្យចាប់អារម្មណ៍នោះ គឺថាវិធានរបស់ប្រទេសកម្ពុជាមានចែងយ៉ាងច្បាស់ថា ភាគីអាចជំទាស់នឹងមជ្ឈត្តករដែលខ្លួនបានតែងតាំង ឬដែលខ្លួនបានចូលរួមក្នុងការតែងតាំង តែក្នុងករណីដែលភាគីនោះបានដឹងអំពីមូលហេតុក្នុងការជំទាស់នោះក្រោយការតែងតាំងតែប៉ុណ្ណោះ។ ចំនុចនេះ មិនឃើញមានចែងនៅក្នុងវិធានរបស់សហរដ្ឋអាមេរិកឡើយ។

### ខ. នីតិវិធីក្នុងការប្តឹងជំទាស់

- ករណីកម្ពុជា

ក្នុងវិធានរបស់ប្រទេសកម្ពុជា ភាគីវិវាទដែលមានបំណងជំទាស់ទៅនឹងមជ្ឈត្តករ ត្រូវបញ្ជូនសេចក្តីជូនដំណឹងអំពីការជំទាស់របស់ខ្លួនទៅវេទិកាមជ្ឈត្តកម្ម ភាគីវិវាទម្ខាងទៀត ឬគូភាគីវិវាទ និងអគ្គលេខាធិការដ្ឋាន ក្នុងអំឡុងពេល ១៥ ថ្ងៃប្រតិទិន បន្ទាប់ពីបានទទួលសេចក្តីជូនដំណឹងអំពីការរៀបចំបង្កើតវេទិកាមជ្ឈត្តកម្ម ឬក្នុងអំឡុងពេល ១៥ ថ្ងៃប្រតិទិន បន្ទាប់ពីភាគីវិវាទបានដឹងអំពីកាលៈទេសៈនានាដែលនាំឲ្យមានការជំទាស់នឹងមជ្ឈត្តករ។[108] សេចក្តីជូនដំណឹងនេះ ត្រូវតែមានបញ្ជាក់អំពីមូលហេតុនៃការជំទាស់នឹងមជ្ឈត្តករ។[109] ក្នុងពេល ១៥ ថ្ងៃប្រតិទិន ក្រោយពីបានទទួលសេចក្តីជូនដំណឹងអំពីការជំទាស់ មជ្ឈត្តករដែលត្រូវបានជំទាស់ ភាគីវិវាទម្ខាងទៀត និងសមាជិកដទៃទៀតនៃវេទិកាមជ្ឈត្តកម្ម ប្រសិនបើមាន អាចផ្តល់នូវយោបល់របស់ខ្លួនទាក់ទងនឹងការជំទាស់នឹងមជ្ឈត្តករទៅវេទិកាមជ្ឈត្តកម្ម ភាគីវិវាទម្ខាងទៀត ឬគូភាគីវិវាទ និងអគ្គលេខាធិការដ្ឋាន។[110]

មជ្ឈត្តករដែលត្រូវបានជំទាស់នោះ ត្រូវដកខ្លួនចេញ បើសិនជាភាគីវិវាទម្ខាងយល់ស្របចំពោះការជំទាស់ ដែលស្នើឡើងដោយភាគីវិវាទម្ខាងទៀត។[111] ក្នុងរយៈពេល ៧ ថ្ងៃប្រតិទិន បន្ទាប់ពីបានទទួលយោបល់ចំពោះការជំទាស់ ឬបន្ទាប់ពីផុតអំឡុងពេលកំណត់សម្រាប់បញ្ជូនការផ្តល់

[108] វិធានស្តីពីមជ្ឈត្តការរបស់ ម.ជ.ម. នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៤, វិធាន១៣.២, កថា. ១។
[109] វិធានស្តីពីមជ្ឈត្តការរបស់ ម.ជ.ម. នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៤, វិធាន១៣.២, កថា. ២។
[110] វិធានស្តីពីមជ្ឈត្តការរបស់ ម.ជ.ម. នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៤, វិធាន១៣.៣។
[111] វិធានស្តីពីមជ្ឈត្តការរបស់ ម.ជ.ម. នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៤, វិធាន១៣.៤, កថា. ១។

យោបល់ចំពោះការជំទាស់ មជ្ឈត្តករដែលត្រូវបានជំទាស់ ត្រូវជូនដំណឹងទៅគូភាគីវិវាទ សមាជិកផ្សេងទៀតនៃវេទិកាមជ្ឈត្តកម្ម និងអគ្គលេខាធិការដ្ឋាន អំពីការឆ្លើយតបរបស់ខ្លួនចំពោះការជំទាស់នេះ។[112] ចំពោះវេទិកាមជ្ឈត្តកម្មនៃមជ្ឈត្តករមួយរូប បើនៅក្នុងការឆ្លើយតបនេះ មជ្ឈត្តករដែលត្រូវបានជំទាស់ បដិសេធក្នុងការដកខ្លួនចេញពីវេទិកាមជ្ឈត្តកម្ម ភាគីវិវាទដែលបានជំទាស់នោះអាចដាក់ពាក្យតវ៉ាទៅ ម.ជ.ម. តាមរយៈអគ្គលេខាធិការដ្ឋាន ក្នុងអំឡុងពេល ៣០ថ្ងៃប្រតិទិន បន្ទាប់ពីបានទទួលសេចក្តីជូនដំណឹងអំពីការបដិសេធនេះ។[113] ចំពោះវេទិកាមជ្ឈត្តកម្មនៃមជ្ឈត្តករបីរូប ដូចនៅក្នុងករណីខាងលើនេះ វេទិកាមជ្ឈត្តកម្មត្រូវសម្រេចលើការជំទាស់នោះក្នុងអំឡុងពេល ៧ ថ្ងៃប្រតិទិន បន្ទាប់ពីបានទទួលសេចក្តីជូនដំណឹងអំពីការបដិសេធលើការជំទាស់នោះ។[114] ប្រសិនបើវេទិកាមជ្ឈត្តកម្មសម្រេចបដិសេធការជំទាស់នឹងមជ្ឈត្តករ ភាគីវិវាទដែលបានជំទាស់អាចប្តឹងតវ៉ាទៅ ម.ជ.ម. តាមរយៈអគ្គលេខាធិការដ្ឋាន ក្នុងអំឡុងពេល៣០ ថ្ងៃប្រតិទិន បន្ទាប់ពីបានទទួលនូវសេចក្តីសម្រេចរបស់វេទិកាមជ្ឈត្តកម្ម។[115] ក្នុងពេល ១៥ ថ្ងៃប្រតិទិន បន្ទាប់ពីអគ្គលេខាធិការដ្ឋានបានទទួលនូវការតវ៉ាចំពោះការជំទាស់នឹងមជ្ឈត្តករ ម.ជ.ម. តាមរយៈគណៈកម្មាធិការតែងតាំងត្រូវសម្រេចលើការតវ៉ាចំពោះការជំទាស់នឹងមជ្ឈត្តករ។[116] សេចក្តីសម្រេចនេះ គឺជាសេចក្តីសម្រេចស្ថាពរ និងបិទផ្លូវតវ៉ា ហើយមិនចាំបាច់បង្ហាញនូវហេតុផលឡើយ។[117] ប្រសិនបើគណៈកម្មាធិការតែងតាំងយល់ស្របចំពោះការជំទាស់នេះ នោះអាណត្តិរបស់មជ្ឈត្តករដែលត្រូវបានជំទាស់នោះនឹងត្រូវបញ្ចប់ ដោយមានប្រសិទ្ធភាពចាប់ពីកាលបរិច្ឆេទនៃសេចក្តីសម្រេចនោះ និងត្រូវរកមជ្ឈត្តករជំនួស។[118]

- ❖ ករណីសហរដ្ឋអាមេរិក

ដោយឡែកក្នុងវិធានរបស់សហរដ្ឋអាមេរិកវិញ ភាគីដែលមានបំណងជំទាស់នឹងមជ្ឈត្តករណាមួយ អាចធ្វើការជំទាស់ទៅកាន់ ស.ម.ស. បាន។ ស.ម.ស. ស្របតាមការផ្តួចផ្តើមផ្ទាល់ខ្លួន ឬក៏តាមការជំទាស់របស់ភាគីវិវាទណាមួយ ត្រូវកំណត់ថាមជ្ឈត្តករដែលត្រូវបានជំទាស់នោះ អាចត្រូវ

[112] វិធានស្តីពីមជ្ឈត្តការរបស់ ម.ជ.ម. នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៤, វិធាន១៣.៤, កថា. ១។
[113] វិធានស្តីពីមជ្ឈត្តការរបស់ ម.ជ.ម. នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៤, វិធាន១៣.៤, កថា. ២។
[114] វិធានស្តីពីមជ្ឈត្តការរបស់ ម.ជ.ម. នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៤, វិធាន១៣.៤, កថា. ៣។
[115] វិធានស្តីពីមជ្ឈត្តការរបស់ ម.ជ.ម. នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៤, វិធាន១៣.៤, កថា. ៣។
[116] វិធានស្តីពីមជ្ឈត្តការរបស់ ម.ជ.ម. នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៤, វិធាន១៣.៥, កថា. ១។
[117] វិធានស្តីពីមជ្ឈត្តការរបស់ ម.ជ.ម. នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៤, វិធាន១៣.៦។
[118] វិធានស្តីពីមជ្ឈត្តការរបស់ ម.ជ.ម. នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៤, វិធាន១៣.៥, កថា. ២។

បានជំនួសដោយមជ្ឈត្តករថ្មីដែរឬទេ ស្របតាមលក្ខខណ្ឌដែលបានកំណត់នៅក្នុងវិធាន១៨(a)។[119] បន្ទាប់ពីធ្វើសេចក្តីសម្រេចរួចមក ស.ម.ស. ត្រូវជូនដំណឹងដល់គូភាគីអំពីសេចក្តីសម្រេចរបស់ខ្លួនដែលត្រូវតែច្បាស់លាស់។[120] ក្នុងនីតិវិធីរហ័សសម្រាប់រឿងក្តីដែលតម្លៃនៃបណ្តឹងទាមទារ ឬបណ្តឹងតបមិនលើសពី ៧៥,០០០ ដុល្លាអាមេរិក[121] ភាគីដែលមានបំណងជំទាស់ទៅនឹងមជ្ឈត្តករណាមួយត្រូវជូនដំណឹងអំពីការជំទាស់នោះទៅ ស.ម.ស. ក្នុងកំឡុងពេល ៧ ថ្ងៃប្រតិទិន។[122] ការជំទាស់នេះត្រូវតែធ្វើឡើងជាលាយលក្ខណ៍អក្សរ ដោយភាគីត្រូវផ្ញើការជំទាស់នេះទៅភាគីផ្សេងទៀតដែរ។[123]

❖ ការប្រៀបធៀប

តាមការប្រៀងធៀប យើងសង្កេតឃើញថា វិធានរបស់ប្រទេសកម្ពុជាមានលក្ខណៈពិស្តាជាងត្រង់ចំណុចនីតិវិធីនៃការជំទាស់របស់ភាគីទៅលើមជ្ឈត្តករណាមួយ។ ជាក់ស្តែងនៅក្នុងវិធានរបស់ប្រទេសកម្ពុជា មានបញ្ជាក់យ៉ាងច្បាស់ទាក់ទងថេរវេលានៃដំណាក់កាលនីមួយៗនៃការប្តឹងជំទាស់របស់ភាគី។ ចំណុចនេះ បង្កឲ្យមានភាពងាយស្រួលចំពោះភាគីក្នុងការប្តឹងជំទាស់។ លើសពីនេះទៅទៀត វិធានរបស់ប្រទេសកម្ពុជា បង្ហាញពីនីតិវិធីដែលផ្តល់សិទ្ធិឲ្យមជ្ឈត្តករដែលត្រូវបានប្តឹងជំទាស់នោះ បញ្ចេញយោបល់របស់ខ្លួននៅក្នុងកំឡុងពេលកំណត់មួយ និងជាពិសេស ផ្តល់សិទ្ធឲ្យមជ្ឈត្តករបដិសេធចំពោះការប្តឹងជំទាស់របស់ភាគីទៀតផង។ វិធានរបស់ប្រទេសកម្ពុជា ក៏បង្ហាញនិងវែកញែកយ៉ាងច្បាស់អំពីនីតិវិធីផ្សេងៗគ្នា ដែលត្រូវប្រើក្នុងករណីវេទិកាមជ្ឈត្តកម្មនៃមជ្ឈត្តករមួយរូប និងបីរូបឬច្រើនជាងនេះ និងបង្ហាញពីការចូលរួមអន្តរាគមន៍របស់ ម.ជ.ម.។ យ៉ាងណាមិញ វិធានរបស់សហរដ្ឋអាមេរិក មិនចែងយ៉ាងពិស្តាដូចជាវិធានរបស់ប្រទេសកម្ពុជាឡើយ។ ប៉ុន្តែចំណុចដែលគួរឲ្យកត់សម្គាល់នោះ គឺថាវិធាននេះផ្តល់អំណាចទៅឲ្យ ស.ម.ស. ក្នុងការវិនិច្ឆ័យលើការដកមជ្ឈត្តករណាមួយ នៅពេលដែល ស.ម.ស. យល់ឃើញថាលក្ខខណ្ឌដែលទាមទារក្នុងវិធាន១៨(a) ត្រូវបានបំពេញ ទោះបីជាគ្មានការជំទាស់របស់ភាគីណាមួយក៏ដោយ។ លើសពីនេះទៀត វិធានរបស់សហរដ្ឋអាមេរិក មានផ្តល់នូវនីតិវិធីពិសេសក្នុងការជំទាស់មជ្ឈត្តករសម្រាប់រឿងក្តីដែលមានតម្លៃនៃបណ្តឹងទាមទារ ឬបណ្តឹងតបទាប។ ចំនុចនេះពិតជាបង្កឲ្យការដោះស្រាយវិវាទកាន់តែឆាប់រហ័ស ពោលគឺមិនចាំបាច់ចំណាយពេលវែងទៅលើនីតិវិធីនៃរឿងក្តីតូចតាចនោះឡើយ។

---

[119] វិធានស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម និងនីតិវិធីសន្ទានកម្មរបស់ ស.ម.ស. ឆ្នាំ២០១៣, វិធាន១៨(c)។
[120] វិធានស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម និងនីតិវិធីសន្ទានកម្មរបស់ ស.ម.ស. ឆ្នាំ២០១៣, វិធាន១៨(c)។
[121] វិធានស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម និងនីតិវិធីសន្ទានកម្មរបស់ ស.ម.ស. ឆ្នាំ២០១៣, វិធាន១(b)។
[122] វិធានស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម និងនីតិវិធីសន្ទានកម្មរបស់ ស.ម.ស. ឆ្នាំ២០១៣, វិធាន E4(a)។
[123] វិធានស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម និងនីតិវិធីសន្ទានកម្មរបស់ ស.ម.ស. ឆ្នាំ២០១៣, វិធាន E4(a)។

**២.១.២.៣. ការដាក់មជ្ឈត្តករជំនួស**

សម្រាប់វិធានរបស់ប្រទេសកម្ពុជា មជ្ឈត្តករអាចត្រូវបានដាក់ជំនួស នៅពេលមជ្ឈត្តករណាម្នាក់ទទួលមរណភាព ដកខ្លួន ឬលាលែងពីតំណែង ឬនៅពេលបញ្ចប់អាណត្តិរបស់មជ្ឈត្តករណាម្នាក់ ដោយមូលហេតុផ្សេងៗស្របតាមវិធាននេះ។[124] ការជ្រើសតាំងមជ្ឈត្តករជំនួស អាចត្រូវបានធ្វើឡើងដោយភាគីវិវាទ ឬ ម.ជ.ម.។ ចំពោះការជ្រើសតាំងមជ្ឈត្តករជំនួសដោយភាគីវិវាទ ភាគីត្រូវជ្រើសតាំងមជ្ឈត្តករជំនួសនោះស្របតាមនីតិវិធីនៃការតែងតាំងមជ្ឈត្តករក្នុងវិធាន១០ ក្នុងពេល ១៥ ថ្ងៃប្រតិទិន ក្រោយពីភាគីវិវាទដែលត្រូវជ្រើសតាំងមជ្ឈត្តករជំនួស បានទទួលសេចក្ដីជូនដំណឹងអំពីការដាក់មជ្ឈត្តករជំនួស។[125] សម្រាប់ការជ្រើសតាំងមជ្ឈត្តករជំនួសដោយ ម.ជ.ម. វិញ ភាគីណាមួយអាចដាក់សំណើររបស់ខ្លួនទៅអគ្គលេខាធិការដ្ឋាន។[126] តាមរយៈសំណើរនេះផងដែរ ប្រសិនបើ ម.ជ.ម. តាមរយៈគណៈកម្មាធិការតែងតាំង កំណត់ថាដើម្បីធានាភាពឆាប់រហ័សនៃដំណើរការមជ្ឈត្តការ ឬដើម្បីជៀសវាងការពន្យារពេលដែលមិនចាំបាច់ ម.ជ.ម. តាមរយៈគណៈកម្មាធិការតែងតាំង អាចជ្រើសតាំងមជ្ឈត្តករជំនួសណាម្នាក់ ជំនួសឲ្យគូភាគីវិវាទ បន្ទាប់ពីបានទុកឱកាសឲ្យគូភាគីវិវាទ និងមជ្ឈត្តករដទៃទៀតនៃវេទិកាមជ្ឈត្តកម្ម ផ្ដល់យោបល់រួចហើយ។[127]

ដោយឡែក វិធានរបស់សហរដ្ឋអាមេរិក មិនមានចែងអំពីនីតិវិធីនៃការតែងតាំងមជ្ឈត្តករជំនួសឡើយ។ តាមការសន្និដ្ឋាន ការតែងតាំងមជ្ឈត្តករជំនួសអាចត្រូវបានធ្វើឡើងស្របតាមនីតិវិធីសម្រាប់តែងតាំងមជ្ឈត្តករដែរ ឬក៏ត្រូវជ្រើសតាំងដោយ ស.ម.ស. តែម្ដង។

**២.១.៣. ការរៀបចំដំណើរការមជ្ឈត្តការ**

ចំណុច ២.១.៣. នេះ នឹងបកស្រាយ និងប្រៀបធៀបរវាងវិធាននៃប្រទេសទាំងពីរទាក់ទងនឹងច្បាប់អនុវត្តក្នុងដំណើរការមជ្ឈត្តការ (**២.១.៣.១.**) ភាសាប្រើប្រាស់ក្នុងមជ្ឈត្តកម្ម (**២.១.៣.២.**) ទីកន្លែងធ្វើមជ្ឈត្តកម្ម (**២.១.៣.៣.**) កាលបរិច្ឆេទ ពេលវេលា និងទីកន្លែងនៃសវនាការ (**២.១.៣.៤.**) សាក្សី និងអ្នកជំនាញ (**២.១.៣.៥.**) ការដោះស្រាយវិវាទដោយស្ម័គ្រចិត្ត (**២.១.៣.៦.**) និងចុងក្រោយវិធានការបណ្ដោះអាសន្ន(**២.១.៣.៧.**)។

---

[124] វិធានស្ដីពីមជ្ឈត្តការរបស់ ម.ជ.ម. នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៤, វិធាន១៥.១។
[125] វិធានស្ដីពីមជ្ឈត្តការរបស់ ម.ជ.ម. នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៤, វិធាន១៥.២។
[126] វិធានស្ដីពីមជ្ឈត្តការរបស់ ម.ជ.ម. នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៤, វិធាន១៥.៣។
[127] វិធានស្ដីពីមជ្ឈត្តការរបស់ ម.ជ.ម. នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៤, វិធាន១៥.៣។

### ២.១.៣.១. ច្បាប់អនុវត្តក្នុងដំណើរការមជ្ឈត្តការ

វិធានរបស់ប្រទេសកម្ពុជា ផ្តល់សេរីភាពដល់គូភាគីវិវាទក្នុងការព្រមព្រៀងយកច្បាប់ណាមួយ ដែលវេទិកាមជ្ឈត្តកម្មត្រូវយកមកអនុវត្ត ហើយវេទិកាមជ្ឈត្តកម្មត្រូវអនុវត្តច្បាប់នោះចំពោះខ្លឹមសារនៃវិវាទ។[128] ក្នុងករណីដែលភាគីមិនបានព្រមព្រៀងគ្នា វេទិកាមជ្ឈត្តកម្មត្រូវកំណត់យកច្បាប់ណាមួយ ដែលវេទិកាមជ្ឈត្តកម្មយល់ថាសមស្របមកអនុវត្ត។[129] វេទិកាមជ្ឈត្តកម្មត្រូវផ្អែកទៅតាមសមធម៌ ឬតាមការសម្រុះសម្រួល តែក្នុងករណី និងក្នុងកម្រិតដែលគូភាគីវិវាទបានអនុញ្ញាតយ៉ាងច្បាស់លាស់ឱ្យវេទិកាមជ្ឈត្តកម្មធ្វើដូច្នោះតែប៉ុណ្ណោះ។[130] លើសពីនេះទៀត វេទិកាមជ្ឈត្តកម្មត្រូវយកមកពិចារណានូវបញ្ញត្តិនានាដែលមាន ចែងក្នុងកិច្ចសន្យា ប្រសិនបើមាន រួមទាំងទម្លាប់ពាណិជ្ជកម្មនានាដែលពាក់ព័ន្ធផងដែរ។[131] ទាក់ទងនឹងនីតិវិធីនៃដំណើរការមជ្ឈត្តកម្ម គូភាគីវិវាទអាចព្រមព្រៀងលើច្បាប់ ឬវិធានណាផ្សេង ក្រៅពីនីតិវិធីដែលមានចែងនៅក្នុងវិធាននេះបាន ដោយយោងតាមសេរីភាពឆន្ទៈរបស់ភាគី។

ដោយឡែក វិធានរបស់សហរដ្ឋអាមេរិកមិនមានចែងច្បាស់លាស់អំពីច្បាប់ដែលនឹងត្រូវយកមកអនុវត្តនោះទេ។ យ៉ាងណាក៏ដោយ គូភាគីអាចព្រមព្រៀងលើច្បាប់ណាមួយដែលត្រូវយកមកអនុវត្តក្នុងការធ្វើមជ្ឈត្តកម្ម។ ច្បាប់ដែលវេទិកាមជ្ឈត្តកម្មត្រូវអនុវត្ត អាចត្រូវបានលើកយកមកពិភាក្សានៅក្នុងដំណាក់កាលសវនាការបឋម[132] ដែលសវនាការនេះធ្វើឡើងក្នុងគោលបំណងរៀបចំដំណើរការមជ្ឈត្តការប្រកបដោយប្រសិទ្ធភាពឆាប់រហ័យ និងចំណាយតិច។

### ២.១.៣.២. ភាសាប្រើប្រាស់ក្នុងមជ្ឈត្តកម្ម

វិធានរបស់ប្រទេសកម្ពុជា ផ្តល់សេរីភាពឲ្យគូភាគីវិវាទក្នុងការព្រមព្រៀងគ្នាយកភាសាណាមួយ ឬច្រើនមកប្រើប្រាស់ក្នុងដំណើរការមជ្ឈត្តការ។[133] បើសិនជាគូភាគីវិវាទមិនបានព្រមព្រៀងគ្នាលើភាសាណាមួយទេ វេទិកាមជ្ឈត្តកម្មអាចសម្រេចយកភាសាណាមួយជាភាសាសម្រាប់ប្រើប្រាស់ក្នុងដំណើរការមជ្ឈត្តការបាន ដោយគិតពិចារណាលើកាលៈទេសៈនានាដែលពាក់ព័ន្ធទាំងអស់ រួម

---

[128] វិធានស្តីពីមជ្ឈត្តការរបស់ ម.ជ.ម. នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៤, វិធាន១៧.១។
[129] វិធានស្តីពីមជ្ឈត្តការរបស់ ម.ជ.ម. នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៤, វិធាន១៧.១។
[130] វិធានស្តីពីមជ្ឈត្តការរបស់ ម.ជ.ម. នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៤, វិធាន១៧.២។
[131] វិធានស្តីពីមជ្ឈត្តការរបស់ ម.ជ.ម. នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៤, វិធាន១៧.៣។
[132] វិធានស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម និងនីតិវិធីសន្ទានកម្មរបស់ ស.ម.ស. ឆ្នាំ២០១៣, វិធាន P២(a)(v)។
[133] វិធានស្តីពីមជ្ឈត្តការរបស់ ម.ជ.ម. នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៤, វិធាន១៨.១។

បញ្ចូលទាំងភាសានៃកិច្ចសន្យាផង។[134] ចំពោះការទាក់ទងជាលាយលាយលក្ខណ៍អក្សរ ឬដោយផ្ទាល់មាត់ណាមួយ វេទិកាមជ្ឈត្តកម្ម អាចបង្គាប់ឲ្យភាគីវិវាទណាមួយធ្វើការបកប្រែទៅជាភាសាណាមួយ និងក្នុងទម្រង់ណាមួយដែលវេទិកាមជ្ឈត្តកម្មយល់ថាសមស្រប។[135] ចំណុចដែលគួរឲ្យចាប់អារម្មណ៍នោះ គឺថាភាសានៃមជ្ឈត្តវិនិច្ឆ័យ ឬសេចក្តីបង្គាប់ ដែលចេញដោយវេទិកាមជ្ឈត្តកម្មត្រូវតែជាភាសាខ្មែរ ឬភាសាអង់គ្លេស បន្ទាប់ពីបានពិភាក្សាជាមួយគូភាគីរួចហើយ ទោះបីជាភាសានៃដំណើរការមជ្ឈត្តការជាភាសាផ្សេងក្រៅពីភាសាខ្មែរ ឬភាសាអង់គ្លេសក៏ដោយ។[136]

ចំណែកឯវិធានរបស់សហរដ្ឋអាមេរិក មិនមានចែងទាក់ទងនឹងភាសាដែលត្រូវប្រើប្រាស់ក្នុងមជ្ឈត្តកម្មឡើយ។ តាមការសន្និដ្ឋាន គូភាគីមានសិទ្ធក្នុងការព្រមព្រៀងគ្នាដើម្បីប្រើប្រាស់ភាសាណាមួយសម្រាប់មជ្ឈត្តការ ហើយភាសាអង់គ្លេសអាចជាភាសាដែលត្រូវប្រើប្រាស់ ព្រោះភាសានេះជាភាសាជាតិរបស់សហរដ្ឋអាមេរិក និងជាភាសាអន្តរជាតិផងដែរ។

### ២.១.៣.៣. ទីកន្លែងធ្វើមជ្ឈត្តកម្ម

- ករណីកម្ពុជា

ក្នុងវិធានរបស់ប្រទេសកម្ពុជា ភាគីអាចធ្វើការព្រមព្រៀងលើទីកន្លែងសម្រាប់ធ្វើមជ្ឈត្តការ។ យ៉ាងណាមិញ ទីកន្លែងធ្វើមជ្ឈត្តការនៃមជ្ឈត្តកម្មទាំងអស់ដែលធ្វើឡើងក្រោមវិធាននេះ គឺរាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា លើកលែងតែគូភាគីវិវាទបានព្រមព្រៀងផ្សេងពីនេះ ឬដោយសារកាលៈទេសៈនានានៃសំណុំរឿង ដែលវេទិកាមជ្ឈត្តកម្មសម្រេចថាទីកន្លែងធ្វើមជ្ឈត្តការផ្សេងទៀតមានលក្ខណៈសមស្របជាង។[137] យ៉ាងណាក៏ដោយ ទីកន្លែងធ្វើមជ្ឈត្តការ មិនទាន់អាចកំណត់បានអំពីទីកន្លែង ដែលវេទិកាមជ្ឈត្តកម្មអាចជួបប្រជុំ និងធ្វើសវនាការនោះទេ។[138] បានសេចក្តីថា វេទិកាមជ្ឈត្តកម្មអាចរៀបចំការប្រជុំ និងសវនាការ តាមមធ្យោបាយណាផ្សេងទៀត និងនៅទីកន្លែងណាផ្សេងទៀត ដែលវេទិកាមជ្ឈត្តកម្មយល់ថាសមស្រប។[139]

---

[134] វិធានស្តីពីមជ្ឈត្តការរបស់ ម.ជ.ម. នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៤, វិធាន១៨.១។
[135] វិធានស្តីពីមជ្ឈត្តការរបស់ ម.ជ.ម. នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៤, វិធាន១៨.២។
[136] វិធានស្តីពីមជ្ឈត្តការរបស់ ម.ជ.ម. នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៤, វិធាន១៨.៣។
[137] វិធានស្តីពីមជ្ឈត្តការរបស់ ម.ជ.ម. នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៤, វិធាន១៦។
[138] វិធានស្តីពីមជ្ឈត្តការរបស់ ម.ជ.ម. នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៤, វិធាន១៦ និង វិធាន២៤.៣។
[139] វិធានស្តីពីមជ្ឈត្តការរបស់ ម.ជ.ម. នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៤, វិធាន២៤.៣។

❖ ករណីសហរដ្ឋអាមេរិក

ដោយឡែកសម្រាប់វិធានរបស់សហរដ្ឋអាមេរិក គូភាគីក៏អាចធ្វើការព្រមព្រៀងលើទីកន្លែងសម្រាប់ធ្វើមជ្ឈត្តការដែរ។[140] រាល់វិវាទទាំងអស់ដែលទាក់ទងនឹងទីកន្លែងធ្វើមជ្ឈត្តការ ហើយដែលត្រូវដោះស្រាយដោយ ស.ម.ស. ភាគីត្រូវផ្ញើវិវាទនេះទៅ ស.ម.ស. និងភាគីដទៃទៀត ក្នុងកំឡុងពេល ១៤ ថ្ងៃប្រតិទិន បន្ទាប់ពីថ្ងៃដែលស.ម.ស. ចាប់ផ្តើមរឿងក្តី ឬក៏ថ្ងៃដែលត្រូវបានសន្មតដោយ ស.ម.ស.។[141] វិវាទដែលទាក់ទងនឹងទីកន្លែងធ្វើមជ្ឈត្តការ ត្រូវដោះស្រាយដោយរបៀបដូចខាងក្រោម៖[142]

ក. នៅពេលដែលកិច្ចព្រមព្រៀងមជ្ឈត្តកម្មរបស់គូភាគី មិនមាននិយាយទាក់ទងនឹងទីកន្លែងនៃមជ្ឈត្តការ ហើយប្រសិនបើគូភាគីមិនយល់ព្រមលើទីកន្លែងនៃមជ្ឈត្តការទេ ស.ម.ស. អាចកំណត់ជាបឋមនូវទីកន្លែងនៃមជ្ឈត្តការ ដែលត្រូវកំណត់ចុងក្រោយដោយមជ្ឈត្តករដែលត្រូវបានតែងតាំងនោះ។

ខ. នៅពេលដែលកិច្ចព្រមព្រៀងមជ្ឈត្តកម្មរបស់គូភាគី បានកំណត់អំពីទីកន្លែងជាក់លាក់នៃមជ្ឈត្តការ បើសិនជាគូភាគីមិនបានព្រមព្រៀងដើម្បីកែប្រែទេ ឬក៏មជ្ឈត្តករដែលត្រូវបានតែងតាំងនោះបានកំណត់ពីទីកន្លែងផ្សេងស្របតាមច្បាប់ដែលត្រូវយកមកអនុវត្តក៏ដោយ ក៏ទីកន្លែងធ្វើមជ្ឈត្តកម្មគឺជាទីកន្លែងដែលបានកំណត់នៅក្នុងកិច្ចព្រមព្រៀងនោះ។

គ. បើសិនជាការកំណត់ពីទីកន្លែងធ្វើមជ្ឈត្តកម្មនៅក្នុងកិច្ចព្រមព្រៀងមជ្ឈត្តកម្ម មានភាពមិនច្បាស់លាស់ ហើយគូភាគីមិនអាចព្រមព្រៀងលើទីកន្លែងជាក់លាក់ណាមួយទេ ស.ម.ស. ត្រូវកំណត់ពីទីកន្លែងធ្វើមជ្ឈត្តកម្ម ដែលក្រោយមកត្រូវស្ថិតនៅក្នុងសមត្ថកិច្ចរបស់មជ្ឈត្តករជាអ្នកកំណត់ទីកន្លែងចុងក្រោយ។

❖ ការប្រៀបធៀប

តាមការប្រៀងធៀប យើងឃើញថាវិធាននៃប្រទេសទាំងពីរ សុទ្ធតែផ្តល់សិទ្ធិឲ្យគូភាគីធ្វើការព្រមព្រៀងលើទីកន្លែងសម្រាប់ធ្វើមជ្ឈត្តកម្មរបស់ខ្លួនដូចគ្នា។ ចំណុចគួរឲ្យកត់សម្គាល់នោះគឺថា វិធានរបស់ប្រទេសកម្ពុជា កំណត់យ៉ាងជាក់លាក់ថារាជធានីភ្នំពេញនៃប្រទេសកម្ពុជា ជាកន្លែងធ្វើមជ្ឈត្តកម្ម ក្នុងករណីដែលគូភាគីវិវាទមិនបានព្រមព្រៀងផ្សេងពីនេះ ឬក៏មិនមានកាលៈទេសៈនានានៃសំណុំរឿង ដែលវេទិកាមជ្ឈត្តកម្មសម្រេចថាទីកន្លែងធ្វើមជ្ឈត្តកម្មផ្សេងទៀតមានលក្ខណៈ

140 វិធានស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម និងនីតិវិធីសន្ធានកម្មរបស់ ស.ម.ស. ឆ្នាំ២០១៣, វិធាន១១។
141 វិធានស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម និងនីតិវិធីសន្ធានកម្មរបស់ ស.ម.ស. ឆ្នាំ២០១៣, វិធាន១១។
142 វិធានស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម និងនីតិវិធីសន្ធានកម្មរបស់ ស.ម.ស. ឆ្នាំ២០១៣, វិធាន១១។

សមស្របជាងនេះ។ ដោយឡែក វិធានរបស់សហរដ្ឋអាមេរិកមិនមានបញ្ជាក់ច្បាស់ដូចនេះឡើយ។ ប៉ុន្តែវិធានរបស់សហរដ្ឋអាមេរិក ផ្តល់នូវនីតិវិធីយ៉ាងច្បាស់លាស់ក្នុងការដោះស្រាយវិវាទទាក់ទងនឹងទីកន្លែងសម្រាប់ធ្វើមជ្ឈត្តកម្ម។ ចំណែកឯវិធានរបស់ប្រទេសកម្ពុជា មិនមានចែងអំពីនីតិវិធីនៅក្នុងការដោះស្រាយវិវាទលើទីកន្លែងធ្វើមជ្ឈត្តកម្ម ដូចវិធានរបស់សហរដ្ឋអាមេរិកឡើយ។

### ២.១.៣.៤. កាលបរិច្ឆេទ ពេលវេលា និងទីកន្លែងនៃសវនាការ

❖ ករណីកម្ពុជា

ដូចបានបង្ហាញខាងលើ សម្រាប់វិធានរបស់ប្រទេសកម្ពុជា វេទិកាមជ្ឈត្តកម្មអាចរៀបចំនូវកិច្ចប្រជុំ និងសវនាការនៃមជ្ឈត្តកម្ម តាមមធ្យោបាយផ្សេងទៀត និងនៅទីកន្លែងណាផ្សេងទៀតប្រសិនបើវេទិកាមជ្ឈត្តកម្មយល់ថាសមស្រប។ ហេតុដូច្នេះ វេទិកាមជ្ឈត្តកម្មត្រូវកំណត់នូវទីកន្លែងក៏ដូចជាកាលបរិច្ឆេទ និងពេលវេលា ដោយត្រូវផ្តល់ដំណឹងជាមុនទៅគូភាគីវិវាទយ៉ាងហោចណាស់ ១៥ថ្ងៃប្រតិទិន មុនកាលបរិច្ឆេទធ្វើសវនាការ។[143]

❖ ករណីសហរដ្ឋអាមេរិក

ដោយឡែកនៅក្នុងវិធានរបស់សហរដ្ឋអាមេរិក វេទិកាមជ្ឈត្តកម្មត្រូវកំណត់អំពីកាលបរិច្ឆេទ ពេលវេលា និងទីកន្លែងសម្រាប់សវនាការនីមួយៗ។[144] គូភាគីវិវាទ ត្រូវឆ្លើយតបនឹងសំណើរអំពីកាលបរិច្ឆេទនៃសវនាការមជ្ឈត្តកម្មឲ្យទាន់ពេលវេលា និងត្រូវសហការក្នុងការកំណត់កាលបរិច្ឆេទយ៉ាងលឿនបំផុត និងត្រូវគោរពតាមកាលវិភាគដែលបានកំណត់សម្រាប់សវនាការ។[145] ស.ម.ស. ត្រូវផ្ញើសេចក្តីជូនដំណឹងអំពីសវនាការទៅគូភាគីវិវាទយ៉ាងតិច ១០ថ្ងៃប្រតិទិនមុនកាលបរិច្ឆេទនៃសវនាការ លើកលែងតែគូភាគីបានព្រមព្រៀងផ្សេងពីនេះ។[146] នៅក្នុងនីតិវិធីរហ័សនៃវិធានរបស់សហរដ្ឋអាមេរិក វេទិកាមជ្ឈត្តកម្មត្រូវកំណត់អំពី កាលបរិច្ឆេទ ពេលវេលា និងទីកន្លែងសម្រាប់ធ្វើសវនាការ ដើម្បីឲ្យសវនាការចាប់ផ្តើមក្នុងរយៈពេល ៣០ថ្ងៃប្រតិទិន បន្ទាប់ពីមានការយល់ព្រមអំពី

[143] វិធានស្តីពីមជ្ឈត្តការរបស់ ម.ជ.ម. នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៤, វិធាន២៤.៤។
[144] វិធានស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម និងនីតិវិធីសន្ទានកម្មរបស់ ស.ម.ស. ឆ្នាំ២០១៣, វិធាន២៤។
[145] វិធានស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម និងនីតិវិធីសន្ទានកម្មរបស់ ស.ម.ស. ឆ្នាំ២០១៣, វិធាន២៤។
[146] វិធានស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម និងនីតិវិធីសន្ទានកម្មរបស់ ស.ម.ស. ឆ្នាំ២០១៣, វិធាន២៤។

ការជ្រើសតាំងមជ្ឈត្តករ។[147] ស.ម.ស. នឹងជូនដំណឹងជាមុនទៅគូភាគីអំពីកាលបរិច្ឆេទនៃសវនាការមុនពេលដែលសវនាការចាប់ផ្ដើម។[148]

❖ ការប្រៀបធៀប

តាមការប្រៀបធៀប យើងសង្កេតឃើញថា ថេរវេលាសម្រាប់វេទិកាមជ្ឈត្តកម្មក្នុងការជូនដំណឹងអំពីកាលបរិច្ឆេទ ពេលវេលា និងទីកន្លែងនៃសវនាការមជ្ឈត្តកម្មទៅគូភាគី ក្នុងវិធានរបស់ប្រទេសកម្ពុជា មានរយៈពេលវែងជាងថេរវេលាដែលផ្ដល់ឲ្យក្នុងវិធានរបស់សហរដ្ឋអាមេរិក។ វិធានរបស់ប្រទេសកម្ពុជា ផ្ដល់ឲ្យថេរវេលាវែងជាងចំនួនប្រាំថ្ងៃ។ ចំណែកឯ វិធានរបស់សហរដ្ឋអាមេរិកមានចែងអំពីនីតិវិធីរហ័សទាក់ទងនឹងការកំណត់កាលបរិច្ឆេទ ពេលវេលា និងទីកន្លែង។ ចំណុចនេះជាការណ៍ល្អមួយសម្រាប់ជួយពន្លឿននីតិវិធីឲ្យកាន់តែឆាប់រហ័ស។

### ២.១.៣.៥. សាក្សី និងអ្នកជំនាញ

❖ ករណីកម្ពុជា

ក្នុងវិធានរបស់ប្រទេសកម្ពុជា វេទិកាមជ្ឈត្តកម្មអាចតម្រូវឲ្យភាគីវិវាទនីមួយៗផ្ដល់សេចក្ដី-ជូនដំណឹងជាមុននៅមុនពេលដំណើរការសវនាការ អំពីអត្តសញ្ញាណរបស់សាក្សី ឬសាក្សីជំនាញដែលភាគីវិវាទនីមួយៗមានបំណងកោះហៅ ក៏ដូចជាអំពីកម្មវត្ថុ និងទំនាក់ទំនងនៃសក្ខីកម្មរបស់សាក្សី រួមទាំងភាសាដែលសាក្សីនោះនឹងប្រើសម្រាប់ធ្វើសក្ខីកម្ម។[149] វេទិកាមជ្ឈត្តកម្ម អាចតម្រូវឲ្យសាក្សីណាម្នាក់ ធ្វើសក្ខីកម្មក្រោមសម្បថ ឬការអះអាង។[150] លើសពីនេះទៅទៀត វេទិកាមជ្ឈត្តកម្មមានឆន្ទានុសិទ្ធិក្នុងការអនុញ្ញាត ការកម្រិត ឬការបដិសេធ ចំពោះការបង្ហាញរបស់សាក្សីនោះ។[151] ក្រៅពីនេះ វេទិកាមជ្ឈត្តកម្មអាចកំណត់ឲ្យសាក្សីធ្វើសក្ខីកម្មជាលាយលក្ខណ៍អក្សរ ឬក្នុងទម្រង់ផ្សេងទៀតសម្រាប់ធ្វើកំណត់ត្រា។[152] គួរកត់សម្គាល់ផងដែរថា ភាគីវិវាទអាចស្នើឲ្យសាក្សីចូលរួមក្នុងការសាកសួរដោយផ្ទាល់មាត់ផងដែរ។[153]

[147] វិធានស្ដីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម និងនីតិវិធីសន្ទានកម្មរបស់ ស.ម.ស. ឆ្នាំ២០១៣, វិធានE7។
[148] វិធានស្ដីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម និងនីតិវិធីសន្ទានកម្មរបស់ ស.ម.ស. ឆ្នាំ២០១៣, វិធានE7។
[149] វិធានស្ដីពីមជ្ឈត្តការរបស់ ម.ជ.ម. នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៤, វិធាន២៦.១។
[150] វិធានស្ដីពីមជ្ឈត្តការរបស់ ម.ជ.ម. នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៤, វិធាន២៦.៥។
[151] វិធានស្ដីពីមជ្ឈត្តការរបស់ ម.ជ.ម. នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៤, វិធាន២៦.២។
[152] វិធានស្ដីពីមជ្ឈត្តការរបស់ ម.ជ.ម. នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៤, វិធាន២៦.៣។
[153] វិធានស្ដីពីមជ្ឈត្តការរបស់ ម.ជ.ម. នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៤, វិធាន២៦.៣។

ម៉្យាងវិញទៀត វេទិកាមជ្ឈត្តកម្ម អាចតែងតាំងអ្នកជំនាញឯករាជ្យមួយរូប ឬច្រើនរូប ឲ្យធ្វើរបាយការណ៍ជាលាយលក្ខណ៍អក្សរទៅវេទិកាមជ្ឈត្តកម្ម អំពីចំណុចវិវាទជាក់លាក់ណាមួយ ដែលវេទិកាមជ្ឈត្តកម្មបានកំណត់ លើកលែងតែគូភាគីវិវាទបានព្រមព្រៀងផ្សេងពីនេះ។[154] ការតែងតាំងនេះ ត្រូវតែធ្វើឡើងក្រោយពីវេទិកាមជ្ឈត្តកម្មបានពិភាក្សាជាមួយភាគីវិវាទ។[155] វេទិកាមជ្ឈត្តកម្មអាចតម្រូវឲ្យភាគីវិវាទផ្តល់ព័ត៌មានពាក់ព័ន្ធនឹងអ្នកជំនាញ ឬបង្ហាញ ឬអនុញ្ញាតឲ្យអ្នកជំនាញពិនិត្យទីតាំង ទំនិញ ទ្រព្យ ឬឯកសារផ្សេងៗ។[156] អ្នកជំនាញដែលត្រូវបានតែងតាំងនោះ ត្រូវដាក់នូវរបាយការណ៍ជាលាយលក្ខណ៍អក្សររបស់ខ្លួនទៅវេទិកាមជ្ឈត្តកម្ម។[157] បន្ទាប់មក វេទិកាមជ្ឈត្តកម្មត្រូវបញ្ជូនរបាយការណ៍មួយច្បាប់ ទៅគូភាគីវិវាទ និងស្នើឲ្យគូភាគីវិវាទផ្តល់យោបល់របស់ពួកគេជាលាយលក្ខណ៍អក្សរលើរបាយការណ៍នោះ។[158] អ្នកជំនាញនោះត្រូវចូលរួមក្នុងសវនាការផងដែរ ប្រសិនបើវេទិកាមជ្ឈត្តកម្មយល់ថាចាំបាច់ និងមានការយល់ព្រមពីគូភាគីវិវាត។[159]

- ❖ ករណីសហរដ្ឋអាមេរិក

ដោយឡែកក្នុងវិធានរបស់សហរដ្ឋអាមេរិកវិញ ភាគីត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅវេទិកាមជ្ឈត្តកម្ម អំពីសាក្សី ឬសាក្សីជំនាញដែលបានផ្តល់សក្ខីកម្មជាលាយលក្ខណ៍អក្សរ ដើម្បីឲ្យសាក្សីនោះបង្ហាញខ្លួននៅក្នុងសវនាការមជ្ឈត្តកម្ម។[160] នៅក្នុងដំណាក់កាលនៃសវនាការបឋមវេទិកាមជ្ឈត្តកម្មអាចបង្គាប់ឲ្យភាគីបញ្ជាក់ពីអត្តសញ្ញាណរបស់សាក្សី ក៏ដូចជាកម្មវត្ថុនៃសក្ខីកម្មដែលសាក្សីនឹងផ្តល់ឲ្យនៅក្នុងសវនាការ។[161] លើសពីនេះទៅទៀត វេទិកាមជ្ឈត្តកម្មក៏អាចបង្គាប់ឲ្យគូភាគីវិវាទផ្លាស់ប្តូរគ្នាទៅវិញទៅមកនូវសក្ខីកម្ម ដែលត្រូវបានធ្វើជាលាយលក្ខណ៍អក្សររបស់សាក្សីខ្លួន និងអាចធ្វើការសម្រេចថា សាក្សីចាំបាច់ត្រូវផ្តល់សក្ខីកម្មរបស់ខ្លួនម្តងទៀតនៅក្នុងសវនាការដែរឬទេ ដោយពិនិត្យលើសក្ខីកម្មជាលាយលក្ខណ៍អក្សរនោះ។[162] វេទិកាមជ្ឈត្តកម្ម ក៏អាចតម្រូវឲ្យ

[154] វិធានស្តីពីមជ្ឈត្តការរបស់ ម.ជ.ម. នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៤, វិធាន២៧.១, កថា. ១។
[155] វិធានស្តីពីមជ្ឈត្តការរបស់ ម.ជ.ម. នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៤, វិធាន២៧.១, កថា. ១។
[156] វិធានស្តីពីមជ្ឈត្តការរបស់ ម.ជ.ម. នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៤, វិធាន២៧.១, កថា. ២។
[157] វិធានស្តីពីមជ្ឈត្តការរបស់ ម.ជ.ម. នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៤, វិធាន២៧.២។
[158] វិធានស្តីពីមជ្ឈត្តការរបស់ ម.ជ.ម. នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៤, វិធាន២៧.២។
[159] វិធានស្តីពីមជ្ឈត្តការរបស់ ម.ជ.ម. នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៤, វិធាន២៧.៣។
[160] វិធានស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម និងនីតិវិធីសន្ទានកម្មរបស់ ស.ម.ស. ឆ្នាំ២០១៣, វិធាន៣៥(a)។
[161] វិធានស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម និងនីតិវិធីសន្ទានកម្មរបស់ ស.ម.ស. ឆ្នាំ២០១៣, វិធានP២(xii)(a)។
[162] វិធានស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម និងនីតិវិធីសន្ទានកម្មរបស់ ស.ម.ស. ឆ្នាំ២០១៣, វិធានP២(xii)(a)។

សាក្សីផ្តល់សក្ខីកម្មក្រោមសម្បថ ហើយប្រសិនបើមានភាគីណាមួយទាមទារ ឬក៏ច្បាប់តម្រូវ នោះសាក្សីត្រូវតែធ្វើសម្បថមុនផ្តល់សក្ខីកម្ម។[163]

❖ ការប្រៀបធៀប

តាមការប្រៀបធៀប យើងសង្កេតឃើញថាវិធានរបស់ប្រទេសទាំងពីរសុទ្ធតែមានចែងអំពីការចូលរួមរបស់សាក្សីក្នុងដំណើរការមជ្ឈត្តកម្ម។ ត្រង់ចំណុចនេះ វិធាននៃប្រទេសទាំងពីរ សុទ្ធតែតម្រូវឲ្យគូភាគីជូនដំណឹងអំពីអត្តសញ្ញាណរបស់សាក្សីទៅវេទិកាមជ្ឈត្តកម្ម មុនពេលបើកសវនាការមជ្ឈត្តកម្ម ដើម្បីឲ្យសាក្សីនោះផ្តល់សក្ខីកម្មដោយផ្ទាល់មាត់នៅក្នុងសវនាការ។ ត្រង់ចំណុចនេះ វិធានរបស់សហរដ្ឋអាមេរិកចែងយ៉ាងច្បាស់ថា សាក្សីដែលបានធ្វើសក្ខីកម្មជាលាយលក្ខណ៍អក្សរនៅមុនពេលបើកសវនាការ ត្រូវតែចូលបង្ហាញខ្លួននៅក្នុងសវនាការ ពុំនោះទេវេទិកាមជ្ឈត្តកម្មនឹងមិនទទួលស្គាល់នូវសក្ខីកម្មជាលាយលក្ខណ៍អក្សរនោះឡើយ។ លើសពីនេះ វិធានទាំងពីរមានចែងដូចគ្នាទាក់ទងនឹងសាក្សីជំនាញ។ ក៏ប៉ុន្តែ វិធានរបស់សហរដ្ឋអាមេរិកមិនមានចែងទាក់ទងទៅនឹងអ្នកជំនាញដែលតែងតាំងដោយវេទិកាមជ្ឈត្តកម្ម ដូចក្នុងករណីប្រទេសកម្ពុជាឡើយ។

### ២.១.៣.៦. ការដោះស្រាយវិវាទដោយស្ម័គ្រចិត្ត

❖ ករណីកម្ពុជា

ក្នុងវិធានរបស់ប្រទេសកម្ពុជា គូភាគីវិវាទអាចព្រមព្រៀងគ្នាដើម្បីដោះស្រាយវិវាទរបស់ខ្លួនដោយស្ម័គ្រចិត្តបាន។ វេទិកាមជ្ឈត្តកម្មត្រូវចេញសេចក្តីបង្គាប់បញ្ឈប់ដំណើរការមជ្ឈត្តការ ប្រសិនបើមុនពេលដែលចេញមជ្ឈត្តវិនិច្ឆ័យស្ថាពរ គូភាគីព្រមព្រៀងដោះស្រាយវិវាទដោយស្ម័គ្រចិត្ត។[164] លើសពីនេះទៅទៀត វេទិកាមជ្ឈត្តកម្មត្រូវកត់ត្រាដំណោះស្រាយវិវាទដោយស្ម័គ្រចិត្តនោះនៅក្នុងទម្រង់ជាមជ្ឈត្តវិនិច្ឆ័យតាមការព្រមព្រៀង ប្រសិនបើមានសំណើរបស់ភាគីវិវាទទាំងពីរ និងតាមវិសាលភាពនៃសំណើនោះ និងតាមការទទួលយល់ព្រមរបស់វេទិកាមជ្ឈត្តកម្ម។[165] វេទិកាមជ្ឈត្តកម្មមិនចាំបាច់ផ្តល់មូលហេតុចំពោះមជ្ឈត្តវិនិច្ឆ័យបែបនេះនោះឡើយ។[166] ការដោះស្រាយវិវាទដោយស្ម័គ្រចិត្តនេះ ត្រូវរួមបញ្ចូលផងដែរនូវការដោះស្រាយទាក់ទងនឹងការបង់កម្រៃសេវាមជ្ឈត្តកម្ម។[167]

[163] វិធានស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម និងនីតិវិធីសន្ទានកម្មរបស់ ស.ម.ស. ឆ្នាំ២០១៣, វិធាន២៧។
[164] វិធានស្តីពីមជ្ឈត្តការរបស់ ម.ជ.ម. នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៤, វិធាន៣០.១។
[165] វិធានស្តីពីមជ្ឈត្តការរបស់ ម.ជ.ម. នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៤, វិធាន៣០.១។
[166] វិធានស្តីពីមជ្ឈត្តការរបស់ ម.ជ.ម. នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៤, វិធាន៣០.១។
[167] វិធានស្តីពីមជ្ឈត្តការរបស់ ម.ជ.ម. នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៤, វិធាន៣០.២។

មានន័យថា ភាគីវិវាទត្រូវបង់កម្រៃសេវាមជ្ឈត្តកម្មផងដែរ បើទោះបីជាគូភាគីដោះស្រាយវិវាទដោយស្ម័គ្រចិត្តដូចក្នុងករណីខាងលើនេះក៏ដោយ។

❖ ករណីសហរដ្ឋអាមេរិក

រីឯនៅក្នុងវិធានរបស់សហរដ្ឋអាមេរិកវិញ គូភាគីវិវាទក៏អាចព្រមព្រៀងគ្នាដោះស្រាយវិវាទរបស់ខ្លួនដោយស្ម័គ្រចិត្តបានដែរ ក្នុងដំណាក់ណាមួយនៃមជ្ឈត្តការ។ បើសិនជាគូភាគីវិវាទបានព្រមព្រៀងដោះស្រាយវិវាទរបស់ខ្លួនដោយស្ម័គ្រចិត្ត ក្នុងដំណាក់កាលណាមួយនៃមជ្ឈត្តការ និងបើសិនជាមានសំណើរបស់គូរភាគី វេទិកាមជ្ឈត្តកម្មត្រូវកត់ត្រាដំណោះស្រាយវិវាទដោយស្ម័គ្រចិត្តនោះនៅក្នុងទម្រង់ជាមជ្ឈត្តវិនិច្ឆ័យតាមការព្រមព្រៀង។[168] ការដោះស្រាយវិវាទដោយស្ម័គ្រចិត្តនេះត្រូវរួមបញ្ចូលផងដែរនូវការសម្រេចទាក់ទងទៅនឹងការបង់កម្រៃសេវាមជ្ឈត្តកម្ម ដែលរាប់បញ្ចូលទាំងតម្លៃនិងការចំណាយរដ្ឋបាល ក៏ដូចជាថ្លៃនិងការចំណាយលើមជ្ឈត្តករដែរ។[169] មជ្ឈត្តវិនិច្ឆ័យតាមការព្រមព្រៀងនេះ នឹងមិនត្រូវបានប្រកាសចេញទៅភាគីទេ លើកលែងតែតម្លៃសេវារដ្ឋបាល និងតម្លៃសេវាមជ្ឈត្តករត្រូវបានបង់រួចរាល់។[170]

***ឧទាហរណ៍*** ប្រសិនបើភាគីវិវាទខកខានក្នុងការបង់កម្រៃសេវា ដោយហេតុផលថាខ្លួនបានដោះស្រាយវិវាទដោយស្ម័គ្រចិត្ត មជ្ឈត្តករនឹងមិនប្រកាសចេញមជ្ឈត្តវិនិច្ឆ័យដោយស្ម័គ្រចិត្តនេះទៅគូភាគីឡើយ រហូតដល់កម្រៃសេវាដែលត្រូវបានសម្រេចដោយមជ្ឈត្តករក្នុងមជ្ឈត្តវិនិច្ឆ័យនោះត្រូវបានបង់រួចរាល់។

❖ ការប្រៀបធៀប

តាមការប្រៀបធៀប យើងសង្កេតឃើញថា វិធានរបស់ប្រទេសទាំងពីរសុទ្ធតែផ្តល់សិទ្ធឲ្យគូភាគីវិវាទដោះស្រាយវិវាទរបស់ខ្លួនដោយស្ម័គ្រចិត្ត។ ការដោះស្រាយនោះ ត្រូវតែធ្វើនៅមុនពេលដែលចេញមជ្ឈត្តវិនិច្ឆ័យស្ថាពរ និងអាចធ្វើឡើងក្នុងទម្រង់មជ្ឈត្តវិនិច្ឆ័យតាមការព្រមព្រៀងដូចគ្នា។ ទាក់ទងនឹងមជ្ឈត្តវិនិច្ឆ័យតាមការព្រមព្រៀងនេះ វិធានទាំងពីរសុទ្ធតែទាមទារឲ្យមានការបង់កម្រៃសេវាមជ្ឈត្តកម្មផងដែរ ពុំនោះទេវេទិកាមជ្ឈត្តកម្មមិនអាចចេញមជ្ឈត្តវិនិច្ឆ័យតាមការព្រមព្រៀងទៅគូភាគីបានឡើយ។ លក្ខណៈខុសគ្នាមួយគួរឲ្យកត់សម្គាល់នោះគឺថា វិធានរបស់ប្រទេសកម្ពុជា

[168] វិធានស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម និងនីតិវិធីសន្ទានកម្មរបស់ ស.ម.ស. ឆ្នាំ២០១៣, វិធាន៤៨(a)។
[169] វិធានស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម និងនីតិវិធីសន្ទានកម្មរបស់ ស.ម.ស. ឆ្នាំ២០១៣, វិធាន៤៨(a)។
[170] វិធានស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម និងនីតិវិធីសន្ទានកម្មរបស់ ស.ម.ស. ឆ្នាំ២០១៣, វិធាន៤៨(b)។

ទាមទារឲ្យមានការយល់ព្រមផងដែរពីសំណាក់វេទិកាមជ្ឈត្តកម្ម ចំពោះការស្នើសុំរបស់គូភាគី ដើម្បីកត់ត្រាដំណោះស្រាយវិវាទដោយស្ម័គ្រចិត្តនោះ ក្នុងទម្រង់ជាមជ្ឈត្តវិនិច្ឆ័យតាមការព្រមព្រៀង។ ដោយឡែក វិធានរបស់សហរដ្ឋអាមេរិក គ្រាន់តែទាមទារឲ្យមានសំណើររបស់គូភាគីប៉ុណ្ណោះ។ លើសពីនេះទៅទៀត វិធានរបស់ប្រទេសកម្ពុជា មិនទាមទារឲ្យវេទិកាមជ្ឈត្តកម្មបញ្ជាក់ពីមូលហេតុចំពោះមជ្ឈត្តវិនិច្ឆ័យតាមការព្រមព្រៀងនេះឡើយ។

### ២.១.៣.៧. វិធានការបណ្ដោះអាសន្ន

❖ ករណីកម្ពុជា

ក្នុងវិធានរបស់ប្រទេសកម្ពុជា វេទិកាមជ្ឈត្តកម្មអាចចាត់វិធានការបណ្ដោះអាសន្ន តាមរយៈការចេញមជ្ឈត្តវិនិច្ឆ័យដែលមានមូលហេតុ ឬសេចក្ដីបង្គាប់ ក្នុងពេលណាមួយមុនពេលដែលចេញមជ្ឈត្តវិនិច្ឆ័យស្ថាពរ តាមសំណើររបស់ភាគីវិវាទណាមួយ។[171] វិធានការបណ្ដោះអាសន្ននេះ គឺជាវិធានការដែលមានលក្ខណៈ ចាំបាច់ និងបន្ទាន់ និងមិនត្រូវប៉ះពាល់ដល់សេចក្ដីសម្រេចស្ថាពររបស់វេទិកាមជ្ឈត្តកម្ម ចំពោះអង្គសេចក្ដីនៃសំណុំរឿងឡើយ។[172] វិធានការបណ្ដោះអាសន្ននេះ រួមមានជាអាទិ៍នូវ សេចក្ដីបង្គាប់នានាះ

ក. ដើម្បីថែរក្សា និងស្ដារស្ថានភាពឡើងវិញ ក្នុងពេលដែលវិវាទមិនទាន់ត្រូវបានដោះស្រាយ
ខ. ដើម្បីចំណាត់ការសកម្មភាព ក្នុងគោលបំណងរារាំង ឬទប់ស្កាត់ ការធ្វើសកម្មភាព ដែលអាចបង្កឲ្យមាន (i) ការខូចខាតបច្ចុប្បន្ន ឬបន្ទាន់ ឬ (ii) សេចក្ដីលម្អៀង ចំពោះដំណើរការមជ្ឈត្តការ
គ. ដើម្បីផ្ដល់មធ្យោបាយក្នុងការថែរក្សាទ្រព្យសម្បត្តិ ដែលអាចទាក់ទងនឹងការ បំពេញតាមមជ្ឈត្តវិនិច្ឆ័យបន្ទាប់ ឬ
ឃ. ដើម្បីរក្សាទុកនូវភស្តុតាងដែលអាចពាក់ព័ន្ធ និងដែលមានសារៈសំខាន់សម្រាប់ការដោះ-ស្រាយវិវាទ។

សំណើសុំវិធានការបណ្ដោះអាសន្ននេះត្រូវបញ្ជូនទៅវេទិកាមជ្ឈត្តកម្ម តាមរយៈសេចក្ដីថ្លែងដោយឡែក។[173] សេចក្ដីថ្លែងដោយឡែក ត្រូវតែមានការពណ៌នាយ៉ាងច្បាស់លាស់អំពីវិធានការបណ្ដោះអាសន្នដែលស្នើសុំ និងមូលហេតុនៃសំណើ រួមទាំងភាពចាំបាច់ និងភាពបន្ទាន់នៃវិធានការ

[171] វិធានស្ដីពីមជ្ឈត្តការរបស់ ម.ជ.ម. នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៤, វិធាន២៨.១។
[172] វិធានស្ដីពីមជ្ឈត្តការរបស់ ម.ជ.ម. នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៤, វិធាន២៨.២។
[173] វិធានស្ដីពីមជ្ឈត្តការរបស់ ម.ជ.ម. នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៤, វិធាន២៨.៣។

បណ្ដោះអាសន្ននោះ។[174] វេទិកាមជ្ឈត្តកម្មដោយមិនពន្យារពេលត្រូវជូនដំណឹងទៅគូភាគីវិវាទអំពីរបៀបដែលវេទិកាមជ្ឈត្តកម្ម នឹងចាត់ដំណើរការ ជាពិសេសថាតើនឹងមានសវនាការ ឬក៏តម្រូវឲ្យមាននូវសេចក្ដីថ្លែងបន្ថែម។[175] វេទិកាមជ្ឈត្តកម្មត្រូវផ្ដល់នូវវិធានការបណ្ដោះអាសន្នតាមការស្នើសុំ តែក្នុងករណីដែលវេទិកាមជ្ឈត្តកម្មយល់ថា វិធានការបណ្ដោះអាសន្ននោះត្រូវការជាចាំបាច់ និងបន្ទាន់។[176] សំណើសុំវិធានការបណ្ដោះអាសន្ន ដែលធ្វើឡើងមុន ឬក្នុងអំឡុងពេលនៃដំណើរការមជ្ឈត្តការ ដោយភាគីវិវាទណាមួយទៅតុលាការ មិនត្រូវចាត់ទុកជាការបោះបង់ការព្រមព្រៀងនោះទេ និងមិនត្រូវប៉ះពាល់ដល់អំណាចពាក់ព័ន្ធរបស់វេទិកាមជ្ឈត្តកម្មឡើយ។ ភាគីវិវាទណាមួយដែលបានដាក់សំណើរសុំវិធានការបណ្ដោះអាសន្នទៅតុលាការ ត្រូវជូនដំណឹងទៅវេទិកាមជ្ឈត្តកម្ម អំពីសំណើរនោះភ្លាម និងអំពីការសម្រេចរបស់តុលាការអំពីបញ្ហានោះ។

❖ ករណីសហរដ្ឋអាមេរិក

ក្នុងវិធានរបស់សហរដ្ឋអាមេរិកវិញ វេទិកាមជ្ឈត្តកម្មអាចចាត់វិធានការបណ្ដោះអាសន្ន នៅពេលដែលគាត់សន្មតថាមានភាពចាំបាច់ ដែលរួមមានទាំងសេចក្ដីសម្រេចហាមនូវទង្វើណាមួយសម្រាប់ការពារ ឬថែរក្សាទ្រព្យសម្បត្តិ និងការចាត់ចែងទំនិញផ្សេងៗ។[177] វិធានការបណ្ដោះអាសន្ននោះអាចត្រូវបានធ្វើឡើងក្នុងទម្រង់ជាមជ្ឈត្តវិនិច្ឆ័យបណ្ដោះអាសន្ន ហើយវេទិកាមជ្ឈត្តកម្មអាចតម្រូវឲ្យភាគីបង់នូវប្រាក់ធានាសមស្របសម្រាប់វិធានការនោះ។[178] សំណើររបស់ភាគីណាមួយទៅតុលាការដើម្បីឲ្យចាត់វិធានការបណ្ដោះអាសន្ននោះ មិនត្រូវបានចាត់ទុកថាផ្ទុយនឹងកិច្ចព្រមព្រៀងមជ្ឈត្តកម្មរបស់គូភាគី ឬជាការបោះបង់សិទ្ធនៅក្នុងការធ្វើមជ្ឈត្តកម្មនោះទេ។[179]

លើសពីនេះវិធានរបស់សហរដ្ឋអាមេរិក ចែងផងដែរអំពីវិធានការបន្ទាន់។ មុនពេលដែលវេទិកាមជ្ឈត្តកម្មត្រូវបានបង្កើត ភាគីណាមួយដែលស្នើឲ្យមានវិធានការបន្ទាន់ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅ ស.ម.ស. និងភាគីផ្សេងទៀត អំពីសេចក្ដីសម្រេចដែលខ្លួនចង់បាន ហើយនឹងហេតុផលអំពីភាពបន្ទាន់នៃសេចក្ដីសម្រេចនេះ។[180] ពាក្យស្នើសុំនោះ ក៏ត្រូវបញ្ជាក់ផងដែរអំពី

[174] វិធានស្តីពីមជ្ឈត្តការរបស់ ម.ជ.ម. នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៤, វិធាន២៨.៣។
[175] វិធានស្តីពីមជ្ឈត្តការរបស់ ម.ជ.ម. នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៤, វិធាន២៨.៤។
[176] វិធានស្តីពីមជ្ឈត្តការរបស់ ម.ជ.ម. នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៤, វិធាន២៨.៦។
[177] វិធានស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម និងនីតិវិធីសន្ទានកម្មរបស់ ស.ម.ស. ឆ្នាំ២០១៣, វិធាន៣៧(a)។
[178] វិធានស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម និងនីតិវិធីសន្ទានកម្មរបស់ ស.ម.ស. ឆ្នាំ២០១៣, វិធាន៣៧(b)។
[179] វិធានស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម និងនីតិវិធីសន្ទានកម្មរបស់ ស.ម.ស. ឆ្នាំ២០១៣, វិធាន៣៧(c)។
[180] វិធានស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម និងនីតិវិធីសន្ទានកម្មរបស់ ស.ម.ស. ឆ្នាំ២០១៣, វិធាន៣៨(b)។

មូលហេតុដែលភាគីស្នើសុំមានសិទ្ធិទទួលបានវិធានការបន្ទាន់នេះ។[181] ភាគីអាចផ្ញើនូវសេចក្តីជូនដំណឹងនេះ តាមរយៈទូរសារ ឬអ៊ីម៉ែល ឬក៏មធ្យោបាយដែលអាចទុកចិត្តបានផ្សេងទៀត ប៉ុន្តែត្រូវបញ្ជាក់ផងដែរពីការជូនដំណឹងនេះទៅភាគីផ្សេងទៀត។[182] ក្នុងរយៈពេលមួយថ្ងៃ ចាប់ពីពេលទទួលសេចក្តីជូនដំណឹងនេះ ស.ម.ស. ត្រូវតែងតាំងមជ្ឈត្តករមួយរូបសម្រាប់វិនិច្ឆ័យលើពាក្យស្នើនេះ។[183] មជ្ឈត្តករូបនោះត្រូវបង្ហាញអំពីអព្យាក្រឹតភាព និងឯករាជភាពរបស់ខ្លួនភ្លាម។[184] ហើយការជំទាស់នឹងមជ្ឈត្តករ ត្រូវតែធ្វើឡើងក្នុងកំឡុងពេលមួយថ្ងៃរាប់ចាប់ពីពេលដែល ស.ម.ស. បានជូនដំណឹងទៅភាគីអំពីការតែងតាំងមជ្ឈត្តករ។[185] ក្នុងកំឡុងពេលពីរថ្ងៃ បន្ទាប់ពីពេលដែលមជ្ឈត្តករត្រូវបានតែងតាំង មជ្ឈត្តករូបនោះត្រូវដាក់កាលវិភាគសម្រាប់ពិចារណាទៅលើពាក្យស្នើសុំរបស់ភាគី។[186] ប្រសិនបើ មជ្ឈត្តករមើលឃើញថា ការមិនចេញសេចក្តីសម្រេចបន្ទាន់នេះនឹងនាំឲ្យមានការខាតបង់ ឬការខូចខាតភ្លាមៗ ឬដែលមិនអាចជួសជុលបាន ហើយបើភាគីវិវាទនោះមានសិទ្ធទទួលបាននូវសេចក្តីសម្រេចនេះដែរ នោះមជ្ឈត្តករអាចចេញសេចក្តីបង្គាប់ ឬមជ្ឈត្តវិនិច្ឆ័យបណ្តោះអាសន្នដើម្បីផ្តល់សេចក្តីសម្រេច ដែលភាគីនោះចង់បានទាក់ទងនឹងវិធានការបណ្តោះអាសន្ននេះ។[187] សំណើរបស់ភាគីវិវាទណាមួយទៅតុលាការដើម្បីឲ្យចាត់វិធានការបន្ទាន់ មិនត្រូវបានចាត់ទុកថាផ្ទុយនឹងកិច្ចព្រមព្រៀងមជ្ឈត្តកម្មរបស់គូភាគី ឬជាការបោះបង់សិទ្ធិនៅក្នុងការធ្វើមជ្ឈត្តកម្មនោះទេ។[188]

❖ ការប្រៀបធៀប

តាមការប្រៀបធៀង យើងសង្កេតឃើញថា វិធាននៃប្រទេសទាំងពីរសុទ្ធតែផ្តល់សិទ្ធិឲ្យភាគីណាមួយនៃវិវាទក្នុងការស្នើសុំឲ្យវេទិកាមជ្ឈត្តកម្មចាត់វិធានការបណ្តោះអាសន្ន ដែលត្រូវតែមានភាពចាំបាច់ដូចគ្នា ក្នុងគោលបំណងថែរក្សាការពារទ្រព្យសម្បត្តិ កម្មវត្ថុនៃវិវាទជាដើម។ ប៉ុន្តែ យើងសង្កេតឃើញថា វិធានរបស់សហរដ្ឋអាមេរិក មានចែងផងដែរអំពីវិធានការបន្ទាន់ ដាច់ដោយឡែកពីវិធានការបណ្តោះអាសន្ន។ ទាក់ទងនឹងវិធានការបណ្តោះអាសន្ន វិធាននៃប្រទេសកម្ពុជាទាមទារឲ្យមាននូវលក្ខខណ្ឌចំនួនពីរគឺ ភាពចាំបាច់ និងភាពបន្ទាន់នៃវិធានការបណ្តោះអាសន្ននេះ ដើម្បីឲ្យ

[181] វិធានស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម និងនីតិវិធីសន្ទានកម្មរបស់ ស.ម.ស. ឆ្នាំ២០១៣, វិធាន៣៨(b)។
[182] វិធានស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម និងនីតិវិធីសន្ទានកម្មរបស់ ស.ម.ស. ឆ្នាំ២០១៣, វិធាន៣៨(b)។
[183] វិធានស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម និងនីតិវិធីសន្ទានកម្មរបស់ ស.ម.ស. ឆ្នាំ២០១៣, វិធាន៣៨(c)។
[184] វិធានស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម និងនីតិវិធីសន្ទានកម្មរបស់ ស.ម.ស. ឆ្នាំ២០១៣, វិធាន៣៨(c)។
[185] វិធានស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម និងនីតិវិធីសន្ទានកម្មរបស់ ស.ម.ស. ឆ្នាំ២០១៣, វិធាន៣៨(c)។
[186] វិធានស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម និងនីតិវិធីសន្ទានកម្មរបស់ ស.ម.ស. ឆ្នាំ២០១៣, វិធាន៣៨(d)។
[187] វិធានស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម និងនីតិវិធីសន្ទានកម្មរបស់ ស.ម.ស. ឆ្នាំ២០១៣, វិធាន៣៨(e)។
[188] វិធានស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម និងនីតិវិធីសន្ទានកម្មរបស់ ស.ម.ស. ឆ្នាំ២០១៣, វិធាន៣៨(h)។

វេទិកាមជ្ឈត្តកម្មផ្តល់នូវវិធានការនេះតាមការស្នើសុំ។ យ៉ាងណាមិញ វិធានរបស់សហរដ្ឋអាមេរិក ទាមទារត្រឹមតែភាពចាំបាច់នៃវិធានការបណ្តោះអាសន្នតែប៉ុណ្ណោះ ដើម្បីឲ្យមជ្ឈត្តករផ្តល់វិធានការ នេះដល់ភាគីវិវាទ។ ចំណុចដូចគ្នាគួរឲ្យកត់សម្គាល់មួយ គឺថាវេទិកាមជ្ឈត្តកម្មអាចចេញនូវវិធានការ បណ្តោះអាសន្ននេះក្នុងទម្រង់ជាមជ្ឈត្តវិច្ឆ័យបណ្តោះអាសន្ន។ ក្រៅពីនេះ វិធាននៃប្រទេសទាំងពីរ សុទ្ធតែទទួលស្គាល់ដូចគ្នាអំពីសិទ្ធិរបស់ភាគីវិវាទក្នុងការពឹងពាក់តុលាការ ដើម្បីឲ្យចេញវិធានការ បណ្តោះអាសន្ននេះ ហើយការពឹងពាក់តុលាការនេះមិនប៉ះពាល់ដល់កិច្ចព្រមព្រៀងមជ្ឈត្តកម្មរបស់ គូភាគីវិវាទ ឬមិនមានជាការបោះបង់សិទ្ធិក្នុងការធ្វើមជ្ឈត្តកម្មឡើយ។

ទោះជាយ៉ាងណាក៏ដោយ យើងសង្កេតឃើញថា វិធានរបស់សហរដ្ឋអាមេរិកមានចែងយ៉ាង ពិស្តារអំពីវិធានការបន្ទាន់ ក្នុងករណីដែលវេទិកាមជ្ឈត្តកម្មមិនទាន់ត្រូវបានបង្កើតឡើង។ វិធានការ នេះ ត្រូវតែមានភាពបន្ទាន់ និងភាពចាំបាច់ ដើម្បីជាមូលដ្ឋានសម្រាប់មជ្ឈត្តករក្នុងការពិចារណា។ ដូចគ្នាទៅនឹងវិធានការបណ្តោះអាសន្នដែរ សំណើរបស់ភាគីណាមួយទៅតុលាការដើម្បីឲ្យចាត់នូវ វិធានការបន្ទាន់នេះ មិនត្រូវបានចាត់ទុកថាផ្ទុយនឹងកិច្ចព្រមព្រៀងមជ្ឈត្តកម្មរបស់គូភាគីវិវាទ ឬជា ការបោះបង់សិទ្ធិនៅក្នុងការធ្វើមជ្ឈត្តកម្មនោះទេ។

## ២.២. សវនាការ និងមជ្ឈត្តវិនិច្ឆ័យ

ចំណុច ២.២.នេះនឹងធ្វើការបកស្រាយ និងប្រៀបធៀបដាច់ដោយឡែកពីគ្នាអំពី សវនាការ (២.២.១.) និងមជ្ឈត្តវិនិច្ឆ័យ (២.២.២.)។

### ២.២.១. សវនាការ

ក្នុងវិធានរបស់ប្រទេសទាំងពីរ សវនាការមជ្ឈត្តកម្មអាចត្រូវបានធ្វើឡើងដោយផ្ទាល់មាត់ ឬ ដោយផ្អែកលើឯកសារ និងលិខិតស្នាមផ្សេងៗ។[189] តាមវិធានរបស់ប្រទេសកម្ពុជា វេទិកាមជ្ឈត្តកម្ម ត្រូវសម្រេចថាតើនឹងត្រូវធ្វើសវនាការដោយផ្ទាល់មាត់ ឬត្រូវដំណើរការមជ្ឈត្តការ ដោយផ្អែកទៅ លើឯកសារ និងលិខិតស្នាមផ្សេងៗតែប៉ុណ្ណោះ លើកលែងតែគូភាគីនៃវិវាទបានព្រមព្រៀងអំពី

[189] វិធានស្តីពីមជ្ឈត្តការរបស់ ម.ជ.ម. នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៤, វិធាន២៤.១, កថា. ១។ វិធានស្តីពីមជ្ឈត្តការ ផ្នែកពាណិជ្ជកម្ម និងនីតិវិធីសន្ទានកម្មរបស់ ស.ម.ស. ឆ្នាំ២០១៣, វិធាន៣២(d)។

របៀបនៃការធ្វើសវនាការរួចហើយ។[190] យ៉ាងណាក៏ដោយ វេទិកាមជ្ឈត្តកម្មត្រូវធ្វើសវនាការដោយផ្ទាល់មាត់ ប្រសិនបើមានការស្នើសុំដោយភាគីវិវាទណាមួយ។[191]

ចំណុច ២.២.១. នេះនឹងធ្វើការសិក្សាប្រៀបធៀបអំពី ដំណើរការនៃសវនាការ **(២.២.១.១.)** លក្ខណៈឯកជននៃសវនាការ និងការចូលរួមក្នុងសវនាការ **(២.២.១.២.)** ការបញ្ចប់សវនាការ និងដំណើរការមជ្ឈត្តការ **(២.២.១.៣.)** និងចុងក្រោយ ការបើកសវនាការ និងដំណើរការមជ្ឈត្តការជាថ្មី **(២.២.១.៤.)**។

### ២.២.១.១. ដំណើរការនៃសវនាការ

❖ ករណីកម្ពុជា

វិធានរបស់ប្រទេសកម្ពុជា មិនមានកំណត់ជាក់ច្បាស់អំពីរបៀបវារៈនៃដំណើរការសវនាការមជ្ឈត្តកម្មនោះទេ។ យ៉ាងណាក៏ដោយ នៅក្នុងសវនាការ វេទិកាមជ្ឈត្តកម្មអាចតម្រូវឲ្យភាគីវិវាទធ្វើការបង្ហាញភស្តុតាងរបស់ខ្លួន រួមទាំងឯកសារ និងវត្ថុតាងផ្សេងៗផងដែរ។[192] ភាគីម្ខាងទៀតមានសិទ្ធិក្នុងការពិនិត្យភស្តុតាងដែលបង្ហាញដោយភាគីវិវាទរបស់ខ្លួនដែរ។[193] លើសពីនេះទៀត ភាគីវិវាទអាចស្នើឲ្យសាក្សីចូលរួមក្នុងការសាកសួរផ្ទាល់មាត់ ក្រោយពីសាក្សីនោះបានផ្តល់នូវសក្ខីកម្មជាលាយលក្ខណ៍អក្សរ។[194] ក្នុងករណីដែលសាក្សីនោះខកខាននៅក្នុងការចូលរួមការសាកសួរផ្ទាល់មាត់ វេទិកាមជ្ឈត្តកម្មអាចដាក់ទម្ងន់នៃពិចារណារបស់ខ្លួនទៅលើសក្ខីកម្មជាលាយលក្ខណ៍អក្សរដែលវេទិកាមជ្ឈត្តកម្មយល់ថាសមស្រប ឬទាត់ចោល ឬលុបចោលសក្ខីកម្មនោះទាំងស្រុង។[195] នៅពេលដែលសាក្សីណាមួយចូលរួមក្នុងការធ្វើសក្ខីកម្មដោយផ្ទាល់មាត់ នោះវេទិកាមជ្ឈត្តកម្ម ក៏ដូចជាភាគីវិវាទនីមួយៗអាចធ្វើការសាកសួរសាក្សីនោះនៅក្នុងទម្រង់ណាមួយ ដែលវេទិកាមជ្ឈត្តកម្មបានកំណត់។[196] វេទិកាមជ្ឈត្តកម្មក៏អាចតម្រូវឲ្យសាក្សីធ្វើសក្ខីកម្មក្រោមសម្បថ។[197] លើសពីនេះទៀត វេទិកាមជ្ឈត្តកម្មអាចតម្រូវឲ្យអ្នកជំនាញចូលរួមក្នុងសវនាការ បន្ទាប់ពីបានដាក់របាយការណ៍ជា

---

[190] វិធានស្តីពីមជ្ឈត្តការរបស់ ម.ជ.ម. នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៤, វិធាន២៤.១, កថា. ១។
[191] វិធានស្តីពីមជ្ឈត្តការរបស់ ម.ជ.ម. នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៤, វិធាន២៤.១, កថា. ១។
[192] វិធានស្តីពីមជ្ឈត្តការរបស់ ម.ជ.ម. នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៤, វិធាន២៥.២, កថា. ១។
[193] វិធានស្តីពីមជ្ឈត្តការរបស់ ម.ជ.ម. នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៤, វិធាន២៥.២, កថា. ២។
[194] វិធានស្តីពីមជ្ឈត្តការរបស់ ម.ជ.ម. នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៤, វិធាន២៦.៣។
[195] វិធានស្តីពីមជ្ឈត្តការរបស់ ម.ជ.ម. នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៤, វិធាន២៦.៣។
[196] វិធានស្តីពីមជ្ឈត្តការរបស់ ម.ជ.ម. នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៤, វិធាន២៦.៤។
[197] វិធានស្តីពីមជ្ឈត្តការរបស់ ម.ជ.ម. នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៤, វិធាន២៦.៥។

លាយលក្ខណ៍អក្សររបស់ខ្លួនរួចហើយ។[198] នៅពេលដែលអ្នកជំនាញចូលរួមក្នុងសវនាការ ភាគីត្រូវមានឱកាសក្នុងការសាកសួរអ្នកជំនាញនោះ។[199] គ្រប់សវនាការទាំងអស់ ត្រូវធ្វើឡើងជាលក្ខណៈឯកជន ហើយភាគីវិវាទទាំងអស់ត្រូវមានសិទ្ធិក្នុងការចូលរួមក្នុងសវនាការដោយផ្ទាល់មាត់។

❖ ករណីសហរដ្ឋអាមេរិក

រីឯវិធានរបស់សហរដ្ឋអាមេរិក ក៏មិនមានចែងពីរបៀបវិរៈច្បាស់លាស់សម្រាប់ដំណើរការនៃសវនាការមជ្ឈត្តកម្មដែរ។ យោងតាមវិធាននេះ ក្នុងពេលធ្វើសវនាការ ភាគីប្តឹងទាមទារត្រូវបង្ហាញនូវភស្តុតាងដើម្បីគាំទ្រនូវការទាមទាររបស់ខ្លួន។[200] បន្ទាប់មកទៀត ភាគីឆ្លើយតបត្រូវធ្វើការបង្ហាញភស្តុតាងដើម្បីគាំទ្រនូវការឆ្លើយតបរបស់ខ្លួន។[201] គួរកត់សម្គាល់ថា រាល់ភស្តុតាងទាំងអស់ ត្រូវតែបានបង្ហាញឡើងនៅចំពោះមុខវេទិកាមជ្ឈត្តកម្ម និងភាគីទាំងអស់ លើកលែងតែភាគីណាមួយអវត្តមាន ខកខានមិនបានចូលរួម ឬបោះបង់សិទ្ធិក្នុងការបង្ហាញខ្លួន។[202] លើសពីនេះ ភាគីវិវាទអាចស្នើសុំឲ្យសាក្សីចូលរួមក្នុងការសាកសួរដោយផ្ទាល់មាត់ផងដែរ។[203] វេទិកាមជ្ឈត្តកម្ម និងភាគីណាមួយ ត្រូវមានសិទ្ធិក្នុងការសាកសួរសាក្សីរបស់ភាគីណាមួយបានដែរ។[204] ចំពោះសាក្សី ឬសាក្សីជំនាញ ដែលបានផ្តល់សក្ខីកម្មជាលាយលក្ខណ៍អក្សរមុនពេលបើកសវនាការ ត្រូវតែបង្ហាញខ្លួននៅក្នុងសវនាការ។[205] ក្នុងករណីដែលសាក្សីនោះខកខានក្នុងការបង្ហាញខ្លួន នោះវេទិកាមជ្ឈត្តកម្មអាចមិនទទួលស្គាល់នូវសក្ខីកម្មជាលាយលក្ខណ៍អក្សរ ឬក៏របាយការណ៍របស់អ្នកជំនាញនោះ ឬក៏ធ្វើសេចក្តីបង្គាប់ណាមួយផ្សេងទៀត ដែលវេទិកាមជ្ឈត្តកម្មយល់ថាត្រឹមត្រូវ និងសមហេតុផល។[206] យ៉ាងណាក៏ដោយ វេទិកាមជ្ឈត្តកម្មមានឆន្ទានុសិទ្ធិក្នុងការកែប្រែនីតិវិធីនេះ ដោយត្រូវធានាថា ភាគីទាំងអស់ត្រូវបានប្រព្រឹត្តទៅលើដោយស្មើភាព និងត្រូវបានផ្តល់ឱកាសឲ្យស្មើៗគ្នា។[207]

---

[198] វិធានស្តីពីមជ្ឈត្តការរបស់ ម.ជ.ម. នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៤, វិធាន២៧.៣។

[199] វិធានស្តីពីមជ្ឈត្តការរបស់ ម.ជ.ម. នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៤, វិធាន២៧.៣។

[200] វិធានស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម និងនីតិវិធីសន្ធានកម្មរបស់ ស.ម.ស. ឆ្នាំ២០១៣, វិធាន៣២(a)។

[201] វិធានស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម និងនីតិវិធីសន្ធានកម្មរបស់ ស.ម.ស. ឆ្នាំ២០១៣, វិធាន៣២(a)។

[202] វិធានស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម និងនីតិវិធីសន្ធានកម្មរបស់ ស.ម.ស. ឆ្នាំ២០១៣, វិធាន៣៤(a)។

[203] វិធានស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម និងនីតិវិធីសន្ធានកម្មរបស់ ស.ម.ស. ឆ្នាំ២០១៣, វិធាន៣២(a)។

[204] វិធានស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម និងនីតិវិធីសន្ធានកម្មរបស់ ស.ម.ស. ឆ្នាំ២០១៣, វិធាន៣២(a)។

[205] វិធានស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម និងនីតិវិធីសន្ធានកម្មរបស់ ស.ម.ស. ឆ្នាំ២០១៣, វិធាន៣៥(a)។

[206] វិធានស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម និងនីតិវិធីសន្ធានកម្មរបស់ ស.ម.ស. ឆ្នាំ២០១៣, វិធាន៣៥(a)។

[207] វិធានស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម និងនីតិវិធីសន្ធានកម្មរបស់ ស.ម.ស. ឆ្នាំ២០១៣, វិធាន៣២(a)។

❖ ការប្រៀបធៀប

តាមការប្រៀបធៀប យើងសង្កេតឃើញថា វិធានរបស់ប្រទេសទាំងពីរមិនមានចែងច្បាស់អំពីរបៀបវារៈសម្រាប់ប្រើក្នុងសវនាការដូចគ្នា។ យ៉ាងណាមិញ វិធានទាំងពីរមានចែងស្រដៀងគ្នាអំពីការសាកសួរសាក្សី សាក្សីជំនាញ និងការបង្ហាញភស្តុតាងរបស់ភាគី ក្នុងពេលធ្វើសវនាការ។ លក្ខណៈស្រដៀងគ្នាគួរឲ្យកត់សម្គាល់នោះគឺថា ភាគីម្ខាងនៃវិវាទមានសិទ្ធិក្នុងការពិនិត្យភស្តុតាងរបស់ភាគីម្ខាងទៀត នឹងមានសិទ្ធិសាកសួរសាក្សីរបស់ភាគីម្ខាងទៀតដែរ ក្នុងពេលធ្វើសវនាការ។ ហើយលក្ខណៈបែបនេះ មានភាពស្រដៀងគ្នាទៅនឹងនីតិវិធីដែលត្រូវបានប្រើនៅក្នុងសវនាការនៃតុលាការរដ្ឋប្បវេណីដែរ ប៉ុន្តែរបៀបវារៈក្នុងសវនាការមជ្ឈត្តកម្ម មានលក្ខណៈសាមញ្ញជាង។ រីឯចំណុចខុសគ្នាគួរឲ្យកត់សម្គាល់នោះគឺថា ក្នុងវិធានរបស់ប្រទេសកម្ពុជា វេទិកាមជ្ឈត្តកម្មនៅតែអាចទទួលស្គាល់នូវសក្ខីកម្មជាលាយលក្ខណ៍អក្សររបស់សាក្សី ឬរបាយការរបស់សាក្សីជំនាញដដែលនៅពេលដែលសាក្សីនោះខកខានក្នុងការបង្ហាញខ្លួននៅក្នុងសវនាការ។ ប៉ុន្តែត្រង់ចំនុចនេះ ក្នុងវិធានរបស់សហរដ្ឋអាមេរិក វេទិកាមជ្ឈត្តកម្មអាចមិនទទួលស្គាល់នូវសក្ខីកម្មជាលាយលក្ខណ៍អក្សររបស់សាក្សី ឬរបាយការណ៍របស់សាក្សីជំនាញនោះឡើយ។

### ២.២.១.២. លក្ខណៈឯកជននៃសវនាការ និងការចូលរួមក្នុងសវនាការ

វិធានរបស់ប្រទេសកម្ពុជា ក៏ដូចជាវិធានរបស់សហរដ្ឋអាមេរិក តម្រូវឲ្យវេទិកាមជ្ឈត្តកម្មធ្វើសវនាការមជ្ឈត្តកម្មជាលក្ខណៈឯកជន លើកលែងតែភាគីបានព្រមព្រៀងផ្សេងពីនេះ។[208] ភាគីទាំងអស់ត្រូវមានសិទ្ធិចូលរួមក្នុងសវនាការដោយផ្ទាល់មាត់។[209] ត្រង់ចំណុចនេះដែរ វិធានរបស់សហរដ្ឋអាមេរិក បញ្ជាក់បន្ថែមយ៉ាងច្បាស់ថា ភាគីណាដែលមានប្រយោជន៍ទាក់ទងនឹងមជ្ឈត្តកម្មនេះ មានសិទ្ធិក្នុងការចូលរួមនៅក្នុងសវនាការមជ្ឈត្តកម្មបាន។[210] លើសពីនេះទៅទៀត នៅក្នុងវិធានទាំងពីរ វេទិកាមជ្ឈត្តកម្មអាចតម្រូវឲ្យសាក្សីណាមួយចាកចេញពីសវនាការ នៅពេលដែលសាក្សីផ្សេងទៀតកំពុងធ្វើសក្ខីកម្ម ឬកំពុងត្រូវបានសាកសួរ។[211] ហេតុដូច្នេះ វិធានរបស់ប្រទេសទាំងពីរសុទ្ធតែទទួល

---

[208] វិធានស្តីពីមជ្ឈត្តការរបស់ ម.ជ.ម. នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៤, វិធាន២៦.៦។ វិធានស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម និងនីតិវិធីសន្ទានកម្មរបស់ ស.ម.ស. ឆ្នាំ២០១៣, វិធាន២៥។

[209] វិធានស្តីពីមជ្ឈត្តការរបស់ ម.ជ.ម. នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៤, វិធាន២៦.៦។ វិធានស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម និងនីតិវិធីសន្ទានកម្មរបស់ ស.ម.ស. ឆ្នាំ២០១៣, វិធាន២៥។

[210] វិធានស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម និងនីតិវិធីសន្ទានកម្មរបស់ ស.ម.ស. ឆ្នាំ២០១៣, វិធាន២៥។

[211] វិធានស្តីពីមជ្ឈត្តការរបស់ ម.ជ.ម. នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៤, វិធាន២៦.៦។ វិធានស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម និងនីតិវិធីសន្ទានកម្មរបស់ ស.ម.ស. ឆ្នាំ២០១៣, វិធាន២៥ ។

ស្គាល់នូវលក្ខណៈឯកជននៃសវនាការរបស់មជ្ឈត្តការផ្នែកពាណិជ្ជកម្ម ហើយលក្ខណៈបែបនេះអាចជាមូលហេតុមួយផងដែរ ដែលគូភាគីព្រមព្រៀងដាក់វិវាទរបស់ខ្លួនឲ្យដោះស្រាយតាមមជ្ឈត្តការត្បិតថាគូភាគី ជាទូទៅ តែងតែមិនចង់ឲ្យវិវាទរបស់ខ្លួនផ្សព្វផ្សាយជាសាធារណៈ។

### ២.២.១.៣. ការបញ្ចប់សវនាការ និងដំណើរការមជ្ឈត្តការ

វិធានរបស់ប្រទេសកម្ពុជាមិនមានបញ្ជាក់ច្បាស់ពីការបញ្ចប់សវនាការនោះទេ ប៉ុន្តែបញ្ជាក់យ៉ាងច្បាស់ពីការបញ្ចប់ដំណើរការមជ្ឈត្តការ។ ចំណែកឯវិធានរបស់សហរដ្ឋអាមេរិក មិនមានចែងច្បាស់ថាដំណើរការមជ្ឈត្តការត្រូវបានបញ្ចប់នៅពេលណានោះទេ ប៉ុន្តែមានចែងយ៉ាងច្បាស់អំពីការបញ្ចប់នៃសវនាការមជ្ឈត្តកម្ម។ ស្របតាមវិធានរបស់សហរដ្ឋអាមេរិក វេទិកាមជ្ឈត្តកម្មត្រូវធ្វើការបញ្ជាក់ឲ្យបានច្បាស់ជាមួយគូភាគីវិវាទថា គូភាគីមិនមានភស្តុតាងបន្ថែមទៀតដែលត្រូវបង្ហាញ ឬក៏មិនមានសាក្សីណាទៀតដែលត្រូវធ្វើការសាកសួរនោះទេ។ បន្ទាប់ពីបញ្ជាក់ច្បាស់ហើយ វេទិកាមជ្ឈត្តកម្មត្រូវប្រកាសបិទសវនាការ។[212]

ចំណែកឯវិធានប្រទេសកម្ពុជា បញ្ជាក់យ៉ាងច្បាស់ពីការបញ្ចប់ដំណើរការមជ្ឈត្តការ តែមិនមានបញ្ជាក់អំពីការបញ្ចប់សវនាការនោះឡើយ។ ស្របតាមវិធាននេះ ក្រោយពីបានពិភាក្សាជាមួយគូភាគីវិវាទ វេទិកាមជ្ឈត្តកម្មត្រូវប្រកាសបញ្ចប់ដំណើរការមជ្ឈត្តការ នៅពេលដែលវេទិកាមជ្ឈត្តកម្មយល់ថាគូភាគីវិវាទមិនមានភស្តុតាងពាក់ព័ន្ធ និងសំខាន់បន្ថែម ដែលត្រូវបង្ហាញ ឬត្រូវបញ្ជូនមកវេទិកាមជ្ឈត្តកម្មទៀតទេ។[213] បន្ទាប់ពីបានប្រកាសបញ្ចប់ដំណើរការមជ្ឈត្តការ ភាគីមិនត្រូវដាក់ឬបង្ហាញភស្តុតាងបន្ថែមឡើយ។[214] លើសពីនេះទៅទៀត វេទិកាមជ្ឈត្តកម្មក៏ត្រូវចេញសេចក្តីបង្គាប់ដើម្បីបញ្ឈប់ដំណើរការមជ្ឈត្តការផងដែរ បើសិនជាគូភាគីវិវាទព្រមព្រៀងក្នុងការបញ្ចប់ដំណើរការមជ្ឈត្តការ ឬ បើវេទិកាមជ្ឈត្តកម្មយល់ថាការបន្តដំណើរការមជ្ឈត្តការ គឺមិនចាំបាច់ ឬមិនអាចទៅរួច ដោយមូលហេតុណាមួយ។[215]

យ៉ាងណាក៏ដោយ រយៈពេលសម្រាប់វេទិកាមជ្ឈត្តកម្មក្នុងការចេញមជ្ឈត្តវិនិច្ឆ័យ ត្រូវរាប់ចាប់ពីពេលនេះដូចគ្នា ពោលគឺចាប់ពីពេលដែលសវនាការត្រូវបានបញ្ចប់ ឬចាប់ពីពេលដែលដំណើរការមជ្ឈត្តកម្មត្រូវបានបញ្ចប់។

---

[212] វិធានស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម និងនីតិវិធីសន្ទានកម្មរបស់ ស.ម.ស. ឆ្នាំ២០១៣, វិធាន៣៩(a)។

[213] វិធានស្តីពីមជ្ឈត្តការរបស់ ម.ជ.ម. នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៤, វិធាន២៩, កថា. ១។

[214] វិធានស្តីពីមជ្ឈត្តការរបស់ ម.ជ.ម. នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៤, វិធាន២៩, កថា. ១។

[215] វិធានស្តីពីមជ្ឈត្តការរបស់ ម.ជ.ម. នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៤, វិធាន៣១។

### ២.២.១.៤. ការបើកសវនាការ និងដំណើរការមជ្ឈត្តការជាថ្មី

ដូចគ្នានឹងចំណុចខាងលើដែរ វិធានរបស់ប្រទេសកម្ពុជាមានបញ្ញាក់យ៉ាងច្បាស់អំពីការបើកដំណើរការមជ្ឈត្តការជាថ្មី តែមិនមានបញ្ញាក់ពីការបើកសវនាការជាថ្មីនោះទេ។ ដោយឡែកវិធានរបស់សហរដ្ឋអាមេរិក បញ្ញាក់យ៉ាងច្បាស់អំពីការបើកសវនាការជាថ្មី តែមិនមានបញ្ញាក់អំពីការបើកដំណើរការសវនាការជាថ្មីនោះទេ។ យោងតាមវិធានរបស់សហរដ្ឋអាមេរិក វេទិកាមជ្ឈត្តកម្មអាចបើកសវនាការជាថ្មីបាន តាមការផ្តួចផ្តើមផ្ទាល់ខ្លួន ឬតាមពាក្យស្នើសុំរបស់ភាគីណាមួយ នៅមុនពេលចេញមជ្ឈត្តវិនិច្ឆ័យ។[216] យ៉ាងណាក៏ដោយ ប្រសិនបើការបើកសវនាការជាថ្មីនោះអាចនាំឲ្យការចេញមជ្ឈត្តវិនិច្ឆ័យមិនទាន់ពេល ដូចដែលបានកំណត់នៅក្នុងកិច្ចព្រមព្រៀងមជ្ឈត្តកម្មរបស់ខ្លួន នោះវេទិកាមជ្ឈត្តកម្មអាចនឹងមិនបើកសវនាការជាថ្មីបាន លើកលែងតែភាគីបានព្រមព្រៀងក្នុងការពន្យាពេលដែលបានកំណត់នោះ។[217]

ចំណែកឯវិធានរបស់ប្រទេសកម្ពុជា មិនមានបញ្ញាក់អំពីការបើកសវនាការជាថ្មីនោះទេ តែមានបញ្ញាក់អំពីការបើកដំណើរការមជ្ឈត្តការជាថ្មី។ ស្របតាមវិធាននេះ ក្នុងកាលៈទេសៈពិសេសណាមួយ វេទិកាមជ្ឈត្តកម្មអាចបើកដំណើរការមជ្ឈត្តការជាថ្មី នៅក្នុងពេលវេលាណាមួយមុនពេលចេញមជ្ឈត្តវិនិច្ឆ័យស្ថាពរ។[218] ការបើកដំណើរការមជ្ឈត្តការជាថ្មីនេះ អាចត្រូវបានធ្វើឡើងតាមរយៈការផ្តួចផ្តើមផ្ទាល់ខ្លួន ឬតាមការស្នើសុំរបស់ភាគីវិវាទ។[219]

### ២.២.២. មជ្ឈត្តវិនិច្ឆ័យ

មជ្ឈត្តវិនិច្ឆ័យ គឺជាសេចក្តីសម្រេចរបស់អាជ្ញាកណ្តាលណាមួយទោះបីមានការគ្រប់គ្រងដោយស្ថាប័នមជ្ឈត្តការអចិន្ត្រៃយ៍ក្តី ឬមិនមែនអចិន្ត្រៃយ៍ក្តី។[220] ចំណុច២.២.២. នឹងធ្វើការសិក្សាប្រៀបធៀបអំពី ការសម្រេចរបស់វេទិកាមជ្ឈត្តកម្ម **(២.២.២.១.)** ទម្រង់នៃមជ្ឈត្តវិនិច្ឆ័យ **(២.២.២.២.)**

[216] វិធានស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម និងនីតិវិធីសន្ទានកម្មរបស់ ស.ម.ស. ឆ្នាំ២០១៣, វិធាន៤០។
[217] វិធានស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម និងនីតិវិធីសន្ទានកម្មរបស់ ស.ម.ស. ឆ្នាំ២០១៣, វិធាន៤០។
[218] វិធានស្តីពីមជ្ឈត្តការរបស់ ម.ជ.ម. នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៤, វិធាន២៩, កថា. ២។
[219] វិធានស្តីពីមជ្ឈត្តការរបស់ ម.ជ.ម. នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៤, វិធាន២៩, កថា. ២។
[220] ច្បាប់ស្តីពីការយល់ព្រម និងការអនុវត្តអនុសញ្ញាអង្គការសហប្រជាជាតិចែងអំពីការទទួលស្គាល់ និងការប្រតិបត្តិសេចក្តីសម្រេចមជ្ឈត្តករបរទេស នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៧០១/១០, ២៣ កក្កដា ២០០១ (ពីនេះតទៅហៅថា ច្បាប់ស្តីពីការយល់ព្រម និងការអនុវត្តអនុសញ្ញាទីក្រុងញូវយ៉កនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០១), មាត្រា២ (២)។

ការចេញមជ្ឈត្តវិនិច្ឆ័យ (២.២.២.៣.) ការកែតម្រូវមជ្ឈត្តវិនិច្ឆ័យ (២.២.២.៤.) និងចុងក្រោយ ការបំភ្លឺលម្អិត និងការបកស្រាយ និងការចេញមជ្ឈត្តវិនិច្ឆ័យបន្ថែម (២.២.២.៥.)។

### ២.២.២.១. ការសម្រេចរបស់វេទិកាមជ្ឈត្តកម្ម

❖ ករណីកម្ពុជា

ស្របតាមវិធាននៃប្រទេសកម្ពុជា វេទិកាមជ្ឈត្តកម្មត្រូវចេញមជ្ឈត្តវិនិច្ឆ័យ ឬសេចក្តីសម្រេចផ្សេងៗ ដោយផ្អែកទៅលើមតិភាគច្រើនដោយប្រៀបនៃមជ្ឈត្តករទាំងអស់ ក្នុងករណីដែលវេទិកាមជ្ឈត្តកម្ម ជាវេទិកានៃមជ្ឈត្តករច្រើនរូប។[221] ម៉្យាងមិញទៀត ប្រធានវេទិកាមជ្ឈត្តកម្មអាចសម្រេចលើបញ្ហានីតិវិធីតែម្នាក់ឯងបាន បើមានការយល់ព្រមជាមុនពីវេទិកាមជ្ឈត្តកម្ម។[222]

❖ ករណីសហរដ្ឋអាមេរិក

យ៉ាងណាមិញ វិធានរបស់សហរដ្ឋអាមេរិកក៏មានចែងស្រដៀងគ្នានេះដែរ។ ស្របតាមវិធាននេះ ក្នុងករណីដែលសមាជិកនៃវេទិកាមជ្ឈត្តកម្មមានលើសពីមួយរូប នោះមជ្ឈត្តករភាគច្រើនត្រូវធ្វើសេចក្តីសម្រេច លើកលែងតែច្បាប់ ឬកិច្ចព្រមព្រៀងមជ្ឈត្តកម្មរបស់គូភាគីតម្រូវផ្សេងពីនេះ។[223] ក្នុងករណីដែលវេទិកាមជ្ឈត្តកម្ម ជាវេទិកានៃមជ្ឈត្តករបីរូប ហើយបើគ្មានភាគី ឬមជ្ឈត្តករណាមួយជំទាស់នោះទេ ប្រធាននៃវេទិកាមជ្ឈត្តកម្មមានអំណាចនៅក្នុងការសម្រេចលើវិវាទទាក់ទងទៅនឹងការផ្លាស់ប្តូរព័ត៌មានរបស់ភាគី ឬក៏បញ្ហាផ្សេងៗទាក់ទងនឹងនីតិវិធី ដោយមិនចាំបាច់ធ្វើការប្រឹក្សាជាមួយមជ្ឈត្តករផ្សេងទៀតនោះទេ។[224]

❖ ការប្រៀបធៀប

តាមការប្រៀបធៀប យើងសង្កេតឃើញថា វិធានរបស់ប្រទេសកម្ពុជាមិនមានកំណត់អំពីករណីលើកលែង ដែលទាក់ទងនឹងការសម្រេចតាមរយៈសម្លេងភាគច្រើនដោយប្រៀបរបស់វេទិកាមជ្ឈត្តកម្ម ក្នុងករណីវេទិកាមជ្ឈត្តកកម្មនៃមជ្ឈត្តករច្រើនរូបនោះទេ។ យ៉ាងណាមិញ វិធានរបស់សហរដ្ឋអាមរិក កំណត់អំពីករណីលើកលែងចំពោះការសម្រេចដោយសម្លេងភាគច្រើននេះ ពោលគឺវេទិកាមជ្ឈត្តកម្មត្រូវគោរពតាមបទបញ្ញត្តិនៃច្បាប់ ឬកិច្ចព្រមព្រៀងរបស់ភាគីវិញ បើបទបញ្ញត្តិ ឬ

[221] វិធានស្តីពីមជ្ឈត្តការរបស់ ម.ជ.ម. នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៤, វិធាន៣២.១។
[222] វិធានស្តីពីមជ្ឈត្តការរបស់ ម.ជ.ម. នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៤, វិធាន៣២.២។
[223] វិធានស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម និងនីតិវិធីសន្ទានកម្មរបស់ ស.ម.ស. ឆ្នាំ២០១៣, វិធាន៤៤(a)។
[224] វិធានស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម និងនីតិវិធីសន្ទានកម្មរបស់ ស.ម.ស. ឆ្នាំ២០១៣, វិធាន៤៤(b)។

កិច្ចព្រមព្រៀងនោះកំណត់ផ្សេងពីវិធាននេះ។ លើសពីនេះទៅទៀត ស្របតាមវិធានរបស់ប្រទេសកម្ពុជា ប្រធានវេទិកាមជ្ឈត្តកម្មនៃមជ្ឈត្តករច្រើនរូប អាចធ្វើការសម្រេចលើបញ្ហានីតិវិធីតែម្នាក់ឯងបាន បើគ្មានការជំទាស់ពីវេទិកាមជ្ឈត្តកម្ម។ ដោយឡែក ស្របតាមវិធានរបស់សហរដ្ឋអាមេរិក ប្រធាននៃវេទិកាមជ្ឈត្តកម្មអាចសម្រេចលើបញ្ហាផ្សេងៗទាក់ទងនឹងនីតិវិធីបាន សម្រាប់តែករណីដែលវេទិកាមជ្ឈត្តកម្ម ជាវេទិកានៃមជ្ឈត្តករបីរូបតែប៉ុណ្ណោះ ហើយបើគ្មានភាគី ឬមជ្ឈត្តករណាមួយជំទាស់។ ក្នុងករណីដដែលនេះដែរ ប្រធានវេទិកាមជ្ឈត្តកម្មក៏អាចសម្រេចលើវិវាទទាក់ទងទៅនឹងការផ្លាស់ប្តូរព័ត៌មានរបស់គូភាគីផងដែរ ក្រៅពីបញ្ហាទាក់ទងនឹងនីតិវិធី។

#### ២.២.២.២. ទម្រង់នៃមជ្ឈត្តវិនិច្ឆ័យ

❖ ករណីកម្ពុជា

ស្របតាមវិធានរបស់ប្រទេសកម្ពុជា មជ្ឈត្តវិនិច្ឆ័យត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ។[225] លើសពីនេះទៅទៀត មជ្ឈត្តវិនិច្ឆ័យត្រូវមានសំអាងហេតុដែលជាមូលដ្ឋានក្នុងការសម្រេចផងដែរ លើកលែងតែភាគីបានព្រមព្រៀងផ្សេងពីនេះ និងស្របតាមវិធាន៣០ ដែលស្តីពីការដោះស្រាយវិវាទដោយស្ម័គ្រចិត្ត។[226]ម្យ៉ាងវិញទៀត មជ្ឈត្តវិនិច្ឆ័យត្រូវតែមានចុះកាលបរិច្ឆេទ និងទីកន្លែងដែលមជ្ឈត្តវិនិច្ឆ័យត្រូវបានចេញ។[227] មជ្ឈត្តវិនិច្ឆ័យនោះ ត្រូវមានចុះហត្ថលេខាដោយមជ្ឈត្តករទាំងអស់ផងដែរ។[228] ចំពោះវេទិកាមជ្ឈត្តកម្មនៃមជ្ឈត្តករច្រើនរូប ហត្ថលេខារបស់សមាជិកភាគច្រើននៃវេទិកាមជ្ឈត្តកម្មត្រូវបានចាត់ទុកថាគ្រប់គ្រាន់ នៅពេលណាដែលមានការបញ្ជាក់អំពីមូលហេតុដែលមជ្ឈត្តករដទៃទៀតមិនបានចុះហត្ថលេខា។[229] ទោះជាយ៉ាងណាក៏ដោយ វេទិកាមជ្ឈត្តកម្មមិនត្រូវចេញមជ្ឈត្តវិនិច្ឆ័យណាមួយឡើយ ប្រសិនបើអគ្គលេខាធិការដ្ឋានមិនទាន់បានពិនិត្យពិច័យ និងឯកភាពលើទម្រង់របស់មជ្ឈត្តវិនិច្ឆ័យនោះទេ។[230]

[225] វិធានស្តីពីមជ្ឈត្តការរបស់ ម.ជ.ម. នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៤, វិធាន៣៤.១។
[226] វិធានស្តីពីមជ្ឈត្តការរបស់ ម.ជ.ម. នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៤, វិធាន៣៤.១។
[227] វិធានស្តីពីមជ្ឈត្តការរបស់ ម.ជ.ម. នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៤, វិធាន៣៤.២។
[228] វិធានស្តីពីមជ្ឈត្តការរបស់ ម.ជ.ម. នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៤, វិធាន៣៤.៣។
[229] វិធានស្តីពីមជ្ឈត្តការរបស់ ម.ជ.ម. នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៤, វិធាន៣៤.៣។
[230] វិធានស្តីពីមជ្ឈត្តការរបស់ ម.ជ.ម. នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៤, វិធាន៣៤.៥។

❖ ករណីសហរដ្ឋអាមេរិក

យ៉ាងណាមិញ វិធានរបស់សហរដ្ឋអាមេរិក តម្រូវឲ្យរាល់មជ្ឈត្តវិនិច្ឆ័យទាំងអស់ធ្វើឡើងជាលាយលក្ខណ៍អក្សរ ហើយត្រូវបានចុះហត្ថលេខាដោយមជ្ឈត្តករភាគច្រើន។[231] លើសពីនេះទៀត វេទិកាមជ្ឈត្តកម្មត្រូវអនុវត្តតាមទម្រង់ និងលក្ខណៈដែលច្បាប់តម្រូវ។[232] ម្យ៉ាងវិញទៀត មជ្ឈត្តករមិនចាំបាច់ចេញមជ្ឈត្តវិនិច្ឆ័យដែលមានហេតុផលសំអាងនោះទេ លើកលែងតែគូភាគីបានស្នើសុំជាលាយលក្ខណ៍អក្សរឲ្យមានមជ្ឈត្តវិនិច្ឆ័យប្រភេទនេះ មុនពេលដែលមជ្ឈត្តករត្រូវបានតែងតាំង ឬក៍មជ្ឈត្តករយល់ឃើញថាមជ្ឈត្តវិនិច្ឆ័យដែលមានហេតុផល គឺសមរម្យ។[233]

❖ ការប្រៀបធៀប

តាមការប្រៀបធៀប យើងសង្កេតឃើញថា វិធានរបស់ប្រទេសកម្ពុជា និងសហរដ្ឋអាមេរិក សុទ្ធតែតម្រូវឲ្យមជ្ឈត្តវិនិច្ឆ័យទាំងអស់ធ្វើឡើងជាលាយលក្ខណ៍អក្សរ និងត្រូវមានចុះហត្ថលេខារបស់មជ្ឈត្តករ។ ទោះជាយ៉ាងនេះក្តី វិធានរបស់ប្រទេសកម្ពុជាមានលក្ខណៈពិស្តាជាង ដោយវិធាននេះមានកំណត់ជាក់លាក់តែម្តងត្រង់ទម្រង់នៃមជ្ឈត្តវិនិច្ឆ័យនេះ។ តាមវិធានរបស់ប្រទេសកម្ពុជា មជ្ឈត្តវិនិច្ឆ័យត្រូវមានចុះកាលបរិច្ឆេទ និងទីកន្លែង ដែលមជ្ឈត្តវិនិច្ឆ័យត្រូវបានចេញផងដែរ ក្រៅពីលក្ខខណ្ឌជាលាយលក្ខណ៍អក្សរ និងហត្ថលេខារបស់មជ្ឈត្តករ។ ដោយឡែក វិធានរបស់សហរដ្ឋអាមេរិកតម្រូវឲ្យមជ្ឈត្តករអនុវត្តតាមទម្រង់ និងលក្ខណៈដែលច្បាប់តម្រូវ។ មានន័យថា មជ្ឈត្តករត្រូវអនុត្តតាមច្បាប់សហព័ន្ធស្តីពីមជ្ឈត្តការរបស់សហរដ្ឋអាមេរិក និងអាចច្បាប់រដ្ឋណាមួយរបស់សហរដ្ឋអាមេរិក និងអាចជាច្បាប់ណាមួយផ្សេងទៀតដែលគូភាគីវិវាទបានព្រមព្រៀងផងដែរ។ លើសពីនេះ វិធានរបស់ប្រទេសកម្ពុជា តម្រូវឲ្យវេទិកាមជ្ឈត្តកម្មចេញនូវមជ្ឈត្តវិនិច្ឆ័យដែលមានសំអាងហេតុ លើកលែងតែករណីដូចបង្ហាញខាងលើ។ ផ្ទុយមកវិញ វិធានរបស់សហរដ្ឋអាមេរិកមិនតម្រូវឲ្យមជ្ឈត្តករចេញនូវមជ្ឈត្តវិនិច្ឆ័យដែលមានសំអាងហេតុនោះទេ លើកលែងតែគូភាគីបានស្នើសុំ ឬមជ្ឈត្តករយល់ថាសមរម្យ ដូចមានបង្ហាញខាងលើ។ ទាក់ទងនឹងហត្ថលេខារបស់មជ្ឈត្តករវិញ វិធានរបស់សហរដ្ឋអាមេរិក គ្រាន់តែតម្រូវឲ្យមជ្ឈត្តករភាគច្រើនចុះហត្ថលេខាប៉ុណ្ណោះ។ ចំណែកឯវិធានរបស់កម្ពុជា តម្រូវឲ្យមជ្ឈត្តករទាំងអស់ចុះហត្ថលេខា។ ហត្ថលេខារបស់មជ្ឈត្តករភាគច្រើន

---

[231] វិធានស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម និងនីតិវិធីសន្ទានកម្មរបស់ ស.ម.ស. ឆ្នាំ២០១៣, វិធាន៤៦(a)។
[232] វិធានស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម និងនីតិវិធីសន្ទានកម្មរបស់ ស.ម.ស. ឆ្នាំ២០១៣, វិធាន៤៦(a)។
[233] វិធានស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម និងនីតិវិធីសន្ទានកម្មរបស់ ស.ម.ស. ឆ្នាំ២០១៣, វិធាន៤៦(b)។

ត្រូវបានចាត់ទុកថាគ្រប់គ្រាន់ លុះត្រាតែមានការបញ្ជាក់ពីមូលហេតុ ដែលមជ្ឈត្តករដទៃទៀតមិនបានចុះហត្ថលេខា។

### ២.២.២.៣. ការចេញមជ្ឈត្តវិនិច្ឆ័យ

❖ ករណីកម្ពុជា

ស្របតាមវិធានរបស់ប្រទេសកម្ពុជា វេទិកាមជ្ឈត្តមិនត្រូវចេញមជ្ឈត្តវិនិច្ឆ័យដោយភ្លាមៗនោះទេ។ វេទិកាមជ្ឈត្តកម្ម ជាដំបូងត្រូវបញ្ជូនសេចក្ដីព្រាងមជ្ឈត្តវិនិច្ឆ័យទៅអគ្គលេខាធិការដ្ឋានក្នុងកំឡុងពេល ៤៥ ថ្ងៃប្រតិទិន បន្ទាប់ពីកាលបរិច្ឆេទដែលវេទិកាមជ្ឈត្តកម្មបានប្រកាសបិទនូវដំណើរការមជ្ឈត្តកម្ម លើកលែងតែអគ្គលេខាធិការដ្ឋានពន្យារពេលវេលាកំណត់តាមសំណើរសុំរបស់វេទិកាមជ្ឈត្តកម្ម ឬគូភាគីបានព្រមព្រៀងផ្សេងពីនេះ។[234] ការបញ្ជូនសេចក្ដីព្រាងមជ្ឈត្តវិនិច្ឆ័យទៅអគ្គលេខាធិកាដ្ឋានដូចនេះ គឺក្នុងគោលបំណងឲ្យអគ្គលេខាធិការដ្ឋានពិនិត្យពិច័យលើទម្រង់របស់មជ្ឈត្តវិនិច្ឆ័យ។[235] អគ្គលេខាធិការដ្ឋានអាចស្នើសុំឲ្យកែប្រែលើទម្រង់របស់មជ្ឈត្តវិនិច្ឆ័យ និងអាចស្នើសុំឲ្យវេទិកាមជ្ឈត្តកម្មយកចិត្តទុកដាក់លើចំណុចសារធាតុនានានៃមជ្ឈត្តវិនិច្ឆ័យ ដោយមិនឲ្យប៉ះពាល់ដល់សេរីភាពក្នុងការសម្រេចរបស់វេទិកាមជ្ឈត្តកម្ម ក្នុងកំឡុងពេល ៣០ថ្ងៃប្រតិទិនបន្ទាប់ពីបានទទួលសេចក្ដីព្រាងមជ្ឈត្តវិនិច្ឆ័យ។[236]

យ៉ាងណាក៏ដោយ នីតិវិធីនេះមិនត្រូវយកមកអនុវត្តចំពោះមជ្ឈត្តវិនិច្ឆ័យតាមការព្រមព្រៀង និងមជ្ឈត្តវិនិច្ឆ័យដែលចេញពាក់ព័ន្ធនឹងវិធានការបណ្ដោះអាសន្នឡើយ។[237] បន្ទាប់ពីពិនិត្យពិច័យឃើញថា មជ្ឈត្តវិនិច្ឆ័យបំពេញនូវលក្ខខណ្ឌទម្រង់រួចហើយ អគ្គលេខាធិការដ្ឋានត្រូវធ្វើការបោះត្រា ម.ជ.ម. លើមជ្ឈត្តវិនិច្ឆ័យនោះដោយមិនបង្អង់ និងបញ្ជូនមជ្ឈត្តវិនិច្ឆ័យនោះទៅភាគីវិវាទទាំងអស់ ប្រសិនបើការបង់ប្រាក់ជាមុនដែលតម្រូវត្រូវបានបង់ទៅ ម.ជ.ម. ឬប្រសិនបើកម្រៃសេវាទាំងអស់លើមជ្ឈត្តការ ត្រូវបានបង់គ្រប់ចំនួនទៅ ម.ជ.ម. សម្រាប់ករណីមជ្ឈត្តវិនិច្ឆ័យស្ថាពរ។[238]

[234] វិធានស្ដីពីមជ្ឈត្តការរបស់ ម.ជ.ម. នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៤, វិធាន៣៥.១(ក)។
[235] វិធានស្ដីពីមជ្ឈត្តការរបស់ ម.ជ.ម. នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៤, វិធាន៣៥.១(ក)។
[236] វិធានស្ដីពីមជ្ឈត្តការរបស់ ម.ជ.ម. នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៤, វិធាន៣៥.១(ក)។
[237] វិធានស្ដីពីមជ្ឈត្តការរបស់ ម.ជ.ម. នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៤, វិធាន៣៥.១(ខ)។
[238] វិធានស្ដីពីមជ្ឈត្តការរបស់ ម.ជ.ម. នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៤, វិធាន៣៦។

❖ ករណីសហរដ្ឋអាមេរិក

យ៉ាងណាមិញ វិធានរបស់សហរដ្ឋអាមេរិក មិនមានតម្រូវឲ្យមជ្ឈត្តករផ្ញើនូវសេចក្ដីព្រាងនៃមជ្ឈត្តវិនិច្ឆ័យទៅ ស.ម.ស. មុននឹងចេញមជ្ឈត្តវិនិច្ឆ័យ ដូចវិធានរបស់ប្រទេសកម្ពុជាឡើយ។ ស្របតាមវិធាននេះ មជ្ឈត្តករត្រូវចេញនូវមជ្ឈត្តវិនិច្ឆ័យភ្លាមតាមដែលអាចធ្វើបាន និងមិនឲ្យលើសរយៈពេល៣០ថ្ងៃប្រតិទិន បន្ទាប់ពីថ្ងៃដែលសវនាការត្រូវបានបិទ ឬបន្ទាប់ពីថ្ងៃផុតកំណត់សម្រាប់ទទួលសេចក្ដីថ្លែង និងភស្តុតាងចុងក្រោយរបស់ភាគី ប្រសិនបើគូភាគីបោះបង់សិទ្ធិក្នុងការធ្វើសវនាការផ្ទាល់មាត់ លើកលែងតែគូភាគីបានព្រមព្រៀងផ្សេងពីនេះ ឬច្បាប់កំណត់ផ្សេងពីនេះ។[239] សម្រាប់នីតិវិធីរហ័ស មជ្ឈត្តករត្រូវតែចេញមជ្ឈត្តវិនិច្ឆ័យនៅក្នុងពេលណាមួយមិនឲ្យលើសរយៈពេល១៤ថ្ងៃប្រតិទិន បន្ទាប់ពីថ្ងៃដែលសវនាការត្រូវបានបិទ ឬបន្ទាប់ពីថ្ងៃផុតកំណត់សម្រាប់ទទួលសេចក្ដីថ្លែង និងភស្តុតាងចុងក្រោយរបស់ភាគី ប្រសិនបើគូភាគីវិវាទបោះបង់សិទ្ធិក្នុងការធ្វើសវនាការផ្ទាល់មាត់ លើកលែងតែគូភាគីបានព្រមព្រៀងផ្សេងពីនេះ ឬច្បាប់កំណត់ផ្សេងពីនេះ។[240]

❖ ការប្រៀបធៀប

តាមការប្រៀបធៀប វិធានរបស់ប្រទេសកម្ពុជាតម្រូវឲ្យវេទិកាមជ្ឈត្តកម្មផ្ញើនូវសេចក្ដីព្រាងនៃមជ្ឈត្តវិនិច្ឆ័យទៅអគ្គលេខាធិការដ្ឋានជាមុនសិន ដើម្បីឲ្យអគ្គលេខាធិការដ្ឋានពិនិត្យពិច័យលើទម្រង់នៃមជ្ឈត្តវិនិច្ឆ័យនោះ ហើយថែមទាំងអាចស្នើសុំឲ្យវេទិកាមជ្ឈត្តកម្មយកចិត្តទុកដាក់ទៅលើចំណុចសារធាតុនានារបស់មជ្ឈត្តវិនិច្ឆ័យទៀតផង។ បន្ទាប់មកទៀត ទើបអគ្គលេខាធិការដ្ឋានបញ្ជូនមជ្ឈត្តវិនិច្ឆ័យនោះទៅភាគីនីមួយៗ។ យ៉ាងណាមិញ វិធានរបស់សហរដ្ឋអាមេរិក ពិតជាមានលក្ខណៈខុសគ្នាខ្លាំង ត្រង់ថាមជ្ឈត្តករមិនតម្រូវឲ្យបញ្ជូនសេចក្ដីព្រាងទៅ ស.ម.ស. ជាមុននោះទេ មុននឹងចេញមជ្ឈត្តវិនិច្ឆ័យស្ថាពរទៅភាគីនីមួយៗ។ យន្តការនេះអាចធ្វើឲ្យមជ្ឈត្តវិនិច្ឆ័យក្នុងវិធានរបស់ប្រទេសកម្ពុជា កាត់បន្ថយកំហុសឆ្គងបានច្រើនជាងមជ្ឈត្តវិនិច្ឆ័យនៅក្នុងវិធានរបស់សហរដ្ឋអាមេរិក។ ទោះជាយ៉ាងនេះក៏ដោយ យន្តការដែលមានកំណត់កំឡុងពេលវែងដូចមានចែងក្នុងវិធានរបស់ប្រទេសកម្ពុជា នឹងនាំឲ្យការចេញមជ្ឈត្តវិនិច្ឆ័យក្នុងវិធាននេះ មានភាពយឺតយ៉ាវជាងនៅក្នុងវិធានរបស់សហរដ្ឋអាមេរិក។

[239] វិធានស្ដីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម និងនីតិវិធីសន្ទានកម្មរបស់ ស.ម.ស. ឆ្នាំ២០១៣, វិធាន៤៥។
[240] វិធានស្ដីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម និងនីតិវិធីសន្ទានកម្មរបស់ ស.ម.ស. ឆ្នាំ២០១៣, វិធានE៩។

### ២.២.២.៤. ការកែតម្រូវមជ្ឈត្តវិនិច្ឆ័យ

❖ ករណីកម្ពុជា

ស្របតាមវិធានរបស់ប្រទេសកម្ពុជា ភាគីណាមួយ អាចស្នើសុំវេទិកាមជ្ឈត្តកម្មឲ្យកែតម្រូវកំហុសក្នុងការគណនា កំហុសផ្នែកការងារ លេខាធិការ ឬកំហុសក្នុងការបោះពុម្ព ឬកំហុសផ្សេងៗដែលមានលក្ខណៈស្រដៀងនោះ ដែលមាននៅក្នុងមជ្ឈត្តវិនិច្ឆ័យ ក្នុងអំឡុងពេល ៣០ថ្ងៃប្រតិទិននៃការទទួលបាននូវមជ្ឈត្តវិនិច្ឆ័យ លើកលែងតែមានការពន្យារអំឡុងពេលបន្ថែមផ្សេងពីនេះតាមការព្រមព្រៀងរវាងគូភាគីវិវាទមុនពេលបិទដំណើរការមជ្ឈត្តការ។[241] ក្នុងការស្នើសុំ ភាគីដែលមានបំណងស្នើសុំ ត្រូវជូនដំណឹងទៅកាន់ភាគីវិវាទម្ខាងទៀត ក៏ដូចជាទៅកាន់អគ្គលេខាធិការដ្ឋាន និងវេទិកាមជ្ឈត្តកម្ម។[242] ភាគីវិវាទម្ខាងទៀតអាចផ្តល់មតិរបស់ខ្លួនទាក់ទងនឹងសំណើរនេះ ក្នុងអំឡុងពេលសមរម្យណាមួយដែលកំណត់ដោយវេទិកាមជ្ឈត្តកម្ម។[243] ប្រសិនបើវេទិកាមជ្ឈត្តកម្មយល់ថាសំណើរណាមួយសមរម្យ នោះវេទិកាមជ្ឈត្តកម្មត្រូវកែតម្រូវមជ្ឈត្តវិនិច្ឆ័យ ក្នុងកំឡុងពេល ៣០ថ្ងៃប្រតិទិន បន្ទាប់ពីបានទទួលសំណើរនោះ។[244]

លើសពីនេះ ចំពោះការផ្លាស់ប្តូរដែលចាំបាច់ ឬសមស្រប ដែលពាក់ព័ន្ធទៅនឹងការកែតម្រូវមជ្ឈត្តវិនិច្ឆ័យ វេទិកាមជ្ឈត្តកម្មត្រូវបញ្ជូនសេចក្តីព្រាងមជ្ឈត្តវិនិច្ឆ័យនោះទៅអគ្គលេខាធិការដ្ឋានសម្រាប់ការពិនិត្យពិច័យលើទម្រង់ជាមុនសិន។[245] អគ្គលេខាធិការដ្ឋាន អាចស្នើឲ្យវេទិកាមជ្ឈត្តកម្មកែប្រែលើទម្រង់មជ្ឈត្តវិនិច្ឆ័យ និងអាចស្នើសុំឲ្យយកចិត្តទុកដាក់ទៅលើចំណុចសារធាតុនានារបស់មជ្ឈត្តវិនិច្ឆ័យបានដែរ ដោយមិនឲ្យប៉ះពាល់ដល់សេរីភាពនៅក្នុងការសម្រេចសេចក្តីរបស់វេទិកាមជ្ឈត្តកម្ម ក្នុងអំឡុងពេល ១៥ថ្ងៃប្រតិទិន បន្ទាប់ពីទទួលបានសេចក្តីព្រាងមជ្ឈត្តវិនិច្ឆ័យនោះ។[246] ក្នុងករណីនេះ វិធាន៣៦ស្តីពីការចេញមជ្ឈត្តវិនិច្ឆ័យ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ។[247] គួរកត់សម្គាល់ផងដែរថា វេទិកាមជ្ឈត្តកម្មអាចផ្តួចផ្តើមក្នុងការកែតម្រូវកំហុសបាន ក្នុងអំឡុងពេល ៣០ថ្ងៃប្រតិទិន បន្ទាប់ពីចេញមជ្ឈត្តវិនិច្ឆ័យ។

[241] វិធានស្តីពីមជ្ឈត្តការរបស់ ម.ជ.ម. នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៤, វិធាន៣៨.១, កថា. ១។
[242] វិធានស្តីពីមជ្ឈត្តការរបស់ ម.ជ.ម. នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៤, វិធាន៣៨.១, កថា. ១។
[243] វិធានស្តីពីមជ្ឈត្តការរបស់ ម.ជ.ម. នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៤, វិធាន៣៨.១, កថា. ៤។
[244] វិធានស្តីពីមជ្ឈត្តការរបស់ ម.ជ.ម. នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៤, វិធាន៣៨.២, កថា. ១។
[245] វិធានស្តីពីមជ្ឈត្តការរបស់ ម.ជ.ម. នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៤, វិធាន៣៥.២, កថា. ១។
[246] វិធានស្តីពីមជ្ឈត្តការរបស់ ម.ជ.ម. នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៤, វិធាន៣៥.២, កថា. ២។
[247] វិធានស្តីពីមជ្ឈត្តការរបស់ ម.ជ.ម. នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៤, វិធាន៣៨.២, កថា. ២។

❖ ករណីសហរដ្ឋអាមេរិក

យ៉ាងណាមិញ វិធានរបស់សហរដ្ឋអាមេរិកកំណត់ថា ភាគីណាមួយអាចស្នើសុំមជ្ឈត្តករ តាមរយៈ ស.ម.ស. ដើម្បីឲ្យមជ្ឈត្តករកែតម្រូវកំហុសផ្នែកការងារ កំហុសក្នុងការបោះពុម្ភ ឬកំហុសក្នុងការគណនាផ្សេងៗ នៅក្នុងមជ្ឈត្តវិនិច្ឆ័យ ក្នុងអំឡុងពេល ២០ថ្ងៃប្រតិទិន បន្ទាប់ពីមជ្ឈត្តករបានចេញមជ្ឈត្តវិនិច្ឆ័យ។[248] ក្នុងការស្នើសុំនេះ ភាគីណាមួយដែលមានបំណងស្នើសុំ ត្រូវតែជូនដំណឹងអំពីការស្នើសុំនេះទៅភាគីវិវាទរបស់ខ្លួនផងដែរ។[249] ទោះជាយ៉ាងណាក៏ដោយ មជ្ឈត្តករមិនមានអំណាចនៅក្នុងការវិនិច្ឆ័យម្តងទៀត លើអង្គសេចក្តីនៃការទាមទារណាមួយ ដែលត្រូវបានវិនិច្ឆ័យរួចហើយបាននោះឡើយ។[250] ភាគីម្ខាងទៀតត្រូវមានរយៈពេល ១០ថ្ងៃប្រតិទិនក្នុងការឆ្លើយតបទៅនឹងការស្នើសុំនេះ។[251] មជ្ឈត្តករត្រូវធ្វើការសម្រេចលើការស្នើសុំនេះ នៅក្នុងអំឡុងពេល ២០ថ្ងៃប្រតិទិន បន្ទាប់ពីពេលដែល ស.ម.ស. បានបញ្ជូនសេចក្តីស្នើសុំ និងការឆ្លើយតបផ្សេងៗនឹងការស្នើសុំនេះទៅមជ្ឈត្តករ។[252]

❖ ការប្រៀបធៀប

តាមការប្រៀបធៀប វិធាននៃប្រទេសទាំងពីរសុទ្ធតែផ្តល់សិទ្ធិឲ្យភាគីណាមួយក្នុងការស្នើសុំឲ្យធ្វើការកែប្រែនូវកំហុសឆ្គងផ្សេងៗនៅក្នុងមជ្ឈត្តវិនិច្ឆ័យ ស្របទៅតាមនីតិវិធីជាក់លាក់របស់ខ្លួន។ យ៉ាងណាក៏ដោយ នីតិវិធីក្នុងវិធាននៃប្រទេសកម្ពុជា មានលក្ខណៈស្មុគស្មាញ និងត្រូវប្រើរយៈពេលយូរជាង។ ជាក់ស្តែង វិធាននៃប្រទេសកម្ពុជាផ្តល់រយៈពេលរហូតទៅដល់ ៣០ថ្ងៃប្រតិទិន សម្រាប់ភាគីក្នុងការស្នើសុំឲ្យវេទិការមជ្ឈត្តកម្មធ្វើការកែប្រែ និងអាចឲ្យពន្យារពេលលើសពីនេះបានទៀតផង ខណៈពេលដែលវិធានរបស់សហរដ្ឋអាមេរិកផ្តល់រយៈពេលត្រឹមតែ ២០ថ្ងៃប្រតិទិនប៉ុណ្ណោះ។ លើសពីនេះទៅទៀត វិធានរបស់ប្រទេសកម្ពុជាផ្តល់រយៈពេលរហូតទៅដល់ ៣០ថ្ងៃប្រតិទិនដូចគ្នាផងដែរ សម្រាប់ឲ្យវេទិកាមជ្ឈត្តកម្មធ្វើការសម្រេចលើសំណើរនេះ ប៉ុន្តែវិធានរបស់សហរដ្ឋអាមេរិកផ្តល់រយៈពេលត្រឹមតែ ២០ថ្ងៃប្រតិទិនប៉ុណ្ណោះ។ ម្យ៉ាងមិញទៀត ក្នុងវិធានរបស់ប្រទេសកម្ពុជាវេទិកាមជ្ឈត្តកម្មត្រូវអនុវត្តនីតិវិធីដូចគ្នានឹងការចេញមជ្ឈត្តវិនិច្ឆ័យផងដែរ ចំពោះការផ្លាស់ប្តូរដែលចាំបាច់ ឬសមស្រប ដែលពាក់ព័ន្ធទៅនឹងការកែតម្រូវមជ្ឈត្តវិនិច្ឆ័យ គ្រាន់តែប្រើរយៈពេលខ្លីជាង

[248] វិធានស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម និងនីតិវិធីសន្ទានកម្មរបស់ ស.ម.ស. ឆ្នាំ២០១៣, វិធាន៥០។
[249] វិធានស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម និងនីតិវិធីសន្ទានកម្មរបស់ ស.ម.ស. ឆ្នាំ២០១៣, វិធាន៥០។
[250] វិធានស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម និងនីតិវិធីសន្ទានកម្មរបស់ ស.ម.ស. ឆ្នាំ២០១៣, វិធាន៥០។
[251] វិធានស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម និងនីតិវិធីសន្ទានកម្មរបស់ ស.ម.ស. ឆ្នាំ២០១៣, វិធាន៥០។
[252] វិធានស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម និងនីតិវិធីសន្ទានកម្មរបស់ ស.ម.ស. ឆ្នាំ២០១៣, វិធាន៥០។

ប៉ុណ្ណោះ។ ចំណុចខុសគ្នាមួយទៀតគួរឲ្យកត់សម្គាល់នោះគឺថា វិធាននៃប្រទេសកម្ពុជាអនុញ្ញាតឲ្យវេទិកាមជ្ឈត្តកម្មធ្វើការផ្តួចផ្តើមក្នុងការកែតម្រូវកំហុសនានាបាន ក៏ប៉ុន្តែវិធានរបស់សហរដ្ឋអាមេរិកមិនមានបញ្ជាក់ពីចំណុចនេះទេ។

### ២.២.២.៥. ការបំភ្លឺលំអិត និងការបកស្រាយមជ្ឈត្តវិនិច្ឆ័យ និង មជ្ឈត្តវិនិច្ឆ័យបន្ថែម

ស្របតាមវិធានរបស់ប្រទេសកម្ពុជា ភាគីណាមួយនៃវិវាទអាចស្នើសុំឲ្យវេទិកាមជ្ឈត្តកម្មធ្វើការបកស្រាយ ឬបំភ្លឺលម្អិត លើចំណុចជាក់លាក់ណាមួយ ឬផ្នែកណាមួយនៃមជ្ឈត្តវិនិច្ឆ័យ។[253] ក្រៅពីនេះ ភាគីណាមួយក៏អាចស្នើសុំឲ្យវេទិកាមជ្ឈត្តកម្មចេញមជ្ឈត្តវិនិច្ឆ័យបន្ថែម លើចំណុចដែលត្រូវបានបង្ហាញក្នុងដំណើរការមជ្ឈត្តការ ប៉ុន្តែមិនបានដាក់បញ្ចូលនៅក្នុងមជ្ឈត្តវិនិច្ឆ័យដែលបានទទួលផងដែរ។[254] ទាក់ទងទៅនឹងការបំភ្លឺលំអិត និងការបកស្រាយមជ្ឈត្តវិនិច្ឆ័យ វេទិកាមជ្ឈត្តកម្មក៏ដូចជាភាគី ត្រូវអនុវត្តដូចគ្នានឹងនីតិវិធីនៃការកែប្រែមជ្ឈត្តវិនិច្ឆ័យ ដូចដែលបានបង្ហាញខាងលើនេះផងដែរ លើកលែងតែវិធាន៣៦ ដែលស្តីពីការចេញនូវមជ្ឈត្តវិនិច្ឆ័យ។[255] ចំណែកឯការចេញនូវមជ្ឈត្តវិនិច្ឆ័យបន្ថែម វេទិកាមជ្ឈត្តកម្មក៏ដូចជាភាគី ត្រូវអនុវត្តនូវនីតិវិធីដូចគ្នានឹងនីតិវិធីនៃការកែប្រែមជ្ឈត្តវិនិច្ឆ័យដែរ។[256] យ៉ាងណាក៏ដោយ វិធានរបស់កម្ពុជាមិនមានបញ្ជាក់ថា វេទិកាមជ្ឈត្តកម្មអាចផ្តួចផ្តើមក្នុងការបំភ្លឺលំអិត ការបកស្រាយមជ្ឈត្តវិនិច្ឆ័យ ឬក៏ការចេញមជ្ឈត្តវិនិច្ឆ័យបន្ថែម ដូចជានៅក្នុងនីតិវិធីនៃការកែប្រែមជ្ឈត្តវិនិច្ឆ័យទេ។

យ៉ាងណាមិញ វិធានរបស់សហរដ្ឋអាមេរិកមិនមានបញ្ជាក់អំពីការបំភ្លឺលំអិត ការបកស្រាយមជ្ឈត្តវិនិច្ឆ័យ និងការចេញមជ្ឈត្តវិនិច្ឆ័យបន្ថែម ដូចជាវិធានរបស់ប្រទេសកម្ពុជាឡើយ។

---

[253] វិធានស្តីពីមជ្ឈត្តការរបស់ ម.ជ.ម. នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៤, វិធាន៣៨.១, កថា. ២។

[254] វិធានស្តីពីមជ្ឈត្តការរបស់ ម.ជ.ម. នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៤, វិធាន៣៨.១, កថា. ៣។

[255] វិធានស្តីពីមជ្ឈត្តការរបស់ ម.ជ.ម. នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៤, វិធាន៣៨.១ និង៣៨.២។

[256] វិធានស្តីពីមជ្ឈត្តការរបស់ ម.ជ.ម. នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៤, វិធាន៣៨.១ និង៣៨.២។

# ជំពូកទី ៣

# ការប្តឹងជំទាស់ ការទទួលស្គាល់ និងការដាក់ឲ្យអនុវត្តមជ្ឈត្តវិនិច្ឆ័យ

ដំណើរការនៃមជ្ឈត្តការត្រូវបានចាត់ទុកថាបានបញ្ចប់ជាស្ថាពរ នៅពេលវេទិកាមជ្ឈត្តកម្មបានចេញមជ្ឈត្តវិនិច្ឆ័យស្ថាពររួចហើយ។ ចំណែកឯការប្តឹងជំទាស់ ការទទួលស្គាល់ និងការដាក់ឲ្យអនុវត្តមជ្ឈត្តវិនិច្ឆ័យ គឺជានីតិវិធីក្រោយពីវេទិកាមជ្ឈត្តកម្មបានចេញមជ្ឈត្តវិនិច្ឆ័យប៉ុណ្ណោះ។

ក្នុងដំណាក់កាលនេះ វេទិកាមជ្ឈត្តកម្មមិនមានសមត្ថកិច្ចអ្វីទៀតឡើយទាក់ទងនឹងការប្តឹងជំទាស់ ការទទួល និងការដាក់ឲ្យអនុវត្តមជ្ឈត្តវិនិច្ឆ័យ ប៉ុន្តែមានតែតុលាការប៉ុណ្ណោះដែលមានសមត្ថកិច្ចលើរឿងទាំងនេះ។ ហេតុដូច្នេះហើយទើបបានជាវិធាននៃប្រទេសទាំងពីរមិនមានកំណត់អំពីនីតិវិធីលើការប្តឹងជំទាស់ ការទទួលស្គាល់ និងការដាក់ឲ្យអនុវត្តមជ្ឈត្តវិនិច្ឆ័យ ហើយមានតែច្បាប់គ្រប់គ្រងលើមជ្ឈត្តការរបស់ប្រទេសទាំងពីរប៉ុណ្ណោះ ដែលមានបញ្ជាក់អំពីនីតិវិធីទាំងនេះ។[257] លើសពីទៅទៀតនេះ តុលាការដែលមានសមត្ថកិច្ច អាចដំណើរការនីតិវិធីទាក់ទងនឹងការបដិសេធមជ្ឈត្តវិនិច្ឆ័យ ឬការទទួលស្គាល់ និងការជំទាស់នឹងមជ្ឈត្តវិនិច្ឆ័យនេះ តែក្នុងករណីដែលភាគីណាមួយធ្វើបណ្តឹងជំទាស់ ឬដាក់ពាក្យស្នើសុំឲ្យអនុវត្តមជ្ឈត្តវិនិច្ឆ័យប៉ុណ្ណោះ។

ដោយយោងលើហេតុផលនេះ ជំពូកទី៣នេះ នឹងធ្វើការសិក្សាប្រៀបធៀបដោយផ្អែកជាចម្បងលើច្បាប់ស្តីពីមជ្ឈត្តការរបស់ព្រះរាជាណាចក្រកម្ពុជា និងច្បាប់សហព័ន្ធនៃមជ្ឈត្តការរបស់សហរដ្ឋអាមេរិក រួមទាំងច្បាប់ស្តីពីការយល់ព្រម និងការអនុវត្តអនុសញ្ញាអង្គការសហប្រជាជាតិចែងអំពីការទទួលស្គាល់ និងការប្រតិបត្តិសេចក្តីសម្រេចមជ្ឈត្តករបរទេស និងអនុសញ្ញាអង្គការសហប្រជាជាតិចែងអំពីការទទួលស្គាល់និងការប្រតិបត្តិសេចក្តីសម្រេចមជ្ឈត្តករបរទេស។

ចំណុចទី១ នៃជំពូកនេះ នឹងធ្វើការបកស្រាយ និងប្រៀបធៀបទាក់ទងនឹងបណ្តឹងជំទាស់នឹងការអនុវត្តមជ្ឈត្តវិនិច្ឆ័យ **(៣.១)**។ ចំណែកឯ ចំណុចទី២ នៃជំពូកនេះដែរ នឹងធ្វើការបកស្រាយ និងប្រៀបធៀបអំពីការទទួលស្គាល់ និងការដាក់ឲ្យអនុវត្តមជ្ឈត្តវិនិច្ឆ័យ **(៣.២)**។

---

[257] ជាទូទៅ វិធាននៃស្ថាប័នមជ្ឈត្តការផ្សេងៗទៀតលើពិភពលោក មិនមានកំណត់អំពីនីតិវិធីរបស់តុលាការលើបណ្តឹងជំទាស់ និងការទទួលស្គាល់ និងការអនុវត្តមជ្ឈត្តវិនិច្ឆ័យឡើយ ហើយមានតែច្បាប់គ្រប់គ្រងមជ្ឈត្តការប៉ុណ្ណោះដែលកំណត់ពីនីតិវិធីទាំងនេះ។ *ឧទាហរណ៍* ករណីប្រទេសកម្ពុជា ច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ក្រមនីតិវិធីរដ្ឋប្បវេណី រួមទាំងច្បាប់ស្តីពីការយល់ព្រម និងការអនុវត្តអនុសញ្ញាអង្គការសហប្រជាជាតិចែងអំពីការទទួលស្គាល់ និងការប្រតិបត្តិសេចក្តីសម្រេចមជ្ឈត្តករបរទេស មានចែងអំពីនីតិវិធីទាក់ទងនឹងការប្តឹងជំទាស់ ការទទួលស្គាល់ និងការអនុវត្តមជ្ឈត្ត-វិនិច្ឆ័យ។

## ៣.១. បណ្ដឹងជំទាស់នឹងការអនុវត្តមជ្ឈត្តវិនិច្ឆ័យ

បណ្ដឹងជំទាស់នឹងការអនុវត្តមជ្ឈត្តវិនិច្ឆ័យ សំដៅទៅលើបណ្ដឹងមួយដែលភាគីណាមួយនៃវិវាទដាក់ទៅតុលាការដែលមានសមត្ថកិច្ច ដើម្បីចេញសេចក្ដីសម្រេចបដិសេធនឹងមជ្ឈត្តវិនិច្ឆ័យ។ យោងតាមច្បាប់នៃប្រទេសប្រទេសកម្ពុជា ក៏ដូចជាច្បាប់របស់សហរដ្ឋអាមេរិក ភាគីណាមួយនៃវិវាទអាចធ្វើការប្ដឹងជំទាស់នឹងការអនុវត្តមជ្ឈត្តវិនិច្ឆ័យដែលចេញដោយមជ្ឈត្តករ ឬវេទិកាមជ្ឈត្តកម្ម ទោះបីជាមជ្ឈត្តវិនិច្ឆ័យរបស់មជ្ឈត្តការជាតិ ឬមជ្ឈត្តវិនិច្ឆ័យបរទេសក៏ដោយ។

ចំណុចនេះនឹងធ្វើការបកស្រាយ និងប្រៀបធៀបអំពី បណ្ដឹងជំទាស់នឹងមជ្ឈត្តវិនិច្ឆ័យរបស់មជ្ឈត្តការជាតិ **(៣.១.១.)** និងបណ្ដឹងជំទាស់នឹងមជ្ឈត្តវិនិច្ឆ័យបរទេស **(៣.១.២.)**។

### ៣.១.១. បណ្ដឹងជំទាស់នឹងមជ្ឈត្តវិនិច្ឆ័យរបស់មជ្ឈត្តការជាតិ

តាមច្បាប់នៃប្រទេសទាំងពីរ ក្នុងការប្ដឹងជំទាស់នឹងមជ្ឈត្តវិនិច្ឆ័យរបស់មជ្ឈត្តការជាតិ ភាគីវិវាទត្រូវតែមានសំអាងលើហេតុផលណាមួយដែលកំណត់នៅក្នុងច្បាប់ ដែលជាមូលហេតុគតិយុត្តក្នុងការប្ដឹងជំទាស់ (**៣.១.១.១.** មូលហេតុក្នុងការប្ដឹងជំទាស់) និងត្រូវតែគោរពតាមនីតិវិធីនៃការដាក់បណ្ដឹងជំទាស់ ដែលមានកំណត់ដោយច្បាប់នៃប្រទេសទាំងពីរ (**៣.១.១.២.** នីតិវិធីនៃបណ្ដឹងជំទាស់)។

#### ៣.១.១.១. មូលហេតុនៃបណ្ដឹងជំទាស់

- ករណីកម្ពុជា

យោងតាមច្បាប់ស្ដីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្មនៃប្រទេសកម្ពុជា ភាគីដែលមានបំណងប្ដឹងជំទាស់នឹងមជ្ឈត្តវិនិច្ឆ័យរបស់វេទិកាមជ្ឈត្តកម្ម ដែលបានធ្វើមជ្ឈត្តវិនិច្ឆ័យនៅក្នុងប្រទេសកម្ពុជាត្រូវផ្អែកលើមូលហេតុដែលមានកំណត់នៅក្នុងច្បាប់នេះ។ ស្របតាមច្បាប់នេះ មូលហេតុតាមច្បាប់ដែលភាគីអាចប្ដឹងបដិសេធនឹងមជ្ឈត្តវិនិច្ឆ័យទៅតុលាការបាន មានដូចតទៅ៖[258]

១. ភាគីមួយនៃកិច្ចព្រមព្រៀងផ្សះផ្សាដូចមានយោងនៅក្នុងមាត្រា៧ នៃច្បាប់នេះ បានបាត់បង់សិទ្ធិមួយចំនួនខាងផ្លូវច្បាប់ ឬកិច្ចព្រមព្រៀងផ្សះផ្សានោះ ពុំអាចយកជាការបាន បើយោងតាមច្បាប់ដែលភាគីវិវាទបានសំអាង ឬកិច្ចព្រមព្រៀងផ្សះផ្សាពុំបានគោរពតាមបញ្ញត្តិណាមួយនៃច្បាប់របស់ព្រះរាជាណាចក្រកម្ពុជា។

[258] ច្បាប់ស្ដីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្មនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦, មាត្រា៤៧(២)(ក)។

២. ភាគីវិវាទដែលដាក់ពាក្យសុំបដិសេធនោះ មិនបានទទួលដំណឹងត្រឹមត្រូវអំពីការតែងតាំងមជ្ឈត្តករ ឬពីដំណើរការមជ្ឈត្តការ ឬភាគីនោះពុំអាចបង្ហាញពីអង្គហេតុរបស់ខ្លួនបានដោយប្រសិទ្ធភាព។

៣. មជ្ឈត្តវិនិច្ឆ័យដែលទាក់ទិននឹងវិវាទនោះពុំឆ្លើយតប ឬពុំគោរពតាមលក្ខខណ្ឌនៃកិច្ចព្រម-ព្រៀងផ្សះផ្សា។ ប្រសិនបើបញ្ហាដែលដាក់ឲ្យធ្វើមជ្ឈត្តការនោះ អាចផ្តាច់ចេញពីបញ្ហាដែលមិនបានដាក់ឲ្យធ្វើមជ្ឈត្តការ ការបដិសេធអាចធ្វើទៅបានតែត្រង់ផ្នែកមួយ នៃមជ្ឈ-ត្តវិនិច្ឆ័យ លើបញ្ហាដែលបានដាក់ឲ្យធ្វើមជ្ឈត្តការពីមុនបណ្តោះ។

៤. ការបង្កើតវេទិកាមជ្ឈត្តកម្ម ឬដំណើរការមជ្ឈត្តការ ពុំស្របនឹងកិច្ចព្រមព្រៀងរបស់គូភាគីវិវាទ ក្នុងករណីដែលកិច្ចព្រមព្រៀងនោះស្របតាមបទបញ្ញត្តិនៃច្បាប់នេះ។ ក្នុងករណីដែលគ្មានកិច្ចព្រមព្រៀងផ្សះផ្សានោះទេ ការបង្កើតវេទិកាមជ្ឈត្តកម្ម ឬដំណើរការមជ្ឈត្ត-ការខាងលើមិនស្របតាមច្បាប់នេះ។

លើសពីនេះទៅទៀត សាលាឧទ្ធរណ៍ និងតុលាការកំពូលក៏អាចបដិសេធនឹងមជ្ឈត្តវិនិច្ឆ័យរបស់មជ្ឈត្តករបានផងដែរ ក្នុងករណីដែលតុលាការនោះយល់ឃើញថាកម្មវត្ថុនៃវិវាទនោះមិនអាចដោះស្រាយបានតាមរយៈការធ្វើមជ្ឈត្តការឡើយ បើយោងតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា[259] ឬក៏មជ្ឈត្តវិនិច្ឆ័យនោះផ្ទុយនឹងនយោបាយសាធារណៈនៃព្រះរាជាណាចក្រកម្ពុជា[260]។

***ឧទាហរណ៍*** មជ្ឈត្តករបានចេញនូវមជ្ឈត្តវិនិច្ឆ័យមួយ ដែលសម្រេចឲ្យម្ចាស់ផ្ទះអនុវត្តតាមកិច្ចសន្យាជួលទីតាំងមួយកន្លែងសម្រាប់ផ្ទុកទំនិញ ប៉ុន្តែក្រោយមកតុលាការដែលមានសមត្ថកិច្ចរកឃើញថាទីតាំងនោះមានផ្ទុកនូវទំនិញខុសច្បាប់ ដែលមានទាំងគ្រឿងញៀណផងដែរ។ ក្នុងករណីនេះ តុលាការអាចសម្រេចបដិសេធនឹងមជ្ឈត្តវិនិច្ឆ័យបាន ព្រោះការអនុវត្តមជ្ឈត្តវិនិច្ឆ័យនោះនឹងនាំឲ្យផ្ទុយនឹងច្បាប់ជាតិ ក៏ដូចជានយោបាយសារណៈផងដែរ។

❖ ករណីសហរដ្ឋអាមេរិក

ដោយឡែក ច្បាប់សហព័ន្ធស្តីពីមជ្ឈត្តការរបស់សហរដ្ឋអាមេរិក ក៏មានកំណត់នូវមូលហេតុជាក់លាក់មួយចំនួន ដែលភាគីវិវាទណាមួយអាចធ្វើជាមូលដ្ឋានក្នុងការប្តឹងជំទាស់នឹងមជ្ឈត្តវិនិច្ឆ័យ

[259] ច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្មនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦, មាត្រា៤៤(២)(ខ)(ខ.១)។
[260] ច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្មនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦, មាត្រា៤៤(២)(ខ)(ខ.២)។

របស់មជ្ឈត្តការក្នុងប្រទេសរបស់ខ្លួនដែរ។ យោងតាមច្បាប់សហព័ន្ធនេះ ភាគីណាមួយដែលមានបំណងប្តឹងជំទាស់នឹងមជ្ឈត្តវិនិច្ឆ័យ ត្រូវសំអាងលើហេតុផលដូចខាងក្រោម៖[261]

១. មជ្ឈត្តវិនិច្ឆ័យត្រូវបានធ្វើឡើងដោយមានអំពីពុករលួយ ការបោកប្រាស់ ឬក៏អំពីផ្សេងៗទៀតស្រដៀងនេះ

២. វេទិកាមជ្ឈត្តកម្ម ឬមជ្ឈត្តករណាមួយនៃវេទិកាមជ្ឈត្តកម្ម មានភាពលំអៀងយ៉ាងជាក់-ច្បាស់ ឬក៏បានប្រព្រឹត្តអំពើពុករលួយយ៉ាងជាក់ច្បាស់

៣. មជ្ឈត្តករមានកំហុសក្នុងតួនាទីរបស់ខ្លួនក្នុងការបដិសេធចំពោះការពន្យារពេលសវនាការ ទោះបីជាមានមូលហេតុគ្រប់គ្រាន់ត្រូវបានលើកឡើងក៏ដោយ ឬមជ្ឈត្តករមានកំហុសក្នុងការបដិសេធចំពោះការទទួលយកភស្តុតាង ដែលពាក់ព័ន្ធ និងមានសារៈសំខាន់នៅក្នុងការដោះស្រាយវិវាទ ឬមជ្ឈត្តករបានប្រព្រឹត្តខុសដែលនាំឲ្យប៉ះពាល់ដល់សិទ្ធិរបស់ភាគីណាមួយ

៤. មជ្ឈត្តករបានរំលោភលើអំណាចរបស់ខ្លួន ឬក៏បានអនុវត្តនូវអំណាចរបស់ខ្លួនដោយមានកំហុស ដែលនាំឲ្យខកខាននៅក្នុងការចេញមជ្ឈត្តវិនិច្ឆ័យស្ថាពរលើកម្មវត្ថុនៃវិវាទរបស់គូភាគីវិវាទ។

❖ ការប្រៀបធៀប

តាមការប្រៀបធៀប យើងសង្កេតឃើញថា មូលហេតុសម្រាប់ភាគីណាមួយក្នុងការប្តឹងជំទាស់នឹងមជ្ឈត្តវិនិច្ឆ័យនៃមជ្ឈត្តការក្នុងប្រទេស ដែលកំណត់ដោយច្បាប់នៃប្រទេសទាំងពីរ មានលក្ខណៈខុសគ្នាច្រើន។ តួយ៉ាងច្បាប់របស់ប្រទេសកម្ពុជា ផ្តោតសំខាន់ទៅលើការបាត់បង់សិទ្ធិ ឬការបំពានសិទ្ធិរបស់ភាគី ភាពមិនត្រឹមត្រូវនៃដំណើរការមជ្ឈត្តការ និងមជ្ឈត្តវិនិច្ឆ័យ និងអសុពលភាពនៃកិច្ចព្រមព្រៀងផ្សះផ្សា។ ចំណែកឯច្បាប់របស់សហរដ្ឋអាមេរិក ផ្តោតសំខាន់លើការប្រព្រឹត្តកំហុសរបស់មជ្ឈត្តករនៅក្នុងដំណើរការមជ្ឈត្តការ ដែលនាំឲ្យប៉ះពាល់សិទ្ធិរបស់ភាគីវិវាទណាមួយ ដូចជា ការប្រើអំណាចហួសព្រំដែន អំពើពុករលួយ ភាពលម្អៀង។ល។ លើសពីនេះទៅទៀត ច្បាប់របស់ប្រទេសកម្ពុជាអនុញ្ញាតឲ្យមជ្ឈត្តករធ្វើការបដិសេធនឹងមជ្ឈត្តវិនិច្ឆ័យបាន ប្រសិនបើកម្មវត្ថុនៃវិវាទមិនអាចដោះស្រាយបានតាមរយៈមជ្ឈត្តការឡើយបើយោងតាមច្បាប់របស់ប្រទេសកម្ពុជា ឬក៏មជ្ឈត្តវិនិច្ឆ័យនោះផ្ទុយនឹងនយោបាយសាធារណៈរបស់ព្រះរាជាណាចក្រកម្ពុជា។ យ៉ាងណាមិញ ច្បាប់សហព័ន្ធរបស់សហរដ្ឋអាមេរិក មិនមានបញ្ជាក់ត្រង់ចំនុចនេះនោះទេ។

[261] ច្បាប់សហព័ន្ធនៃមជ្ឈត្តការរបស់សហរដ្ឋអាមេរិក (FAA) ឆ្នាំ១៩២៥, មាត្រា១០(a)។

### ៣.១.១.២. ការដាក់បណ្តឹងជំទាស់

❖ ករណីកម្ពុជា

តាមច្បាប់នៃប្រទេសកម្ពុជា សាលាជម្រះក្តីដែលមានសមត្ថកិច្ចក្នុងការសម្រេចលើបណ្តឹងជំទាស់បាន គឺសាលាឧទ្ធរណ៍នៃព្រះរាជាណាចក្រកម្ពុជា ចំណែកឯតុលាកាកំពូលជាសាលាជម្រះក្តីចុងក្រោយ ដែលមានសមត្ថកិច្ចជំនុំជម្រះបណ្តឹងជំទាស់របស់ភាគីវិវាទ ដែលមិនសុខចិត្តនឹងសេចក្តីសម្រេចរបស់សាលាឧទ្ធរណ៍ ក្នុងរយៈពេល ១៥ថ្ងៃ។[262] ភាគីវិវាទអាចប្តឹងជំទាស់នឹងមជ្ឈត្តវិនិច្ឆ័យបានតាមទ្រង់ទ្រាយជាបណ្តឹងបដិសេធ។[263] ចំពោះបណ្តឹងបដិសេធនេះ ភាគីត្រូវដាក់ពាក្យស្នើសុំបដិសេធ ក្នុងអំឡុងពេល ៣០ថ្ងៃ គិតចាប់ពីថ្ងៃដែលភាគីសុំបដិសេធនេះបានទទួលមជ្ឈត្តវិនិច្ឆ័យ ឬបើសិនជាមានសំណើសុំកែប្រែ ឬបកស្រាយមជ្ឈត្តវិនិច្ឆ័យ រយៈពេល ៣០ថ្ងៃនោះ ត្រូវគិតចាប់ពីកាលបរិច្ឆេទដែលវេទិកាមជ្ឈត្តកម្មបានដោះស្រាយលើសំណើនោះរួចរាល់។[264] លើសពីនេះទៀត សាលាឧទ្ធរណ៍ និងតុលាការកំពូលក៏អាចផ្អាកដំណើរការបដិសេធនោះ ក្នុងរយៈពេលដែលកំណត់ដោយសាលាឧទ្ធរណ៍ និងតុលាការកំពូលដែរ ដើម្បីផ្តល់ឱកាសដល់វេទិកាមជ្ឈត្តកម្មធ្វើដំណើរការមជ្ឈត្តការឡើងវិញ ឬចាត់វិធានការណាមួយតាមការយល់ឃើញរបស់វេទិកាថា អាចនឹងលុបបំបាត់មូលហេតុនៃការសុំបដិសេធនេះបាន បើសិនជាមានលក្ខណៈសមស្រប ហើយមានសំណើរពីភាគីណាមួយ។[265]

❖ ករណីសហរដ្ឋអាមេរិក

យ៉ាងណាមិញ យោងតាមច្បាប់សហព័ន្ធរបស់សហរដ្ឋអាមេរិក សាលាជម្រះក្តីដែលមានសមត្ថកិច្ចនៅក្នុងការសម្រេចលើបណ្តឹងជំទាស់ គឺអាស្រ័យទៅលើទីកន្លែងដែលមជ្ឈត្តករនោះបានចេញមជ្ឈត្តវិនិច្ឆ័យ ពោលគឺសាលាដំបូង ដែលស្ថិតនៅក្នុង ឬដែលមានយុត្តាធិការគ្របដណ្តប់លើស្រុកដែលមជ្ឈត្តករបានចេញមជ្ឈត្តវិនិច្ឆ័យនោះ។[266] គួរបញ្ជាក់ផងដែរថា ភាគីដែលមានបំណងប្តឹងជំទាស់ ត្រូវជូនដំណឹងទៅភាគីម្ខាងទៀត ក្នុងអំឡុងពេល ៣ខែ ចាប់ពីពេលដែលមជ្ឈត្តករបានចេញមជ្ឈត្តវិនិច្ឆ័យ ឬពីពេលដែលមជ្ឈត្តវិនិច្ឆ័យត្រូវបានបញ្ជូនទៅគូភាគីវិវាទ។[267] សាលាដំបូង

---

[262] ច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្មនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦, មាត្រា៤២ និង៤៣។

[263] ច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្មនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦, មាត្រា៤៤។

[264] ច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្មនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦, មាត្រា៤៤(៣)។

[265] ច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្មនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦, មាត្រា៤៤(៤)។

[266] ច្បាប់សហព័ន្ធនៃមជ្ឈត្តការរបស់សហរដ្ឋអាមេរិក (FAA) ឆ្នាំ១៩២៥, មាត្រា១០(a)។

[267] ច្បាប់សហព័ន្ធនៃមជ្ឈត្តការរបស់សហរដ្ឋអាមេរិក (FAA) ឆ្នាំ១៩២៥, មាត្រា១២។

នោះ អាចសម្រេចបដិសេធមជ្ឈត្តវិនិច្ឆ័យដោយផ្អែកទៅលើហេតុផលដូចបានបញ្ជាក់ខាងលើ។[268] ប្រសិនបើមជ្ឈត្តវិនិច្ឆ័យត្រូវបានបដិសេធ ហើយពេលវេលាដែលគូភាគីវិវាទបានព្រមព្រៀងសម្រាប់មជ្ឈត្តករក្នុងការចេញមជ្ឈត្តវិនិច្ឆ័យ មិនទាន់ផុត នោះតុលាការស្របតាមឆន្ទានុសិទ្ធិរបស់ខ្លួន អាចបង្គាប់ឲ្យមជ្ឈត្តករបើកសវនាការម្តងទៀត។[269] តាមខ្លឹមសាររបស់មាត្រា ១៦នៃច្បាប់សហព័ន្ធនេះ ភាគីវិវាទណាមួយអាចប្តឹងជំទាស់នឹងសេចក្តីសម្រេចរបស់សាលាដំបូងបានដែរ។

- ការប្រៀបធៀប

តាមការប្រៀបធៀប យើងសង្កេតឃើញថា ច្បាប់នៃប្រទេសទាំងពីរផ្តល់សមត្ថកិច្ចទៅឲ្យតុលាការខុសគ្នា ដើម្បីដោះស្រាយលើបណ្តឹងជំទាស់មជ្ឈត្តវិនិច្ឆ័យ ពោលគឺសាលាឧទ្ធរណ៍សម្រាប់ករណីប្រទេសកម្ពុជា និងសាលាដំបូងសម្រាប់ករណីសហរដ្ឋអាមេរិក។ ម្យ៉ាងវិញទៀត ច្បាប់នៃប្រទេសកម្ពុជា បញ្ជាក់ច្បាស់អំពីរយៈពេលដែលភាគីអាចប្តឹងជំទាស់បាន។ យ៉ាងណាមិញ ច្បាប់សហព័ន្ធរបស់សហរដ្ឋអាមេរិកមិនមានបញ្ជាក់ពីចំណុចនេះទេ ប៉ុន្តែមានកំណត់ពីរយៈពេលដែលភាគីត្រូវជូនដំណឹងទៅភាគីម្ខាងទៀតអំពីបណ្តឹងបដិសេធរបស់ខ្លួន។ ចំណុចមួយទៀតដែលគួរឲ្យកត់សម្គាល់នោះគឺថា ច្បាប់នៃប្រទេសទាំងពីរសុទ្ធតែអនុញ្ញាតឲ្យតុលាការផ្តល់ឱកាសទៅមជ្ឈត្តករដើម្បីឲ្យបើកដំណើរការមជ្ឈត្តការ ឬសវនាការឡើងវិញ តែស្ថិតនៅក្នុងរូបភាពពីរផ្សេងគ្នា។ ពោលគឺ ច្បាប់របស់ប្រទេសកម្ពុជា តម្រូវឲ្យមាននូវភាពសមស្រប និងការស្នើសុំរបស់ភាគីណាមួយ ហើយអាចធ្វើនៅមុនពេលដែលចេញសេចក្តីសម្រេចបដិសេធមជ្ឈត្តវិនិច្ឆ័យ។ ចំណែកឯ ច្បាប់សហព័ន្ធរបស់សហរដ្ឋអាមេរិក តុលាការអាចបង្គាប់ដូច្នេះ ស្របតាមឆន្ទានុសិទ្ធិរបស់ខ្លួន និងនៅក្រោយចេញសេចក្តីសម្រេចបដិសេធមជ្ឈត្តវិនិច្ឆ័យ ហើយពេលវេលាសម្រាប់មជ្ឈត្តករក្នុងការចេញមជ្ឈត្តវិនិច្ឆ័យមិនទាន់ផុតប៉ុណ្ណោះ។

### ៣.១.២. បណ្តឹងជំទាស់ការអនុវត្តមជ្ឈត្តវិនិច្ឆ័យបរទេស

- ករណីកម្ពុជា

ចំពោះករណីកម្ពុជា តុលាការដែលមានសមត្ថកិច្ចលើបណ្តឹងជំទាស់នឹងការទទួលស្គាល់ ឬការជំទាស់ទៅនឹងការដាក់ឲ្យអនុវត្តនូវមជ្ឈត្តវិនិច្ឆ័យបរទេស គឺសាលាឧទ្ធរណ៍នៃព្រះរាជាណាចក្រកម្ពុជា។[270] រីឯតុលាការកំពូល មានសមត្ថកិច្ចលើបណ្តឹងជំទាស់នឹងសេចក្តីសម្រេចរបស់សាលា

[268] ច្បាប់សហព័ន្ធនៃមជ្ឈត្តការរបស់សហរដ្ឋអាមេរិក (FAA) ឆ្នាំ១៩២៥, មាត្រា១០(a)។

[269] ច្បាប់សហព័ន្ធនៃមជ្ឈត្តការរបស់សហរដ្ឋអាមេរិក (FAA) ឆ្នាំ១៩២៥, មាត្រា១០(b)។

[270] ច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្មនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦, មាត្រា៤២។

ឧទ្ធរណ៍។[271] នៅក្នុងការប្តឹងជំទាស់នេះ ភាគីប្តឹងជំទាស់ត្រូវបញ្ជាក់អំពីមូលហេតុនៃការប្តឹងជំទាស់ដើម្បីជាមូលដ្ឋានក្នុងការសម្រេចលើបណ្តឹងនេះ។ មូលហេតុដែលច្បាប់មានកំណត់សម្រាប់បណ្តឹងជំទាស់នេះ គឺដូចគ្នានឹងមូលហេតុសម្រាប់ប្តឹងជំទាស់នឹងមជ្ឈត្តវិនិច្ឆ័យនៃមជ្ឈត្តការជាតិដែរ ដូចបានបង្ហាញខាងលើ។[272] បន្ថែមលើមូលហេតុទាំងនេះ ភាគីក៏អាចប្តឹងជំទាស់បានផងដែរ ប្រសិនបើមជ្ឈត្តវិនិច្ឆ័យនោះពុំទាន់បានក្លាយទៅជាកាតព្វកិច្ចនៅឡើយសម្រាប់ភាគីវិវាទ បើយោងតាមច្បាប់នៃប្រទេសដែលធ្វើសេចក្តីសម្រេចនោះ ឬម្យ៉ាងទៀតមជ្ឈត្តវិនិច្ឆ័យត្រូវបានបដិសេធ ឬព្យួរទុកដោយតុលាការនៃប្រទេសដែលធ្វើមជ្ឈត្តវិនិច្ឆ័យនោះ។[273]

❖ ករណីសហរដ្ឋអាមេរិក

ចំណែកឯច្បាប់សហព័ន្ធរបស់សហរដ្ឋអាមេរិក គ្រាន់តែបញ្ជាក់ថាសាលាដំបូងនៃសហរដ្ឋអាមេរិកមានយុត្តាធិការដោះស្រាយលើបណ្តឹងជំទាស់នឹងការទទួលស្គាល់ និងការដាក់ឲ្យអនុវត្តនូវមជ្ឈត្តវិនិច្ឆ័យបរទេស ក៏ប៉ុន្តែមិនមានបញ្ជាក់ច្បាស់អំពីសាលាដំបូងសម្រាប់ស្រុកណាមួយទេ។[274] យ៉ាងណាមិញ មូលហេតុដែលភាគីត្រូវធ្វើជាមូលដ្ឋានសម្រាប់ប្តឹងជំទាស់នេះ គឺដូចគ្នានឹងមូលហេតុសម្រាប់ភាគីក្នុងការប្តឹងជំទាស់នឹងមជ្ឈត្តវិនិច្ឆ័យរបស់មជ្ឈត្តការជាតិដែរ។[275] លើសពីនេះទៅទៀតបណ្តឹងជំទាស់នេះត្រូវធ្វើឡើង ក៏ដូចជានឹងត្រូវបានដោះស្រាយស្របតាមនីតិវិធីដូចគ្នានឹងនីតិវិធីនៃបណ្តឹងជំទាស់នឹងមជ្ឈត្តវិនិច្ឆ័យនៃមជ្ឈត្តការជាតិដែរ។[276]

❖ ការប្រៀបធៀប

តាមការប្រៀបធៀប យើងសង្កេតឃើញថា ច្បាប់របស់កម្ពុជាមានបញ្ជាក់យ៉ាងជាក់លាក់អំពីតុលាការដែលមានសមត្ថកិច្ចលើបណ្តឹងជំទាស់របស់ភាគី។ យ៉ាងណាមិញ ច្បាប់សហព័ន្ធរបស់សហរដ្ឋអាមេរិក គ្រាន់តែបញ្ជាក់ថាសាលាដំបូងជាតុលាការដែលមានសមត្ថកិច្ចលើបណ្តឹងជំទាស់ប៉ុណ្ណោះ ប៉ុន្តែមិនមានបញ្ជាក់ច្បាស់លាស់ពីសាលាដំបូងសម្រាប់ស្រុកណាមួយនោះទេ។ ទោះជា-យ៉ាងនេះក្តី ច្បាប់សហព័ន្ធរបស់សហរដ្ឋអាមេរិក មាត្រា ២០៤ បញ្ជាក់ថា សាលាជម្រះក្តីដែលមានសមត្ថកិច្ចគឺ សាលាដំបូងសម្រាប់ស្រុកដែលមជ្ឈត្តករបានចេញមជ្ឈត្តវិនិច្ឆ័យនោះ ក្នុងករណីដែល

[271] ច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្មនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦, មាត្រា៤២។
[272] ច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្មនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦, មាត្រា៤៦(១) និង៤៦(២)។
[273] ច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្មនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦, មាត្រា៤៦(១)(ង)។ ច្បាប់ស្តីពីការយល់-ព្រម និងការអនុវត្តអនុសញ្ញាទីក្រុងញូវយ៉កនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០១, មាត្រា ១៥(ក)(៥)។
[274] ច្បាប់សហព័ន្ធនៃមជ្ឈត្តការរបស់សហរដ្ឋអាមេរិក (FAA) ឆ្នាំ១៩២៥, មាត្រា២០៣ និង២០៤។
[275] ច្បាប់សហព័ន្ធនៃមជ្ឈត្តការរបស់សហរដ្ឋអាមេរិក (FAA) ឆ្នាំ១៩២៥, មាត្រា ២០៨ និង ១០។
[276] ច្បាប់សហព័ន្ធនៃមជ្ឈត្តការរបស់សហរដ្ឋអាមេរិក (FAA) ឆ្នាំ១៩២៥, មាត្រា ២០៨។

មជ្ឈត្តការនៃវិវាទរវាងពលរដ្ឋអាមេរិក និងពលរដ្ឋនៃប្រទេសដទៃ ធ្វើនៅក្នុងសហរដ្ឋអាមេរិក។[277] លើសពីនេះទៅទៀត ច្បាប់របស់ប្រទេសកម្ពុជា បន្ថែមនូវមូលហេតុមួយផ្សេងទៀតដែលភាគីអាចធ្វើជាមូលដ្ឋានក្នុងការប្តឹងជំទាស់បាន។ យ៉ាងណាមិញ ច្បាប់សហព័ន្ធរបស់សហរដ្ឋអាមេរិក មិនមានបញ្ជាក់អំពីមូលហេតុបន្ថែមដូចនេះឡើយ បើទោះបីជាអនុសញ្ញាទីក្រុងញូវយ៉កស្តីពីការទទួលស្គាល់ និងការអនុវត្តសេចក្តីសម្រេចរបស់មជ្ឈត្តករបរទេស (Convention on the Recognition and Enforcement of Foreign Arbitral Awards) មានចែងច្បាស់អំពីមូលហេតុបន្ថែមនេះក៏ដោយ។[278]

## ៣.២. ការទទួលស្គាល់ និងការដាក់ឲ្យអនុវត្តមជ្ឈត្តវិនិច្ឆ័យ

ការដាក់ពាក្យស្នើសុំទៅតុលាការឲ្យទទួលស្គាល់ និងអនុវត្តនូវមជ្ឈត្តវិនិច្ឆ័យ ពិតជាមានសារៈសំខាន់សម្រាប់ភាគីនៃមជ្ឈត្តកម្ម បើទោះបីជាមជ្ឈត្តការនោះជាមជ្ឈត្តការជាតិ ឬមជ្ឈត្តការអន្តរជាតិក៏ដោយ។ នេះគឺដោយសារតែ ភាគីណាមួយអាចនឹងខកខានក្នុងការអនុវត្តមជ្ឈត្តវិនិច្ឆ័យដែលមជ្ឈត្តករបានចេញ ហើយមជ្ឈត្តករ ឬវេទិកាមជ្ឈត្តកម្ម មិនមានអំណាចក្នុងការចាប់បង្ខំភាគីដែលខកខាននោះ ឲ្យអនុវត្តតាមមជ្ឈត្តវិនិច្ឆ័យរបស់ខ្លួនឡើយ។ ហេតុដូច្នេះហើយ ភាគីវិវាទអាចពឹងតុលាការដើម្បីឲ្យអនុវត្តមជ្ឈត្តវិនិច្ឆ័យនោះ តាមរយៈការចេញដីកាសម្រេចអនុវត្តដោយបង្ខំ[279] ព្រោះថាតុលាការមានកងកំលាំងសាធារណៈរបស់ខ្លួន ក្នុងការបង្ខំឲ្យភាគីម្ខាងទៀតដែលខកខាននោះអនុវត្តតាមមជ្ឈត្តវិនិច្ឆ័យដែលមានអនុភាពអនុវត្តលើខ្លួន។ ទោះបីជាយ៉ាងនេះក្តី តុលាការនៅតែអាចបដិសេធការទទួលស្គាល់ និងការអនុវត្តមជ្ឈត្តវិនិច្ឆ័យបាន បើសិនជាតុលាការយល់ឃើញថាមានមូលហេតុណាមួយក្នុងការបដិសេធ ដែលច្បាប់កំណត់។

**ចំណុច ៣.២.១** នឹងធ្វើការបកស្រាយ និងប្រៀបធៀបអំពីការដាក់ឲ្យអនុវត្តមជ្ឈត្តវិនិច្ឆ័យរបស់មជ្ឈត្តការជាតិ។ ចំណែកឯ ការដាក់ឲ្យអនុវត្តមជ្ឈត្តវិនិច្ឆ័យបរទេស នឹងត្រូវបានបកស្រាយ និងប្រៀបធៀបនៅក្នុង **ចំណុច ៣.២.២**។

[277] ច្បាប់សហព័ន្ធនៃមជ្ឈត្តការរបស់សហរដ្ឋអាមេរិក (FAA) ឆ្នាំ១៩២៥, មាត្រា ២០៨, ២០៣ និង ២០២។

[278] អនុសញ្ញាទីក្រុងញូវយ៉ក ឆ្នាំ១៩៥៨, មាត្រា៥(១)(e)។

[279] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦ (ពីនេះតទៅហៅថា ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦), មាត្រា៣៥៣(១)។

### ៣.២.១. ការដាក់ឲ្យអនុវត្តមជ្ឈត្តវិនិច្ឆ័យរបស់មជ្ឈត្តការជាតិ

❖ ករណីកម្ពុជា

យោងតាមច្បាប់របស់ប្រទេសកម្ពុជា តុលាការដែលមានសមត្ថកិច្ចលើពាក្យស្នើសុំឲ្យអនុវត្តមជ្ឈត្តវិនិច្ឆ័យ ដែលត្រូវបានធ្វើឡើងដោយវេទិកាមជ្ឈត្តកម្មនៅក្នុងប្រទេស គឺតុលាការដែលមានសមត្ថកិច្ចលើទីកន្លែងរបស់កូនបំណុលនៃការអនុវត្ត។[280] តាមមាត្រា៨ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃប្រទេសកម្ពុជា ប្រសិនបើកូនបំណុលនៃការអនុវត្តជារូបវន្តបុគ្គល សាលាដំបូងដែលមានសមត្ថកិច្ច គឺសាលាដំបូងនៃលំនៅឋាន ទីសំណាក់ ឬក៏លំនៅឋានចុងក្រោយរបស់កូនបំណុលនៃការអនុវត្តនោះ។[281] ប្រសិនបើកូនបំណុលជានីតិបុគ្គលក្នុងប្រទេស នោះសាលាដំបូងដែលមានសមត្ថកិច្ច គឺសាលាដំបូងនៃទីតាំងនៃទីស្នាក់ការ ឬទីកន្លែងអាជីវកម្មជាចម្បង ឬលំនៅឋានរបស់អ្នកតំណាង ឬរបស់អ្នកទទួលខុសត្រូវភារកិច្ចចាត់ចែងការងារជាចម្បង បើគ្មានទីស្នាក់ការ ឬទីកន្លែងអាជីវកម្មទេ។[282] លើសពីនេះទៅទៀត ក្នុងករណីដែលកូនបំណុលនៃការអនុវត្ត ជានីតិបុគ្គលបរទេស នោះតុលាការដែលមានសមត្ថកិច្ច គឺជាតុលាការនៃទីតាំងនៃទីស្នាក់ការ ឬទីកន្លែងអាជីវកម្មចម្បង ឬក៏លំនៅដ្ឋានរបស់អ្នកតំណាងប្រចាំនៅក្នុងប្រទេសកម្ពុជា ប្រសិនបើគ្មានទីស្នាក់ការ ឬក៏ទីកន្លែងអាជីវកម្មនៅព្រះរាជាណាចក្រកម្ពុជាទេ។[283] ម្យ៉ាងមិញទៀត ក្នុងករណីដែលមិនអាចកំណត់បានអំពីសមត្ថកិច្ចរបស់តុលាការទេ តុលាការដែលមានសមត្ថកិច្ចគឺសាលាដំបូងដែលមានសមត្ថកិច្ចលើទីកន្លែងដែលកម្មវត្ថុនៃការទាមទារ ឬក៏ទ្រព្យរបស់កូនបំណុលនៃការអនុវត្តដែលអាចរឹបអូសបានស្ថិតនៅ។[284]

ក្រៅពីនេះ ភាគីដែលដាក់ពាក្យសុំឲ្យអនុវត្តមជ្ឈត្តវិនិច្ឆ័យ ត្រូវដាក់ទៅតុលាការដែលមានសមត្ថកិច្ចនូវច្បាប់ដើមនៃសេចក្ដីសម្រេចរបស់មជ្ឈត្តករដោយត្រូវបានបញ្ជាក់ដោយត្រឹមត្រូវ ឬក៏ឯកសារចម្លងដែលមានសេចក្ដីបញ្ជាក់ត្រឹមត្រូវ។[285] បន្ថែមលើសពីនេះទៀត ភាគីត្រូវដាក់ច្បាប់ដើម

[280] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦, មាត្រា៣៥៣(៥)។
[281] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦, មាត្រា៨(ក)។
[282] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦, មាត្រា៨(ខ)។
[283] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦, មាត្រា៨(គ)។
[284] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦, មាត្រា៣៥៣(៥)។
[285] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦, មាត្រា៣៥៣(២)(ក)។

នៃកិច្ចសន្យាពាណិជ្ជកម្ម ឬក៏ឯកសារចម្លងនៃកិច្ចសន្យានេះ ដែលមានសេចក្ដីបញ្ជាក់ត្រឹមត្រូវ។[286] ភាគីដែលមិនពេញចិត្តនឹងដីកាសម្រេចរបស់តុលាការ អាចធ្វើការប្ដឹងជំទាស់បាន។[287]

❖ ករណីសហរដ្ឋអាមេរិក

ដោយឡែក ច្បាប់សហព័ន្ធរបស់សហរដ្ឋអាមេរិកអនុញ្ញាតឲ្យភាគីដាក់ពាក្យស្នើសុំឲ្យអនុវត្តមជ្ឈត្តវិនិច្ឆ័យ ដែលត្រូវបានធ្វើឡើងដោយវេទិកាមជ្ឈត្តកម្មក្នុងប្រទេស ទៅសាលាដំបូងសហព័ន្ធរបស់សហរដ្ឋអាមេរិកណាមួយ ដែលមានកំណត់ក្នុងកិច្ចព្រមព្រៀងមជ្ឈត្តកម្មរបស់គូភាគីបាន។[288] ប្រសិនបើកិច្ចព្រមព្រៀងមិនមានកំណត់នោះទេ សាលាដំបូងដែលមានសមត្ថកិច្ច គឺសាលាដំបូងសម្រាប់ស្រុកដែលមជ្ឈត្តករបានចេញមជ្ឈត្តវិនិច្ឆ័យ។[289] លើសពីនេះ ភាគីដែលមានបំណងដាក់ពាក្យសុំឲ្យអនុវត្តមជ្ឈត្តវិនិច្ឆ័យ ត្រូវដាក់ពាក្យសុំនោះ ក្នុងរយៈពេល ១ឆ្នាំ បន្ទាប់ពីមជ្ឈត្តករបានចេញមជ្ឈត្តវិនិច្ឆ័យ។[290] ក្នុងការដាក់ពាក្យស្នើសុំនេះ ភាគីត្រូវដាក់ទៅតុលាការដែលមានសមត្ថកិច្ចនូវកិច្ចព្រមព្រៀងមជ្ឈត្តកម្មរបស់គូភាគី មជ្ឈត្តវិនិច្ឆ័យ និងសេចក្ដីបង្គាប់ណាមួយក្នុងការកែប្រែ ឬកែតម្រូវមជ្ឈត្តវិនិច្ឆ័យនោះ ប្រសិនបើមាន។[291] ភាគីដែលមិនពេញចិត្តនឹងសេចក្ដីសម្រេចរបស់សាលាដំបូងដែលមានសមត្ថកិច្ច អាចធ្វើការប្ដឹងជំទាស់បាន។[292]

❖ ការប្រៀបធៀប

តាមការប្រៀបធៀប យើងសង្កេតឃើញថា ច្បាប់របស់ប្រទេសទាំងពីរសុទ្ធតែមានបញ្ជាក់ច្បាស់លាស់អំពីតុលាការដែលមានសមត្ថកិច្ចលើពាក្យសុំ ឲ្យអនុវត្តនូវមជ្ឈត្តវិនិច្ឆ័យរបស់មជ្ឈត្តការជាតិ ដែលសុទ្ធតែជាសាលាដំបូងដូចគ្នា។ ទោះជាយ៉ាងនេះក្ដី ការកំណត់អំពីសាលាដំបូងដែលមានសមត្ថកិច្ចក្នុងច្បាប់នីមួយៗ មានលក្ខណៈខុសគ្នា ពោលគឺច្បាប់របស់ប្រទេសកម្ពុជា កំណត់សាលាដំបូងដែលមានសមត្ថកិច្ច ដោយផ្អែកទៅលើទីកន្លែងនៃកូនបំណុលនៃការអនុវត្ត ដូចនីតិវិធីក្នុងរឿងក្ដីរដ្ឋប្បវេណីទូទៅដែរ។ ចំណែកឯច្បាប់សហព័ន្ធរបស់សហរដ្ឋអាមេរិក កំណត់ដោយផ្អែកទៅលើទីកន្លែងដែលមជ្ឈត្តករបានចេញមជ្ឈត្តវិនិច្ឆ័យ។ លើសពីនេះ ច្បាប់របស់សហរដ្ឋអាមេរិក

[286] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦, មាត្រា៣៥៣(២)(ខ)។
[287] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦, មាត្រា៣៥៣(៩)។
[288] ច្បាប់សហព័ន្ធនៃមជ្ឈត្តការរបស់សហរដ្ឋអាមេរិក (FAA) ឆ្នាំ១៩២៥, មាត្រា៩។
[289] ច្បាប់សហព័ន្ធនៃមជ្ឈត្តការរបស់សហរដ្ឋអាមេរិក (FAA) ឆ្នាំ១៩២៥, មាត្រា៩។
[290] ច្បាប់សហព័ន្ធនៃមជ្ឈត្តការរបស់សហរដ្ឋអាមេរិក (FAA) ឆ្នាំ១៩២៥, មាត្រា៩។
[291] ច្បាប់សហព័ន្ធនៃមជ្ឈត្តការរបស់សហរដ្ឋអាមេរិក (FAA) ឆ្នាំ១៩២៥, មាត្រា១៣។
[292] ច្បាប់សហព័ន្ធនៃមជ្ឈត្តការរបស់សហរដ្ឋអាមេរិក (FAA) ឆ្នាំ១៩២៥, មាត្រា១៦(a)(១)(D)។

តម្រូវឲ្យភាគីដាក់នូវសេចក្ដីបង្គាប់ក្នុងការកែប្រែ ឬកែតម្រូវមជ្ឈត្តវិនិច្ឆ័យផងដែរ ប៉ុន្តែច្បាប់របស់ប្រទេសកម្ពុជាមិនមានបញ្ជាក់អំពីចំណុចនេះឡើយ។ ចំណុចចុងក្រោយគួរឲ្យកត់សម្គាល់នោះ គឺថាច្បាប់របស់សហរដ្ឋអាមេរិក មានកំណត់ច្បាស់លាស់អំពីរយៈពេលដែលភាគីវិវាទត្រូវដាក់ពាក្យសុំឲ្យអនុវត្ត ប៉ុន្តែច្បាប់កម្ពុជាមិនមានកំណត់ឡើយ។

### ៣.២.២. ការដាក់ឲ្យអនុវត្តមជ្ឈត្តវិនិច្ឆ័យបរទេស

- ករណីកម្ពុជា

ក្នុងករណីប្រទេសកម្ពុជា តុលាការដែលមានសមត្ថកិច្ចលើពាក្យសុំឲ្យអនុវត្តសេចក្ដីសម្រេចរបស់មជ្ឈត្តករបរទេស គឺសាលាឧទ្ធរណ៍នៃព្រះរាជាណាចក្រកម្ពុជា។[293] រីឯតុលាការកំពូល គឺជាតុលាការដែលមានសមត្ថកិច្ចលើបណ្ដឹងជំទាស់នឹងសេចក្ដីសម្រេចរបស់សាលាឧទ្ធរណ៍។[294] ភាគីដែលដាក់ពាក្យសុំឲ្យអនុវត្តមជ្ឈត្តវិនិច្ឆ័យត្រូវផ្ដល់ច្បាប់ដើមត្រឹមត្រូវពិតប្រាកដនៃមជ្ឈត្តវិនិច្ឆ័យ និងច្បាប់ដើមនៃកិច្ចព្រមព្រៀងមជ្ឈត្តកម្ម ឬក៏អត្ថបទថតចម្លងដែលបញ្ជាក់ថាបានចម្លងត្រឹមត្រូវតាមច្បាប់ដើម។[295] ក្នុងករណីដែលមជ្ឈត្តវិនិច្ឆ័យ ឬកិច្ចព្រមព្រៀងមជ្ឈត្តកម្មនេះមិនបានធ្វើជាភាសាខ្មែរទេ ភាគីនោះត្រូវផ្ដល់សេចក្ដីបកប្រែជាភាសាខ្មែរ ដែលមានការបញ្ជាក់ត្រឹមត្រូវតាមច្បាប់ដើម។[296]

ក្នុងរយៈពេល ១០ថ្ងៃ ក្រោយពីទទួលបានពាក្យសុំនេះ សាលាឧទ្ធរណ៍ត្រូវធ្វើលិខិតជូនដំណឹងអំពីបណ្ដឹងនេះទៅភាគីវិវាទដែលសេចក្ដីសម្រេចត្រូវអនុវត្តចំពោះខ្លួន។[297] ភាគីវិវាទដែលសេចក្ដីសម្រេចត្រូវអនុវត្តចំពោះខ្លួន មានសិទ្ធិប្ដឹងជំទាស់ទៅសាលាឧទ្ធរណ៍កុំឲ្យទទួលស្គាល់ និងកុំឲ្យប្រតិបត្តិនូវសេចក្ដីសម្រេចរបស់មជ្ឈត្តករបរទេស ដោយផ្ដល់នូវភស្តុតាងយ៉ាងរឹងមាំ ក៏ដូចជាមូលដ្ឋានណាមួយស្របតាមច្បាប់ ក្នុងរយៈពេល ៦០ថ្ងៃប្រតិទិន ក្រោយពីសាលាឧទ្ធរណ៍បានទទួលពាក្យសុំឲ្យទទួលស្គាល់និងការប្រតិបត្តិ។[298] ក្នុងករណីដែលគ្មានពាក្យស្នើសុំដើម្បីបដិសេធការទទួលស្គាល់ និងការប្រតិបត្តិនូវសេចក្ដីសម្រេចរបស់មជ្ឈត្តករបរទេសនោះទេ សាលាឧទ្ធរណ៍

---

[293] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦, មាត្រា៣៥៣(៦)។

[294] ច្បាប់ស្ដីពីការយល់ព្រម និងការអនុវត្តអនុសញ្ញាទីក្រុងញូវយ៉កនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០១, មាត្រា ២១។

[295] ច្បាប់ស្ដីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្មនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦, មាត្រា៤៥, កថា. ២។

[296] ច្បាប់ស្ដីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្មនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦, មាត្រា៤៥, កថា. ២។

[297] ច្បាប់ស្ដីពីការយល់ព្រម និងការអនុវត្តអនុសញ្ញាទីក្រុងញូវយ៉កនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០១, មាត្រា ៨។

[298] ច្បាប់ស្ដីពីការយល់ព្រម និងការអនុវត្តអនុសញ្ញាទីក្រុងញូវយ៉កនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០១, មាត្រា ៩។

ត្រូវធ្វើការសម្រេចទទួលស្គាល់នូវសេចក្ដីសម្រេចរបស់មជ្ឈត្តករបរទេស ក្រោយពីបានទទួលពាក្យបណ្ដឹងអស់រយៈពេល ៦០ថ្ងៃប្រតិទិននៅចុងម៉ោងធ្វើការ។[299]

❖ ករណីសហរដ្ឋអាមេរិក

យ៉ាងណាមិញ ច្បាប់សហព័ន្ធរបស់សហរដ្ឋអាមេរិក ផ្ដល់សិទ្ធិឲ្យភាគីណាមួយក្នុងការដាក់ពាក្យស្នើសុំឲ្យអនុវត្តមជ្ឈត្តវិនិច្ឆ័យរបស់មជ្ឈត្តករបរទេស ទៅសាលាដំបូងដែលគូភាគីវិវាទបានព្រមព្រៀងនៅក្នុងកិច្ចព្រមព្រៀងមជ្ឈត្តកម្ម។[300] ភាគីក៏អាចដាក់ពាក្យស្នើសុំទៅសាលាដំបូង ដែលមានយុត្តាធិការលើស្រុកដែលមជ្ឈត្តករបានចេញមជ្ឈត្តវិនិច្ឆ័យ បើមជ្ឈត្តកម្មត្រូវបានធ្វើឡើងនៅក្នុងសហរដ្ឋអាមេរិក។[301] ភាគីដែលមានបំណងដាក់ពាក្យសុំ ត្រូវដាក់ពាក្យសុំនេះទៅតុលាការដែលមានសមត្ថកិច្ច ក្នុងរយៈពេល ៣ឆ្នាំ គិតចាប់ពីពេលដែលមជ្ឈត្តករបានចេញមជ្ឈត្តវិនិច្ឆ័យ។[302] ក្នុងការដាក់ពាក្យនេះ ភាគីត្រូវផ្ដល់ច្បាប់ដើមនៃមជ្ឈត្តវិនិច្ឆ័យ និងច្បាប់ដើមនៃកិច្ចព្រមព្រៀងមជ្ឈត្តកម្មរបស់គូភាគី ឬអត្ថបទថតចម្លងដែលមានបញ្ជាក់ថាបានចម្លងត្រឹមត្រូវតាមច្បាប់ដើម។[303] ភាគីម្ខាងទៀតត្រូវទទួលបានដំណឹងអំពីពាក្យស្នើសុំនេះ។[304] បន្ទាប់ពីតុលាការចេញសេចក្ដីសម្រេចលើពាក្យស្នើសុំឲ្យអនុវត្តមជ្ឈត្តវិនិច្ឆ័យ ភាគីណាមួយដែលមិនពេញចិត្តនឹងសេចក្ដីសម្រេចរបស់តុលាការអាចប្ដឹងជំទាស់នឹងសេចក្ដីសម្រេចនេះបាន។[305]

❖ ការប្រៀបធៀប

តាមការប្រៀបធៀប យើងសង្កេតឃើញថា ច្បាប់នៃប្រទេសកម្ពុជាមានបញ្ជាក់យ៉ាងច្បាស់អំពីតុលាការដែលមានសមត្ថកិច្ច នៅក្នុងការដោះស្រាយលើពាក្យស្នើសុំឲ្យអនុវត្តនូវមជ្ឈត្តវិនិច្ឆ័យរបស់មជ្ឈត្តករបរទេស ពោលគឺសាលាឧទ្ធរណ៍នៃព្រះរាជាណាចក្រកម្ពុជា។ យ៉ាងណាមិញ ច្បាប់សហព័ន្ធរបស់សហរដ្ឋអាមេរិក មិនមានបញ្ជាក់ច្បាស់លាស់នៅឡើយថាតើសាលាដំបូងមួយណាដែលមានសមត្ថកិច្ច ក្នុងករណីដែលកិច្ចព្រមព្រៀងមជ្ឈត្តកម្មមិនមានកំណត់អំពីតុលាការដែលមានសមត្ថកិច្ច និងមជ្ឈត្តកម្មមិនបានធ្វើឡើងនៅក្នុងសហរដ្ឋអាមេរិក។ លើសពីនេះទៅទៀត ច្បាប់នៃ

[299] ច្បាប់ស្ដីពីការយល់ព្រម និងការអនុវត្តអនុសញ្ញាទីក្រុងញូវយ៉កនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០១, មាត្រា ១៧។
[300] ច្បាប់សហព័ន្ធនៃមជ្ឈត្តការរបស់សហរដ្ឋអាមេរិក (FAA) ឆ្នាំ១៩២៥, មាត្រា២០៤។
[301] ច្បាប់សហព័ន្ធនៃមជ្ឈត្តការរបស់សហរដ្ឋអាមេរិក (FAA) ឆ្នាំ១៩២៥, មាត្រា២០៤។
[302] ច្បាប់សហព័ន្ធនៃមជ្ឈត្តការរបស់សហរដ្ឋអាមេរិក (FAA) ឆ្នាំ១៩២៥, មាត្រា២០៧។
[303] អនុសញ្ញាទីក្រុងញូវយ៉ក ឆ្នាំ១៩៥៨, មាត្រា៤(១)។
[304] ច្បាប់សហព័ន្ធនៃមជ្ឈត្តការរបស់សហរដ្ឋអាមេរិក (FAA) ឆ្នាំ១៩២៥, មាត្រា២០៨ និង៩។
[305] ច្បាប់សហព័ន្ធនៃមជ្ឈត្តការរបស់សហរដ្ឋអាមេរិក (FAA) ឆ្នាំ១៩២៥, មាត្រា២០៨ និង១៦(a)(១)(D)។

ប្រទេសកម្ពុជា មានកំណត់ច្បាស់លាស់អំពីរយៈពេលក្នុងដំណាក់កាលនីមួយៗនៃនីតិវិធី ប៉ុន្តែមិនមានកំណត់នូវកំឡុងពេល ដែលភាគីត្រូវដាក់ពាក្យស្នើសុំទៅតុលាការដើម្បីឲ្យអនុវត្តមជ្ឈត្តវិនិច្ឆ័យនោះទេ។ ដោយឡែកច្បាប់សហព័ន្ធរបស់សហរដ្ឋអាមេរិក មានកំណត់ច្បាស់លាស់អំពីរយៈពេលដែលភាគីវិវាទត្រូវដាក់ពាក្យស្នើសុំនេះ ពោលគឺ ៣ឆ្នាំ បន្ទាប់ពីពេលដែលមជ្ឈត្តករបានចេញនូវមជ្ឈត្តវិនិច្ឆ័យ។ ក្រៅពីនេះ ច្បាប់នៃប្រទេសទាំងពីរ សុទ្ធតែផ្តល់សិទ្ធិឲ្យភាគីវិវាទក្នុងការប្តឹងជំទាស់នឹងសេចក្តីសម្រេចរបស់តុលាការលើពាក្យស្នើសុំនេះ។ ត្រង់ចំណុចនេះ ច្បាប់របស់កម្ពុជាបញ្ជាក់ច្បាស់ថា តុលាការកំពូលមានសមត្ថកិច្ចលើបណ្តឹងជំទាស់នេះ ក៏ប៉ុន្តែច្បាប់សហព័ន្ធរបស់សហរដ្ឋអាមេរិកមិនមានបញ្ជាក់ច្បាស់ថាតុលាការមួយណាមានសមត្ថកិច្ចនោះទេ។

# សេចក្តីសន្និដ្ឋាន

ឆ្លងកាត់ការបកស្រាយ និងប្រៀបធៀបរវាងនីតិវិធីមជ្ឈត្តការផ្នែកពាណិជ្ជកម្មរបស់ប្រទេសកម្ពុជា និងសហរដ្ឋអាមេរិករួចមក យើងអាចសន្និដ្ឋានបានថា ទាំងកម្ពុជា និងសហរដ្ឋអាមេរិកពិតជាមាននូវលក្ខណៈពិសេសរៀងៗខ្លួនក្នុងនីតិវិធីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម។ លើសពីនេះទៅទៀត នីតិវិធីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ដែលមានចែងក្នុងច្បាប់ ក៏ដូចជាវិធាននៃប្រទេសទាំងពីរ ពិតជាមានលក្ខណៈដូចគ្នាជាទូទៅ ប៉ុន្តែក៏មានលក្ខណៈខុសមួយចំនួនគួរឲ្យកត់សម្គាល់ផងដែរ ដែលជាគន្លឹះដ៏សំខាន់សម្រាប់ប្រទេសកម្ពុជាក្នុងការអភិវឌ្ឍវិស័យមជ្ឈត្តការផ្នែកពាណិជ្ជកម្មរបស់ខ្លួន។

ចំនុចដូចគ្នានៃនីតិវិធីនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្មក្នុងប្រទេសទាំងពីរ មានច្រើន។ តួយ៉ាង ប្រទេសទាំងពីរ តម្រូវឲ្យភាគីមាននូវកិច្ចព្រមព្រៀងមជ្ឈត្តកម្មដើម្បីយកវិវាទពាណិជ្ជកម្មរបស់ខ្លួនទៅដោះស្រាយតាមរយៈមជ្ឈត្តការ។ លើសពីនេះទៅទៀត លក្ខខណ្ឌគតិយុត្តិ ក៏ដូចជាអនុភាពនៃកិច្ចព្រមព្រៀងមជ្ឈត្តកម្មក្នុងច្បាប់នៃប្រទេសទាំងពីរ មានលក្ខណៈស្រដៀងគ្នា ពោលគឺមានលក្ខខណ្ឌគ្រឹះ និងលក្ខខណ្ឌទម្រង់ដូចគ្នា ហើយទទួលស្គាល់ថាកិច្ចព្រមព្រៀងមជ្ឈត្តកម្មនេះ មានលក្ខណៈដាច់ដោយឡែកពីកិច្ចសន្យាពាណិជ្ជកម្មរបស់គូភាគីវិវាទ ក៏ដូចជាការផ្តល់សមត្ថកិច្ចទៅឲ្យមជ្ឈត្តករ ឬវេទិកាមជ្ឈត្តកម្មនៅក្នុងការដោះស្រាយវិវាទរបស់ខ្លួនផងដែរ នៅពេលដែលភាគីបានបង្កើតកិច្ចព្រមព្រៀងនេះ។

ក្រៅពីកិច្ចព្រមព្រៀងមជ្ឈត្តកម្ម នីតិវិធីសម្រាប់ប្រើក្នុងដំណាក់កាលដែលគូភាគីយកវិវាទពាណិជ្ជកម្មរបស់ខ្លួនទៅដោះស្រាយតាមរយៈមជ្ឈត្តការ ដែលមានស្ថាប័ន ម.ជ.ម. និង ស.ម.ស. គ្រប់គ្រង ក៏មានលក្ខណៈស្រដៀងគ្នាដែរ។ តួយ៉ាង ភាគីត្រូវតែដាក់សេចក្តីជូនដំណឹងអំពីមជ្ឈត្តកម្មទៅស្ថាប័នមជ្ឈត្តការជាមុនសិន បន្ទាប់មកស្ថាប័ននោះត្រូវធ្វើឲ្យប្រាកដថាភាគីឆ្លើយតបបានទទួលនូវសេចក្តីជូនដំណឹងនេះ និងទុកឱកាសឲ្យភាគីឆ្លើយតបដាក់សេចក្តីជូនដំណឹងអំពីការឆ្លើយតប។ បើគ្មានការជំទាស់ពីសមត្ថកិច្ចរបស់មជ្ឈត្តករនោះទេ គូភាគីត្រូវធ្វើការជ្រើសរើសមជ្ឈត្តករ ឬវេទិកាមជ្ឈត្តកម្មដើម្បីដោះស្រាយវិវាទរបស់ខ្លួន។ បន្ទាប់មកទៀត គូភាគីវិវាទ ដោយមានការចូលរួមពីសំណាក់មជ្ឈត្តករ ត្រូវធ្វើការរៀបចំដំណើរការមជ្ឈត្តការ ដោយមានការកំណត់ឲ្យបានច្បាស់អំពីច្បាប់សម្រាប់អនុវត្តនៅក្នុងមជ្ឈត្តការ ភាសាដែលត្រូវប្រើប្រាស់ ទីកន្លែងធ្វើមជ្ឈត្តកម្ម កាលបរិច្ឆេទពេលវេលា និងទីកន្លែងនៃសវនាការ និងសាក្សី ក៏ដូចជាអ្នកជំនាញជាដើម នៅមុនពេលដំណើរការនៃសវនាការ។ មុនពេលចេញមជ្ឈត្តវិនិច្ឆ័យស្ថាពរ ភាគីវិវាទណាមួយអាចស្នើសុំឲ្យមាននូវវិធានការ

បណ្តោះអាសន្ន ហើយគូភាគីទាំងពីរក៏អាចដោះស្រាយវិវាទដោយស្ម័គ្រចិត្តបានផងដែរ។ បន្ទាប់មក វេទិកាមជ្ឈត្តកម្មត្រូវបើកសវនាការ បើសិនភាគីបានព្រមព្រៀង ឬស្នើដូច្នេះ ដែលត្រូវធ្វើឡើងជាលក្ខណៈឯកជន។ បន្ទាប់មកទៀត វេទិកាមជ្ឈត្តកម្មត្រូវចេញមជ្ឈត្តវិនិច្ឆ័យ ដែលក្រោយមកអាចត្រូវបានសុំឲ្យមានការកែតម្រូវ ឬបកស្រាយ ឬចេញមជ្ឈត្តវិនិច្ឆ័យបន្ថែមផងដែរ។ លើសពីនេះច្បាប់នៃប្រទេសទាំងពីរសុទ្ធតែទទួលស្គាល់ដូចគ្នាផងដែរថា ភាគីណាមួយមានសិទ្ធិក្នុងការប្តឹងទៅតុលាការដើម្បីបដិសេធនឹងការអនុវត្តមជ្ឈត្តវិនិច្ឆ័យ។ ផ្ទុយមកវិញ ភាគីណាមួយក៏អាចធ្វើការស្នើសុំឲ្យមានការទទួលស្គាល់ និងការអនុវត្តមជ្ឈត្តវិនិច្ឆ័យដែរ ទោះជាមជ្ឈត្តវិនិច្ឆ័យនៃមជ្ឈត្តការជាតិ ឬអន្តរជាតិក៏ដោយ។

ទន្ទឹមនឹងលក្ខណៈដូចគ្នាទាំងនេះ នីតិវិធីនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្មនៃប្រទេសទាំងពីរក៏មានលក្ខណៈខុសគ្នា ក៏ដូចជាលក្ខណៈពិសេសរៀងខ្លួនមួយចំនួនគួរឲ្យកត់សម្គាល់ផងដែរនៅក្នុងដំណាក់កាលនីមួយៗនៃនីតិវិធី។ តួយ៉ាង ក្នុងការជ្រើសរើសមជ្ឈត្តករ វិធាននៃសហរដ្ឋអាមេរិកផ្តល់សិទ្ធិឲ្យភាគីធ្វើការព្រមព្រៀងដើម្បីជ្រើសតាំងមជ្ឈត្តកររបស់ខ្លួន ដោយមានភាពលម្អៀងទៅភាគីដែលបានជ្រើសរើសខ្លួន។ ក្នុងករណីនេះ ភាពលម្អៀងមិនអាចក្លាយជាមូលហេតុក្នុងការប្តឹងជំទាស់នឹងមជ្ឈត្តករបានឡើយ។ យ៉ាងណាមិញ វិធានរបស់កម្ពុជាមិនមានចែងអំពីចំណុចនេះនោះទេ បានសេចក្តីថាមជ្ឈត្តករដែលខ្លួនជ្រើសរើសត្រូវតែមាននូវអព្យាក្រឹតភាព។ ម៉្យាងមិញទៀត វិធានរបស់សហរដ្ឋអាមេរិក មានកំណត់អំពីនីតិវិធីពិសេសមួយនៅក្នុងការជ្រើសរើសមជ្ឈត្តករចេញពីបញ្ជីមជ្ឈត្តករនៃស្ថាប័ន ក្នុងករណីដែលភាគីមិនទាន់បានជ្រើសរើសមជ្ឈត្តកររបស់ខ្លួន ក៏ដូចជាមិនបានព្រមព្រៀងពីរបៀបជ្រើសរើសមជ្ឈត្តកររបស់ខ្លួននៅឡើយ (**សូមមើលចំណុច ២.១.២.១. ត្រង់ចំណុចប្រៀបធៀប**)។ យ៉ាងណាមិញ វិធានរបស់ប្រទេសកម្ពុជា មានចែងអំពីនីតិវិធីនៅក្នុងការដាក់មជ្ឈត្តករជំនួសក្នុងករណីដែលមជ្ឈត្តករណាមួយត្រូវបានដកចេញ ប៉ុន្តែវិធានរបស់សហរដ្ឋអាមេរិកមិនមានបញ្ជាក់ទេ។ លើសពីនេះទៅទៀត វិធានរបស់កម្ពុជាចែងថា ភាគីវិវាទណាមួយអាចស្នើសុំឲ្យវេទិកាមជ្ឈត្តកម្មចេញនូវវិធានការបណ្តោះអាសន្ន នៅមុនពេលដែលចេញមជ្ឈត្តវិនិច្ឆ័យស្ថាពរ ប៉ុន្តែមិនមានបញ្ជាក់អំពីនីតិវិធីក្នុងការជ្រើសរើសមជ្ឈត្តករសម្រាប់វិធានការបណ្តោះអាសន្ននេះ ក្នុងករណីដែលវេទិកាមជ្ឈត្តកម្មមិនទាន់ត្រូវបានបង្កើតឡើងនោះទេ។ ក្នុងករណីបែបនេះ វិធានរបស់សហរដ្ឋអាមេរិក មានកំណត់យ៉ាងច្បាស់អំពីនីតិវិធីក្នុងការជ្រើសរើសមជ្ឈត្តករដើម្បីដោះស្រាយលើវិធានការបន្ទាន់។ ទាក់ទងនឹងកាចេញនូវមជ្ឈត្តវិនិច្ឆ័យវិញ វិធានរបស់កម្ពុជាតម្រូវឲ្យមជ្ឈត្តករ ឬវេទិកាមជ្ឈត្តកម្ម ផ្ញើសេចក្តីព្រាងមជ្ឈត្តវិនិច្ឆ័យទៅអគ្គលេខាធិការដ្ឋានជាមុនសិន ប៉ុន្តែវិធានរបស់

សហរដ្ឋអាមេរិកមិនតម្រូវឲ្យមជ្ឈត្តករធ្វើដូច្នេះនោះឡើយ។ ចំពោះការប្ដឹងជំទាស់ ពាក្យស្នើសុំឲ្យមានការទទួលស្គាល់ និងអនុវត្តមជ្ឈត្តនូវវិនិច្ឆ័យទាំងជាតិ និងអន្តរជាតិ ច្បាប់របស់ប្រទេសទាំងពីរផ្ដល់សមត្ថកិច្ចទៅតុលាការខុសគ្នា ដើម្បីដោះស្រាយលើបណ្ដឹង និងពាក្យសុំទាំងនេះ និងផ្អែកលើមូលដ្ឋានផ្សេងគ្នាក្នុងការកំណត់សមត្ថកិច្ចរបស់តុលាការ។

លើសពីនេះទៅទៀត វិធានរបស់សហរដ្ឋអាមេរិកមានកំណត់ផងដែរអំពីនីតិវិធីរហ័ស (Expedited Procedures) ក៏ដូចជានីតិវិធីសម្រាប់វិវាទពាណិជ្ជកម្មដែលមានលក្ខណៈធំដុំ និងស្មុគស្មាញ (Procedures for Large, Complex Commercial Disputes)។ នីតិវិធីរហ័ស ជានីតិវិធីដែលប្រើសម្រាប់បណ្ដឹងទាមទារ ឬបណ្ដឹងតបដែលមានតម្លៃកម្មវត្ថុមិនលើស ៧៥,០០០ ដុល្លារ។ ចំណែកឯនីតិវិធីសម្រាប់វិវាទដែលមានលក្ខណៈធំដុំ និងស្មុគស្មាញ គឺជានីតិវិធីដែលត្រូវប្រើប្រាស់សម្រាប់បណ្ដឹងទាមទារ ឬក៏បណ្ដឹងតបដែលមានតម្លៃកម្មវត្ថុចាប់ពី ៥០០,០០០ ដុល្លារឡើងទៅ។ ការកំណត់បែបនេះពិតជាមានអត្ថប្រយោជន៍យ៉ាងខ្លាំង ជាពិសេសអាចជួយពន្លឿននីតិវិធីត្បិតថាភាគីមិនចាំបាច់គោរពតាមនីតិវិធីដែលមានលក្ខណៈស្មុគស្មាញ និងត្រូវប្រើប្រាស់រយៈពេលវែងសម្រាប់រឿងក្ដីតូចតាចនោះឡើយ។ ម៉្យាងវិញទៀត វិធានរបស់កម្ពុជា ជាទូទៅ កំណត់អំឡុងពេលវែងជាងវិធានរបស់សហរដ្ឋអាមេរិកនៅគ្រប់ដំណាក់កាលនៃនីតិវិធី ដែលការណ៍នេះអាចនាំឲ្យមានការចំណាយពេលច្រើនក្នុងការដោះស្រាយវិវាទ។

ភាពខុសគ្នាទាំងនេះ បង្ហាញឲ្យឃើញអំពីលក្ខណៈពិសេសនៃនីតិវិធីមជ្ឈត្តការរបស់កម្ពុជា ហើយក៏បង្ហាញឲ្យឃើញថាកម្ពុជាមានចំណុចខ្វះខាតមួយចំនួនដែលត្រូវបំពេញផងដែរ។ វិធានរបស់ប្រទេសកម្ពុជាគួរតែមានកំណត់អំពីនីតិវិធីពិសេស នៅក្នុងការជ្រើសរើសមជ្ឈត្តករចេញពីបញ្ជីមជ្ឈត្តកររបស់ខ្លួនដូចជានៅសហរដ្ឋអាមេរិកផងដែរ (**សូមមើលនីតិវិធីនេះនៅចំណុច ២.១.២.១. ត្រង់ចំណុចប្រៀបធៀប**)។ ឧទាហរណ៍ ដូចជាករណីដែលភាគីមិនអាចព្រមព្រៀងក្នុងការជ្រើសរើសមជ្ឈត្តករចេញពីក្នុងបញ្ជីមជ្ឈត្តកររបស់ ម.ជ.ម. វិធានរបស់ប្រទេសកម្ពុជាគួរតែមាននីតិវិធីដូចនៅក្នុងសហរដ្ឋអាមេរិកដែរ ដែលភាគីទាំងសងខាង ក្រោយមកត្រូវគូសចោលនូវឈ្មោះរបស់មជ្ឈត្តករណាដែលខ្លួនមិនពេញចិត្តក្នុងបញ្ជីដែលបានផ្ដល់ឲ្យ និងត្រូវរៀបឈ្មោះមជ្ឈត្តករដែលនៅសល់តាមលំដាប់នៃការពេញចិត្តរបស់ខ្លួន និងផ្ញើបញ្ជីនោះទៅគណៈកម្មការតែងតាំងវិញ។ ក្រោយមកទៀត គណៈកម្មការតែងតាំង ត្រូវវិនិច្ឆ័យ និងកំណត់ពីមជ្ឈត្តករណាដែលត្រូវបានជ្រើសរើសដោយគូភាគីតាមរយៈការផ្ទៀងផ្ទាត់ឈ្មោះមជ្ឈត្តករដែលនៅសល់ក្នុងបញ្ជីដែលភាគីបានផ្ញើមកវិញនោះ។

ម្យ៉ាងវិញទៀត វិធានរបស់កម្ពុជាគួរតែមានកំណត់ដែរអំពីនីតិវិធីក្នុងការជ្រើសរើសមជ្ឈត្តករ សម្រាប់សម្រេចលើសំណើសុំវិធានការបន្ទាន់ ក្នុងករណីដែលមជ្ឈត្តករ ឬក៏វេទិកាមជ្ឈត្តកម្ម មិនទាន់ត្រូវបានបង្កើតឡើង។ លើសពីនេះទៅទៀត វិធានកម្ពុជាគួរតែកំណត់ឲ្យបានច្បាស់ និងដាច់ដោយឡែកពីនីតិវិធីរហ័ស និងនីតិវិធីសម្រាប់វិវាទដែលមានតម្លៃកម្មវត្ថុច្រើនដូចជានៅវិធានរបស់សហរដ្ឋអាមេរិកដែរ ព្រោះការកំណត់បែបនេះពិតជាមានអត្ថប្រយោជន៍យ៉ាងច្រើនក្នុងការពន្លឿននីតិវិធី ចំណាយពេលតិច និងចំណាយប្រាក់តិច ដែលជាគោលបំណងចម្បងនៃការធ្វើមជ្ឈត្តការ។ ក្នុងការបំពេញបំណងនេះដែរ វិធានរបស់ប្រទេសកម្ពុជាក៏គួរតែកាត់បន្ថយពេលវេលាដែលផ្តល់ឲ្យក្នុងដំណាក់កាលនីមួយៗនៃនីតិវិធីផងដែរ ពោលគឺដើម្បីជៀសវាងនូវការចំណាយពេលវែងដែលមិនចាំបាច់។

យ៉ាងណាក៏ដោយ ប្រទេសកម្ពុជាក៏មានចំណុចល្អ និងលក្ខណៈពិសេសរបស់ខ្លួនក្នុងនីតិវិធីមជ្ឈត្តការផ្នែកពាណិជ្ជកម្មដែរ។ យើងសង្កេតឃើញថា ជាទូទៅ នីតិវិធីមជ្ឈត្តការផ្នែកពាណិជ្ជកម្មរបស់ប្រទេសកម្ពុជា ទាំងក្នុងច្បាប់គ្រប់គ្រងមជ្ឈត្តការ និងវិធានស្តីពីមជ្ឈត្តការរបស់ ម.ជ.ម. ក៏ដូចជាច្បាប់ដែលពាក់ព័ន្ធដទៃទៀត កំណត់យ៉ាងលំអិត ពិស្តា និងច្បាស់លាស់នៅគ្រប់ដំណាក់កាលនៃនីតិវិធីទាំងអស់។ គួយ៉ាង វិធានរបស់ប្រទេសកម្ពុជាមានកំណត់យ៉ាងច្បាស់អំពីនីតិវិធីសម្រាប់ជ្រើសតាំងមជ្ឈត្តករជំនួស ក្នុងករណីដែលមជ្ឈត្តករណាមួយត្រូវបានដកចេញ។ លើសពីនេះទៀត លក្ខណៈមួយដែលវិធានរបស់ប្រទេសកម្ពុជាតម្រូវឲ្យមជ្ឈត្តករ ឬវេទិកាមជ្ឈត្តកម្ម ផ្ញើសេចក្តីព្រាងមជ្ឈត្តវិនិច្ឆ័យទៅអគ្គលេខាធិការដ្ឋានជាមុនសិនដើម្បីពិនិត្យពិច័យនោះ ពិតជាចំណុចដ៏ល្អមួយរបស់កម្ពុជា ដោយហេតុថាការធ្វើបែបនេះអាចកាត់បន្ថយនូវកំហុសផ្សេងៗនៅក្នុងមជ្ឈត្តវិនិច្ឆ័យ។ យ៉ាងណាក៏ដោយ ត្រង់ចំណុចទាំងនេះ កម្ពុជាគួរតែកាត់បន្ថយនូវថេរវេលាដែលកំណត់ឲ្យដើម្បីជួយពន្លឿនដំណើរការនីតិវិធីដែរ។

# អនុសាសន៍

ជាចុងក្រោយ ខ្ញុំបាទជានិស្សិតច្បាប់មួយរូបដែលចង់ឃើញវិស័យមជ្ឈត្តការនៅកម្ពុជាមានការរីកចម្រើន និងដើម្បីឲ្យមជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្មទទួលបានការជឿទុកចិត្តកាន់តែមុតមាំពីសំណាក់សាធារណៈជន ខ្ញុំបាទសូមស្នើសុំឲ្យមជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម មជ្ឈត្តករ ក៏ដូចជាអ្នកច្បាប់ទាំងឡើយ ពិចារណាទៅលើលក្ខណៈពិសេសរបស់នីតិវិធីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ដែលត្រូវបានប្រើនៅក្នុងសហរដ្ឋអាមេរិក ជាពិសេសនីតិវិធីផ្សេងៗដូចបានបង្ហាញខាងលើ និងធ្វើការដាក់បញ្ចូលនីតិវិធីទាំងនោះ ក្នុងនីតិវិធីនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្មរបស់ប្រទេសកម្ពុជាផងដែរ។ ធ្វើដូច្នេះ វិស័យមជ្ឈត្តការផ្នែកពាណិជ្ជកម្មនៅក្នុងប្រទេសកម្ពុជានឹងមានការរីកចម្រើន ត្បិតថានីតិវីធីនៃមជ្ឈត្តការគឺជាផ្នែកដ៏សំខាន់នៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម។

លើសពីនេះទៅទៀត មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម គួរតែបង្កើតឲ្យមាននូវវគ្គបណ្តុះបណ្តាលកាន់ច្រើន និងកាន់តែមានប្រសិទ្ធភាពថែមទៀត អំពីមជ្ឈត្តការផ្នែកពាណិជ្ជកម្មដល់មជ្ឈត្តករ ក៏ដូចជាសមាជិកនៃមជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ដើម្បីទទួលបានការគ្រាំទ្រ និងជឿទុកចិត្តកាន់តែខ្លាំងពីសំណាក់សាធារណៈជនទាំងក្នុងស្រុក និងក្រៅស្រុក។ មិនត្រឹមតែប៉ុណ្ណោះ មជ្ឈមណ្ឌលក៏គួរតែលើកទឹកចិត្តឲ្យមជ្ឈត្តករនានាចូលរួមក្នុងវគ្គបណ្តុះបណ្តាលផ្សេងៗ ដែលរៀបចំឡើងដោយក្រុមមជ្ឈត្តករអន្តរជាតិដើម្បីសិក្សាបន្ថែមអំពីមជ្ឈត្តការអន្តរជាតិ និងដកបទពិសោធន៍គ្នាទៅវិញទៅមក។ ជាក់ស្តែង ក្នុងពេលឆាប់ៗខាងមុខនេះ មជ្ឈត្តករអន្តរជាតិ និងសាស្ត្រាចារ្យមួយក្រុម ដែលដឹកនាំដោយនាយិការនៃកម្មវិធីប្រកួតសវនាការប្រឌិតអន្តរជាតិស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្មអន្តរជាតិ (Willem C. Vis International Commercial Arbitration Moot) នឹងបង្កើតនូវវគ្គបណ្តុះបណ្តាលដល់និស្សិត និងមជ្ឈត្តករនៅប្រទេសកម្ពុជា នៅក្នុងគោលបំណងលើកស្ទួយយន្តការមជ្ឈត្តការផ្នែកពាណិជ្ជកម្មនៅប្រទេសកម្ពុជា។

ចុងក្រោយ រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា គួរតែលើកទឹកចិត្ត និងដាក់ចេញនូវគោលនយោបាយនានា ដើម្បីជម្រុញឲ្យវិស័យមជ្ឈត្តការផ្នែកពាណិជ្ជកម្មនៅប្រទេសកម្ពុជាកាន់តែមានការរីកចម្រើនឡើង។ រាជរដ្ឋាភិបាល គួរតែជួយផ្សព្វផ្សាយអំពីយន្តការមជ្ឈត្តការផ្នែកពាណិជ្ជកម្មតាមរយៈមធ្យោបាយផ្សេងៗ និងបំផុសឲ្យមាននូវការអប់រំអំពីមជ្ឈត្តការផ្នែកពាណិជ្ជកម្មនៅក្នុងកម្មវិធីអប់រំរបស់និស្សិត ដើម្បីឲ្យនិស្សិត ក៏ដូចជាសាធារណៈជននានា យល់ដឹងកាន់តែច្បាស់អំពីសារៈសំខាន់របស់យន្តការមជ្ឈត្តការក្នុងការដោះស្រាយវិវាទពាណិជ្ជកម្មនៅប្រទេសកម្ពុជា។

# តារាងសម្គាល់អក្សរកាត់ និងពាក្យបំព្រួញ

| អក្សរកាត់ និងពាក្យបំព្រួញ | ពាក្យពេញ |
|---|---|
| កថា. | កថាខណ្ឌ |
| ម.ជ.ម. | មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្មនៃព្រះរាជាណាចក្រកម្ពុជា<br>National Commercial Arbitration Center (NCAC) |
| ស.ម.ស. | សមាគមមជ្ឈត្តការនៃសហរដ្ឋអាមេរិក<br>American Arbitration Association (AAA) |
| ច្បាប់សហព័ន្ធរបស់សហរដ្ឋអាមេរិក | ច្បាប់សហព័ន្ធនៃមជ្ឈត្តការរបស់សហរដ្ឋអាមេរិក<br>Federal Arbitration Act 1925 (FAA) |
| វិធានរបស់ប្រទេសកម្ពុជា | វិធានស្ដីពីមជ្ឈត្តការរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្មនៃព្រះរាជាណាចក្រកម្ពុជា |
| វិធានរបស់សហរដ្ឋអាមេរិក | វិធានស្ដីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម និងនីតិវិធីសន្ធានកម្មរបស់សមាគមមជ្ឈត្តការនៃសហរដ្ឋអាមេរិក<br>Commercial Arbitration Rules and Mediation Procedures 2013 of American Arbitration Association |
| អនុសញ្ញាទីក្រុងញូវយ៉ក | អនុសញ្ញាអង្គការសហប្រជាជាតិស្ដីពីការទទួលស្គាល់ និងការប្រតិបត្តិមជ្ឈត្តវិនិច្ឆ័យបរទេស<br>Convention on the Recognition and Enforcement of Foreign Arbitral Awards 1958 (New York Convention) |

# គន្ថនិទ្ទេស

## ច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត

### អន្តរជាតិ

- Convention on the Recognition and Enforcement of Foreign Arbitral Award [អនុសញ្ញាស្តីពីការទទួលស្គាល់ និងការប្រតិបត្តិសេចក្តីសម្រេចមជ្ឈត្តករបរទេស]. អង្គការសហប្រជាជាតិ. ទីក្រុងញូវយ៉ក. ១៩៥៨។
- UNCITRAL Model Law on International Commercial Arbitration [ច្បាប់គម្រូនៃគណៈកម្មការអង្គការសហប្រជាជាតិទាក់ទងនឹងច្បាប់ពាណិជ្ជកម្មអន្តរជាតិស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្មអន្តរជាតិ]. លេខ ៤០/៧២. ១១ ធ្នូ ១៩៨៥។

### កម្ពុជា

- ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា. លេខ នស/រកម/១២០៧/០៣០. ០៨ ធ្នូ ២០០៧។
- ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា. លេខ នស/រកម/០៧០៦/០២១. ០៦ កក្កដា ២០០៦។
- ច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្មនៃព្រះរាជាណាចក្រកម្ពុជា. លេខ នស/រកម/០៥០៦/០១០. ០៥ ឧសភា ២០០៦។
- ច្បាប់ស្តីពីការយល់ព្រម និងការអនុវត្តអនុសញ្ញាអង្គការសហប្រជាជាតិចែងអំពីការទទួលស្គាល់ និង ការប្រតិបត្តិសេចក្តីសម្រេចមជ្ឈត្តករបរទេស. លេខ នស/រកម/០៧០១/១០. ២៣ កក្កដា ២០០១។
- អនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម លេខ១២៤ អនក្រ.បក. ១២ សីហា ២០០៩។
- អនុក្រឹត្យស្តីពីវិសោធនកម្មមាត្រា ៥២នៃអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់មជ្ឈ-មណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម. លេខ ១៨២ អនក្រ.បក. ៣១ ធ្នូ ឆ្នាំ២០១០។
- វិធានស្តីពីមជ្ឈត្តការរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម (ម.ជ.ម.). ១១ កក្កដា ២០១៤។
- បទបញ្ជាផ្ទៃក្នុងរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្មនៃព្រះរាជាណាចក្រកម្ពុជា ១១ កក្កដា ២០១៤។

### សហរដ្ឋអាមេរិក

- United Sates Code (U.S.C.) [ក្រមរបស់សហរដ្ឋអាមេរិក]. ១៩២៦។
- The Federal Arbitration Act [ច្បាប់សហព័ន្ធនៃមជ្ឈត្តការរបស់សហរដ្ឋអាមេរិក]. ១២ កុម្ភៈ ១៩២៥។
- Uniform Arbitration Act [ច្បាប់ឯកភាពនៃមជ្ឈត្តការរបស់សហរដ្ឋអាមេរិក]. ១៩៥៥។
- Revised Uniform Arbitration Act [ច្បាប់ឯកភាពនៃមជ្ឈត្តការរបស់សហរដ្ឋអាមេរិកដែលត្រូវបានកែសម្រួល]. ២០០០។
- Commercial Arbitration Rules and Mediation Procedures of American Arbitration Association: Including Procedures for Large, Complex Commercial Disputes [វិធានស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម និងនីតិវិធីសន្ធានកម្មរបស់សមាគមមជ្ឈត្តការសហរដ្ឋអាមេរិក៖ រួមបញ្ចូលទាំងនីតិវិធីសម្រាប់វិវាទពាណិជ្ជកម្ម ដែលធំដុំ និងស្មុគស្មាញ]. ១ តុលា ២០១៣។
- International Dispute Resolution Procedures (Including Mediation and Arbitration Rules) of American Arbitration Association [នីតិវិធីមសម្រាប់ដោះស្រាយវិវាទអន្តរជាតិ (រួមបញ្ចូលទាំងវិធាននៃសន្ធានកម្ម និងមជ្ឈត្តការ) របស់សមាគមន៍មជ្ឈត្តការសហរដ្ឋអាមេរិក].០១ មិថុនា ២០១៤។

### សៀវភៅ និងឯកសារផ្សេងៗ

- ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណី និងគណៈកម្មការទទួលបន្ទុកការពារសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណី. *សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមនីតិវិធីរដ្ឋប្បវេណី*. ភ្នំពេញ៖ ២០០៨។
- ក្រសួងពាណិជ្ជកម្ម. *ការដោះស្រាយវិវាទក្រៅផ្លូវតុលាការ៖ រួមមានមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ការសម្រុះសម្រួល និងការផ្សះផ្សា*. ភ្នំពេញ៖ ក្រសួងពាណិជ្ជកម្ម។
- Bun and Associates, *Introductory Guide: Commercial Arbitration in Cambodia* [សេចក្តីណែនាំ៖ មជ្ឈត្តការផ្នែកពាណិជ្ជកម្មនៅកម្ពុជា]. Bun and Associates, ២០១៤។ អាចស្វែងរកបាននៅ៖ http://www.bun-associates.com/wp-content/uploads/2015/01/Introductory-Guide-Commercial-Arbitration-in-Cambodia.pdf

- Margaret L. Moses. *The Principles and Practice of International Commercial Arbitration* [គោលការណ៍ និងការអនុវត្តនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្មអន្តរជាតិ], បោះពុម្ពលើកទី២. Cambridge: Cambridge University Press, 2012។
- Mark W. Friedman និង Floriane Lavaud, International Bar Association, Arbitration Guide, IBA Arbitration Committee, *UNITED STATES* [សហរដ្ឋអាមេរិក]. New York: Debevoise & Plimpton LLP, កញ្ញា ២០១២។ អាចរកបាននៅ៖ http://www.ibanet.org/Document/Default.aspx?DocumentUid=939CE0D4-8D8A-4350-81D7-B7FEFE923C11
- Stefan Michael Kröll, Loukas A. Mistelis, et. al., កែសម្រួល. *International Arbitration and International Commercial Law: Synergy, Convergence and Evolution* [មជ្ឈត្តការអន្តរជាតិ និងច្បាប់ពាណិជ្ជកម្មអន្តរជាតិ], *Chapter 8: Competence Competence and Separability-American Style* [គោលការណ៍ កំពិតង់ កំពិតង់ និងគោលការណ៍ដាច់ដោយឡែកតាមបែបអាមេរិក]. Great Britian: Kluwer Law International, 2011។ អាចស្វែងរកបាននៅ៖ http://digitalcommons.tourolaw.edu/cgi/viewcontent.cgi?article=1402&context=scholarlyworks
- Stephen Smerek និង Daniel Whang, *Preemption and the Federal Arbitration Act: What law will govern your Agreement to Arbitrate?* [ការរាំងការអនុវត្ត និងច្បាប់សហ-ព័ន្ធនៃមជ្ឈត្តការ៖ តើច្បាប់ណានឹងគ្រប់គ្រងកិច្ចព្រមព្រៀងមជ្ឈត្តកម្មរបស់អ្នក?]។ អាចស្វែងរកបាននៅ៖ http://apps.americanbar.org/buslaw/newsletter/0051/materials/pp7.pdf
- Steven M. Austermiller, Esq. *Alternative Dispute Resolution: Cambodia: A Textbook of Essential Concepts* [ការដោះស្រាយជម្លោះក្រៅប្រព័ន្ធតុលាការនៅកម្ពុជា៖ សៀវភៅនៃទស្សន:សំខាន់ៗ]. Phnom Penh: JSRC printing house, មករា ២០១០។ អាចស្វែងរកបាននៅ៖ http://www.americanbar.org/content/dam/aba/directories/roli/cambodia/cambodia_adr_book_english_01_19_09.authcheckdam.pdf
- Susan Patterson និង Grant Seabolt, *Essentials of Alternative Dispute Resolution* [ចំណុចសំខាន់ៗនៃការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ], បោះពុម្ពលើកទី២. ២០០១។
- United Nations Conference on Trade and Development (UNCTAD). *Dispute Settlement: International Commercial Arbitration* [ការដោះស្រាយជម្លោះ៖ មជ្ឈត្តការផ្នែកពាណិជ្ជកម្មអន្តរជាតិ]. New York and Geneva: United Nations, ២០០៥។

## សេចក្ដីសម្រេចរបស់តុលាការ

- Prima Paint Corp. v. Flood & Conklin Mfg. Co. សាលដីការបស់តុលាកាកំពូលនៃសហរដ្ឋអាមេរិក. សហរដ្ឋអាមេរិក, លេខ ៣៨៣, សម្រេចនៅថ្ងៃទី១២ មិថុនា ១៩៦៧។ អាចស្វែងរកបាននៅ៖ https://www.law.cornell.edu/supremecourt/text/388/395
- BUCKEYE CHECK CASHING, INC., Petitioner, v. John CARDEGNA et al. សាលដីការបស់តុលាកំពូលនៃរដ្ឋហ្វ្លរីដា. សហរដ្ឋអាមេរិក, លេខ ០៤-១២៦៤, សម្រេចនៅថ្ងៃទី២១ កុម្ភៈ ២០០៦។ អាចស្វែងរកបាននៅ៖ http://classactiondefense.jmbm.com/buckeyeclassactiondefense_opn.pdf

## គេហទំព័រ

- គេហទំព័រផ្លូវការរបស់ មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម៖ http://ncac.org.kh
- គេហទំព័រផ្លូវការរបស់សមាគមន៍មជ្ឈត្តការសហរដ្ឋអាមេរិក (AAA)៖ https://www.adr.org
- គេហទំព័រផ្លូវការរបស់មជ្ឈមណ្ឌលអន្តរជាតិសម្រាប់ការដោះស្រាយវិវាទ៖ https://www.icdr.org/
- មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម, គម្រូខថៃងអំពី មជ្ឈត្តការរបស់ ម.ជ.ម. ១២ មិថុនា២០១៤។ តាមរយៈ៖ http://ncac.org.kh/?page=detail&menu1= 295&ctype=article&id=295&lg=en&menu1=217&menu2=228&lg=kh
- Olga Boltenko, Cambodia's Arbitration Centre sets off on its First Flight [មជ្ឈមណ្ឌលមជ្ឈត្តការរបស់កម្ពុជាចាប់ផ្ដើមដំណើរការដំបូងបំផុតរបស់ខ្លួន]. ១០ មិថុនា ២០១៥។ អាចស្វែងរកបាននៅ៖ http://kluwerarbitrationblog.com/2015/06/10/cambodias-arbitration-centre-sets-off-on-its-first-flight/
- Uniform Law Commission, "Arbitration Act (2000) Summary" [ច្បាប់ស្ដីពីមជ្ឈត្តការ (២០០០) សេចក្ដីសង្ខេប]។ តាមរយៈ៖ http://www.uniformlaws.org/ActSummary.aspx?title=Arbitration%20Act%20(2000)

# តារាងឧបសម្ព័ន្ធ

| | |
|---|---|
| ឧបសម្ព័ន្ធទី១ | Convention on the Recognition and Enforcement of Foreign Arbitral Awards (New York, 1958) |
| ឧបសម្ព័ន្ធទី២ | The Federal Arbitration Act 1925 (USA) |
| ឧបសម្ព័ន្ធទី៣ | Commercial Arbitration Rules and Mediation Procedures: Including Procedures for Large, Complex Commercial Disputes, October 1, 2013 (USA) |

UNITED NATIONS CONFERENCE

ON INTERNATIONAL COMMERCIAL ARBITRATION

# CONVENTION

## ON THE RECOGNITION AND ENFORCEMENT OF FOREIGN ARBITRAL AWARDS

*UNITED NATIONS*

*1958*

## CONVENTION ON THE RECOGNITION AND ENFORCEMENT OF FOREIGN ARBITRAL AWARDS

### *Article I*

1. This Convention shall apply to the recognition and enforcement of arbitral awards made in the territory of a State other than the State where the recognition and enforcement of such awards are sought, and arising out of differences between persons, whether physical or legal. It shall also apply to arbitral awards not considered as domestic awards in the State where their recognition and enforcement are sought.

2. The term "arbitral awards" shall include not only awards made by arbitrators appointed for each case but also those made by permanent arbitral bodies to which the parties have submitted.

3. When signing, ratifying or acceding to this Convention, or notifying extension under article X hereof, any State may on the basis of reciprocity declare that it will apply the Convention to the recognition and enforcement of awards made only in the territory of another Contracting State. It may also declare that it will apply the Convention only to differences arising out of legal relationships, whether contractual or not, which are considered as commercial under the national law of the State making such declaration.

### *Article II*

1. Each Contracting State shall recognize an agreement in writing under which the parties undertake to submit to arbitration all or any differences which have arisen or which may arise between them in respect of a defined legal relationship, whether contractual or not, concerning a subject matter capable of settlement by arbitration.

2. The term "agreement in writing" shall include an arbitral clause in a contract or an arbitration agreement, signed by the parties or contained in an exchange of letters or telegrams.

3. The court of a Contracting State, when seized of an action in a matter in respect of which the parties have made an agreement within the meaning of this article, shall, at the request of one of the parties, refer the parties to arbitration, unless it finds that the said agreement is null and void, inoperative or incapable of being performed.

### *Article III*

Each Contracting State shall recognize arbitral awards as binding and enforce them in accordance with the rules of procedure of the territory where the award is relied upon, under the conditions laid down in the following articles. There shall not be imposed substantially more onerous conditions or higher fees or charges on the recognition or enforcement of arbitral awards to which this Convention applies than are imposed on the recognition or enforcement of domestic arbitral awards.

### *Article IV*

1. To obtain the recognition and enforcement mentioned in the preceding article, the party applying for recognition and enforce-

ment shall, at the time of the application, supply:

(*a*) The duly authenticated original award or a duly certified copy thereof;

(*b*) The original agreement referred to in article II or a duly certified copy thereof.

2. If the said award or agreement is not made in an official language of the country in which the award is relied upon, the party applying for recognition and enforcement of the award shall produce a translation of these documents into such language. The translation shall be certified by an official or sworn translator or by a diplomatic or consular agent.

### *Article V*

1. Recognition and enforcement of the award may be refused, at the request of the party against whom it is invoked, only if that party furnishes to the competent authority where the recognition and enforcement is sought, proof that:

